គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា

Cooperation Committee for Cambodia

Comité de Coopération Pour le Cambodge

# បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សម្រាប់អង្គការសង្គមស៊ីវិលកម្ពុជា

ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា

Accountability គណនេយ្យភាព
05/10/2018
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
04/10/2021
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

# បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សម្រាប់អង្គការសង្គមស៊ីវិល កម្ពុជា

| | |
|---|---|
| វិភាគបន្ថែម និងរៀបចំរបាយការណ៍ចុងក្រោយ ដោយៈ | Sinthay NEB<br>Declan O'LEARY<br>Vicheanon KHIEU |
| ប្រមូលទិន្នន័យ ដោយៈ | Real-time Data Solutions Co., Ltd. |

**រក្សាសិទ្ធិ © ២០១៩ ៖**

រាល់យោបល់ទាំងឡាយជារបស់អ្នកនិពន្ធ និងទទួលបានពីអ្នកផ្តល់ចម្លើយផ្សេងៗ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈ និងគំនិតរបស់គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា (CCC) និងដៃគូម្ចាស់ជំនួយឡើយ។ សូមលើកទឹកចិត្ត ក្នុងការបោះពុម្ព ឬការផលិតឡើងវិញ ដែលមានការទទួលស្គាល់សមិទ្ធផលរបស់អង្គការ CCC និងអ្នកនិពន្ធ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ____ iv
**បញ្ជីអក្សរកាត់** ____ v
**សេចក្តីសង្ខេប** ____ viii
**សេចក្តីផ្តើម** ____ 1
គោលបំណង និងកម្មវត្ថុនៃការស្រាវជ្រាវ ____ 2
ទិដ្ឋភាពរួមរបស់ប្រទេសកម្ពុជានិងបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល ____ 3
*នយោបាយ* ____ *3*
*សេដ្ឋកិច្ច* ____ *6*
*សង្គម* ____ *8*
*បច្ចេកវិទ្យា* ____ *9*
*ច្បាប់* ____ *10*
*បរិស្ថាន* ____ *11*
**វិធីសាស្ត្រស្រាវជ្រាវ** ____ 13
ការពិនិត្យឡើងវិញនូវក្របខណ្ឌ និងការសម្រួល ____ 13
ការអង្កេតតាមបែបបរិមាណវិស័យ ____ 15
បទសម្ភាសតាមបែបគុណវិស័យ ____ 15
ករណីសិក្សា ____ 17
ការពិនិត្យមើលឯកសារផ្សេងៗ ____ 17
វិសាលភាពសម្រាប់ការសិក្សា ____ 17
**លទ្ធផលនៃការរកឃើញសំខាន់ៗ** ____ 19
***ការបង្កើត និងប្រតិបត្តិការ*** ____ ***19***
ទិដ្ឋភាពរួម ____ 19
លទ្ធផលរកឃើញ និងការវិភាគ ____ 20
ការវិភាគអំពីប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល ____ 36
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ ____ 41
បញ្ហាប្រឈម និងការផ្តល់យោបល់ ____ 42
***សេរីភាពបញ្ចេញមតិ*** ____ ***44***
ទិដ្ឋភាពរួម ____ 44
លទ្ធផលរកឃើញ និងការវិភាគ ____ 46
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ ____ 50
បញ្ហាប្រឈម និងការផ្តល់យោបល់ ____ 51

**ការជួបជុំដោយសន្តិវិធី** *52*
ទិដ្ឋភាពរួម 52
លទ្ធផលរកឃើញ និងការវិភាគ 54
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 56
បញ្ហាប្រឈម និងការផ្តល់យោបល់ 56
**ពន្ធដារ** 57
ទិដ្ឋភាពរួម 57
លទ្ធផលរកឃើញ និងការវិភាគ 57
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 63
បញ្ហាប្រឈម និងការផ្តល់យោបល់ 63
**ការទទួលបានធនធាន (រួមទាំងវិស័យឯកជន)** 64
ទិដ្ឋភាពរួម 64
លទ្ធផលរកឃើញ និងការវិភាគ 66
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 72
បញ្ហាប្រឈម និងការផ្តល់យោបល់ 73
**សិទ្ធិទទួលបានព័ត៌មាន** 74
ទិដ្ឋភាពរួម 74
លទ្ធផលរកឃើញ និងការវិភាគ 77
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 81
បញ្ហាប្រឈម និងការផ្តល់យោបល់ 82
**ទំនាក់ទំនង រវាងអាជ្ញាធរ និង អង្គការសង្គមស៊ីវិល** 83
ទិដ្ឋភាពរួម 83
លទ្ធផលរកឃើញ និងការវិភាគ *84*
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 93
ទិដ្ឋភាពរួម 95
លទ្ធផលរកឃើញ និងការវិភាគ 96
ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨ 105
បញ្ហាប្រឈម និងការផ្តល់យោបល់ 106
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** 108
**ឯកសារយោង** 116
**ឧបសម្ព័ន្ធ** 117
ព័ត៌មានបន្ថែមសម្រាប់ក្របខ័ណ្ឌនៃការវិភាគតាមសមាសភាព 117

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមអង្គការគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា (CCC) សូមថ្លែងអំណរគុណសម្រាប់ការជ្រោមជ្រែង និងចូលរួម ក្នុងការសិក្សាស្រាវជ្រាវ ស្តីពី បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សម្រាប់អង្គការសង្គមស៊ីវិល កម្ពុជា ជាពិសេសម្ចាស់ជំនួយសហាគមន៍អឺរ៉ុប (EU) និងប្រេតហ្វដឺវើល (WfdW)។ សូមអរគុណផងដែរ ដល់អង្គការជំនួយនៃប្រជាពលរដ្ឋន័រវេស្សន៍ (NPA) សម្រាប់ការបោះពុម្ព។

សូមអរគុណដល់អ្នកផ្តល់ចម្លើយ ដែលបានចំណាយពេលវេលាចូលរួមក្នុងការផ្តល់ទិន្នន័យទាំងបែបរិមាណវិស័យ និងគុណវិស័យ ក៏ដូចជាការចូលរួមក្រុមពិភាក្សា និងករណីសិក្សា។

សូមកោតសរសើរដល់ក្រុមការងាររបស់អង្គការ CCC សម្រាប់ការផ្តល់ជាយោបល់ និងគាំទ្របច្ចេកទេសផ្សេង រួមមាន លោក សឿង សារឿន ដែលជានាយកប្រតិបត្តិ លោកស្រីបណ្ឌិត អែល សុធារី ប្រធានកម្មវិធី សម្រាប់ការផ្តល់យោបល់កែសម្រួលការសិក្សានេះ និងលោក ជេន សុជឿន ដែលជាជនបង្គោលសម្រាប់ការស្រាវជ្រាវ។ សូមអរគុណផងដែរ ដល់ក្រុមប្រឹក្សាយោបល់ស្រាវជ្រាវ ដែលបានផ្តល់ការណែនាំលើការស្រាវជ្រាវនេះតាំងពីដំណាក់កាលដំបូង។ សូមទទួលស្គាល់នូវកិច្ចការយ៉ាងសំខាន់ពីក្រុមហ៊ុន រៀលថៃមដាតាសូលូតសិន (Real-Time Data Solutions Co., Ltd)ដែលបានប្រមូលទិន្នន័យ សម្រាប់រៀបចំរបាយការណ៍ដំបូង។

សូមអរគុណសម្រាប់ធាតុចូល ការកែសម្រួលរបាយការណ៍ និងការវិភាគ ដែលសម្របសម្រួលដោយលោក Neb Sinthay និងចូលរួមដោយលោក D. O’Leary និង V. KHIEU ។

លទ្ធផលនេះនឹងចូលរួមចំណែកដល់អង្គការសង្គមស៊ីវិលក៏ដូចជាកិច្ចប្រឹងប្រែងរបស់អង្គការ CCC ដើម្បីធ្វើឱ្យប្រសើរឡើងសម្រាប់សង្គមស៊ីវិល នៅកម្ពុជា ក៏ដូចជាជម្រុញការអភិវឌ្ឍនៅកម្ពុជា។ សង្ឃឹមថាឯកសារនេះនឹងត្រូវបានប្រើប្រាស់ សម្រាប់ចូលរួមធ្វើអោយប្រសើឡើង នូវបរិយាកាសអំណោយផល និងលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន សម្រាប់អង្គការសង្គមស៊ីវិល រាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតនៅក្នុងប្រទេសកម្ពុជា។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADHOC | សមាគមអាដហុក |
| ASEAN | សមាគមអាស៊ាន |
| BfdW | ប្រេដហ្វដឺវើល |
| BoD | ក្រុមប្រឹក្សាភិបាល |
| CBOs | អង្គការសហគមន៍មូលដ្ឋាន |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CRDB/CDC | គណៈកម្មាធិការស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CMDGS | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (ក្របខណ្ឌដែលបានធ្វើមូលដ្ឋាននីយកម្ម សម្រាប់ប្រើប្រាស់ឆ្នាំ២០០០-២០១៥) |
| CNRP | គណៈបក្សសង្គ្រោះជាតិ |
| CoM | ទីស្តីការគណៈរដ្ឋមន្ត្រី |
| CPP | គណៈបក្សប្រជាជនកម្ពុជា |
| CSAF | វេទិកាសម្ព័ន្ធសង្គមស៊ីវិល |
| CSDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (ក្របខណ្ឌដែលបានធ្វើមូលដ្ឋាន នីយកម្មសម្រាប់ប្រើប្រាស់ឆ្នាំ២០១៦-២០៣០) |
| CSF | មូលនីធិសង្គមស៊ីវិល |
| CSOs | អង្គការសង្គមស៊ីវិល |
| CIVICUS | សម្ព័ន្ធអង្គការពិភពលោក ផ្តោតការងារលើការពង្រឹងសកម្មភាពពលរដ្ឋ និងសង្គមស៊ីវិលជុំវិញពិភពលោក |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| DCPS | កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ |
| DP | ដៃគូអភិវឌ្ឍន៍ |
| EBA | អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ (colloquial term give to the EU's Generalised Scheme of (Trade) Preferences (GSP), providing duty and quota-free access for almost all products (as the programme's name indicates, excluding arms and ammunition)[1] |
| EE&IP | បរិយាកាសអំណោយផល និងភាពជាដៃគូ |
| EENA | ការវាយតម្លៃបរិយាកាសអំណោយផលថ្នាក់ជាតិ (គំនិតផ្តួចផ្តើមរបស់ CIVICUS) |

[1] https://www.un.org/ldcportal/preferential-market-access-european-union-everything-but-arms-initiative/

| | |
|---|---|
| EU | សហភាពអឺរ៉ុប |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម របស់អង្គការសហប្រជាជាតិ |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FFMP | គម្រោងពិនិត្យតាមដានសេរីភាពជាមូលដ្ឋាន |
| FGDs | ការពិភាក្សាក្រុម |
| FNGO | អង្គការមិនមែនរដ្ឋាភិបាលបរទេស |
| GDP | ផលិតផលជាតិក្នុងស្រុកសរុប |
| HACC | គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព |
| ICNL | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនស្វែងរកប្រាក់ចំណេញ |
| ISAF | ក្របខណ្ឌអនុវត្តគណនេយ្យភាពសង្គម |
| KAPE | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |
| KIIs | ការសម្ភាសន៍ជាមួយបុគ្គលសំខាន់ៗ |
| LANGO | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
| LDC | ប្រទេសអភិវឌ្ឍន៍តិចតួច |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MoA | កិច្ចព្រមព្រៀងគ្នា |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoFAIC | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoI | ក្រសួងមហាផ្ទៃ |
| MoPT | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MoU | អនុស្សរណៈនៃការយោគយល់ |
| MPD | សន្ទស្សន៍នៃភាពក្រីក្រពហុវិស័យ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ODA | ជំនួយអភិវឌ្ឍបរទេស |
| OOF | ហិរញ្ញប្បទានបរទេសផ្សេងទៀត |
| OHCHR | (អង្គការសហប្រជាជាតិ) ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស |
| PESTLE | នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកទេស ច្បាប់ និងបរិស្ថាន (ក្របខណ្ឌសម្រាប់វិភាគបរិបទទូទៅ) |

| | |
|---|---|
| RSIV | យុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍ ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៤ |
| SAAS | កម្មវិធីកុំព្យូទ័រ (Software As a Service Application) |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SIDA | ភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការស៊ុយអ៊ែត |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| STEM | វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា |
| TI | តម្លាភាពអន្តរជាតិ |
| TWG | ក្រុមការងារបច្ចេកទេស |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |

# សេចក្តីសង្ខេប

## សាវតា

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដោយមានការគាំទ្រពីសហភាពអឺរ៉ុប (EU) និងអង្គការប្រេដហ្វដឺវើល (BfdW) បានរៀបចំការសិក្សាមួយក្នុងឆ្នាំ២០១៨ ដើម្បីស្វែងយល់ពីបរិយាកាសអំណោយផលក្នុងប្រទេស ចាប់តាំងពីមានការស្រាវជ្រាវថ្នាក់ជាតិកន្លងមកក្នុងឆ្នាំ២០១៣ (ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់អង្គការCIVICUS និងការស្រាវជ្រាវថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១៥។ វិសាលភាពនៃការសិក្សាបច្ចុប្បន្ន ក៏ត្រូវបានពង្រីកផងដែរ ដើម្បីស្វែងយល់ពីការប្រែប្រួល និងពិនិត្យមើលបន្ថែមពីភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដែលជាយន្តការមួយសម្រាប់ដំណើរវិវឌ្ឍន៍។

ការសិក្សានេះត្រូវបានផ្តួចផ្តើមគំនិតនៅឆ្នាំ២០១៨ នៅពេលដែលការពិគ្រោះយោបល់មួយត្រូវបានធ្វើឡើង ដើម្បីបង្កើតវិធីសាស្ត្រមួយក្នុងការប្រមូលធាតុចូលសម្រាប់ការសិក្សានេះ ហើយបានស្នើវិធីសាស្ត្រចម្រុះមួយ ដែលមានការពាក់ព័ន្ធនឹងការអង្កេតអ្នកតំណាង ដែលត្រូវបានជ្រើសរើសធ្វើជាសំណាករបស់អង្គការសង្គមស៊ីវិល (CSOs) មកពីអង្គការសមាជិកភាពផ្សេងៗ (អង្គការ CCC អង្គការ NGO-Forum អង្គការHACC និងអង្គការ NEP) ដើម្បីប្រមូលព័ត៌មានបែបបរិមាណ។ ព្រមទាំងរៀបចំអោយមានការប្រើប្រាស់វិធីសាស្ត្របែបគុណភាពជាចម្បង ដូចជាបទសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) ការពិភាក្សាក្រុមគោលដៅ (FGDs) ករណីសិក្សា (case study) និងការពិនិត្យប្រភពបន្ទាប់បន្សំ (secondary data review)។ ឧបករណ៍ និងមគ្គុទ្ទេសក៍ ត្រូវបានបង្កើតឡើងដោយសម្របតាមការវាយតម្លៃបរិយាកាសអំណោយផលជាតិ (EENA)។ ទិដ្ឋភាពផ្នែកផ្សេងៗត្រូវបានជ្រើសរើសសម្រាប់ការសិក្សា រួមមាន៖ (ក) ការបង្កើតនិងប្រតិបត្តិការ (ខ) សេរីភាពក្នុងការបញ្ចេញមតិ (គ) ការប្រមូលផ្តុំដោយសន្តិវិធី/ការជួបជុំ (ឃ) ពន្ធដារ (ង) លទ្ធភាពទទួលបានធនធាន (ច) សិទ្ធិទទួលបានព័ត៌មាន (ឆ) ទំនាក់ទំនងរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ហើយក៏មានការដាក់បន្ថែម (ជ) ភាពជាដៃគូប្រកបដោយបរិយាប័ន្នផងដែរ។

អង្គការសង្គមស៊ីវិលប្រហែល ៤០០អង្គការ ដំបូងឡើយត្រូវបានបង្កើតទៅជាធាតុចូលសម្រាប់ជ្រើសរើសក្នុងការអង្កេត ក្នុងក្តីសង្ឃឹមថានឹងទទួលបានអ្នកឆ្លើយតបចំនួន ១៥០។ នៅចុងបញ្ចប់មានតែ ៦៧ អង្គការសង្គមស៊ីវិលប៉ុណ្ណោះ ដែលបានឆ្លើយតប។ នេះជាសំណាក ដែលបានឆ្លើយតប ដែលទទួលបាន ហើយទិន្នន័យត្រូវបានបញ្ចូល សម្អាត និងវិភាគ។ ការពិភាក្សាក្រុម និងការសម្ភាសស៊ីជម្រៅ ត្រូវបានធ្វើផងដែរ លើក្រុមគោលដៅ ដែលបានបានចូលរួម។ ដោយមានមូលដ្ឋានលើការវិភាគ និងការឆ្លើយតប របាយការណ៍ព្រាងមួយត្រូវបានរៀបចំ និងដាក់ជូន។ នាពេលក្រោយមក ក្រុមការងារដាច់ដោយឡែកមួយបានចូលរួមក្នុងខែមិថុនា ឆ្នាំ២០១៩ ដើម្បីពិនិត្យមើល និងបញ្ចប់របាយការណ៍នេះ។

## បរិបទសង្គមស៊ីវិល

ការសិក្សានេះផ្តោតលើអង្គការសង្គមស៊ីវិល (CSOs) ដែលបានចុះបញ្ជី និងមិនគ្របដណ្តប់លើបណ្តាញដែលទូលំទូលាយខ្លាំងនៃអង្គការសហគមន៍មូលដ្ឋាន (CBOs)ក្រៅផ្លូវការឡើយ។ យោងតាមឧបនាយក រដ្ឋមន្រ្តី មានការរាយការណ៍ថា (គិតត្រឹមខែធ្នូ ឆ្នាំ២០១៨) មានសមគមនិងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៥.៥២៣ (អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.២២៦ និងសមាគមចំនួន ២.២៩៧) ដែលបានផ្តល់ឯកសារ និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ[2]។

## បរិបទរបស់ប្រទេស

ក្របខ័ណ្ឌផ្នែក នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (PESTLE) ត្រូវបានប្រើប្រាស់ ដើម្បីពិពណ៌នាដោយសង្ខេបអំពីបរិបទប្រទេស ដែលកំពុងវិវឌ្ឍន៍។

ប្រទេសកម្ពុជា បាន និងកំពុងឆ្លងកាត់អំឡុងពេលរឹតវរមួយចាប់ពីការវាយតម្លៃអំពីបរិយាកាសអំណោយផលចុងក្រោយក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៥។ ការណ៍នេះបានមើលឃើញលំហរពលរដ្ឋធ្លាក់ចុះគួរអោយកត់សំគាល់ ហើយត្រូវបានគេមើលឃើញដំណើរវិលត្រលប់ទៅរកការអនុវត្តបែបផ្តាច់ការ។ ក្រុមអ្នកការពារសិទ្ធិមនុស្ស និងតស៊ូមតិ ក្រុមអ្នករិះគន់រដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយត្រូវបានផ្តោតទិសដៅ ដែលបង្កឲ្យមានក្រុម/ក្រុមហ៊ុនមួយចំនួនត្រូវបានបង្ខំឲ្យបិទទ្វារ ហើយចំពោះបុគ្គលត្រូវបានកាត់ទោស។

## លទ្ធផលរកឃើញ

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីលទ្ធផលរកឃើញសំខាន់ៗ រួមជាមួយនឹងអនុសាសន៍សម្រាប់ក្រុមភាគីពាក់ព័ន្ធសំខាន់ៗនីមួយ។

### ១) ការបង្កើត និងប្រតិបត្តិការ

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ឆ្នាំ២០១៥ បច្ចុប្បន្នគឺជាច្បាប់សំខាន់ដែលជះឥទ្ធិពលលើការបង្កើតអង្គការសង្គមស៊ីវិលក្នុងស្រុក និងអង្គការបរទេស ដែលមានបំណងប្រតិបត្តិការក្នុងប្រទេសកម្ពុជា។ ច្បាប់នេះតម្រូវឲ្យអង្គការក្នុងស្រុកទាំងអស់ចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងទីក្រុងភ្នំពេញ ហើយបច្ចុប្បន្ន គឺជាដំណើរការមជ្ឈការ (និងស៊ីពេលវេលា)។

នៅលើឯកសារ ដំណើរការចុះបញ្ជី (សមាសធាតុអនុម័ត) មានន័យថាត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃ ប្រសិនបើឯកសារ ដែលតម្រូវទាំងអស់អាចត្រូវបានដាក់ជូន ឬក្នុងរយៈពេល ៦០ថ្ងៃបន្ថែម ប្រសិនបើព័ត៌មានបន្ថែមត្រូវបានតម្រូវ។ ទោះជាយ៉ាងណា ជាញឹកញាប់ដំណើរការចុះបញ្ជីចំណាយពេលយូរជាងនេះក្នុងរយៈពេល៦ខែទៅ១ឆ្នាំដែលត្រូវបានលើកឡើងដោយអង្គការសង្គម

[2] Sar Kheng, deputy prime minister and minister of MoI, speech at the Partnership Forum between Government and NGOs on 17th January 2019.

ស៊ីវិល ដែលបានឆ្លងកាត់ដំណើរការនេះ។ ក្រុមមន្ត្រីដែលពាក់ព័ន្ធនឹងការពិនិត្យមើលពាក្យស្នើសុំចុះបញ្ជី ជាញឹកញាប់តម្រូវឲ្យអង្គការដែលជាអ្នកដាក់ពាក្យសុំកែទម្រង់ និងកែពាក្យពេជន៍ឯកសាររួមទាំងលក្ខន្តិក:អង្គការក្នុងរបៀបពិសេសមួយ ហើយការទាមទារទាំងនេះត្រូវបានធ្វើតាម មុនពេលមានការដាក់ពាក្យជាផ្លូវការ ដើម្បីទទួលបានការអនុម័ត ហើយការទាមទារទាំងនេះច្បាស់ណាស់បង្កឲ្យមានការពន្យាពេល។ ក៏មានការរាយការណ៍ផងដែរថា "ការត្រួតពិនិត្យរហ័ស" លើពាក្យសុំអាចត្រូវបានបានធ្វើឡើងផងដែរបើមានការចំណាយកម្រៃក្រៅផ្លូវការ។ ជាងពាក់កណ្តាលនៃអង្គការសង្គមស៊ីវិល ដែលត្រូវបានអង្កេត (៥០%) បានជឿថា ដំណើរការចុះបញ្ជីអង្គការសង្គមស៊ីវិលមានការលំបាក។

ទាក់ទងនឹងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល វិសាលភាពនៃច្បាប់ LANGO នៅមានកម្រិតខ្លាំង។ ច្បាប់នេះដាក់ចេញលក្ខខណ្ឌតម្រូវឲ្យដាក់ជូនរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬច្បាប់ចម្លងនៃរបាការណ៍ដែលដាក់ជូនទៅម្ចាស់ជំនួយ ព្រមទាំងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងគម្រោងផងដែរ។ ការមិនអនុលោមតាមលក្ខខណ្ឌតម្រូវទាំងនេះ អាចបង្កឲ្យមានការផ្អាក ឬបិទអង្គការ។ ច្បាប់ LANGO ក៏ចែងផងដែរថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា (និងខចែងប្រហាក់ប្រហែលនេះអនុវត្តចំពោះអង្គការបរទេសដែលបានចុះបញ្ជី) ដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត អាចត្រូវបានបិទទ្វារ។ ប៉ុន្តែរបៀបដែលខចែងទាំងនេះត្រូវបាន ឬអាចត្រូវបានបកស្រាយ នៅតែមានភាពមិនច្បាស់លាស់។ ប្រសិនបើមានការចោទប្រកាន់ពីបទរំលោភខចែងទាំងនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍។

## ២) សេរីភាពក្នុងការបញ្ចេញមតិ

បើទោះបីជាត្រូវបានការពារដោយច្បាប់អន្តរជាតិ និងរដ្ឋធម្មនុញ្ញក្តី ក៏សេរីភាពក្នុងការបញ្ចេញមតិបច្ចុប្បន្នត្រូវបានចាត់ទុកថាត្រូវបានរឹតបន្តឹង ខណៈដែលបច្ចុប្បន្នមានឧទាហរណ៍ជាច្រើនអំពីការកាត់ទោសមនុស្សដោយសារការបញ្ចេញទស្សនៈប្រឆាំង។ ជាងពាក់កណ្តាលនៃអង្គការសង្គមស៊ីវិលដែលត្រូវបានអង្កេត (៥៨%) បានជឿថា ស្ថានភាពសម្រាប់សេរីភាពក្នុងការបញ្ចេញមតិ បានធ្លាក់ចុះបើធៀបនឹងឆ្នាំ២០១៥។ ជិតបីភាគបួននៃអង្គការសង្គមស៊ីវិល (៧៣%) បានជឿថា បុគ្គលិករបស់ពួកគេមានអារម្មណ៍ថាត្រូវបានរឹតបន្តឹងក្នុងអ្វីដែលពួកគេអាចនិយាយចេញមក។ ការតាមសង្កត់ដែលកំពុងធ្វើឡើងលើសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិផ្សេងទៀត កំពុងចាប់ផ្តើមមើលឃើញដូចស្ថានភាពបច្ចុប្បន្ននេះ និងជះឥទ្ធិពលដល់របៀបដែលអង្គការសង្គមស៊ីវិលប្រតិបត្តិការ។ ជាងមួយភាគបីនៃអង្គការសង្គមស៊ីវិល (៣៧%) មានការពេញចិត្ត ជាមួយនឹងបរិយាកាសអំណោយផលបច្ចុប្បន្ន ខណៈដែលអង្គការសង្គមស៊ីវិលជាច្រើនធ្វើការងារលើវិស័យសង្គម និង

វិស័យមិនប្រឈមផ្សេងទៀត និងលើបញ្ហានានា ស្របពេលដែលតិចជាងមួយភាគបីនៃអង្គការសង្គមស៊ីវិល (៣១%) មិនពេញចិត្តនឹងបរិយាកាសអំណោយផលដែលបានផ្លាស់ប្តូរ។

### ៣) ការប្រមូលផ្តុំដោយសន្តិវិធី/សេរីភាពក្នុងការជួបជុំ

បើទោះជាត្រូវបានការពារដោយរដ្ឋធម្មនុញ្ញក្តី ក៏ ៥៩% នៃអង្គការសង្គមស៊ីវិលបានជឿថា សេរីភាពក្នុងការប្រមូលផ្តុំ ត្រូវបានរឹតបន្តឹងកាន់តែខ្លាំងឡើង។ ៦៤% នៃអង្គការសង្គមស៊ីវិលបានរាយការណ៍ពីការជួបប្រទះទម្រង់នៃការរឹតបន្តឹងមួយចំនួន ដែលត្រូវបានដាក់ដោយអាជ្ញាធរសាធារណៈលើការរៀបចំការប្រមូលផ្តុំជាសាធារណៈ ឬដោយសន្តិវិធីរបស់ពួកគេ។ ដំបូងឡើយ អាជ្ញាធរមូលដ្ឋានក្នុងតំបន់ខ្លះនៃប្រទេសកម្ពុជា បានតម្រូវឲ្យអង្គការសង្គមស៊ីវិល ត្រូវទទួលបានការឯកភាពសម្រាប់ការរៀបចំព្រឹត្តិការណ៍នានា ហើយលក្ខខណ្ឌតម្រូវទាំងនេះបានរីករាលដាល់ដល់ទីតាំងផ្សេងទៀតនៃប្រទេស។

ក្នុងខែតុលា ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំមួយ ដោយតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាល "ជូនដំណឹង" ដល់អាជ្ញាធរមូលដ្ឋានជាមុនអំពីសកម្មភាពនានា ហើយការជូនដំណឹងនេះ ជាញឹកញាប់ត្រូវបានបកស្រាយដោយអាជ្ញាធរមូលដ្ឋានថា ជាការតម្រូវឲ្យសុំការអនុញ្ញាត។ ខណៈដែលការណ៍នេះត្រូវបានចាត់ទុកថាជាការរឹតបន្តឹងផ្នែករដ្ឋបាល អង្គការសង្គមស៊ីវិលភាគច្រើនបានជម្នះនឹងបញ្ហានេះ បើទោះជាមានបញ្ហាស្មុគស្មាញតាមវិស័យក្តី។ អង្គការសង្គមស៊ីវិលដែលធ្វើការងារលើបញ្ហាសង្គម/សេវាកម្ម ជីវភាពរស់នៅ ជាដើម មិនមានបញ្ហាក្នុងការធ្វើសកកម្មភាព ឬរៀបចំព្រឹត្តិការណ៍ក្នុងឃុំនានាឡើយ។ អង្គការសង្គមស៊ីវិលដែលធ្វើការងារលើបញ្ហាសិទ្ធិ និងតស៊ូមតិ ឬត្រូវបានកំណត់ (ដោយអាជ្ញាធរ) ថាជាអង្គការដែលរិះគន់ ជាញឹកញាប់អាចមិនទទួលបាន "ការអនុញ្ញាត" ឬអង្គការទាំងនោះនឹងមិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពទៅមុខទៀត ដូច្នេះមិនអាច ឬនឹងមិនអាចធ្វើសកម្មភាពក្នុងឃុំនានាបានឡើយ ដោយភ័យខ្លាចនឹងការប្រឈមមុខដាក់គ្នា ឬការសងសឹក។

### ៤) ពន្ធដារ

រហូតមកដល់ពេលបច្ចុប្បន្ននេះ ការអនុវត្តប្រព័ន្ធពន្ធជាតិជាញឹកញាប់មិនជាក់លាក់ និងមានការខ្វះចន្លោះ។ អង្គការសង្គមស៊ីវិលអាចប្រាសចាកពីការមិនបានបង់ពន្ធ។ ទោះជាយ៉ាងណាខណៈពេលដែលសេដ្ឋកិច្ចបានកើនឡើង ហើយសមត្ថភាពស្ថាប័នមានភាពប្រសើរឡើង រដ្ឋាភិបាលបានពង្រីកជាបន្តបន្ទាប់នូវមូលធនពន្ធរបស់ខ្លួន។ អង្គការសង្គមស៊ីវិលត្រូវបានចាត់ទុកថាជាស្ថាប័នដំបូងគេ ដែលទទួលខុសត្រូវលើទម្រង់ពន្ធមួយចំនួន (ជាធម្មតាពន្ធលើប្រាក់បៀវត្ស) ក្នុងច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧។ នៅក្នុងឆ្នាំ២០១៨ ប្រកាសថ្មីមួយ (លេខ៤៦៤) បានផ្តោតទិសដៅជាពិសេសលើអង្គការមិនមែនរដ្ឋាភិបាល ដោយតម្រូវឲ្យអង្គការទាំងអស់ចុះបញ្ជីជាមួយនាយកដ្ឋាន

ពន្ធដារ។ ប្រកាសនេះក៏លើកឡើងផងដែរអំពីការលើកលែងពន្ធលើប្រាក់ចំណូល ដែលបច្ចុប្បន្ននឹងចាំបាច់ត្រូវអនុវត្ត។

បើទោះជាមានការបង្ហាញថា អង្គការសង្គមស៊ីវិល មិនយល់ពីក្របខ័ណ្ឌច្បាប់ពន្ធក្តី ក៏មានការលើកឡើងផងដែរថា រដ្ឋាភិបាលបានប្រើប្រាស់ប្រព័ន្ធពន្ធធ្វើជាអាវុធ ដើម្បីបន្លាចអង្គការសង្គមស៊ីវិល។ ក្នុងឆ្នាំ២០១៧ កាសែតកាសែតខេមបូឌាដេលី ត្រូវបានបង្ខំឲ្យបិទទ្វារ បន្ទាប់ពីការវាយតម្លៃពន្ធត្រូវបានរកឃើញថា កាសែតនេះបានជំពាក់ប្រាក់ពន្ធប្រមាណ ៦លានដុល្លារអាមេរិក។ ការិយាល័យប្រព័ន្ធផ្សព្វផ្សាយផ្សេង (វិទ្យុអាស៊ីសេរី "RFA" និងវិទ្យុសំឡេងសហរដ្ឋអាមេរិក "VoA" នៅកម្ពុជា) ត្រូវបានកំណត់ទិសដៅ ផងដែរក្នុងឆ្នាំ២០១៧ ពីបទមិនអនុលោមតាមរបបពន្ធហើយត្រូវបានបិទការិយាល័យប្រចាំប្រទេសរបស់ខ្លួន។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សក្នុងស្រុកមួយចំនួន ត្រូវបានស៊ើបអង្កេតពីបញ្ហានេះ។ វាបានបង្ហាញកាន់តែច្បាស់ថាសារមួយកំពុងត្រូវបានបញ្ជូនទៅកាន់អង្គការសង្គមស៊ីវិល ដែលកំពុងដំណើរការជាយូរមកហើយថា ប្រសិនបើអង្គការទាំងនោះនៅតែរិះគន់ ប្រវត្តិពន្ធរបស់ពួកគេនឹងត្រូវបានស៊ើបអង្កេត ហើយអាចត្រូវបានប្រើប្រាស់រាំងដល់ពួកគេ។

### ៥) លទ្ធភាពទទួលបានធនធាន (រួមទាំងវិស័យឯកជន)

ខណៈពេលដែលធនធានពិភពលោក ដែលអាចរកបានសម្រាប់ជំនួយអភិវឌ្ឍន៍ ទំនងជាកំពុងធ្លាក់ចុះ តួលេខដែលអាចរកបានសម្រាប់ប្រទេសកម្ពុជា (OECD និង CRDB/CDC) ទំនងជាបង្ហាញពីលំហូរជំនួយប្រកបដោយស្ថិរភាព។ បើទោះជាលក្ខណៈជំនួយបានផ្លាស់ប្តូរទៅតាមពេលវេលាក្តី ដែលទំនងជាបណ្តាលមកពីកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដ៏ប្រសើររបស់ប្រទេសកម្ពុជាក្តី ក៏ប្រហែលពាក់កណ្តាលនៃលំហូរធំៗ ត្រូវបានចាត់ទុកថាជាជំនួយសម្បទាន។

អង្គការមិនមែនរដ្ឋាភិបាលបានទទួលជំនួយប្រហែលមួយភាគប្រាំ នៃជំនួយទាំងអស់ ដែលផ្តល់មកឲ្យកម្ពុជា ដែលជាមធ្យមមានចំនួនពី ២០០ ទៅ ២២០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលរកបានដោយធនធានផ្ទាល់របស់អង្គការទាំងនេះ ដែលអាចជាធនធានបន្ថែមដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍ ហើយមានការព្យាករថា កម្រិតជំនួយរបស់អង្គការសង្គមស៊ីវិលនេះនឹងនៅរក្សាបានកម្រិតនេះរហូតដល់ឆ្នាំ២០២៥។

ទោះជាយ៉ាងណា មានការយល់ឃើញជាទូទៅក្នុងចំណោមអង្គការសង្គមស៊ីវិលថា លទ្ធភាពទទួលបានធនធាន (ហិរញ្ញវត្ថុ) កំពុងធ្លាក់ចុះ ដោយសារការពឹងផ្អែករបស់អង្គការសង្គមស៊ីវិលលើ "ការផ្តល់ជំនួយតាមគម្រោងរយៈពេលខ្លី" និង"មិនមានលទ្ធភាពទទួលបានការគាំទ្រអង្គការទូទៅ"។ ការយល់ឃើញនេះត្រូវបានរួមផ្សំដោយការប្រមូលផ្តុំ ដែលត្រូវបានសង្កេតឃើញនៃការផ្តល់មូលនិធិអង្គការសង្គមស៊ីវិលទៅក្នុងអង្គការមួយចំនួនតូច។ គណៈកម្មាធិការស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) រាយការណ៍ថា ត្រឹមតែប្រមាណ២៥ ឬ ៤៦០ អង្គការប៉ុណ្ណោះ ដែលស្ម័គ្រចិត្តរាយការណ៍ទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ទទួល

បានមូលនិធិ ៥២% នៃមូលនិធិអង្គការសង្គមស៊ីវិល ដែលត្រូវបានរាយការណ៍ទាំងអស់។ ទោះបីជាយ៉ាងណា គួរកត់សម្គាល់ថា អង្គការមិនមែនរដ្ឋាភិបាលធំៗ (ភាគច្រើនជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ) ជាញឹកញាប់ផ្តល់ធនធាន ដែលទទួលបានទៅឲ្យអង្គការសង្គមស៊ីវិលផ្សេងទៀត។

លំហូរធនធានផ្សេងទៀតត្រូវបានរាយការណ៍ថាមានសក្តានុពលខ្លាំង (ពីវិស័យឯកជន និងអាចមកពីរដ្ឋាភិបាលក្នុងពេលអនាគត) ប៉ុន្តែមានការដឹងឮតិចតួចណាស់អំពីវិសាលភាពនៃការគាំទ្របែបនេះនៅក្នុងប្រទេស។ ប្រភពធនធានផ្សេងទៀតអាចត្រូវបានបង្កើតចេញពីសហគ្រាសសង្គម ប៉ុន្តែទាំងនេះនាំមកនោះបញ្ហាពន្ធពាណិជ្ជកម្ម។

អ្វីដែលច្បាប់លាស់នោះគឺថា អង្គការសង្គមស៊ីវិលភាគច្រើនមានបញ្ហាប្រឈមចំពោះលទ្ធភាពចូលទៅកាន់ និងការទទួលបានធនធាន។ ជាទូទៅអង្គការទាំងនេះខ្វះសមត្ថភាព ជំនាញ និងបណ្តាញ ដើម្បីប្រកួតប្រជែងជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិធំៗ។

## ៦) សិទ្ធិទទួលបានព័ត៌មាន

ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសមានការយល់ដឹង ខាងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ដោយល្បឿននៃការប្រើប្រាស់អ៊ីនធឺណិត និងទូរស័ព្ទដៃកើនឡើង។ ការប្រើប្រាស់អ៊ីនធឺណិតកើនពី ៣០០.០០០ នាក់ក្នុងឆ្នាំ២០១០ ដល់ជាង ៤លាននាក់ ក្នុងរយៈពេលបួនឆ្នាំក្រោយមក ខណៈដែលអ្នកមានទូរស័ព្ទប្រើប្រាស់ត្រូវបានរាយការណ៍ថាមាន ៩២ នាក់ក្នុងចំណោម ១០០នាក់។ ដូច្នេះ ឧបករណ៍ចល័ត អាចឲ្យអ្នកប្រើប្រាស់អ៊ីនធឺណិតបាន ដែលបានក្លាយជាប្រភពមួយនៅក្នុងចំណោមប្រភពសាធារណៈដ៏ចម្បងនៃការទទួលបានព័ត៌មាន។

ទោះជាយ៉ាងណា ប្រទេសកម្ពុជាបន្តខ្វះច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) ដែលត្រូវបានព្រាងរួចហើយ ប៉ុន្តែនៅមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ច្បាប់នេះមានចែងអំពីក្របខ័ណ្ឌដែលមួយ ដែលអាចឲ្យប្រជាពលរដ្ឋមានសិទ្ធិទទួលបានព័ត៌មានដែលពួកគេត្រូវការ។ ប្រទេសកម្ពុជាក៏ខ្វះខាតច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិតផងដែរ។ ការអង្កេតរបស់អង្គការសង្គមស៊ីវិលសម្រាប់ការសិក្សានេះបានរកឃើញថា ជាងមួយភាគបីនៃអង្គការសង្គមស៊ីវិល (៣៦%) ជឿថា សិទ្ធិទទួលបានព័ត៌មានពីរដ្ឋនៅថ្នាក់ជាតិ មានការលំបាក ហើយបានពឹងផ្អែកខ្លាំងលើទំនាក់ទំនងផ្ទាល់ខ្លួនជាងលើប្រព័ន្ធសិទ្ធិទទួលបានព័ត៌មានបើកចំហរមួយ។

ទោះជាយ៉ាងណា មានការសង្កេតឃើញថា ចាប់ពីឆ្នាំ២០១៥ មក អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវបានផ្តោតទិសដៅដោយរដ្ឋាភិបាលដោយសារការរិះគន់រដ្ឋ យ៉ាងហោចណាស់មានមនុស្សចំនួន ១៣នាក់ត្រូវបានចោទពីបទល្មើស រួមទាំងការចោទស្ថិតក្រោមច្បាប់ស្តីពីការជេរប្រមាថព្រះមហាក្សត្រ ដែលត្រូវបានអនុម័តនាពេលថ្មីៗនេះ (ឆ្នាំ២០១៨) ខណៈដែលភាគច្រើនក្នុងចំណោមអ្នកទាំងនោះត្រូវបានចោទស្ថិតក្រោមបទបរិហាកេរ្តិ៍ និងការញុះញង់ដែលមិនច្បាស់លាស់ យោងតាម

មាត្រានៃក្រមព្រហ្មទណ្ឌ ដែលត្រូវបានប្រើប្រាស់តាមទំនើងចិត្ត ដើម្បីគាបសង្កត់សេរីភាពក្នុងការនិយាយស្តីរបស់ក្រុមអ្នករិះគន់។

## ៧) ទំនាក់ទំនងរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ផ្នែកនេះមានការលំបាកក្នុងការផ្តល់លក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយសារការឆ្លើយតបរបស់អង្គការសង្គមស៊ីវិលទៅនឹងការអង្កេតនេះមានភាពចម្រុះ។ ក៏មានកត្តាជាច្រើនទៀតផងដែរ ដែលជះឥទ្ធិពលដល់សមាសភាគនេះ។ អង្គការសង្គមស៊ីវិលភាគច្រើនមានទំនាក់ទំនងប្រតិបត្តិការមួយចំនួនជាមួយអាជ្ញាធរ។ ជាញឹកញាប់ ទំនាក់ទំនងនេះកើតមាននៅថ្នាក់ឃុំ និងថ្នាក់ស្រុក ជាទីដែលអង្គការសង្គមស៊ីវិលមានការពាក់ព័ន្ធ និងចូលរួមជាមួយអ្នកតំណាងរបស់អាជ្ញាធរមូលដ្ឋាន ខណៈពេលដែលពួកគេជាញឹកញាប់គឺជាមន្ត្រីស្ម័គ្រចិត្ត ដែលត្រូវបានចាត់តាំងសម្រាប់កម្មភាពអភិវឌ្ឍន៍ជាច្រើន ដូចជា គណៈកម្មការស្ត្រី និងកុមារ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយជាដើម ជាញឹកញាប់នៅថ្នាក់ឃុំ និងថ្នាក់ស្រុក ប៉ុន្តែក៏មាននៅថ្នាក់ខេត្តផងដែរ។

ទោះជាយ៉ាងណា បុគ្គលិកអង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ជាច្រើន បានជឿថា ជាញឹកញាប់មានទំនាក់ទំនង "សោះកក្រោះ" ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីដែលពាក់ព័ន្ធក្នុងអំឡុងពេលពិនិត្យមើល ដែលពួកគេបានពាក់ព័ន្ធជាមួយនឹងការបង្កើនបរិយាកាសនយោបាយដែលព្រួយបារម្ភ។

## ៨) ភាពជាដៃគូប្រកបដោយបរិយាប័ន្ន (ឯកជន រដ្ឋាភិបាល អង្គការសង្គមស៊ីវិល)

មានយន្តការភាពជាដៃគូ និងសម្របសម្រួលជាច្រើននៅថ្នាក់ជាតិ។ ជាទូទៅយន្តការទាំងនេះបានផ្តោតការយកចិត្តទុកដាក់លើភាពជាដៃគូ និងការសម្របសម្រួលជាតុចូលរបស់ដៃគូអភិវឌ្ឍន៍ជាមួយរដ្ឋាភិបាល។ យន្តការដែលត្រូវបានគេស្គាល់ខ្លាំងជាទូទៅនោះ គឺក្រុមការងារបច្ចេកទេស (TWG) ចំនួន២១។ ខណៈពេលដែលយន្តការខ្លះមានភាពសកម្មនោះ យន្តការមួយចំនួនទៀតមិនមានភាពសកម្មឡើយ ប៉ុន្តែវាមានការលំបាកក្នុងការកំណត់ពីផលប៉ះពាល់ដែល កើនឡើងជាបន្តបន្ទាប់នៃសកម្មភាពរបស់យន្តការទាំងនេះ ខណៈយន្តការទាំងនេះមានភាពរប៉ាត់រប៉ាយ។ ភាគីពាក់ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ បានបង្ហាញថា ក្រុមការងារបច្ចេកទេស ជាទូទៅគឺជាយន្តការសម្របសម្រួលថ្នាក់ខ្ពស់។ យន្តការទាំងនេះជាទូទៅមិនមានការពាក់ព័ន្ធនឹងការធ្វើអន្តរាគមន៍ ឬអនុវត្តនយោបាយឡើយ។ មានតំណាងរបស់អង្គការសង្គមស៊ីវិលនៅក្នុង ក្រុមការងារបច្ចេកទេសមួយចំនួន ដែលភាគច្រើន ស្ថិតក្នុងក្រុមការងារបច្ចេកទេស ដែលធ្វើការងារក្នុងវិស័យសង្គម (ការអប់រំ និងសុខាភិបាល ជាដើម)។

## សេចក្តីសន្និដ្ឋាន

បរិបទរបស់ប្រទេសកម្ពុជាបានផ្លាស់ប្តូរខ្លាំងចាប់ពីឆ្នាំ២០១៥ ទាក់ទងនឹងទិដ្ឋភាពច្បាប់ សង្គម សេដ្ឋកិច្ច និងនយោបាយ និងផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះ ចំពោះបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល។ យោងការយល់ឃើញ និងការសង្កេតឃើញរបស់ភាគីពាក់ព័ន្ធអន្តរជាតិ និងជាតិជាច្រើន បរិយាកាសប្រតិបត្តិការរបស់វិស័យនេះបានធ្លាក់ចុះ ជាពិសេសក្នុងអំឡុងពេលនៃការសិក្សាចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ ការណ៍នេះដោយឥទ្ធិពលនយោបាយពីគណបក្សកាន់អំណាច ចំពោះការកើនឡើងសម្លេងឆ្នោតរបស់គណបក្សប្រឆាំងពីការបោះឆ្នោតជាតិឆ្នាំ២០១៣ និងការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ/ឃុំឆ្នាំ២០១៧។ មុនដំណើររំលាយគណបក្សប្រឆាំង បក្សកាន់អំណាចបានផ្តោតទិសដៅ បានបំភិតបំភ័យ និងបានបិទប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលដែលរិះគន់ ហើយការបៀតបៀននេះ មួយផ្នែកមានមូលដ្ឋានលើការដកហូតពន្ធតឹងរឹង និងសេរីវីទារបំណុលពន្ធ ដែលជំពាក់ចាប់តាំងឆ្នាំ១៩៩៧មក។

ដំណើរការចុះបញ្ជីថ្មីទាំងនេះ និងលក្ខខណ្ឌតម្រូវឲ្យរាយការណ៍ ជះឥទ្ធិពលយ៉ាងខ្លាំងដល់សមាសភាគទីមួយនៃក្របខ័ណ្ឌបរិយាកាសអំណោយផល ដែលត្រូវបានសម្រួល សម្រាប់ "**ការបង្កើត និងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល**"។ មានសេចក្តីរាយការណ៍ថា អង្គការសង្គមស៊ីវិលដែលប៉ុនប៉ង់ចុះបញ្ជី ជាញឹកញាប់ត្រូវបានតម្រូវឲ្យពិនិត្យមើលឯកសារ និងលក្ខន្តិកៈរបស់ខ្លួនឡើងវិញ ដើម្បីឲ្យមានអត្ថបទដែលតម្រូវដោយមន្ត្រីក្រសួងមហាផ្ទៃ។ លើសពីនេះទៀត ដំណើរការចុះបញ្ជីមានរយៈពេលយូរជាងរយៈពេលដែលមានចែងក្នុងច្បាប់ (LANGO)។ អង្គការសង្គមស៊ីវិលមួយចំនួនបានរាយការណ៍ថាត្រូវបានស្នើឲ្យបង់ប្រាក់ក្រៅផ្លូវការ ដើម្បីសម្របសម្រួល និងពន្លឿនការចុះបញ្ជី។ ចាប់ពីមានការដាក់ចេញច្បាប់នេះមក ក្រសួងមហាផ្ទៃបានកំណត់ទិសដៅលើអង្គការសង្គមស៊ីវិលមួយចំនួនទាក់ទងនឹងអនុលោមតាមលក្ខខណ្ឌតម្រូវរាយការណ៍របស់ខ្លួន ហើយការមិនអនុលោមតាមអាចបណ្តាលឲ្យមានការផ្អាក ឬបិទទ្វារ ហើយសំណើអនុលោមភាពទាំងនេះ បានកើនឡើងខ្លាំងក្នុងឆ្នាំ២០១៧។ ភាគច្រើននៃអង្គកាសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានពិគ្រោះយោបល់យល់ឃើញថា លក្ខខណ្ឌតម្រូវបង្កើត និងប្រតិបត្តិការបង្កឲ្យមានភាពលំបាកកាន់តែខ្លាំង។

ស្របជាមួយនឹងបញ្ហាបង្កើត និងប្រតិបត្តិការ "**សេរីភាពក្នុងការបញ្ចេញមតិ**" ត្រូវបានរារាំងកាន់តែខ្លាំងចាប់ពីឆ្នាំ២០១៥មក។ ៥៨% នៃអង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ បានយល់ឃើញថា សិទ្ធិសេរីភាពក្នុងការនិយាយស្តី ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញត្រូវបានរារាំង និងថា បុគ្គលិករបស់អង្គការសង្គមស៊ីវិល មានការប្រុងប្រយ័ត្នកាន់តែខ្លាំង ចំពោះអ្វីដែលពួកគេនិយាយ ចាប់ពីឆ្នាំ២០១៥ មក ដោយសារការបំភិតបំភ័យ។

សិទ្ធិជាមូលដ្ឋានផ្សេងទៀត ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ក៏បានធ្លាក់ចុះផងដែរ។ ផ្នែកទីបីនិយាយអំពី "**ការប្រមូលផ្តុំដោយសន្តិវិធី/សេរីភាពក្នុងការជួបជុំ**"។ ការយល់ស៊ីជម្រៅអំពីការណ៍

នេះ មានភាពខុសគ្នាខ្លាំង ពីការឆ្លើយតបរបស់អង្គការសង្គមស៊ីវិល ដោយផ្អែកលើកត្តាទីតាំង និងវិស័យសកម្មភាព ខណៈវិស័យដែលមានភាពចម្រោងចម្រាស់កាន់តែតិច (វិស័យអប់រំ និងសុខាភិបាលជាដើម) បានទទួលរងគ្រោះកាន់តែតិច។ ក្នុងអំឡុងពេលសិក្សា រដ្ឋាភិបាលបានអនុវត្តលក្ខខណ្ឌតម្រូវការស្ថាប័ន (ក្នុងខែតុលា ឆ្នាំ២០១៧) ដែលបានរារាំងដល់សេរីភាពក្នុងការបង្កើតសមាគម ប៉ុន្តែលក្ខខណ្ឌតម្រូវទាំងនេះត្រូវបានដកចេញវិញក្នុងខែតុលា ឆ្នាំ២០១៨។ អង្គការសង្គមស៊ីវិលក៏បានលើកឡើងផងដែរពីការបន្តកង្វះ "**សិទ្ធិទទួលបានព័ត៌មាន**" ខណៈដែលអង្គការសង្គមស៊ីវិល និងសាធារណៈជននៅតែប្រឈមនឹងការទទួលបានព័ត៌មានមូលដ្ឋាន។ វាបានបង្ហាញកាន់តែច្បាស់ក្នុងអំឡុងពេលពិនិត្យមើលដែលថា "**ពន្ធ**" ត្រូវបាន "ប្រើប្រាស់ធ្វើជាអាវុធ" និងត្រូវបានប្រើប្រាស់ធ្វើជាឧបករណ៍មួយសម្រាប់ការបំភិតបំភ័យ និងការគ្រប់គ្រងអង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។

យោបល់ត្រលប់អំពី "**ទំនាក់ទំនងរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល**" ក៏មានភាពខុសគ្នាផងដែរ ខណៈបទពិសោធ ដែលត្រូវបានរាយការណ៍មានភាពចម្រុះ។ ភាគច្រើននៃអង្គការសង្គមស៊ីវិល បានរាយការណ៍ពីការធ្លាក់ចុះលក្ខណៈទំនាក់ទំនងរបស់ខ្លួនជាមួយអាជ្ញាធរ ហើយការធ្លាក់ចុះនេះមានកាន់តែខ្លាំងនៅថ្នាក់ជាតិជាងនៅថ្នាក់ក្រោមជាតិ។ ប៉ុន្តែអង្គការសង្គមស៊ីវិលទាំងអស់បានរាយការណ៍ពីការមានទម្រង់ទំនាក់ទំនងមួយចំនួនជាមួយអាជ្ញាធររដ្ឋាភិបាល ខណៈដែលអង្គការសង្គមស៊ីវិលជាច្រើនបានដឹងថា បញ្ហាដែលកើតមានជាមួយនឹងទំនាក់ទំនងរបស់ពួកគេត្រូវបង្កឡើងមកពីលើ ហើយអាចមិនជះឥទ្ធិពលដល់ភាពពិតប្រាកដនៃទំនាក់ទំនងនេះឡើយ។

ភាគច្រើននៃអង្គការសង្គមស៊ីវិលបានរាយការណ៍ថា ធនធានមានកម្រិត ដើម្បីអនុវត្ត និង/ឬបំពេញការងារ ហើយ**លទ្ធភាពទទួលបានធនធានបន្ថែម** កាន់តែមានការលំបាកជាងពេលមុន។ ការណ៍នេះគឺដោយសារកត្តារួមផ្សំនៃការកើនឡើងនីតិវិធីអនុវត្តស្មុគស្មាញ ការប្រកួតប្រជែងកាន់តែខ្លាំង កង្វះសមត្ថភាពទទួលបានមូលនិធិ និងមូលនិធិកាន់តែមានតិច/មានលក្ខខណ្ឌកាន់តែខ្លាំង។

## អនុសាសន៍

អនុសាសន៍ និងការផ្តល់យោបល់មាននៅគ្រប់ផ្នែកនីមួយៗ ក្នុងឯកសារនេះ សម្រាប់សមាសភាពនៃបរិយាកាសអំណោយផល និងវិសាលភាពនៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន។

### ១. ការបង្កើត និងប្រតិបត្តិការ

ដោយសារនីតិវិធីជាប្រចាំ និងចំពោះកិច្ច ហើយត្រូវបានរាយការណ៍ ដែលកំពុងត្រូវបានអនុវត្តដោយបុគ្គលិកនៅក្រសួងមហាផ្ទៃ ដែលទំនងជាអូសបន្លាយពេលវេលាដល់ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល/សមាគម មានការផ្តល់អនុសាសន៍ថា (i) ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម គួរត្រូវបានធ្វើឡើងតាមអនឡាញ ហើយមួយផ្នែកត្រូវបានវិមជ្ឈការតាមរយៈ "ការិយាល័យច្រកចេញចូលតែមួយ" ក្នុងខេត្ត ដែលនឹងចេញលិខិត/"ការអនុញ្ញាត" ដើម្បីប្រតិបត្តិការ។ (ii) កំណត់ខ្នាតគំរូឲ្យកាន់តែប្រសើរសម្រាប់ដំណើការអនុវត្ត ដើម្បីធ្វើឲ្យដំណើរការនេះកាន់តែមានតម្លាភាព (iii)

បង្កើតសៀវភៅមគ្គុទ្ទេសក៍ចុះបញ្ជីអង្គការសង្គមស៊ីវិល និងការបណ្តុះបណ្តាល ដោយលម្អិតនិងបញ្ជាក់បំភ្លឺអំពីលក្ខខណ្ឌតម្រូវចុះបញ្ជី និងអនុលោមភាព (iv) បង្កើតការបណ្តុះបណ្តាល និងសម្ភារបន្ថែមដែលកំណត់ទិសដៅ សម្រាប់អាជ្ញាធរមូលដ្ឋាន ដើម្បីជូនដំណឹងកាន់ប្រសើរដល់ពួកគេអំពីវិសាលភាព និងបទប្បញ្ញត្តិរបស់ច្បាប់ (LANGO) (v) ចូលរួមជាមួយក្រសួងសាមី ដើម្បីស្វែងរកការបញ្ជាក់បំភ្លឺ និងការធ្វើឲ្យប្រសើរឡើងនូវឧបករណ៍ច្បាប់ដែលពាក់ព័ន្ធស្តីពីការចុះបញ្ជី និងប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាល។

## ២. សេរីភាពក្នុងការបញ្ចេញមតិ

កិច្ចគាំពារ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ អាចសម្រេចបាន លុះត្រាតែមានការធានាថា រាល់អង្គការសង្គមស៊ីវិលទាំងអស់មានការពិនិត្យតាមដានដោយប្រុងប្រយ័ត្ន នូវរាល់ឧប្បត្តិហេតុ និងការប្រតិបត្តិនានា ដែលអាចកាត់បន្ថយសិទ្ធិរបស់ពលរដ្ឋ និងវិស័យសង្គម។ ដើម្បីគាំទ្រដល់តួនាទីនេះ មានការផ្តល់អនុសាសន៍ថា (i) អង្គការសង្គមស៊ីវិលគួរបង្កើតយន្តការមួយ (platform) មួយដើម្បីភ្ជាប់ខ្លួនជាមួយរដ្ឋាភិបាលកាន់តែប្រសើរទាក់ទងនឹងបញ្ហាសេរីភាពក្នុងការបញ្ចេញមតិ (ii & iii) អង្គការសង្គមស៊ីវិលគួរផ្តួចផ្តើមគំនិតធ្វើយុទ្ធនាការក្នុងការជូនដំណឹងកាន់តែប្រសើរដល់អង្គការសង្គមស៊ីវិល និងសាធារណៈអំពីការទាមទារឲ្យមានការពិនិត្យមើល/ការលុបចោលឧបករណ៍ច្បាប់ ដែលកាត់បន្ថយសេរីភាពក្នុងការបញ្ចេញមតិ (iv) ដើម្បីគាំទ្រសកម្មភាពទាំងនេះ អង្គការសង្គមស៊ីវិលចាំបាច់ត្រូវរៀបចំឲ្យបានកាន់តែប្រសើរនូវឯកសារ និងករណីរំលោភសិទ្ធិ និងការគាបសង្កត់ដែលជាប់ទាក់ទងគ្នា (v) បន្សុីសកម្មភាពនានាជាមួយគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា (CSDG) ដែលសម្របឲ្យមានលក្ខណៈក្នុងស្រុក (គោលដៅទី១០ និងទី១៦)។

## ៣. ការប្រមូលផ្តុំដោយសន្តិវិធី/សេរីភាពក្នុងការជួបប្រជុំ

សេរីភាពក្នុងការបញ្ចេញមតិ មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសេរីភាពក្នុងការប្រមូលផ្តុំ ដែលក៏ចាំបាច់ផងដែរក្នុងការពិនិត្យតាមដាន និងការពារដោយសង្គមស៊ីវិល។ ដើម្បីចូលរួមចំណែកដល់ការណ៍នេះ មានការផ្តល់អនុសាសន៍ថា (i) អង្គការសង្គមស៊ីវិល តួអង្គផ្សេងទៀត និងភាគីពាក់ព័ន្ធ លើកកម្ពស់ការផ្សព្វផ្សាយ និងការប្រកាន់ភ្ជាប់ទៅកាន់ក្របខ័ណ្ឌច្បាប់ដោយមន្ត្រី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងមន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋាន។ ការណ៍នេះអាចត្រូវសម្រេចបានតាមរយៈ (ii) ពង្រីកសកម្មភាពកសាងសមត្ថភាព ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងសិទ្ធិដោយមន្ត្រី អង្គការសង្គមស៊ីវិល និងសាធារណៈ។ ក្នុងការគាំទ្រគឺនេះ (iii) រដ្ឋាភិបាលចាំបាច់ត្រូវលើកទឹកចិត្តឲ្យមានការបង្កើតប្រព័ន្ធគណនេយ្យភាព និងកែតម្រូវ ដើម្បីតាមដានការយល់ដឹងអំពី និងការរំលោភសិទ្ធិ និងក្របខ័ណ្ឌច្បាប់ និង (v) តម្រូវឲ្យមានការលើកកម្ពស់ ការពិនិត្យតាមដានការរំលោភសិទ្ធិមនុស្សដោយឯករាជ្យផងដែរ។

## ៤. ពន្ធដារ

វាច្បាស់ណាស់ថា អង្គការសង្គមស៊ីវិលជាច្រើនខ្វះការយល់ដឹងប្រកបដោយប្រសិទ្ធភាពអំពីលក្ខខណ្ឌតម្រូវនិងកាតព្វកិច្ចពន្ធ និងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ ដែលកំពុងវិវឌ្ឍន៍ឡើង។ ក្នុងចំណោមក្តីបារម្ភធំៗ រួមមាន "សញ្ញាវុធនីយកម្ម" នៃប្រព័ន្ធពន្ធ និងច្បាប់ ដែលធ្វើឡើងដោយរដ្ឋាភិបាលក្នុងអំឡុងពេលសិក្សា (ឆ្នាំ២០១៥-២០១៩) ដើម្បីបំភិតបំភ័យអង្គការសង្គមស៊ីវិល ដែលត្រូវបានផ្តោតទិសដៅ ដែលអង្គការទាំងនោះត្រូវបានចាត់ទុកថាជាការគំរាមកំហែង? ប្រការចាំបាច់នោះគឺថា អង្គការសង្គមស៊ីវិលត្រូវគាំទ្រគ្នាទៅវិញទៅមក ប៉ុន្តែក៏ត្រូវធានាផងដែរថា អង្គការសង្គមស៊ីវិលផ្សេងទៀតអនុលោមតាមច្បាប់របស់ប្រទេស។ មានការផ្តល់អនុសាសន៍ថា អង្គការសង្គមស៊ីវិល (i) បន្តផ្សព្វផ្សាយសម្មភាពរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្រូវការក្នុងការអនុលោមតាមច្បាប់ពន្ធ ដែលកំពុងវិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល (ii) បង្កើត និងរក្សាមគ្គុទ្ទេសក៍ពន្ធមួយ និងធនធាន/បណ្ណាល័យ ដែលមានមូលដ្ឋានលើកុំព្យូទ័រខ្លៅ (Cloud) ស្តីពីអនុលោមភាពរបស់អង្គការសង្គមស៊ីវិលទៅនឹងច្បាប់ និងបទប្បញ្ញត្តិពន្ធដែលកំពុងវិវឌ្ឍន៍ (iii) តស៊ូមតិសម្រាប់ការអនុវត្តច្បាប់ពន្ធដោយមិនលម្អៀងទៅកាន់គ្រប់ផ្នែកទាំងអស់នៃសង្គម (iv) ពិនិត្យតាមដានការអនុវត្ត និងបទពិសោធរបស់អង្គការសង្គមស៊ីវិលជាមួយការិយាល័យពន្ធ ដើម្បីធានាថា អង្គការទាំងនេះត្រូវបានប្រព្រឹត្តដោយស្មើភាព (v) តស៊ូមតិសម្រាប់ការលើកលែងពន្ធ និងការអនុវត្តប្រតិសកម្មអតិបរមា នូវលក្ខខណ្ឌតម្រូវច្បាប់ពន្ធសម្រាប់គ្រប់វិស័យ (vi) លើកកម្ពស់ការយល់ដឹងសាធារណៈអំពីការអនុវត្តប្រាក់ចំណូលពន្ធ តាមរយៈ "គំនិតផ្តួចផ្តើមថវិកាបើកចំហរ" និង តម្លាភាព។

## ៥. លទ្ធភាពទទួលបានធនធាន (រួមទាំងវិស័យឯកជន)

ក្តីបារម្ភមួយក្នុងចំណោមក្តីបារម្ភ ដែលត្រូវបានលើកឡើងជាញឹកញាប់បំផុត ដោយអង្គការសង្គមស៊ីវិលជាតិ គឺលទ្ធភាពទទួលបានធនធាន (ហិរញ្ញវត្ថុ)។ ខណៈដែលការណ៍នេះគឺជាបញ្ហាប្រឈមមួយសម្រាប់អង្គការទាំងអស់នៅក្នុងពិភពលោក វាច្បាស់ណាស់ថា អង្គការសង្គមស៊ីវិលជាតិយល់ឃើញថាជួបបញ្ហាប្រឈមយ៉ាងពិសេស។ អង្គការជាច្រើនយល់ឃើញថា ភាពអាចរកបាននៃធនធានបានធ្លាក់ចុះ ប៉ុន្តែភស្តុតាងបង្ហាញថា ខណៈពេលធនធានដែលត្រូវបានប្តេជ្ញាចិត្តដោយម្ចាស់ជំនួយប្រែប្រួល មានការព្យាករថា ធនធានទាំងនេះនឹងនៅតែមានតុល្យភាពត្រឹមត្រូវសម្រាប់ពេលអនាគតដ៏ខ្លី។ មានការផ្តល់អនុសាសន៍ថា (i) ក្រុមអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលចាំបាច់ត្រូវតស៊ូមតិ ដើម្បីធ្វើឲ្យមានរបាយមូលនិធិកាន់តែប្រសើរ តាមរយៈការបន្សីជាមួយនឹងគោលបំណង និងអាទិភាពអភិវឌ្ឍន៍ជាតិ (ii) អង្គការសង្គមស៊ីវិលចាំបាច់ត្រូវបង្កើនសមត្ថភាពដើម្បីទទួលបានធនធានកាន់តែប្រសើរ (iii) លើកកម្ពស់ការចូលរួមរបស់ម្ចាស់ជំនួយ រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីទាញយកប្រយោជន៍ពីគោលបំណងអភិវឌ្ឍន៍ជាតិ ការប្តេជ្ញាចិត្តនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (CSDG) ក្នុងការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច (LDC) និងស្វែងរកសក្តានុពលសម្រាប់

មូលនិធិអង្គការសង្គមស៊ីវិល ដើម្បីចូលរួមចំណែកដល់កិច្ចការទាំងនេះពីប្រភពទាំងនេះ (iv) ស្នើសុំម្ចាស់ជំនួយដែលមានសក្ដានុពល ដើម្បីវាយតម្លៃដោយឯករាជ្យនូវការចំណាយ និងអត្ថប្រយោជន៍នៃការបង្កើត និងគាំទ្រកញ្ចប់មូលនិធិ (Trust Fund) បណ្ដុំអង្គការសង្គមស៊ីវិល/ពហុម្ចាស់ជំនួយ ដើម្បីមើលឃើញថាតើ វានឹងផ្ដល់តម្លៃសម្រាប់ការវិនិយោគធៀបនឹងជម្រើសផ្ដល់មូលនិធិដែលអាចមានផ្សេងទៀតឬយ៉ាងណា។

## ៦. សិទ្ធិទទួលបានព័ត៌មាន

ដើម្បីអាចឲ្យអ្នកធ្វើសេចក្ដីសម្រេចចិត្ត ដែលត្រូវការសិទ្ធិទទួលបានព័ត៌មាន ទទួលបានព័ត៌មាន ប្រទេសកម្ពុជាបាននិងកំពុងបង្កើតច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន (A2I Law) អស់រយៈពេលប៉ុន្មានឆ្នាំមកហើយ។ ខណៈពេលដែលវឌ្ឍនភាពរបស់ច្បាប់នេះស្ថិតនៅទ្រឹងដោយសារការបោះឆ្នោតផ្សេងៗ មានសេចក្ដីរាយការណ៍ថា ច្បាប់នេះស្ថិតនៅលើគន្លងមួយ។ ទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលនៅតែមានក្ដីបារម្ភអំពីវឌ្ឍនភាពរបស់ច្បាប់នេះ។ ដើម្បីពន្លឿនច្បាប់នេះ ការសិក្សានេះផ្ដល់អនុសាសន៍ថា (i) រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតក្របខ័ណ្ឌ A2I ដើម្បីចូលរួមចំណែកដល់ការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាល សម្រាប់រដ្ឋាភិបាលបើកចំហរ (ii) មានតម្រូវការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានរបស់ថ្នាក់ក្រោមជាតិ តាមរយៈការធ្វើឲ្យអាចរកបាននូវទិន្នន័យតាមតំបន់ (geo-referenced) ក្នុងទម្រង់ជាអេឡិចត្រូនិចឲ្យបានទាន់ពេលវេលា ដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍មូលដ្ឋាន និងធ្វើឲ្យអាចរកបាននូវទិន្នន័យលទ្ធផលស្ថាប័ន ដើម្បីបង្កើតគណនេយ្យភាពសាធារណៈ។ ការណ៍នេះនឹងចាំបាច់ត្រូវមានការចូលរួមចំណែកដោយ (iii) ការកសាងសមត្ថភាពស្ថាប័ន និងការអនុម័តយកការកំណត់គម្រូ ដើម្បីទទួលបានព័ត៌មាននៅក្នុងដៃជាសាធារណៈឲ្យបានទាន់ពេលវេលា ហើយជាចុងក្រោយ (iv) ជំរុញទៅមុខជាមួយនឹងការបញ្ចប់ និងអនុម័តច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន និងច្បាប់ស្ដីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត។

## ៧. ទំនាក់ទំនងរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ជាញឹកញាប់មានការលើកឡើងថា ក្នុងអំឡុងពេលសិក្សា បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល ត្រូវបានរារាំង និងថា ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានមានភាពសោះកក្រោះ។ បច្ចុប្បន្ន វាទំនងជាថា ទំនាក់ទំនងបាន និងកំពុងប្រសើរឡើង។ មានការផ្ដល់អនុសាសន៍ថា គួរអង្គ និងភាគីពាក់ព័ន្ធនានា (i) បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ផែនទី និងឯកសារដែលមានមូលដ្ឋានលើកុំព្យូទ័រ លើប្រភពចំហរមួយ (ii) អង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាននៅថ្នាក់ក្រោមជាតិផ្សេងៗ រៀបចំព្រឹត្តិការណ៍រៀនសូត្រ និងចែករំលែកតាមដំណាក់កាល (iii) លើកកម្ពស់យន្តការសម្របសម្រួលមូលដ្ឋាន ដើម្បីកសាងទំនុកចិត្ត និងការយល់ដឹង និង (iv) អនុវត្តគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍សមត្ថភាពរួមគ្នា។

## ៨. ភាពជាដៃគូប្រកបដោយបរិយាប័ន្ន (ឯកជន រដ្ឋាភិបាល អង្គការសង្គមស៊ីវិល)

ភាពជាដៃគូត្រូវបានកំណត់ថាជាយន្តការសំខាន់សម្រាប់ការអភិវឌ្ឍនាពេលអនាគត ខណៈដែលភាពជាដៃគូទាំងនេះអាចចូលរួមចំណែកដល់វិធីសាស្ត្រសហប្រតិបត្តិការ និងរួបរួមគ្នា។ លើសពីនេះទៀត កម្រិតតម្រូវការអភិវឌ្ឍន៍នាពេលអនាគត មានលើសឆ្ងាយពីសមត្ថភាពរបស់ភាគីពាក់ព័ន្ធជាបុគ្គលភាគច្រើន ដើម្បីសម្រេចបានតែម្នាក់ឯង ដូច្នេះការលើកទឹកចិត្ត និងការគាំទ្រឲ្យមានភាពជាដៃគូប្រកបដោយបរិយាប័ន្នរវាងរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិលត្រូវការជាចំបាច់។

ដើម្បីឲ្យភាពជាដៃគូប្រកបដោយបរិយាប័ន្នដើរទៅមុខ មានការផ្តល់អនុសាសន៍ថា ភាគីពាក់ព័ន្ធ (i) លើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃយន្តការភាពជាដៃគូ និងសម្របសម្រួលដែលមានស្រាប់ និងអនាគត ដើម្បីជូនដំណឹងកាន់តែប្រសើរទៅកាន់សាធារណៈ តាមរយៈការប្រមូល និងបោះផ្សាយព័ត៌មានអំពីអ្វីដែលត្រូវបានរៀបចំផែនការ និងពិភាក្សា និងព័ត៌មានអំពីលទ្ធផលកិច្ចប្រជុំដែលត្រូវបានរៀបចំធ្វើឡើង និងព័ត៌មានអំពីផលប៉ះពាល់នៃយន្តការដែលបានព្រមព្រៀង (ii) រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវធានាថា ទស្សនៈ និងសំឡេងរបស់ប្រជាជនថ្នាក់ក្រោមជាតិ ត្រូវបានគេឮនិងយកមកពិចារណាកាន់តែប្រសើរ (iii) យន្តការភាពជាដៃគូ និងសម្របសម្រួលចាំបាច់ត្រូវបង្កើនតំណាងរបស់ភាគីពាក់ព័ន្ធអភិវឌ្ឍន៍ រួមទាំងអង្គការសង្គមស៊ីវិល/ក្រុមអ្នកតំណាង ដែលចាំបាច់ត្រូវរួមបញ្ចូលគ្នាស្ថិតក្រោមបណ្តាញ ដើម្បីតំណាងឲ្យពួកគេ (iv)រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងតួអង្គផ្សេងៗទៀត គួរពិចារណាបង្កើត/រៀបចំវេទិកាសម្របសម្រួលការអភិវឌ្ឍន៍ពហុភាគីពាក់ព័ន្ធ រួមគ្នាមួយ ដើម្បីសម្របសម្រួលកាន់តែប្រសើរ និងអាចឲ្យមានភាពជាដៃគូសម្រាប់ការអភិវឌ្ឍ (v) មានតម្រូវការកសាងសមត្ថភាព និងការយល់ដឹងអំពីវិធីសាស្ត្រភាពជាដៃគូប្រកបដោយបរិយាប័ន្នចំពោះភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចាប់ផ្តើមពន្លឿន និងលើកទឹកចិត្តឲ្យមានការរួមបញ្ចូលគ្នា ដើម្បីអាចឲ្យមានភាពជាដៃគូ។

# សេចក្តីផ្តើម

អង្គការសង្គមស៊ីវិល (CSO) បានដើរតួនាទីយ៉ាងសំខាន់គិតចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ក្នុងការបំពេញបន្ថែម ក៏ដូចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ក្នុងសង្គមកម្ពុជា ហើយតួនាទីទាំងនេះបាន និងកំពុងផ្លាស់ប្តូរ ខណៈពេលដែលប្រទេសកម្ពុជាបានអភិវឌ្ឍទាំងមុខៗ ហេតុដូច្នេះ បរិយាកាសអំណោយផលដែលកំពុងវិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល គឺជាកត្តាសំខាន់មួយ ដើម្បីសម្របសម្រួលអង្គការសង្គមស៊ីវិលឲ្យចូលរួម និងរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពជាតិ និងកិច្ចការពារបរិស្ថាន។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដំបូងឡើយបានសម្របសម្រួល ការវាយតម្លៃ បរិយាកាសអំណោយផលជាតិ (EENA) ក្នុងឆ្នាំ២០១៣ ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមស្រាវជ្រាវរបស់ប្រទេស ចំនួន២២។ បន្ទាប់មកក៏មានការសិក្សាបន្ថែមពីថ្នាក់ក្រោមជាតិ ទៅលើបរិយាកាស អំណោយផលក្នុងឆ្នាំ២០១៥ (២០១៣[3]-២០១៦[4])។ គោលបំណងនៃការសិក្សាឡើងវិញទាំងនេះ គឺដើម្បីវាយតម្លៃបរិយាកាសច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយសម្រាប់សង្គមស៊ីវិលនៅទូទាំងប្រទេស។ ការវាយតម្លៃ បរិយាកាសអំណោយផលជាតិ ត្រូវបានបង្កើតឡើង សម្រាប់ជាឧបករណ៍ផ្ទាល់សម្រាប់ប្រទេស ដែលមានឫសគល់ទិន្នន័យបឋមត្រូវបានប្រមូលនៅថ្នាក់មូលដ្ឋាន និងត្រូវបានធ្វើឲ្យការព្រមព្រៀងមួយតាមការពិគ្រោះ ដែលមានមូលដ្ឋានលើដំណើរការ ពហុភាគីពាក់ព័ន្ធ ហើយវិធីសាស្ត្រនេះ ត្រូវបានសម្រួលសម្រាប់ការពិនិត្យមើលឡើងវិញថ្នាក់ក្រោមជាតិ។ ឧបករណ៍ទាំងនេះមានគោលបំណងទ្វេ គឺ (i) ពង្រឹងសមត្ថភាពសង្គមស៊ីវិលដើម្បីតស៊ូមតិសម្រាប់បរិយាកាសអំណោយផល និង (ii) ធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល[5]។

សនិទានភាពសម្រាប់ការសិក្សានេះ គឺដើម្បីបន្តវាយតម្លៃបរិយាកាសអំណោយផលដែលកំពុងវិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃអភិបាលកិច្ចរបស់អង្គការ គ.ស.ក និងដែនសកម្មភាពតស៊ូមតិសម្រាប់អង្គការសង្គមស៊ីវិល។ វិសាលភាពនៃការសិក្សានេះ ត្រូវបានពង្រីកបន្ថែមទៀត ដើម្បីរុករកស្ថានភាពដែលមានការផ្លាស់ប្តូរ ឥទ្ធិពល និងតម្រូវការសម្រាប់ការលើកទឹកចិត្ត ការបង្កើត ការផ្តល់លទ្ធភាព និងការរក្សានិរន្តរភាពភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដើម្បីចូលរួមចំណែកដល់ការពន្លឿនការអភិវឌ្ឍជាតិ។ ការវាយតម្លៃនេះត្រូវបានផ្តើមឡើងនៅក្នុងឆ្នាំ២០១៨ ហើយត្រូវបានសិក្សាឯកសារបន្ថែម និងត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១៩។

3 http://www.ccc-cambodia.org/en/resources/ccc-publications-and-reports/publications/assessment-of-the-enabling-environment-for-civil-society
4 http://www.ccc-cambodia.org/en/resources/ccc-publications-and-reports/publications/enabling-environment-at-local-level
5 https://www.civicus.org/index.php/what-we-do/defend/civicus-enabling-environment

ការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើវិស័យមួយចំនួន ដែលចាំបាច់តម្រូវឲ្យមានការរុករកបន្ថែមទៀត បន្ទាប់ពីបរិយាកាសច្បាប់ដែលកំពុងវិវឌ្ឍន៍ បាននាំមកនូវការផ្លាស់ប្តូរនានាដូចជា ការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) និងការអនុវត្តការដកហូតពន្ធ និងច្បាប់ស្តីពីការងារ និងឧបករណ៍ច្បាប់ផ្សេងៗទៀត។ ការសិក្សានេះមានបំណងពិនិត្យមើលបរិយាកាសអំណោយផល និងបរិបទដែលបានផ្លាស់ប្តូរ និងកំពុងផ្លាស់ប្តូរសម្រាប់អង្គការសង្គមស៊ីវិល បន្ទាប់ពីជួបប្រទះអំឡុងពេលសេដ្ឋកិច្ច និងសង្គមផ្លាស់ប្តូរនៅចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។

ការសិក្សានេះទទួលបានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប និងអង្គការ BfdW ដោយផ្តោតការយកចិត្តទុកដាក់លើបរិយាកាសអំណោយផលបច្ចុប្បន្ន និងភាពជាដៃគូប្រកបដោយបរិយាប័ន្នក្នុងចំណោមអង្គការសង្គមស៊ីវិល និងភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ព្រមទាំងជាមួយភាគីពាក់ព័ន្ធអភិវឌ្ឍន៍ផ្សេងៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការស្រាវជ្រាវនេះបានសម្រួលគម្រូស្រាវជ្រាវ ដែលប្រើប្រាស់ក្របខ័ណ្ឌអំណោយផលរបស់អង្គការ CIVICUS ។

## គោលបំណង និងកម្មវត្ថុនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សានេះ គឺដើម្បីផ្តល់ការបញ្ជាក់ជាក់ស្តែងនៃបរិយាកាសអំណោយផល (EE) ដែលកំពុងវិវឌ្ឍន៍ និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន (IP) ក្នុងចំណោមអង្គការសង្គមស៊ីវិល និងជាមួយភាគីពាក់ព័ន្ធផ្សេងៗក្នុងប្រទេសកម្ពុជា។ កម្មវត្ថុជាក់លាក់គឺ៖

- ដើម្បីវាយតម្លៃបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល[6] ក្នុងប្រទេសកម្ពុជា
  - បង្កើតអនុសាសន៍ច្បាស់លាស់សម្រាប់ផលប៉ះពាល់អនាគតប្រកបដោយវិជ្ជមាន
  - គាំទ្រលទ្ធផលរកឃើញបន្ថែមទាំងនេះតាមរយៈករណីសិក្សាចំនួន២ នៅថ្នាក់ជាតិ និង នៅថ្នាក់ក្រោមជាតិ
- ដើម្បីសម្លឹងមើលឱកាសភាពជាដៃគូអន្តរវិស័យប្រកបដោយបរិយាប័ន្នតាមរយៈយន្តការ/គោលការណ៍ដែលមានស្រាប់។
  - បំពេញបន្ថែមតាមរយៈករណីសិក្សាចំនួន២ផ្សេងទៀត នៅក្នុងការឆ្លុះបញ្ចាំងពីភាពជាដៃគូ ដូចដែលបានលើកឡើង ក្នុងគោលការណ៍ទីក្រុងប៊ូសាន (Busan Principles) ការអភិវឌ្ឍដោយចីរភាព (SGDs) ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (D&D) យន្តការស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ (DCPS) និងក្របខណ្ឌគណនេយ្យភាព (ISAF) នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

6 The key dimensions of CSO enabling framework of Civicus could be guide in this study including (1) formation, (2) operation, (3) access to resources, (4) expression, (5) peaceful assembly, (6) government-civil society relations, (7) civil society organisations' cooperation and coalition, 8) Internet freedom, 9) Taxation and 10)Access to information.

- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនៅបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន។

## ទិដ្ឋភាពរួមរបស់ប្រទេសកម្ពុជានិងបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល

ផ្នែកនេះពិនិត្យមើលក្របខ័ណ្ឌផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (PESTLE)[7] ដើម្បីសិក្សាពីទិដ្ឋភាពរួម។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដោយសង្ខេប ខណៈដែលការវិភាគលើបរិយាកាសអំណោយផលពាក់ព័ន្ធបញ្ហាទាំងនោះត្រូវបានសម្លឹងមើល ស៊ីជម្រៅសម្រាប់ការសិក្សា។ ចំណុចខ្លះក៏ត្រូវបានលើកមកម្តងទៀត និងត្រូវបានពិចារណាក្នុងលទ្ធផលរកឃើញចម្បងៗនៃការសិក្សានេះ គោលបំណងគឺដើម្បីផ្តល់ទិដ្ឋភាពរួមសង្ខេបមួយ ដែលអាចមិនចាប់យកបញ្ហានានា (ក្តីបារម្ភ) ពីក្រុមទាំងអស់ ដោយសារតម្រូវការរយៈពេលខ្លី។

### នយោបាយ

ប្រទេសកម្ពុជាបានឆ្លងកាត់រយៈពេលនយោបាយតាមតឹង ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ (ឆ្នាំ២០១៦-២០១៩) ដែលបានមើលឃើញមានការអនុវត្ត

(i) ការបោះឆ្នោតថ្នាក់មូលដ្ឋានដែលត្រូវបានជ្រើសរើសដោយផ្ទាល់/ប្រើយ៍ភាព (ដោយប្រជាជន) ក្នុងខែមិថុនា ឆ្នាំ២០១៧ សម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ (នៅកម្រិតឃុំ/សង្កាត់) សម្រាប់អាសនៈក្រុមប្រឹក្សាចំនួន ១១.៦៧០ អាសនៈលើ ១.៦៤៦ អាសនៈនៅទូទាំងប្រទេស។

(ii) ការបោះឆ្នោតដោយមិនផ្ទាល់សម្រាប់សមាជិកព្រឹទ្ធសភា (សភាជាន់ខ្ពស់) នៅខែកុម្ភៈ ឆ្នាំ២០១៨ សម្រាប់សមាជិកចំនួន ៥៨ ក្នុងចំណោមសមាជិកចំនួន ៦២ ដែលត្រូវបានជ្រើសរើស[8]។

> **ក្របខ័ណ្ឌ PESTLE**
>
> - **នយោបាយ** - តើកត្តានយោបាយអ្វីដែលដែលជះឥទ្ធិពលដល់ប្រទេស?
> - **សេដ្ឋកិច្ច** - តើកត្តាសេដ្ឋកិច្ចអ្វីខ្លះដែលជះឥទ្ធិពលដល់ប្រទេស?
> - **សង្គម** - តើទិដ្ឋភាពវប្បធម៌ អ្វីខ្លះដែលជះឥទ្ធិពលដល់ប្រទេស?
> - **បច្ចេកវិទ្យា** - តើការផ្លាស់ប្តូរបច្ចេកវិទ្យាអ្វីខ្លះដែលជះឥទ្ធិពលដល់ប្រទេស?
> - **ច្បាប់** - តើច្បាប់បច្ចុប្បន្ន និងច្បាប់ដែលនឹងដាក់ចេញក្នុងពេលខាងមុខអ្វីខ្លះដែលអាចជះឥទ្ធិពលដល់ប្រទេស?
> - **បរិស្ថាន**- តើការពិចារណាលើបរិស្ថានអ្វីខ្លះដែលជះឥទ្ធិពលដល់ប្រទេស?

[7] PESTLE is considered an expanded variant of the PEST (political, economic, socio-cultural and technological) analysis framework, which were initially developed and applied in the business/ commercial sector. It is part of an external analysis approach when conducting a strategic analysis or doing market research. It is intended to provide an overview of the different macro-environmental factors to be taken into consideration. https://pestleanalysis.com/what-is-pestle-analysis/

[8] 58 members of the Senate are elected by the 11,670 commune councillors and 125 National Assembly members, with two members, nominated by the king and two by the national assembly.

(iii) ការបោះឆ្នោតថ្នាក់ជាតិក្នុងខែកក្កដា ឆ្នាំ២០១៨ សម្រាប់អាសនៈចំនួន ១២៥ នៅសភាជាន់ទាប (រដ្ឋសភា)។

(iv) ការបោះឆ្នោតមិនផ្ទាល់សម្រាប់ក្រុមប្រឹក្សាខេត្ត/រាជធានី និងស្រុក/ក្រុង និងខណ្ឌ ដែលបានធ្វើឡើងនៅខែឧសភា ឆ្នាំ២០១៩។

ទោះជាយ៉ាងណា បរិយាកាសនយោបាយនៃការបោះឆ្នោតទាំងនេះ បានរៀបចំធ្វើឡើង និងបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ ការបោះឆ្នោតទាំងនេះត្រូវបានធ្វើឡើងក្នុងបរិយាកាស មួយដែលមានភាពតានតឹងខ្លាំងផ្នែកនយោបាយ។ ការណ៍នេះអាចត្រូវបានងាកត្រលប់ទៅមើលលទ្ធផលនៃការបោះឆ្នោតជាតិក្នុងឆ្នាំ ២០១៣ វិញ នៅពេលដែលគណបក្សប្រជាជនកម្ពុជាបានមើលឃើញការធ្លាក់ចុះចំនួនអាសនៈរដ្ឋសភា (៦៨អាសនៈ)[9]។ ការណ៍នេះត្រូវបានគេទទួលស្គាល់ថាជាការវាយប្រហារដ៏ធំមួយ ដែលបានមើលឃើញការបាត់បង់អាសនៈច្រើនបំផុតដោយគណបក្សកាន់អំណាចបើគិតមករហូតដល់សព្វថ្ងៃ ហើយទទួលបានចំណែកអាសនៈទាបបំផុតរបស់ខ្លួនគិតចាប់តាំងពីឆ្នាំ១៩៩៨មក[10]។

ការបោះឆ្នោតថ្មីថ្នាក់មូលដ្ឋាននៅក្នុងឆ្នាំ២០១៧ សម្រាប់អាសនៈក្រុមប្រឹក្សាឃុំចំនួន ១១.៦៧០ លើចំនួន ១.៦៤៦ អាសនៈ បានធ្វើឡើងបន្ទាប់ពីមានគំរូលទ្ធផលប្រហាក់ប្រហែលគ្នា ដែលគណបក្សប្រជាជនកម្ពុជាបានឈ្នះសំឡេងភាគច្រើន តិចជាងមុន ដោយមានការកើនឡើងខ្លាំងសម្រាប់គណបក្សសង្គ្រោះជាតិ (គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឆ្នោត ៥១% ហើយគណបក្សសង្គ្រោះជាតិទទួលបានសំឡេងឆ្នោត ៤៩%)[11]។ អ្នកសង្កេតការបានធ្វើការអត្ថាធិប្បាយថា បើទោះជាមានកិច្ចប្រឹងប្រែងបង្ក្រាប បន្លាច/បង្កើត "បរិយាកាសភ័យខ្លាច" និងធ្វើឲ្យចុះខ្សោយដល់អ្នកទាំងឡាយណាដែលត្រូវបានគេចាត់ទុក (ទាំងខុស) ថាជាគូបដិបក្ខរបស់គណបក្សប្រជាជនកម្ពុជា ជាពិសេសគណបក្សសង្គ្រោះជាតិរយៈពេល ៣ ឆ្នាំ (ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៧)[12] ក្តី ក៏លទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ បានបង្ហាញថា វិធីសាស្ត្រនេះមិនជោគជ័យឡើយ។

ដោយប្រឈមនឹងបញ្ហាធ្ងន់ធ្ងរ និងឥតរំពឹងទុកបែបនេះ និងការគំរាមកំហែងចំពោះតួនាទីរបស់ខ្លួន គណបក្សប្រជាជនកម្ពុជា គ្មានជម្រើស ប៉ុន្តែត្រូវធ្វើអ្វី ដែលចាំបាច់ ដើម្បីកម្ទេចគណបក្សសង្គ្រោះជាតិ។ វិធានការចុងក្រោយសម្រាប់ការណ៍នេះ បានកើតមានឡើងនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ២០១៧ ជាមួយនឹងការចាប់ខ្លួនលោក កឹម សុខា ដែលនៅពេលនោះគឺជាមេដឹកនាំគណបក្សសង្គ្រោះជាតិ ដោយចោទប្រកាន់ពីបទក្បត់ជាតិ[13]។ លោក កឹម សុខា ត្រូវបានចាប់ឃុំឃាំងមុនការកាត់ទោសអស់រយៈពេលមួយឆ្នាំ ហើយត្រឹមតែដោះលែងឲ្យនៅក្រៅឃុំជាមួយនឹងការបង់ប្រាក់ធានា (នៅថ្ងៃទី

9 The then emergent opposition (established 2012) the Cambodia National Rescue Party having won 55 seats.
10 https://en.wikipedia.org/wiki/Cambodian_general_election,_2013
11 https://en.wikipedia.org/wiki/Cambodian_communal_elections,_2017#cite_note-5
12 APHR (2017) Death Knell of Democracy,- Attacks on Lawmakers and the Threat to Cambodia's Institutions https://aseanmp.org/wp-content/uploads/2017/03/APHR_Cambodia-MPs-Report_Mar-2017.pdf
13 https://www.rfa.org/english/news/cambodia/kemsokha-arrest-09022017163633.html

១០ ខែកញ្ញា ឆ្នាំ២០១៨) ប៉ុន្តែបានដាក់ឲ្យស្ថិតនៅការឃុំឃាំងក្នុងផ្ទះ តាមរយៈលក្ខណ្ឌនៃការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ជាទីកន្លែងដែលលោកបានស្ថិតនៅរហូតដល់ខែកក្កដា ឆ្នាំ២០១៩។ ប្រហែលជាពីរខែក្រោយមក គណបក្សសង្គ្រោះជាតិ ត្រូវបានរំលាយចោលតាមដីការបស់តុលាការកំពូលកម្ពុជានៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧[14] ដោយចោទប្រកាន់ពីបទ "រៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល"[15] ពីអំណាច។ សេចក្តីសម្រេចរបស់តុលាការបានបញ្ជាឲ្យរំលាយគណបក្សនេះ និងហាមឃាត់មន្ត្រីជាន់ខ្ពស់ចំនួន១១៨នាក់ របស់គណបក្សនេះពីការធ្វើសកម្មភាពនយោបាយរយៈពេលប្រាំឆ្នាំ។

អាសនៈដែលមានស្រាប់ (នៅពេលនោះ) ដែលទទួលដោយគណបក្សសង្គ្រោះជាតិក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ (មេឃុំ/ចៅសង្កាត់ចំនួន៤៨៩អាសនៈ និងក្រុមប្រឹក្សាចំនួន ៥.០០៧អាសនៈ)[16] ក្រោយមកត្រូវបានបែងចែកជាថ្មី ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ទៅឲ្យគណបក្សនយោបាយផ្សេងៗ[17]។ ការបែងចែកជាថ្មីនេះបានមើលឃើញថា គណបក្សប្រជាជនកម្ពុជាគ្រប់គ្រងអាសនៈក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ចំនួន ១.៦៤៦ អាសនៈ ដោយកាន់កាប់ ៩៥% នៃអាសនៈក្រុមប្រឹក្សាឃុំ/សង្កាត់។ ការផ្លាស់ប្តូរទាំងនេះ ដែលបាននាំមកនូវការរំលាយគណបក្សសង្គ្រោះជាតិ ត្រូវបានចាត់ទុក(ដោយមនុស្សមួយចំនួន) ថាបានធ្វើឲ្យប្រទេសកម្ពុជាវិលត្រលប់ទៅរករដ្ឋដែលមានគណបក្សតែមួយ[18]។ ការបោះឆ្នោតរដ្ឋសភានាពេលបន្ទាប់មកក្នុងខែកក្កដា ឆ្នាំ២០១៨ គឺជាការផ្លាស់ប្តូរទាំងស្រុងមួយសម្រាប់គណបក្សប្រជាជនកម្ពុជា ដោយទទួលបានទាំងអស់ ១២៥ អាសនៈ តាមរយៈការបោះឆ្នោតមួយ ដែលមានការចូលរួមប្រកួតប្រជែងគ្នាពីសំណាក់គណបក្សនយោបាយចំនួន ២០ ដែលគ្មានគណបក្សណាមួយអាចទទួលបានសំលេងឆ្នោតគ្រប់គ្រាន់នៅក្នុងមណ្ឌលបោះឆ្នោតណាមួយ ដើម្បីឈ្នះអាសនៈឡើយ។

ជាការឆ្លើយតប និងក្នុងគ្រា ដែលអវត្តមានរបស់គណបក្សប្រឆាំងណាមួយនៅក្នុងរដ្ឋសភាជាតិ រដ្ឋាភិបាលបានបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ (Supreme Consultative Council) និងបានតែងតាំងអ្នកតំណាងចំនួន៣០ នាក់មកពីគណបក្សនយោបាយចំនួន១៦ ធ្វើជាទីប្រឹក្សារបស់រដ្ឋាភិបាលទៅតាមសំណើរបស់លោកនាយករដ្ឋមន្ត្រី។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ត្រូវបានបង្កើតឡើង តាមរយៈព្រះរាជក្រឹត្យមួយ ដែលត្រូវបានចុះហត្ថលេខាដោយព្រះមហាក្សត្រនៅដើមខែកញ្ញា ឆ្នាំ២០១៨។ ទោះជាយ៉ាងណា ឥទ្ធិពលនិងធាតុចូលដែលអាចមានរបស់ឧត្តមក្រុមប្រឹក្សានេះចំពោះគោលនយោបាយ ច្បាប់ និងគណនេយ្យភាពរបស់រដ្ឋាភិបាល និងការចូលរួមរបស់

14 https://www.phnompenhpost.com/national-post-depth-politics/death-democracy-cnrp-dissolved-supreme-court-ruling

15 Phnom Penh Post (17/11/2017) 'Death of democracy': CNRP dissolved by Supreme Court ruling

16 https://en.wikipedia.org/wiki/2017_Cambodian_communal_elections#cite_note-5

17 The CPP took 4,548 of the CNRP seats, Funcinpec Party were given 239, the Khmer National United Party 201 seats, the Cambodian Nationality Party 10 seats, With the Cambodia Youth Party, and the Cambodia Indigenous People Democracy Party being allocated three seats each, https://www.khmertimeskh.com/93703/cnrp-commune-seats-doled/

18 Hunt,L., A New Era for Hun Sen's Cambodia? 17/8/2018, The Diplomat https://thediplomat.com/2018/08/a-new-era-for-hun-sens-cambodia/ , & Strangio, S., (30/11/2017) Sebastian Strangio: Cambodia's troubling return to de facto one-party rule, in Nikkei Asian Review, https://asia.nikkei.com/Politics/Sebastian-Strangio-Cambodia-s-troubling-return-to-de-facto-one-party-rule

ឧត្តមក្រុមប្រឹក្សានេះជាមួយសង្គមស៊ីវិលនៅតែមិនមានគុណភាព និងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## សេដ្ឋកិច្ច[19]

ប្រទេសកម្ពុជាបាននិងកំពុងទទួលបានកំណើន និងការផ្លាស់ប្តូរសេដ្ឋកិច្ចខ្លាំងដែលគួរឲ្យកោតសរសើរ ដែលសម្រេចបានឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (ដែលត្រូវបានកំណត់ទៅតាមស្ថិតិរបស់ធនាគារពិភពលោក) នៅក្នុងឆ្នាំ២០១៥[20]។ រដ្ឋាភិបាលបានបង្ហាញចក្ខុវិស័យ ដើម្បីសម្រេចបានឋានៈជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ ២០៣០ និងឋានៈជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០។ ទោះជាយ៉ាងណា កម្ពុជានៅតែត្រូវបានចាត់ចូលក្នុងប្រភេទប្រទេសមួយក្នុងចំណោមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ចំនួន៤៧ ប្រទេសនៅក្នុងពិភពលោកដោយអង្គការសហប្រជាជាតិ[21] ដោយសារភាពងាយរងគ្រោះផ្នែកសង្គម និងសេដ្ឋកិច្ចពុំរ៉ៃ បើទោះជាមានការរាយការណ៍ថា រដ្ឋាភិបាលមានបំណងបង្កើតគំនិតផ្តួចផ្តើមដំណើរការចាកចេញ ៦ឆ្នាំពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចក្នុងឆ្នាំ២០២១ ក្តី។

**វិស័យសំខាន់ៗសំរាប់ ផ ស ស ឆ្នាំ២០១៧**

(sources: CIA Facebook 2019)




សេដ្ឋកិច្ចបានរក្សាអត្រាកំណើនជាមធ្យម ៧,៧% នៅចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ ២០១៨ ដែលធ្វើឲ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេស ដែលមានសេដ្ឋកិច្ចលូតលាស់ខ្លាំងបំផុតមួយ ក្នុងពិភពលោក ហើយត្រូវបានរំពឹងថា នឹងនៅតែមានកំណើនរឹងមាំក្នុងរយៈពេលមធ្យមខាងមុខ។ នៅក្នុងឆ្នាំ ២០១៨ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់ប្រទេសកម្ពុជា ត្រូវបានរាយការណ៍ថា មានចំនួន ២៤,៦ពាន់លានដុល្លារ ដែលមានទំហំធំជាង ១០ ដងធៀបនឹងកម្រិតដែលត្រូវបានរាយការណ៍កាលពីឆ្នាំ១៩៩៣ (២,៤ពាន់លានដុល្លារ) និងមានទំហំទ្វេដង ធៀបនឹងកម្រិតនៅឆ្នាំ២០១០ ដែលមានចំនួន ១១,២ពាន់លានដុល្លារ[22]។

សេដ្ឋកិច្ច បាននិងកំពុងផ្លាស់ប្តូរជាចម្បងដោយសារការកើនឡើងខ្លាំងនៃការនាំចេញ និងតម្រូវការក្នុងស្រុករឹងមាំ ព្រមទាំងការកើនឡើងការវិនិយោគផ្ទាល់ពីបរទេស (FDI)។ ចំណែកកសិកម្មក្នុង

19 Adapted from the Cambodia Economic Update May 2019 https://www.worldbank.org/en/country/cambodia/publication/cambodia-economic-update-may-2019
20 With a statistically average income above US$1,025 based on the World bank's Atlas method, https://datahelpdesk.worldbank.org/knowledgebase/articles/906519-world-bank-country-and-lending-groups
21 https://unctad.org/en/Pages/ALDC/Least%20Developed%20Countries/LDCs.aspx
22 https://countryeconomy.com/gdp/cambodia

សេដ្ឋកិច្ច បន្តធ្លាក់ចុះ ប៉ុន្តែមានសក្តានុពលសម្រាប់កំណើនខ្លាំង ខណៈពេលដែលវិស័យឧស្សាហកម្មនៅតែរឹងមាំ ហើយចំណែកវិស័យសេវាកម្មក្នុងសេដ្ឋកិច្ចបន្តកើនឡើង។

យោងតាមក្រសួងឧស្សាហកម្ម និងសិប្បកម្ម បច្ចុប្បន្ននៅត្រឹមដំណាច់ឆ្នាំ២០១៨មានរោងចក្រចំនួន ១.៥២៨ នៅក្នុងប្រទេសកម្ពុជា ។ រោងចក្រចំនួន ៩២២ ដែលស្មើនឹងជិតពីរភាគបី ស្ថិតក្នុងវិស័យផលិតកម្មតម្បាញ កាបូប សម្លៀកបំពាក់ និងស្បែកជើង។ វិស័យសម្លៀកបំពាក់បន្តនៅជាវិស័យសំខាន់មួយនៃកំណើនសេដ្ឋកិច្ច ដោយផ្តល់ការងារជាមធ្យមចំនួន ៦៣៥.០០០ កន្លែងក្នុងឆ្នាំ២០១៧ នៅក្នុងរោងចក្រចំនួន ៦៤៣។ ការនាំចេញសម្លៀកបំពាក់មានតម្លៃសរុប ៨,០២ ពាន់លានដុល្លារក្នុងឆ្នាំ២០១៧ (កើនឡើង៩,៥ភាគរយធៀបនឹងឆ្នាំ២០១៦) និងបង្កើតបានជាចំណែក ៧២ភាគរយនៃការនាំចេញទំនិញសរុប។ ការនាំចេញស្បែកជើងបានកើនឡើង ១៩,៤ ភាគរយដល់ចំនួន ៨៧៣លានដុល្លារសម្រាប់ឆ្នាំ២០១៧ ធៀបនឹងឆ្នាំ២០១៦។ ឆ្នាំ២០១៨ បានមើលឃើញការបើកដំណើរការរោងចក្រថ្មីចំនួន១៧៨ ធៀបនឹងចំនួន១៥០ ក្នុងឆ្នាំ២០១៧។ ប្រាក់ចំណូលសរុបពីផលិតកម្មនៃផលិតផលក្នុងស្រុក និងផលិតផលនាំចេញមានតម្លៃប្រហែល ១៣,១៧ ពាន់លានដុល្លារក្នុងឆ្នាំ២០១៨ ដែលកើនឡើង ២៣ភាគរយធៀបនឹងឆ្នាំ២០១៧ (ប្រភព Open Development)[23]។ សហភាពអឺរ៉ុបមានចំណែកទីផ្សារ ៤៦ភាគរយ នៃការនាំចេញរបស់វិស័យនេះ ហើយអាមេរិកមាន ២៤ភាគរយ ប៉ុន្តែការនាំចេញទៅកាន់ទីផ្សារផ្សេងទៀតបាននិងកំពុងកើនឡើងយ៉ាងខ្លាំង។ ហានិភ័យពីការគំរាមបញ្ចប់ឋានៈជាប្រទេស ដែលទទួលបានប្រព័ន្ធអនុគ្រោះពន្ធ "គ្រប់មុខទំនិញលើកលែងតែអាវុធ (EBA)" ទៅកាន់ទីផ្សារអឺរ៉ុបមានទំហំធំធេង។

ប្រទេសកម្ពុជាបន្ថែមកម្លាំងជាមធ្យមចំនួន ២០០.០០០នាក់ ទៅក្នុងកម្លាំងពលកម្មរបស់ខ្លួនក្នុងមួយឆ្នាំ ប៉ុន្តែដូចដែលធនាគារពិភពលោកបានព្រមានដូច្នេះដែរ កម្លាំងពលកម្មដែលកំពុងកើនឡើងតែមួយមុខមិនគ្រប់គ្រាន់ឡើយដើម្បីទាក់ទាញ និងបង្កើតការងារ ជាពិសេសជាមួយនឹងការប្រកួតប្រជែងខាងក្រៅរបស់ប្រទេសកម្ពុជា ដែលពឹងផ្អែកជាចម្បងលើកម្លាំងពលកម្មតម្លៃទាប ដែលកំពុងត្រូវបានបាត់បង់បន្តិចម្តងៗយ៉ាងរហ័ស[24]។ កំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជាបានកើតមានឡើងដោយពឹងផ្អែកលើកម្លាំងពលកម្មតម្លៃទាបរបស់ខ្លួន ប៉ុន្តែដំណាក់កាលនៃការអភិវឌ្ឍរបស់ប្រទេសនេះកំពុងខិតជិតទៅរកការបិទបញ្ចប់ហើយ ហើយចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរឲ្យបានឆាប់រហ័សពីគំរូកំណើនដែលមានជំនាញទាប និងកម្លាំងពលកម្មច្រើនទៅជាគំរូកំណើនដែលត្រូវបានជំរុញដោយជំនាញវិញ។ ការរក្សានិរន្តរភាពកំណើនខ្លាំងក្នុងពេលអនាគត នឹងកាន់តែទាមទារឲ្យប្រទេសកម្ពុជាកសាងកម្លាំងពលកម្មជំនាញមួយ ដែលអាចសម្របខ្លួនយ៉ាងងាយស្រួលទៅនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាដែលកើតមានយ៉ាងទូលំទូលាយនៅក្នុងសេដ្ឋកិច្ចពិភពលោក[25]។ បញ្ហាប្រឈមនេះត្រូវបានទទួល

23 https://opendevelopmentcambodia.net/topics/industries/

24 Thomas, J., (July 2019) Cambodia's workforce needs help, The ASEAN Post https://theaseanpost.com/article/cambodias-workforce-needs-help

25 ibid

ស្គាល់ដោយរដ្ឋាភិបាល ហើយត្រូវបានធ្វើសមាហរណកម្ម ទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដែលមានបំណងធ្វើបច្ចុប្បន្នភាព រចនាសម្ព័ន្ធឧស្សាហកម្មរបស់កម្ពុជា ពីផលិតកម្មប្រើប្រាស់កម្លាំងពលកម្មច្រើនទៅជាផលិតកម្ម ដែលត្រូវបានជំរុញដោយជំនាញនៅត្រឹមឆ្នាំ២០២៥។ ប្រសិនបើត្រូវបានអនុវត្តបានទាន់ពេលវេលា និងប្រកដោយប្រសិទ្ធភាព គោលនយោបាយនេះអាចលើកកម្ពស់ការធ្វើពិពិធកម្ម និងកំណើនប្រកបដោយចីរភាព[26]។

## សង្គម

ភាពក្រីក្រ និងបញ្ហាប្រឈមសង្គមដែលពាក់ព័ន្ធ បានធ្លាក់ចុះជាលំដាប់ ប៉ុន្តែមានកិច្ចការជាច្រើនទៀតដែលនៅតែចាំបាច់ត្រូវធ្វើ ខណៈដែលប្រជាជនក្រីក្រ និងងាយរងគ្រោះនៅតែមាន ជាពិសេសក្នុងតំបន់ជនបទ។ សន្ទស្សន៍សង្គមផ្សេងៗសម្រាប់សុខាភិបាល ការអប់រំ និងសុខុមាលភាពបានមានភាពប្រសើរឡើង។ វឌ្ឍនភាពដែលគួរឲ្យកោតសរសើរត្រូវបានបង្កើតឡើងដោយប្រទេសកម្ពុជាឆ្ពោះទៅរកគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDGs)។

លើសពីនេះទៀត បើទោះជាចំណែកដ៏ច្រើនមួយនៃប្រជាជនបានរួចចាកផុតពីភាពក្រីក្រក្តី ក៏ពួកគេនៅតែប្រឈមនឹងភាពងាយរងគ្រោះខ្លាំងដដែល[27]។ អត្រានៃភាពក្រីក្របានកាត់បន្ថយជាងពាក់កណ្តាល ពី ៥៣%នៃចំនួនប្រជាជនក្នុងឆ្នាំ២០០៤ មកនៅត្រឹម ២០,៥ភាគរយក្នុងឆ្នាំ ២០១១[28] ហើយធ្លាក់ចុះមកនៅត្រឹម ១៣,៥%នៅឆ្នាំ២០១៤[29] ហើយ "ការប៉ាន់ប្រមាណបណ្តោះអាសន្នបង្ហាញថា ការណ៍នេះទំនងជានឹងបានធ្លាក់ចុះមកនៅក្រោម ១០%" នៅឆ្នាំ២០១៨[30] ដោយសារសេដ្ឋកិច្ចមានភាពប្រសើរឡើង។

មានការសង្កេតឃើញថា អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងអង្គការគំនិតផ្តួចផ្តើមភាពក្រីក្រ និងអភិវឌ្ឍន៍មនុស្ស (OPHI) បានបង្កើតនិងអនុម័តយកវិធីសាស្ត្រវិភាគ (ឆ្នាំ២០១០)[31] សម្រាប់ភាពក្រីក្រពហុសមាសភាគ នៅពេលអនុវត្តចំពោះសំណុំទិន្នន័យរបស់កម្ពុជា ដែលនឹងបង្ហាញថា ការរាប់ចំនួនមនុស្សសម្រាប់ភាពក្រីក្រពហុសមាសភាគ (MDP) ចម្រុះរបស់កម្ពុជា[32] អាចមានកម្រិតខ្ពស់ជាង ៣៥% ។

26 Furusawa, M (2017) The Cambodian Economy: Outlook, Risks and Reforms, https://www.imf.org/en/News/Articles/2017/06/06/sp060717-the-cambodian-economy-outlook-risks-and-reforms
27 World Bank. 2013. Where Have All the Poor Gone? : Cambodia Poverty Assessment 2013. Washington, DC. © World Bank. https://openknowledge.worldbank.org/handle/10986/17546
28 https://www.worldbank.org/en/news/press-release/2014/02/20/poverty-has-fallen-yet-many-cambodians-are-still-at-risk-of-slipping-back-into-poverty
29 Midterm Review of the 2013-2018 NSDP https://www.google.com/search?client=firefox-b-d&q=NSDP%2C+midterm+review
30 http://www.kh.undp.org/content/cambodia/en/home/presscenter/pressreleases/2018/clarification--multidimensional-poverty-is-decreasing-in-cambodi.html
31 Assessing multidimensional poverty – one index at the global level http://hdr.undp.org/en/content/assessing-multidimensional-poverty-%E2%80%93-one-index-global-level
32 The MDP approach is more complex analytic which looks at additional broader dimensions (education – 2 indicators, health – 2 indicators and living standards – 6 indicators) than the conventional food security and income based poverty line model adopted by governments, including Cambodia. At present the MDP approach is a supplementary approach (through adopted as a target for the Cambodian Sustainable Development Goals (CSDGs poverty target 1.2)) to complement national planning approaches involving the government and development partner agreed income poverty line model in use.

## បច្ចេកវិទ្យា[33]

ដូចដែលបានលើកឡើងហើយថា ចក្ខុវិស័យរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជាគឺការក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានប្រាក់ចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។ រដ្ឋាភិបាលក៏មានបំណង "បញ្ចប់ការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចឌីជីថល" ផងដែរនៅត្រឹមឆ្នាំ២០២៣ (MoPT ឆ្នាំ២០១៨)។ ដំណើររបស់កម្ពុជាឆ្ពោះទៅកាន់គោលដៅនេះនឹងត្រូវបានកំណត់លទ្ធភាពរបស់ខ្លួនក្នុងការធ្វើជាម្ចាស់ការ និងកេងយកចំណេញលើបច្ចេកវិទ្យាឌីជីថលដែលកំពុងស្ទុះងើប។ ការយោងជាច្រើនដោយរដ្ឋាភិបាលចំពោះផលចំណេញ និងអត្ថប្រយោជន៍នៃបដិវត្តឧស្សាហកម្មទី៤ ("Industry 4.0")[34] បាននិងកំពុងធ្វើឡើង ខណៈដែលរដ្ឋាភិបាលមើលឃើញបដិវត្តឧស្សាហកម្មទី៤ នេះថាជាមធ្យោបាយមួយ ដើម្បីផ្តល់ឲ្យកម្ពុជានូវឱកាស ដើម្បីដើរឆ្ពោះទៅមុខតាមវិធីរបស់ខ្លួនទៅក្នុងអនាគត យ៉ាងហោចណាស់តាមមធ្យោបាយចំនួនពីរ។

| | អត្ថប្រយោជន៍របស់កម្ពុជា | បញ្ហាប្រឈមចំពោះ/សម្រាប់កម្ពុជា |
|---|---|---|
| ទីមួយ- និន្នាការបច្ចេកវិទ្យានឹងជួយប្រទេសកម្ពុជាដើរឆ្ពោះទៅរកសេដ្ឋកិច្ចដែលមានមូលដ្ឋានលើចំណេះដឹង។ | ដោយប្រជាជនដែលមានអាយុក្រោម ៣០ឆ្នាំមានចំនួនជិតពីរភាគបីនៃប្រជាជនសរុប សមាសមាត្រដ៏ធំមួយនៃកម្លាំងពលកម្មដ៏មានសក្តានុពល នឹងកើនឡើងជាមួយនឹងបច្ចេកវិទ្យាឌីជីថល។ | ទោះជាយ៉ាងណា កម្ពុជានឹងត្រូវតែដើរទៅមុខឲ្យបានលឿន ប្រសិនបើប្រទេសនេះចង់ទទួលបានអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រនេះ។<br>ទោះជាយ៉ាងណា ភាពប្រសើរឡើងខាងផ្នែកបច្ចេកវិទ្យា ក៏នឹងមានផលប៉ះពាល់ដល់កម្លាំងពលកម្មយ៉ាងខ្លាំងក្នុងវិស័យប្រពៃណីនានា (កសិកម្ម និងឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន) ហើយផលប៉ះពាល់ដែលអាចកើតមានទាំងនេះអាចមានកម្រិតខ្លាំងសម្រាប់កម្ពុជា។ |
| ទីពីរ- ការអភិវឌ្ឍរចនាសម្ព័ន្ធបច្ចេកវិទ្យានឹងជាកត្តាកំណត់ដ៏សំខាន់មួយ | ការវិនិយោគដែលកំពុងធ្វើឡើងក្នុងហេដ្ឋារចនាសម្ព័ន្ធ នឹងអាចឲ្យប្រទេស | បញ្ហាប្រឈមខាងផ្នែកអប់រំនៅតែមានដោយមានគម្លាតដ៏ធំក្នុងការបញ្ចប់ការសិក្សា និងលទ្ធផល។ |

33 CDRI (2019) Industry 4.0: Prospects and Challenges for Cambodia's Manufacturing Sector https://cdri.org.kh/wp-content/uploads/Industry-4.pdf
34 Industry 4.0 – "the 4th industrial revolution" – refers to the development of advanced technologies, such as 3D printing, robotics, biotech, quantum computing, enhanced communications networks and infrastructures (the Internet of Things) and new production management know-how

| | | |
|---|---|---|
| នៃការធ្វើពិពិធកម្ម ឧស្សាហកម្ម កំណើន ផលិតភាពនិងការប្រកួតប្រជែងនាពេលអនាគតរបស់កម្ពុជា។ | កម្ពុជាដើរឆ្ពោះទៅមុខកាន់តែលឿន ដែលបង្កើតនវានុវត្តន៍លើវិធីសាស្ត្រ និងបច្ចេកវិទ្យា។ | គម្លាតដ៏សំខាន់រវាងបំណងប្រាថ្នា។ |

## ច្បាប់

ប្រទេសកម្ពុជាមានប្រព័ន្ធច្បាប់ដែលកំពុងវិវឌ្ឍន៍មួយ ពោលគឺរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដ៏ទូលំទូលាយរបស់ខ្លួន[35] ដែលត្រូវបានធ្វើវិសោធនកម្ម និងមានចែងអំពីបទប្បញ្ញត្តិនានា ដើម្បីការពារសិទ្ធិពល និងកាតព្វកិច្ចរបស់រដ្ឋ។ ច្បាប់អន្តរជាតិក៏ត្រូវបានចាត់ទុកថាជាប្រភពមួយនៃច្បាប់ក្នុងប្រទេសកម្ពុជាផងដែរ យោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧។ ទោះជាយ៉ាងណាយោងតាមមាត្រា ២៦ នៃរដ្ឋធម្មនុញ្ញ រាល់សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងអស់ត្រូវតែទទួលបានការចុះហត្ថលេខានិងផ្តល់សច្ចាប័នដោយព្រះមហាក្សត្រ បន្ទាប់ពីមានការអនុម័តដោយសភា[36]។

នៅក្នុងបុព្វកថារបស់ខ្លួន រដ្ឋធម្មនុញ្ញចែងថា "ប្រទេសជាតិឲ្យទៅជា 'កោះសន្តិភាព' ឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់"។ (មាត្រា ៨) នៃរដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ "ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ"។ មាត្រា ៣១ ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ មាត្រានេះបន្តចែងថា មនុស្សគ្រប់គ្នាមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់។

អគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់សម្គាល់ថា ក្របខ័ណ្ឌច្បាប់និងស្ថាប័ននៅក្នុងប្រទេសកម្ពុជា បានឆ្លងការការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់មួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ច្បាប់ថ្មីមានបទប្បញ្ញត្តិនានា ដែលអាចរឹតបន្តឹងប្រកបដោយសក្តានុពលនូវសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការប្រមូលផ្តុំ ជាពិសេសច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ច្បាប់ស្តីពីសហជីពដែលត្រូវបានទទ្ទឹងរង់ចាំជាយូរ និងច្បាប់ស្តីពីទូរគមនាគមន៍។ លើសពីនេះទៀត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា បានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឲ្យលុបចោលបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌដែលអាចត្រូវបានប្រើប្រាស់ដើម្បីរឹតបន្តឹងសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការប្រមូលផ្តុំ និងសេរីភាពក្នុងការបង្កើតសមាគម ដើម្បីសម្រេចបានភាពចុះសម្រុងគ្នាកាន់តែ

[35] Constitution of the Kingdom of Cambodia, access at http://pressocm.gov.kh/en/archives/9539

[36] Parliamentary Institute of Cambodia (2016) Legal and Judicial Reforms in Cambodia, www.pic.org.kh/images/2016Research/20170505_Legal_Judicial_Reform_Eng.pdf

ខ្លាំងជាមួយស្តង់សារសិទ្ធិមនុស្សអន្តរជាតិ ដោយលុបចោលទោសទណ្ឌបទល្មើសនានាដូចជាការបរិហាកេរ្តិ៍ជាដើម[37]។

មានការសង្កេតឃើញថា រដ្ឋមិនទាន់មានការបែងចែកអំណាចច្បាស់លាស់ក្នុងចំណោមស្ថាប័នសំខាន់ទាំងបី (និតិបញ្ញត្តិ និតិប្រតិបត្តិ និងតុលាការ) ដែលក្នុងលក្ខណៈបែបនេះ បានបង្កឲ្យមានឱកាសតិចតួច (ឬមិនមាន) សម្រាប់យុត្តិធម៌ ដើម្បីទទួលបានការឈ្នះដោយយុត្តិធម៌ និងស្មើភាព នៅកម្ពុជា។ អគ្គលេខាធិការបានលើកឡើងថា សកម្មភាពតុលាការមួយចំនួនដែលធ្វើឡើងប្រឆាំងនឹងគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលបានឆ្លុះបញ្ចាំងឲ្យឃើញពីកង្វះខាតរចនាសម្ព័ន្ធក្នុងការអនុវត្តច្បាប់និងក្នុងស្ថាប័នតុលាការ ដែលត្រូវបានលើកឡើងជាយូរមកហើយដោយយន្តការសិទ្ធិមនុស្ស រួមទាំងឯករាជ្យភាពរបស់តុលាការ កង្វះការធានានីតិវិធី ដែលបង្កឲ្យមានការពឹងផ្អែកខ្លាំងជ្រុលទៅលើការឃុំខ្លួនមុនការកាត់ទោស មូលដ្ឋានភស្តុតាងខ្សោយសម្រាប់ការផ្តន្ទាទោស និងនិទណ្ឌភាព។ ចំនួន "សំណុំរឿងតាមប្រព័ន្ធទំនាក់ទំនងសង្គម (Facebook)" កំពុងកើនឡើង ដែលកំពុងត្រូវបានតាមដានក្នុងការបង្ហោះនៅលើបណ្តាញទំនាក់ទំនងសង្គម ដែលត្រូវបានប្រើប្រាស់ធ្វើជាភស្តុតាងនៃការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។

## បរិស្ថាន

ខណៈដែលប្រទេសកម្ពុជាត្រូវបានចាត់ទុកថា សម្បូរធនធានបរិស្ថាន និងធម្មជាតិ ទាំងនេះស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំង។ ការកាប់ឈើខុសច្បាប់ អន្តរកាលដីធ្លីនិងការប្រើប្រាស់ដី ឧស្សាហកម្មនិស្សារណកម្ម បន្តបំផ្លិចបំផ្លាញមូលដ្ឋានធនធានរបស់ប្រទេស ដោយអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ចដែលមានគុណភាព និងមានតម្លាភាពនៅមានកម្រិត។ គម្របព្រៃឈើសរុបក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះពីប្រហែល ៧២% ក្នុងឆ្នាំ១៩៧៣ មកនៅត្រឹម ៤៨% ក្នុងឆ្នាំ២០១៤ ខណៈដែលព្រៃក្រាស់បានធ្លាក់ចុះពី ៤២% មកនៅត្រឹម ១៦% ក្នុងរយៈពេលដូចគ្នានេះ។ កម្រិតគម្របព្រៃឈើចម្រុះ (រួមទាំងចម្ការមួយចំនួន) បានមានស្ថិរភាពក្នុងអំឡុងពេលនេះ ដោយមាន ៣១% ក្នុងឆ្នាំ១៩៧៣ និង ៣១% ក្នុងឆ្នាំ២០១៤[38]។

ទិដ្ឋភាពមួយផ្សេងទៀតនៃភាពងាយរងគ្រោះផ្នែកបរិស្ថាន របស់កម្ពុជាគឺការសឹករេចរឹលនៃដី។ អង្គការស្បៀងអាហារ និងកសិកម្ម (FAO) បានរាយការណ៍ថា ក្នុងឆ្នាំ២០០៨ មាន៤៣% (> ៧,៨លានហិចតា) នៃផ្ទៃដីរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាជាដីដែលសឹករេចរឹល[39]។ ក្នុងចំណោមនេះ ផ្ទៃដីចំនួន ៤,៥៥ ហិចតា ត្រូវបានចាត់ចូលជាប្រភេទដីដែលអាចសឹករេចរឹលខ្ពស់[40]។ ក្នុងឆ្នាំ២០២០

37 United Nations General Assembly (November 2018) Report of the Office of the United Nations High Commissioner for Human Rights-Compilation on Cambodia http://daccess-ods.un.org/access.nsf/Get?Open&DS=A/HRC/WG.6/32/KHM/2&Lang=E

38 https://opendevelopmentcambodia.net/profiles/forest-cover/#

39 Pheav, S., () Land Degradation Land Degradation Assessment in Cambodia,cdn.asocon.org/LADA/Documents/Cambodia%20-%20presentation.pdf

40 MAFF (2018) Land Degradation Neutrality Targets, https://knowledge.unccd.int/sites/default/files/ldn_targets/Cambodia%20LDN%20Country%20Commitments.pdf

៥៥% នៃប្រជាជននៅទីជនបទរបស់ប្រទេស បានកំពុងរស់នៅលើដីកសិកម្មដែលកំពុងសឹករេចរឹល ដែលមានចំនួនប្រហែល ៦,៣ លាននាក់ ហើយតួលេខនេះបានកើនឡើង ៣៨% គិតចាប់តាំងពីឆ្នាំ ២០០១[41]មក។ ហានិភ័យពីការសឹករេចរឹលដីទៅលើផលិតភាពកសិកម្ម មិនអាចត្រូវបានបង្ហាញឲ្យឃើញបន្ថែមទៀតនោះទេ ជាពិសេសពេលរួមផ្សំជាមួយនឹងភាពងាយរងគ្រោះផ្នែកអាកាសធាតុរបស់កម្ពុជា។ ការរួមផ្សំគ្នានេះ បង្កហានិភ័យខ្លាំងចំពោះគ្រួសារដែលពឹងផ្អែកលើផ្ទៃដីកសិកម្មតូចៗរបស់កម្ពុជា ដោយចងចាំថា ការកាន់កាប់ផ្ទៃដីជាមធ្យមក្នុងប្រទេសកម្ពុជាមានទំហំ ១,៦ហិចតា[42] (ដោយគ្រួសារកសិករចំនួន ៨៩០.០០០ គ្រួសារកាន់កាប់ផ្ទៃដីតិចជាងមួយហិចតា ហើយ ១,៧ លានគ្រួសារកាន់កាប់ផ្ទៃដីតិចជាងបួនហិចតា) ដោយដាក់កម្រិតគ្រួសារ ដែលមានសក្តានុពលក្នុងការផ្ទេរ/បែងចែងការកាន់កាប់ដីបន្តទៅឲ្យសមាជិកគ្រួសារ ហើយមានតែ ៨៥១ គ្រួសារប៉ុណ្ណោះ ដែលមានផ្ទៃដីកាន់កាប់ច្រើនជាង ៥០ ហិចតា[43]។

ប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេស ដែលមានគ្រោះមហន្តរាយធម្មជាតិខ្លាំងបំផុត និងជាប្រទេសដែលងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងទ្វីបអាស៊ី និងនៅក្នុងពិភពលោក[44]។ ប្រទេសនេះត្រូវបានផ្តល់ចំណាត់ថ្នាក់ទី៨ (ដែលស្ថិតក្នុងហានិភ័យខ្លាំង) ក្នុងចំណោមប្រទេសចំនួន ១៧១ នៅក្នុងសន្ទស្សន៍ហានិភ័យពិភពលោក ក្នុងឆ្នាំ ២០១៦[45]។ ខណៈដែលសន្ទស្សន៍ហានិភ័យពិភពលោករបស់ខ្លួនក្នុងឆ្នាំ២០១៨ មានកម្រិត ៤,៧/១០[46] ដែលជាកម្រិតខ្ពស់បំផុតក្នុងចំណោមប្រទេសជិតខាងចំនួនបីរបស់ខ្លួន (ឡាវ ថៃ និងវៀតណាម)។ គ្រោះថ្នាក់ជាក់លាក់របស់កម្ពុជា និងកត្តាហានិភ័យដែលប្រឈម មានចាប់ពី ៤ សម្រាប់ព្រឹត្តិការណ៍គ្រោះមហន្តរាយដែលបង្កើតឡើងដោយមនុស្ស រហូតដល់ ៩,៥ សម្រាប់ទឹកជំនន់ (INFORM 2018)។ ខណៈដែលគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងស្រុកគឺជាព្រឹត្តិការណ៍កើតមានស្ទើរតែជារៀងរាល់ឆ្នាំ នៅផ្នែកនានាក្នុងប្រទេសនោះ ដូច្នេះភាពងាយរងគ្រោះ/ហានិភ័យចំពោះអាកាសធាតុរបស់កម្ពុជា បង្កការគំរាមកំហែងខ្លាំងមួយដល់ប្រជាជនដែលពឹងផ្អែកលើកសិកម្ម ព្រមទាំងបង្កហានិភ័យកាន់តែខ្លាំងថែមទៀតសម្រាប់ហេដ្ឋានរចនាសម្ព័ន្ធដែលងាយរងគ្រោះ។

បញ្ហាប្រឈមផ្នែកបរិស្ថាន ដែលកំពុងលេចឡើងមួយផ្សេងទៀតសម្រាប់ប្រទេសកម្ពុជា មានទំនាក់ទំនងទៅនឹងការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័សរបស់ប្រទេស ដោយតួលេខមានចាប់ពី ២៣,៨%[47] ដល់ ~៣០%[48] នៃប្រជាជនដែលបច្ចុប្បន្នកំពុងរស់នៅក្នុងតំបន់ទីក្រុង។ ការណ៍នេះមួយ

---

41 Global Mechanism of the UNCCD, 2018.Country Profile of Cambodia.Investing in Land Degradation Neutrality: Making the Case.An Overview of Indicators and Assessments.

42 MAFF (2015) Agricultural Census 2013,www.fao.org/fileadmin/...Census_Agriculture/.../KHM_ENG_REP_2013.pdf

43 MRLG (2019)State of Land in the Mekong https://mrlg.org/resources/state-of-land-in-the-mekong-region/

44 UNESCAP 2010 Asia-Pacific Disaster Report 2010 Reducing Disaster Vulnerability and Building Resilience in Asia and the Pacific The Asia-Pacific Disaster Report, 2010

45 The current (2016) world risk index ranking are (i) Vanuatu; (ii) Tonga; (iii) Philippines; (iv) Guatemala; (v) Bangladesh; (vi) Solomon Islands (vii) Costa Rica (viii) Cambodia, out of 171 countries, in Bündnis Entwicklung Hilft & United Nations University (2016) World Risk Report, https://collections.unu.edu/eserv/UNU:5763/WorldRiskReport2016_small_meta.pdf

46 www.inform.index.org, INFORM is a global, open-source risk assessment for humanitarian crises and disasters and is intended to support decisions about prevention, preparedness and response, and is maintained by UNISAC and the EU.

47 Based on 4/5th of the 2015 (22.2%) to 2020 (24.2) range in the UN (2018 revision) World Urbanisation Report https://www.un.org/development/desa/publications/2018-revision-of-world-urbanization-prospects.html

48 The project figures from the ADB Cambodia Urbanisation Report 2015

ផ្នែកត្រូវបានជំរុញដោយការប្រមូលផ្តុំឧស្សាហកម្មក្នុង និងជុំវិញតំបន់ទីក្រុង ដែលជំរុញឲ្យមានការប្រមូលផ្តុំសេដ្ឋកិច្ចនៅទីក្រុង និងការធ្វើចំណាកស្រុកភាគច្រើនជាយុវជនជនបទ ដើម្បីស្វែងរកការងារដែលមានប្រាក់ខែខ្ពស់។ នគរូបនីយកម្មយ៉ាងឆាប់រហ័សនេះ បាននិងកំពុងបង្កើតឲ្យមានបញ្ហាបំពុលទីក្រុង ដោយសារការគ្រប់គ្រងកាកសំណល់រឹង ដែលត្រូវបានរាយការណ៍ថាមាននៅក្នុងតំបន់នេះចំនួន ៣,៦៥លានតោន (ក្នុងឆ្នាំ២០១៧)[49] ប្រព្រឹត្តិកម្មកាកសំណង់រាវ ដោយសារតែមានតែក្រុងចំនួនបីប៉ុណ្ណោះក្នុងចំណោមក្រុងចំនួន២៧ ដែលត្រូវបានគ្របដណ្តប់មួយផ្នែកដោយប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ ការបំពុលខ្យល់។ល។ ឥទ្ធិពលត្រលប់ ដែលជាញឹកញាប់លើសពីសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយ និងគ្រប់គ្រង។

# វិធីសាស្ត្រស្រាវជ្រាវ

## ការពិនិត្យឡើងវិញនូវក្របខណ្ឌ និងការសម្រួល

ដូចដែលបានលើកឡើង ការសិក្សានេះធ្វើឡើងផ្អែកលើការស្រាវជ្រាវកន្លងមកស្តីពីបរិយាកាសអំណោយផល ដែលបានសម្របសម្រួលដោយអង្គការ គ.ស.ក ដែលដើមឡើយមានបំណងចូលរួមចំណែកដល់ការស្រាវជ្រាវសកល ដើម្បីពិនិត្យមើលលើបញ្ហាដែលជះឥទ្ធិពល និងបញ្ហាប្រឈមដល់សង្គមស៊ីលនៅទូទាំងពិភពលោក ដែលត្រូវបានអនុវត្តឡើង ជាផ្នែកមួយនៃការវាយតម្លៃបរិយាកាសអំណោយផលជាតិ (EENA)។ ផ្អែកលើការសិក្សានេះបានសម្រួលឲ្យក្លាយទៅជាឧបករណ៍ស្រាវជ្រាវដើម្បីសន្ទឹបរិបទក្នុងស្រុក ដោយយោងតាមក្របខណ្ឌដែលបានបង្កើតឡើងដោយអង្គការសម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ (CIVICUS World Alliance for Citizen Participation) និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនស្វែងរកប្រាក់ចំណេញ (ICNL) ស្ថិតក្រោមកម្មវិធីគំនិតផ្តួចផ្តើមលំហរពលរដ្ឋរបស់អង្គការទាំងនេះ។ វិធីសាស្ត្រក្នុងការវាយតម្លៃបរិយាកាសអំណោយផលជាតិ គ្របដណ្តប់លើសមាសភាគចំនួនដប់ផ្នែក ដែលមានសារៈសំខាន់សម្រាប់បរិយាកាសច្បាប់ និងបទប្បញ្ញត្តិ ដែលសង្គមស៊ីវិល(គួរ)ប្រតិបត្តិការ។ សម្រាប់ការវាយតម្លៃថ្នាក់ជាតិឆ្នាំ២០១៣[50] ប្រទេសកម្ពុជាបានពិនិត្យមើលឡើងវិញនូវសមាសភាគចំនួនប្រាំពីរផ្នែក (សមាសភាគកំណត់ចំនួនប្រាំមួយ និងបួនសមាសភាគជាជម្រើស) (ដែលត្រូវបានគូសបន្ទាត់ពីក្រោម)។

| សមាសភាគកំណត់ចំនួនប្រាំមួយ | សមាសភាគជម្រើសបួន (ដោយផ្អែកលើបរិបទមូលដ្ឋាន) |
|---|---|
| (i) ការបង្កើត (ii) ប្រតិបត្តិការ (iii) លទ្ធភាពទទួលបានធនធាន (iv) សេរីភាពក្នុងការបញ្ចេញមតិ (v) ការប្រមូលផ្តុំដោយសន្តិវិធី / សេរីភាពក្នុងការជួបប្រជុំ (vi) ទំនាក់ទំនងអង្គការសង្គមស៊ីវិល | (vii) កិច្ចសហប្រតិបត្តិការនិងសម្ព័ន្ធភាពអង្គការសង្គមស៊ីវិល (viii) ពន្ធដារ (ix) សិទ្ធិទទួលបានព័ត៌មាន (x) សេរីភាពអ៊ីនធឺណិត |

49 MoE figures report in Khmer Times (/11/2018) WASTE MANAGEMENT, https://www.khmertimeskh.com/548828/waste-management/
50 http://www.ccc-cambodia.org/en/knowledge-management/online-library/ccc-publications-and-reports

ក្នុងឆ្នាំ២០១៥ អង្គការ គ.ស.ក វិទ្យាស្ថានតស៊ូមតិនិងគោនយោបាយ (API) និងបណ្ដាញថ្នាក់ខេត្តនានា បានអនុវត្តការសិក្សាលក្ខណៈមូលដ្ឋានមួយស្ដីពីបរិយាកាសអំណោយផលនៅថ្នាក់ក្រោមជាតិនៅក្នុងខេត្តចំនួនប្រាំ[51]។ ការណ៍នេះបានអនុវត្តក្របខ័ណ្ឌបន្ថែម ដែលរុករកបទពិសោធពីអាជ្ញាធរមូលដ្ឋាន និងទស្សនវិស័យរបស់អង្គការសង្គមស៊ីវិលថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌដែលត្រូវបានអនុវត្តសម្រាប់ការសិក្សាឆ្នាំ២០១៥ បានសិក្សាលើសមាសភាគដែលបានសម្រួលបានសម្រួល ដូចខាងក្រោម៖

| **ក. ព័ត៌មានដែលផ្ដល់ដោយអាជ្ញាធរមូលដ្ឋាន** | **ខ. ព័ត៌មានដែលផ្ដល់ដោយសង្គមស៊ីវិល** |
|---|---|
| ក.១ ប្រតិបត្តិការ និងការបំពេញការងារ | ខ-១ ប្រតិបត្តិការ |
| ក.២ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ | ខ-២ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនង |
| ក.៣ ព័ត៌មាន | ខ-៣ សិទ្ធិទទួលបានព័ត៌មាន |
| ក.៤ ការគ្រប់គ្រងធនធាន | ខ-៤ ការគ្រប់គ្រងធនធាន |

ការសិក្សាបច្ចុប្បន្ន ពឹងផ្អែកលើវិធីសាស្ត្រនាពេលកន្លងមក និងសម្របក្របខ័ណ្ឌចំនួនពីរ (ខាងលើ) ទៅនឹងតម្រូវការ និងការចង់បានដែលកំពុងវិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ហើយបន្ថែមការវាយតម្លៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន។ សម្រាប់ការសិក្សានេះពិនិត្យមើលអំឡុងពេលចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ដែលក្របខ័ណ្ឌត្រូវបានអនុវត្តសម្រាប់ ការសិក្សាមានសមាសភាគដូចខាងក្រោម។

| **បរិយាកាសអំណោយផល និង ក្របខ័ណ្ឌវាយតម្លៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន** | |
|---|---|
| ការបង្កើត និងប្រតិបត្តិការ (CSOs) | ការប្រមូលផ្ដុំដោយសន្តិវិធី/ សេរីភាពក្នុងការជួបប្រជុំ |
| ពន្ធដារ | ការទទួលបានធនធាន |
| សិទ្ធិទទួលបានព័ត៌មាន | ទំនាក់ទំនងរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិល |
| ភាពជាដៃគូប្រកបដោយបរិយាប័ន្ន | |

ការប្រមូលទិន្នន័យសម្រាប់ការសិក្សានេះត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០១៨ ដោយអនុវត្តទាំងវិធីសាស្ត្របែបបរិមាណ និងគុណវិស័យ។ ការសិក្សាបែបគុណវិស័យជាវិធីសាស្ត្រចម្បងនៃការសិក្សានេះ ហើយត្រូវបានជ្រើសរើស ដោយសារភាពស្មុគស្មាញ និងលក្ខខណ្ឌសមាសភាគនៃការសិក្សាតាមរយៈការធ្វើបទសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ (KIIs) និងការពិភាក្សាក្រុមគោលដៅ (FGDs) និងការបង្កើតករណីសិក្សា។

ព័ត៌មានត្រូវបានប្រមូលពីភាគីពាក់ព័ន្ធនៃការអភិវឌ្ឍជាច្រើន រួមទាំងតំណាងរបស់អាជ្ញាធររដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា។ ខណៈដែលសមាសភាគបែបបរិមាណនៃ

51 http://www.ccc-cambodia.org/en/knowledge-management/online-library/ccc-publications-and-reports

ការសិក្សានេះ មានមូលដ្ឋានលើការអង្កេតមួយលើក្រុមអ្នកតំណាងអង្គការសង្គមស៊ីវិលមកពីអង្គការជាសមាជិក បណ្ដាញវិស័យ និងអង្គការផ្សេងទៀត។ ការណ៍នេះក្រោយមកត្រូវបានបំពេញបន្ថែមដោយការពិនិត្យមើលឯកសារផ្សេងៗ និងការវិភាគលើព័ត៌មានជាច្រើនដែលទទួលបានពីប្រភពបន្ទាប់បន្សំ។ ឧបករណ៍ប្រមូលទិន្នន័យ និងវិធីសាស្ត្រដែលត្រូវបានអនុវត្តត្រូវបានសម្រួលដូចខាងក្រោម៖

## ការអង្កេតតាមបែបបរិមាណវិស័យ

បញ្ជីសំណាក (sample frame) ត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ជីសមាជិកដែលត្រូវបានផ្ដល់ជូនពីអង្គការ គ.ស.ក និងអង្គការសមាជិកភាពផ្សេងទៀតដូចជា អង្គការ NGO Forum ជាដើម។ មូលដ្ឋានទិន្នន័យបញ្ជីចុងក្រោយនៃអង្គការសង្គមស៊ីវិលចំនួនប្រហែល ៩០០ រួមមានទាំងព័ត៌មានទំនាក់ទំនងសម្រាប់អង្គការសង្គមស៊ីវិល ដែលតំណាងឲ្យវិស័យសុខាភិបាល អប់រំ ជីវភាពរស់នៅ (livelihood) អភិវឌ្ឍន៍សហគមន៍ កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការតស៊ូមតិ សិទ្ធិមនុស្ស និងការកសាងសមត្ថភាព។ ការអង្កេតមួយត្រូវបានបង្កើតឡើងដោយប្រើប្រាស់ SAAS "Survey To Go" ដោយមានការសហការជាមួយអង្គការ គ.ស.ក។

ការអង្កេតនេះ ត្រូវបានចែកចាយជាប្រភេទឌីជីថលទៅកាន់បុគ្គលិកគ្រប់គ្រងអង្គការសង្គមស៊ីវិលសម្រាប់បំពេញដោយខ្លួនឯង ដោយមានលិខិតអមមួយពីអង្គការ គ.ស.ក។ ក្រោយមកមានការរំឭកចំនួនពីរដង ហើយនឹងទំនាក់ទំនងតាមទូរស័ព្ទ ដើម្បីធ្វើឲ្យប្រសើរឡើង/លើកទឹកចិត្តឲ្យមានការចូលរួម/បំពេញការអង្កេតនេះ។ ទិសដៅបឋមគឺត្រូវបញ្ចប់ការឆ្លើយតបចំនួន ១៥០ ពីបុគ្គលិកគ្រប់គ្រងរបស់អង្គការសង្គមស៊ីវិល ដែលក្នុងករណីនេះ ជាការវិភាគបន្ថែមទៀតអាចត្រូវបានធ្វើឡើង ដើម្បីទទួលព័ត៌មានឲ្យកាន់តែប្រសើរសម្រាប់ការសិក្សាលើផ្នែកបរិមាណ។ ដោយផ្អែកលើក្របខ័ណ្ឌអង្កេតនេះ ដែលបានបង្កើតមូលដ្ឋានទិន្នន័យចេញពីអង្គការចំនួន៩០០ សម្រាប់ការទំនាក់ទំនងតាមសារអេឡិចត្រូនិច ហើយការទូរស័ព្ទទំនាក់ទំនងជាកិច្ចប្រឹងប្រែង ដើម្បីទទួលបានការឆ្លើយតប។

ជាចុងក្រោយ បទសម្ភាសដែលជោគជ័យចំនួនតែ ៦៧ប៉ុណ្ណោះត្រូវបានទទួលពីអ្នកឆ្លើយតប! ដូច្នេះហើយលទ្ធរកឃើញពីការសិក្សាបែបបរិមាណ ត្រូវបានប្រើប្រាស់គ្រាន់តែដើម្បីគាំទ្រ ឬធ្វើឲ្យមានសុពលភាពដល់លទ្ធផលរកឃើញពីគុណវិស័យ ដែលមានបទសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗជាដើម។

## បទសម្ភាសតាមបែបគុណវិស័យ

សមាសភាគបែបគុណវិស័យ នៃការសិក្សានេះ មានបទសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ (KIIs) ដែលត្រូវបានពិពណ៌នាលម្អិតក្នុងរូបភាព ២ ខាងក្រោម ព្រមទាំងការពិភាក្សាក្រុមគោលដៅ (FGDs) ជាមួយក្រុមអង្គការសង្គមស៊ីវិល និងអ្នកតំណាងផ្សេងៗ។

## បទសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs)

បញ្ជីឈ្មោះរបស់មន្ត្រី/តំណាងមកពីថ្នាក់ផ្សេងៗរបស់រដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ ត្រូវបានកំណត់ និងទាក់ទងសម្រាប់ការចូលរួម។ ការឆ្លើយតបមានភាពយឺតយ៉ាវ ដែលនាំឲ្យឈានទៅរកការចំណាយពេលនៅថ្នាក់មូលដ្ឋានយូរជាងការរំពឹងទុក ហេតុផលចំពោះការទទួលបានអត្រាឆ្លើយតបទាប ដោយសារបន្ទុកការងារច្រើន និងជាន់ពេលជួបគ្នា។ល។ មន្ត្រីតំណាងមកពីអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបានជ្រើសរើសនៅថ្នាក់ស្រុក និងថ្នាក់ឃុំ។ សម្រាប់អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ បុគ្គលិកត្រូវបានកំណត់ដោយផ្អែកលើបញ្ជីដែលត្រូវបានផ្តល់ជូនដោយអង្គការ គ.ស.ក និងមួយចំនួនបញ្ជូនមកដោយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត។

មគ្គុទ្ទេសក៍សំណួរសម្រាប់ការសម្ភាសស៊ីជម្រៅ ត្រូវបានបង្កើតឡើងដោយមានមូលដ្ឋានលើក្របខ័ណ្ឌ CIVICUS ដែលត្រូវបានកែសម្រួលមួយ ដោយប្រើប្រាស់សមាសធាតុចំនួនប្រាំពីរ ដែលរួមមាន ប្រតិបត្តិការ/ការបង្កើត ពន្ធដារ សេរីភាពក្នុងការបញ្ចេញមតិ/ការប្រមូលផ្តុំ ការទទួលបានធនធាន សិទ្ធិទទួលបានព័ត៌មាន ទំនាក់ទំនងរវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន។ បទសម្ភាសត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួនប្រាំបី[52] ស្របតាមទីតាំងភូមិសាស្ត្រ ដែលផ្អែកលើការពិចារណានានាដូចជា វត្តមានរបស់បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តជាដើម។ ជាកាយវិការមួយនៃការដឹងគុណសម្រាប់ការចូលរួម សៀវភៅកត់ត្រាមួយត្រូវបានផ្តល់ជូនទៅកាន់អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងអ្នកចូលរួមផ្សេងទៀត និងមានការផ្តល់ជូនថ្លៃចំណាយលើការធ្វើដំណើរផងដែរ ដើម្បីអាចឲ្យពួកគេធ្វើដំណើរទៅចូលរួមការផ្តល់សម្ភាស និងការពិភាក្សាក្រុម។

## ការពិភាក្សាក្រុមគោលដៅ (FGDs)

បន្ថែមលើបទសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ការពិភាក្សាក្រុមគោលដៅ (FGDs) ត្រូវបានធ្វើឡើងក្នុងខេត្តទាំងប្រាំបីដូចគ្នា។ សម្រាប់ការពិភាក្សារក្រុមនីមួយៗ បុគ្គលិករបស់អង្គការសង្គមស៊ីវិលចំនួនប្រាំមួយនាក់ ដែលតំណាងឲ្យថ្នាក់គ្រប់គ្រង ត្រូវបានជ្រើសរើសនៅថ្នាក់ស្រុក និងថ្នាក់ឃុំ។ ការពិភាក្សាក្រុមគោលដៅទាំងនេះត្រូវបានឡើងដោយអ្នកសម្របសម្រួលម្នាក់ និងអ្នកកត់ត្រាម្នាក់។ អ្នកចូលរួមត្រូវបានជ្រើសរើស ដើម្បីធ្វើជាតំណាងរបស់វិស័យផ្សេងៗ រួមទាំងវិស័យសុខាភិបាល អប់រំ ជីវភាពរស់នៅ (livelihood) អភិវឌ្ឍន៍សហគមន៍ កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការតស៊ូមតិ សិទ្ធិមនុស្ស និងការកសាងសមត្ថភាព។

[52] Interviews were conductedin :Battambang, Siem Reap, Ratanakiri, Steung Treng, Kampong Cham, SvayRieng, Preah Sihanouk and Kampot.

## ករណីសិក្សា

ករណីសិក្សាចំនួនបួន ត្រូវបានបង្កើតឡើង។ ករណីសិក្សាចំនួនពីរត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់លទ្ធផលរកឃើញអំពីបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល ខណៈដែលករណីសិក្សាចំនួនពីរផ្សេងទៀតត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់លទ្ធផលរកឃើញ សម្រាប់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន។ ករណីសិក្សាទាំងនេះក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីរុករក និងវាយតម្លៃគំរូនៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដើម្បីជូនដំណឹងអំពីសក្តានុពលនៃគំរូភាពជាដៃគូនាពេលអនាគត។ ករណីសិក្សាទាំងនេះមានការសម្ភាសជាមួយបុគ្គលិក និងការពិនិត្យមើលឯកសារតាមអនឡាញអំពីអង្គការ។

## ការពិនិត្យមើលឯកសារផ្សេងៗ

កិច្ចប្រឹងប្រែងនានាត្រូវបានធ្វើឡើង ដើម្បីប្រមូល និងពិនិត្យមើលប្រភពបន្ថែមជាច្រើនទៀត ដើម្បីព្យាយាមផ្តល់លទ្ធភាពឲ្យការពិនិត្យគោលបំណងអាចត្រូវបានអនុវត្តបាន ជាពិសេសទាក់ទងនឹងអំឡុងពេលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ ប្រភពទាំងនេះត្រូវបានប្រមូលពីប្រភពបោះពុម្ព និងអនឡាញដែលអាចរកបាន។ ខណៈ តម្រូវអោយមានការខិតខំប្រឹងប្រែងស្វែងរកប្រភព ឯកសារផ្សេងប្រកបដោយសក្តានុពលនោះ ពេលវេលានិងកិច្ចខិតខំប្រឹងប្រែងខ្លាំងត្រូវការជាចាំបាច់ ដើម្បីសិក្សាលើប្រភពទាំងនោះ។

## វិសាលភាពសម្រាប់ការសិក្សា

ការសិក្សានេះដូចដែលត្រូវបានអនុវត្តឡើង មានមូលដ្ឋានដ៏ចម្បងលើការយល់ឃើញរបស់អ្នកតំណាងរបស់អង្គការសង្គមស៊ីវិល។ កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ នាយក សមាជិកក្រុមប្រឹក្សាភិបាល អ្នកតំណាងប្រចាំប្រទេស។ល។ ដែលត្រូវបានកំណត់ទិសដៅបឋម ដើម្បីអាចឲ្យមានការទទួលខុសត្រូវ/ការយល់ឃើញ កាន់តែប្រសើរអំពីបញ្ហាផ្សេងៗ។ ទោះជាយ៉ាងណា ដោយសារកង្វះការឆ្លើយតប វិសាលភាពកាន់តែទូលំទូលាយមួយត្រូវបានអនុវត្តឡើង ដើម្បីកំណត់ទិសដៅលើអ្នកគ្រប់គ្រង និងអ្នកដឹកនាំកម្មវិធីផងដែរ ហើយការណ៍នេះអាចកាត់បន្ថយលទ្ធភាពរបស់ការសិក្សានេះ ចំពោះការទទួលខុសត្រូវលើបញ្ហាសំខាន់ៗមួយចំនួន។

ដូចដែលបានលើកឡើង អង្គការចំនួន ៤០០ ត្រូវបានទាក់ទងជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះ ដោយសង្ឃឹមទទួលបានការឆ្លើយតបចំនួន១៥០ ដើម្បីធ្វើជាអ្នកតំណាង សម្រាប់ប្រើប្រាស់ជារបាយអង្គការសង្គមស៊ីវិលនៅទូទាំងប្រទេស។ នៅចុងបញ្ចប់ មានចម្លើយតបចំនួនតែ ៦៧ ប៉ុណ្ណោះ

ទោះមានការរំពឹកជាបន្តបន្ទាប់។ ការណ៍នេះបង្កើតឲ្យមានក្តីបារម្ភអំពីការប្តេជ្ញាចិត្ត និងចំណាប់អារម្មណ៍របស់អង្គការសង្គមស៊ីវិល ចំពោះរបៀបវារៈនៃបរិយាកាសអំណោយផលនេះ។

វាទំនងជាអាចមានវិសមានចិត្ត និងកង្វះចំណាប់អារម្មណ៍ដោយថ្នាក់គ្រប់គ្រងរបស់អង្គការសង្គមស៊ីវិលក្នុងការចូលរួមក្នុងការសិក្សានេះ? ឬតើការណ៍នេះគឺជាកង្វះឆន្ទៈក្នុងការចូលរួម ដែលមានទំនាក់ទំនងទៅនឹងក្តីបារម្ភណ៍ ដែលកំពុងកើតមានអំពីសេរីភាពក្នុងការបញ្ចេញមតិ ដែលសក្តានុពលអ្នកឆ្លើយសម្ភាសន៍មានការស្ទាក់ស្ទើរក្នុងការបង្ហាញទស្សនៈរបស់ពួកគេ នៅក្នុងរយៈកាលបច្ចុប្បន្ន ដែលមានបរិយាកាសរួមតូច។

បញ្ហាមួយផ្សេងទៀតជាមួយនឹងហានិភ័យនៃការបង្កើតគម្លាត ដោយសារមានតែការសម្ភាសអ្នកតំណាងតែម្នាក់គត់ក្នុងមួយអង្គការត្រូវបានធ្វើឡើង។ វាអាចថា តាមការពិត បុគ្គលម្នាក់ទំនងជាយល់ឃើញច្បាស់តែលើបញ្ហាជាក់លាក់នៃការទទួលខុសរបស់គាត់ ហើយការសម្ភាសថ្នាក់ផ្សេងៗនៅក្នុងអង្គការមួយ អាចជួយឲ្យមានទស្សនៈចម្រុះកាន់តែច្រើនអំពីការកំណត់បញ្ហា និងតម្រូវការបន្ទាន់ផ្សេងៗ។

ក្នុងអំឡុងពេលសិក្សាឯកសារ និងរៀបចំរបាយការណ៍ព្រាងថ្មីក្នុងឆ្នាំ២០១៩ ក្រុមការងារ ដែលពាក់ព័ន្ធ អាចត្រឹមតែធ្វើការងារជាមួយទិន្នន័យ ដែលត្រូវបានប្រមូលនាពេលកន្លងមក គឺមានចំនួនឆ្លើយតបដ៏ច្រើនពីការអង្កេតបែបបរិមាណ ស្តែងចេញពីសំណួរបើក។ ការណ៍នេះបានបង្កឲ្យមានការឆ្លើយតបបែបបុគ្គលរាប់រយ ដែលមិនអាចត្រូវបានចងក្រងជាក្រុមបានប្រកបដោយប្រសិទ្ធភាព ឬមិនអាចធ្វើជាតារាងលទ្ធផល (cross tabulated) អោយគ្រប់ជ្រុងជ្រោយ ដែលប៉ះពាល់ដល់លទ្ធផលរកឃើញ តាមរយៈការពិនិត្យមិនបានល្អិតល្អន់លើទិន្នន័យជាច្រើន ក្នុងកាលៈទេសៈនេះ។

ចំនួនមន្ត្រីរដ្ឋាភិបាល និងអ្នកតំណាងរបស់ដៃគូអភិវឌ្ឍន៍ ដែលត្រូវបានរួមបញ្ចូល ត្រឹមតែផ្តល់ការឆ្លើយតប តាមការយល់ដឹងមួយចំនួនប៉ុណ្ណោះ ហើយប្រហែលមិនតំណាងអោយគំនិតយោបល់ចម្រុះមកពីភាគីពាក់ព័ន្ធទាំងនេះឡើយ។ ខណៈដែលការស្រាវជ្រាវនេះពិតជាកំណត់អាកកប្បកិរិយា និងទស្សនៈមួយចំនួនរបស់អ្នកចូលរួមក្នុងការសម្ភាស វាច្បាស់ថា ការឆ្លើយតបបន្ថែមទៀតត្រូវការជាចាំបាច់ ដើម្បីបង្កើតបានជាឥទ្ធិពលពិតប្រាកដ ដែលភាគីពាក់ព័ន្ធទាំងនេះមានលើបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។

# លទ្ធផលនៃការរកឃើញសំខាន់ៗ

ផ្នែកខាងក្រោមបង្ហាញលម្អិតអំពីលទ្ធផលរកឃើញ ដោយផ្អែកលើសមាសភាគចំនួនប្រាំពីរផ្នែក នៃក្របខ័ណ្ឌបរិយាកាសអំណោយផល និងវាយតម្លៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដែលត្រូវបានដាក់ចេញខាងលើ។

## ការបង្កើត និងប្រតិបត្តិការ

### ទិដ្ឋភាពរួម

ផ្នែកនេះលើកឡើងពីការបង្កើតនិងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល **ដំបូងឡើយសំដៅដល់ដំណើរការ និងលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីអង្គការ ឬសមាគម យោងទៅតាមលក្ខខណ្ឌតម្រូវច្បាប់ដែលត្រូវបានអនុម័ត។** ដំណើរការនេះត្រូវបានណែនាំដោយសំណួរនានា[53]ពាក់ព័ន្ធនឹងច្បាប់ដែលគ្រប់គ្រងការបង្កើតអង្គការសង្គមស៊ីវិល ដូចជា (ក) តើអ្នកណាដែលត្រូវបានអនុញ្ញាតឲ្យធ្វើជាស្ថាបនិកអង្គការសង្គមស៊ីវិល? (ខ) ចំនួនបុគ្គលអប្បបរមាដែលត្រូវបានតម្រូវឲ្យបង្កើតអង្គការសង្គមស៊ីវិលមួយ? (គ) លក្ខខណ្ឌតម្រូវសមាជិកភាព? (ឃ) នីតិវិធីដែលត្រូវបានតម្រូវឲ្យចុះបញ្ជី/បង្កើតអង្គការសង្គមស៊ីវិលមួយ? (ង) មូលដ្ឋានជាក់លាក់សម្រាប់ការច្រានចោលពាក្យស្នើសុំចុះបញ្ជី/បង្កើតរបស់អង្គការសង្គមស៊ីវិល? (ច) ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចចិត្តចុះបញ្ជី? (ឆ) ឯកសារដែលតម្រូវឲ្យមានសម្រាប់ការបង្កើត/ការចុះបញ្ជីរបស់អង្គការសង្គមស៊ីវិល? (ជ) លក្ខខណ្ឌតម្រូវសម្រាប់អង្គការសង្គមស៊ីវិលសម្រាប់ការចុះបញ្ជីជាថ្មី? (ឈ) ការចំណាយលើការចុះបញ្ជីអង្គការសង្គមស៊ីវិល? និង (ញ) តើដំណើរការជាធម្មតាចំណាយរយៈពេលយូរប៉ុណ្ណា? ក៏នឹងមានការសម្លឹងមើលផងដែរទៅលើចំនួនដែលត្រូវបានរាយការណ៍នៃអង្គការសង្គមស៊ីវិលបច្ចុប្បន្ន ដែលត្រូវបានចុះបញ្ជីគិតចាប់តាំងពីច្បាប់ស្ដីពីសមាគម និងអង្គការ ត្រូវបានអនុម័តក្នុងឆ្នាំ២០១៥មក។

ក្នុងបរិបទនៃការសិក្សានេះ **ប្រតិបត្តិការសំដៅលើលទ្ធភាពរបស់អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ដើម្បីគ្រប់គ្រង និងអនុវត្តសកម្មភាពរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណរបស់ពួកគេជាមួយរដ្ឋ ព្រមទាំងក្នុងក្របខ័ណ្ឌច្បាប់ជាធរមាន ដោយគ្មានការជ្រៀតជ្រែកពីរដ្ឋ។** ដំណើរការនេះនឹងត្រូវបានការណែនាំដោយសំណួរនានា ប៉ុន្តែមិនកម្រិត (ក) តើច្បាប់អ្វីដែលគ្រប់គ្រងដោយផ្ទាល់លើប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល? (ខ) តើច្បាប់ណាមួយផ្សេងទៀតប៉ះពាល់ ឬជះឥទ្ធិពលដល់ប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលដែរឬទេ? (គ) តើអង្គការសង្គមស៊ីវិលត្រូវបានតម្រូវឲ្យជូនដំណឹងដល់រដ្ឋាភិបាលអំពីសកម្មភាព ឬកិច្ចប្រជុំណាមួយដែរឬទេ? (ឃ) តើអង្គការសង្គមស៊ីវិលត្រូវបានតម្រូវឲ្យដាក់ជូនរបាយការណ៍តាមដំណាក់កាលទៅកាន់រដ្ឋាភិបាលដែរឬទេ? (ង) តើរបាយការណ៍ប្រភេទអ្វី ឧ. របាយការណ៍បូកសរុបសកម្មភាពការងារ ឬរបាយការណ៍ហិរញ្ញវត្ថុ ហើយតើញឹក

53 Adapted from CIVICUS's mandatory dimensions for EENA Research Guide-Questions.

ញាប់ប៉ុណ្ណា? (ច) តើអង្គការសង្គមស៊ីវិលជាកម្មវត្ថុចំពោះការធ្វើសវនកម្ម ឬអធិការកិច្ចរបស់រដ្ឋាភិបាលដែរឬទេ? (ឆ) តើលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលអ្វីខ្លះដែលជះឥទ្ធិពលដល់ប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល? (ជ) តើអង្គការសង្គមស៊ីវិលត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីបន្សីសកម្មភាពរបស់ពួកគេជាមួយអាទិភាពរបស់រដ្ឋាភិបាល ដូចដែលត្រូវបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ជាតិដែរឬទេ? (ឈ) តើរដ្ឋាភិបាលឈរលើមូលដ្ឋានច្បាប់អ្វីដែលត្រូវបានអនុញ្ញាតឲ្យបញ្ចប់ ឬរំលាយអង្គការសង្គមស៊ីវិល? (ញ) តើមានដំណើរការ/នីតិវិធីប្តឹងឧទ្ធរណ៍ដែររទេសម្រាប់សេចក្តីសម្រេចចិត្តបញ្ចប់/រំលាយ?

## លទ្ធផលរកឃើញ និងការវិភាគ

<u>បរិបទរបស់អង្គការសង្គមស៊ីវិលដែលត្រូវបានរាយការណ៍</u>

បច្ចុប្បន្នមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៥.៥២៣ ដែលត្រូវបានរាយការណ៍ (អង្គការមិនមែនរដ្ឋាភិបាលចំនុន ៣.២២៦) និងសមាគម (ចំនួន២.២៩៧) ដែលបានផ្តល់ឯកសារ និងចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ (MoI)[54]។ សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា ដើម្បីបង្កើតអង្គការសង្គមស៊ីវិលមួយក្នុងប្រទេសកម្ពុជា ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ហើយក្នុងការអនុវត្ត ប្រជាពលរដ្ឋអាចមានលទ្ធភាពទទួលបាន និងប្រើប្រាស់សិទ្ធិនេះ។ មាត្រា៩២ នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ និងថា សិទ្ធិនេះត្រូវបានកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

ក្របខ័ណ្ឌច្បាប់ជាធរមាន សម្រាប់ការចុះបញ្ជីអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា បច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១៥ "LANGO"។ គោលបំណងដែលមានចែងរបស់ច្បាប់នេះ គឺ "កំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ទំនាក់ទំនងរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាល ជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជា"[55]។

នៅត្រឹមឆ្នាំ២០១៨ មានអង្គភាពតែ ២៨៩ប៉ុណ្ណោះ (សមាគមចំនួន១៨០ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១០៩) បានចុះបញ្ជី ឬដាក់ពាក្យស្នើសុំទៅកាន់ក្រសួងមហាផ្ទៃ (MoI)[56]។ អង្គការសង្គមស៊ីវិលក្នុងស្រុកដែលត្រូវបានផ្តល់ប្រឹក្សា និងត្រូវបានចុះបញ្ជីកន្លងមក (មុនឆ្នាំ២០១៥) បច្ចុប្បន្នបានរាយការណ៍ពីការតម្រូវឲ្យដាក់ជូនឯកសារបច្ចុប្បន្នភាពបន្ថែម ដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវបុគ្គលិកចំពោះកិច្ចរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានគេជឿថាស្ថិតក្រោមក្របខ័ណ្ឌច្បាប់ (LANGO)។ នៅពេលអង្គការទាំងនោះ ធ្វើដំណើរជូនដំណឹងក្រសួងមហាផ្ទៃអំពីការផ្លាស់ប្តូរអ្នកកាន់មុខតំណែងអង្គ

---

[54] Sar Kheng, deputy prime minister and minister of MoI, speech at the Partnership Forum between Government and NGOs on 17th January 2019.
[55] https://cambodia.ohchr.org/.../sites/.../Unofficial_Translation_of_5th_LANGO_ENG.p...
[56] ibid.

ការរបស់ពួកគេ (សមាជិកក្រុមប្រឹក្សាភិបាលថ្មី/បុគ្គលិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ថ្មី) ការផ្លាស់ប្តូរអាសយដ្ឋានថ្មី ឬការផ្លាស់ប្តូរលក្ខន្តិកៈថ្មី។ល។) តើលក្ខខណ្ឌតម្រូវទាំងនេះមិនត្រូវបានគ្រប់ដណ្តប់ដោយច្បាប់ LANGO? ដូចដែលបានលើកឡើងបន្តិចទៀតនេះ សំណើទាំងនេះច្បាស់ណាស់ធ្លាក់ចូលទៅក្នុងការពិនិត្យ "បុរេវាយតម្លៃ/បុរេដាក់ពាក្យសុំ" នៃឯកសារដែលត្រូវបានដាក់ជូន។ ប៉ុន្តែមិនត្រូវបានគ្រប់ដណ្តប់ដោយនីតិវិធីដាក់ពាក្យចុះបញ្ជីផ្លូវការនិងអ្វីមួយដែលត្រូវការបញ្ជាក់ច្បាស់លាស់។

## ក្របខ័ណ្ឌលក្ខខណ្ឌតម្រូវសម្រាប់ការបង្កើត

**(ក) តើអ្នកណាដែលត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីបម្រើជាស្ថាបនិកអង្គការសង្គមស៊ីវិល?**

ច្បាប់ស្តីពីសមាគម និងអង្គការ ឆ្នាំ២០១៥ (មាត្រា៦) ចែងថា៖

- ជនជាតិណាម្នាក់អាចដាក់ពាក្យសុំបង្កើតអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមមួយ ខណៈដែលមានតែជនជាតិខ្មែរ (ពលរដ្ឋ) ប៉ុណ្ណោះអាចបង្កើតអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ដោយសិទ្ធិត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ (មាត្រា ៤២) តាមរយៈសិទ្ធិនេះត្រូវបានកំណត់ក្នុងច្បាប់។
- មិនមានឧបសគ្គ(ដែលត្រូវបានរាយការណ៍) ផ្សេងទៀតរារាំងដល់ការចុះបញ្ជីជាស្ថាបនិក/នាយកឡើយ

**(ខ) ចំនួនបុគ្គលអប្បបរមាដែលតម្រូវឲ្យមានដើម្បីបង្កើតអង្គការសង្គមស៊ីវិលមួយ?**

- សម្រាប់<u>សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក</u>យ៉ាងហោចណាស់តម្រូវឲ្យមាន<u>សមាជិកស្ថាបនិកចំនួនបីនាក់ ដែលមានអាយុលើសពី ១៨ឆ្នាំ</u>។ វាមានការខុសគ្នាបន្តិចដោយសារសមាគមក្នុងស្រុក ជនជាតិរបស់ស្ថាបនិកមិនត្រូវបានពិចារណាឡើយ ខណៈដែលអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាជិកស្ថាបនិកត្រូវតែជាជនជាតិខ្មែរ។
- សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងចង់ធ្វើការងារក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ (MoFAIC) ដែលពាក្យសុំបែបនេះត្រូវតែអមមកជាមួយដោយលិខិតមកពីប្រធានអង្គការ និងលិខិតចុះបញ្ជីអន្តរជាតិរបស់ខ្លួន។

**(គ) លក្ខខណ្ឌតម្រូវរបស់សមាជិកភាព?**

- លក្ខន្តិកៈរបស់សមាគម អាចកំណត់លក្ខខណ្ឌតម្រូវបន្ថែមទៀត ប៉ុន្តែមិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ឡើយ ខណៈដែលសមាគមត្រូវបានកំណត់ថាជា (មាត្រា ៤) អង្គការសមាជិកភាពដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជាដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងគោលបំណងតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណែក ឬមិនយកកម្រៃមកចែកគ្នា។

➢ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវបានពិពណ៌នា (មាត្រា ៥) "អង្គការមិនមែនសមាជិកភាព រួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើន ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា"។

**(ឃ) នីតិវិធីដែលត្រូវឲ្យចុះបញ្ជី/បង្កើតអង្គការសង្គមស៊ីវិលមួយ?**

➢ មាត្រា៦ នៃច្បាប់ (LANGO) ចែងថា សមាគមនិង/ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងត្រូវដាក់ជូនសំណុំលិខិតជាច្រើន (សូមមើលឧបសម្ព័ន្ធ ១.១)។

- ថ្មីៗនេះក្នុងឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានចេញផ្សាយប្រកាសក្រសួងដែលមាន ៧ជំពូក និង ១៣មាត្រា លេខ ២១៩៣ (ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨) "ស្តីពីការណែនាំអំពីការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា" ដែលមានលក្ខខណ្ឌតម្រូវប្រហាក់ប្រហែលគ្នាទៅនឹងមាត្រា ៦ នៃច្បាប់ (LANGO)។ បើទោះជាមើលទៅទំនងជាខុសគ្នាបន្តិចបន្តួចនៅក្នុង (ការបកស្រាយ) ឯកសារដែលត្រូវាដាក់ជូនក្តី(សូមមើលឧសម្ព័ន្ធ១.១។

➢ ឯកសារមួយក្នុងចំណោមឯកសារនានាដែលតម្រូវឲ្យដាក់ជូន គឺ "លក្ខន្តិកៈរបស់សមាគម/អង្គការ ដែល "ត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន" និងគ្របដណ្តប់លើចំណុចចំនួនប្រាំបី (សូមមើលឧសម្ព័ន្ធ ១.១) រួមទាំងគោលដៅ និងគោលបំណងរបស់អង្គការ។ លក្ខខណ្ឌតម្រូវដែលនៅសេសសល់ គឺជាលក្ខខណ្ឌរដ្ឋបាល និងស្ថាប័ន ទាក់ទងនឹងការដាក់ឈ្មោះរបស់អង្គការ និងរូបសញ្ញារបស់អង្គការ។ល។ នីតិវិធីសម្រាប់ការជ្រើសរើស និងការផ្លាស់ប្តូរក្រុមប្រឹក្សាភិបាល ការផ្លាស់ប្តូរលក្ខន្តិកៈ ប្រភពនិងការគ្រប់គ្រងធនធាន ការរំលាយ និងការលក់ទ្រព្យសកម្មរបស់សមាគម។

**មាត្រា៨នៃច្បាប់ (LANGO) គ្របដណ្តប់លើដំណើរការចុះបញ្ជីសមាគម/អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**

➢ ដំណើរការធ្វើសេចក្តីសម្រេចចិត្តលើពាក្យសុំ ត្រូវចំណាយពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើពាក្យសុំនេះបញ្ចប់ការដាក់ពាក្យបឋម។

- ប្រសិនបើមានការតម្រូវឲ្យមានឯកសារ ឬការបញ្ជាក់បន្ថែម ឯកសារឬការបញ្ជាក់បន្ថែមទាំងនេះចាំបាច់ត្រូវដាក់ជូនក្នុងរយៈពេល ៤៥ថ្ងៃបន្ថែមទៀត ហើយប្រសិនបើគ្រប់គ្រាន់ ក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីសម្រេចចិត្តក្នុងរយៈពេល ១៥ថ្ងៃបន្ថែមទៀត បន្ទាប់ពីដាក់ជូនព័ត៌មានបន្ថែម។

  ➢ ប្រសិនបើក្រសួងមហាផ្ទៃមិនប្រាប់ពីសេចក្តីសម្រេចចិត្ត ឬការស្នើសុំព័ត៌មានបន្ថែមនៅក្នុងអំឡុងពេល ៤៥ថ្ងៃដែលមានចែង នៅពេលនោះសមាគម/អង្គការមិនមែនរដ្ឋាភិបាល

ក្នុងស្រុក "ត្រូវចាត់ទុកថាបានទទួលការចុះបញ្ជី" ស្របតាមច្បាប់ (LANGO) ហើយក្រសួងមហាផ្ទៃត្រូវរៀបចំ និងផ្តល់អាជ្ញាប័ណ្ណដែលតម្រូវឲ្យមាន។

**មាត្រា១២-១៧៖ ការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស**

- ការចុះបញ្ជីស្ថិតក្រោមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងត្រូវបានគ្របដណ្តប់អនុស្សរណៈនៃការយោគយល់ (MoU) មួយរវាងសមាគម/អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ មាត្រា ១៣ មានចែងអំពីឯកសារប្រាំមួយប្រភេទ ដែលតម្រូវឲ្យមាន ដើម្បីគាំទ្រដល់ការដាក់ពាក្យសុំទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (សូមមើលឧសម្ព័ន្ធ ១.១)។
  - ការសម្រេចចិត្តអំពីការចុះបញ្ជីដំណើរការដាក់ពាក្យសុំទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ។
  - សមាមគ/អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវសម្រេចបានកិច្ចព្រមព្រៀងជាមួយ "អាជ្ញាធរសាធារណៈ" (មិនត្រូវបានកំណត់) មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈនៃការយោគយល់។
- ផ្ទុយពីសមាគម/អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាគម/អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវចុះអនុស្សរណៈនៃការយោគយល់ជាថ្មីរៀងរាល់បីឆ្នាំម្តង យោងទៅតាមច្បាប់ (LANGO) ដោយដាក់ពាក្យសុំចុះអនុស្សរណៈជាថ្មីយ៉ាងហោចណាស់ ៩០ថ្ងៃមុនពេលកាលបរិច្ឆេទកំណត់។

សម្រាប់សមាគម/អង្គការមិនមែនរដ្ឋាភិបាល ដែលកន្លងមកបានដាក់ឯកសារទៅកាន់ក្រសួងមហាផ្ទៃមុនពេលមានការអនុម័តច្បាប់ LANGO នៅឆ្នាំ២០១៥

- មាត្រា ៣៧ ចែងថា "បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃ ត្រូវចាត់ទុកថាបានចុះបញ្ជី និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ"។

សម្រាប់សមាគម/អង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់

- មាត្រា ៣៨ ចែងថា បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគមឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ (ដែលមានស្រាប់) ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- ទាំងសមាគម/អង្គការមិនមែនរដ្ឋាភិបាលជាតិ (មាត្រា ១០) និងបរទេស (មាត្រា ១៧) ត្រូវផ្តល់ព័ត៌មានលម្អិត (លេខ ហត្ថលេខី និងទីតាំងរបស់ធនាគារ) របស់គណនីធនាគាររបស់អង្គការនៅកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីពេលចុះបញ្ជីទៅកាន់ក្រសួងសាមី (ក្រសួងមហាផ្ទៃ/ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
    - មាត្រាដូចគ្នានេះក៏តម្រូវឲ្យសមាគម/អង្គការមិនមែនរដ្ឋាភិបាលជាតិ និងបរទេស ផ្តល់ព័ត៌មាន និងច្បាប់ចម្លងឯកសារផ្លាស់ប្តូរទៅកាន់ក្រសួងសាមីអំពីការផ្លាស់ប្តូរៈ
        - ទីតាំងការិយាល័យចុះបញ្ជី
        - ការផ្លាស់ប្តូរហត្ថលេខីដែលទទួលបានសិទ្ធិអំនាចនិងអ្នកកាន់មុខតំណែងនានា
        - ការផ្លាស់ប្តូរលក្ខន្តិកៈ (សម្រាប់សមាគម/អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)

**(ង) មូលដ្ឋានជាក់លាក់សម្រាប់ការច្រានចោលពាក្យសុំចុះបញ្ជី/បង្កើតអង្គការសង្គមស៊ីវិល?**

- សមាគម/អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចត្រូវបានបដិសេធចុះបញ្ជី (មាត្រា ៨) ប្រសិនបើក្រសួងមហាផ្ទៃជឿថា "បានរកឃើញថា [សមាគម/អង្គការមិនមែនរដ្ឋាភិបាលនោះ] មានគោលបំណង និងទិសដៅ ដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិខុសជាតិ ឯកភាពជាតិ វប្បធម៌ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"។

**(ច) ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចចិត្តចុះបញ្ជី?**

- សេចក្តីសម្រេច "ដែលក្រសួងមហាផ្ទៃបដិសេធចំពោះសំណើសុំចុះបញ្ជីមានសិទ្ធិប្តឹងទៅតុលាការ"។

**(ឆ) ឯកសារដែលតម្រូវឲ្យមានសម្រាប់ការបង្កើត/ចុះបញ្ជីរបស់អង្គការសង្គមស៊ីវិល?**

- សូមមើលឧបសម្ព័ន្ធ១.១

**(ជ) លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីអង្គការសង្គមស៊ីវិលជាថ្មី?**

- ការចុះបញ្ជីក្រោមច្បាប់ LANGO គឺ ជាលក្ខខណ្ឌតម្រូវតែមួយលើក។
- ទោះជាយ៉ាងណា ដូចដែលបានលើកឡើងកន្លងមក សមាគម/អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានចុះបញ្ជីដែលជូនដំណឹងអំពីការផ្លាស់ប្តូរ ត្រូវបានស្នើសុំ/តម្រូវឲ្យចុះបញ្ជីឡើងវិញដោយប្រើប្រាស់លក្ខខណ្ឌតម្រូវរបស់ច្បាប់ LANGO។
- មានលក្ខខណ្ឌតម្រូវឲ្យរាយការណ៍ប្រចាំឆ្នាំ។

- មាត្រា ២៥ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្ដល់របាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។
- សមាគម/អង្គការមិនមែនរដ្ឋាភិបាលក៏ត្រូវបានតម្រូវឲ្យដាក់ជូនច្បាប់ចម្លងពីច្បាប់ដើមនៃរបាយការណ៍នានា និងរបាយការណ៍ហិរញ្ញវត្ថុដែលផ្ញើជូនទៅកាន់ម្ចាស់ជំនួយក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីរបាយការណ៍ទាំងនេះត្រូវបានដាក់ជូនម្ចាស់ជំនួយ ហើយឯកសារដែលពាក់ព័ន្ធចាំបាច់ត្រូវរក្សាទុករយៈពេលប្រាំឆ្នាំ។
- សម្រាប់អង្គការមិនមែនរដ្ឋាភិបាលបរទេស
- ត្រូវបានតម្រូវឲ្យដាក់ជូនច្បាប់ចម្លងពីច្បាប់ដើមនៃរបាយការណ៍បូកសរុបសកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលផ្ញើទៅម្ចាស់ជំនួយ ទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីផ្ញើទៅម្ចាស់ជំនួយ។
- ច្បាប់ចម្លងពីច្បាប់ដើមនៃឯកសារគម្រោងដែលបានព្រមព្រៀង និងកិច្ចព្រមព្រៀងហិរញ្ញវត្ថុជាមួយម្ចាស់ជំនួយ ត្រូវដាក់ជូនទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។

**(ឈ) ការចំណាយលើការចុះបញ្ជីអង្គការសង្គមស៊ីវិល?**

មិនមានកម្រៃសេវាផ្លូវការត្រូវបានរាយការណ៍ក្នុងច្បាប់ LANGO ឡើយ បើទោះជាភាគីពាក់ព័ន្ធដែលត្រូវបានពិគ្រោះយោបល់បានអះអាងថា កំណត់សម្គាល់អំពីសេវាផ្លូវការនៅក្រសួងមហាផ្ទៃបង្ហាញថា កម្រៃសេវាគឺ ៣០០.០០០ រៀល (ប្រហែល ៧៥ដុល្លារ) ក្ដី។ ទោះជាយ៉ាងណាក៏មានការលើកឡើងដោយអង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ផងដែរថា ការស្នើសុំការចំណាយក្រៅផ្លូវការដើម្បីបង្កើនល្បឿនដំណើរការ ឬដើម្បីធ្វើការផ្លាស់ប្ដូរ និងបំពេញបញ្ចប់ឯកសារផ្ទៃក្នុង (ក្រសួងមហាផ្ទៃ) គឺជាបញ្ហាដែលកើតមានឡើង។

**(ញ) តើជាធម្មតាដំណើរការនេះចំណាយពេលយូរប៉ុណ្ណា?**

មិនមានព័ត៌មានស៊ីជម្រៅច្បាស់លាស់ ដែលអាចទទួលបានអំពីរយៈពេលនោះទេ បើទោះជារយៈពេលពីប្រាំមួយខែទៅមួយឆ្នាំដើម្បីបញ្ចប់ដំណើរការនេះហាក់ដូចជាករណីដែលត្រូវបានលើកឡើងដោយអង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ក៏ដោយ។ អង្គការសង្គមស៊ីវិលទាំងនេះបានលើកឡើងថា ការណ៍នេះគឺដោយសារតែសំណើសម្របសម្រួល ដើម្បីកែប្រែពាក្យពេជន៍ និងផ្លាស់ប្ដូរឯកសារដែលបានដាក់ជូន គ្មានដំណើរការផ្លូវការ និងខ្វះការប្រកាន់ខ្ជាប់ទៅនឹងពេលវេលាដែលមានចែងក្នុងច្បាប់ LANGO។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងប្រទេសកម្ពុជាបានដាក់ជូនការវិភាគអំពីសិទ្ធិមនុស្សលម្អិតមួយលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥)[57]សម្រាប់ការពិនិត្យមើលឡើងវិញ បន្ទាប់ពីច្បាប់នេះត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាក្នុងខែកក្កដា ឆ្នាំ២០១៥?។ ការណ៍នេះបានបង្ហាញពីការពិនិត្យមើលឡើងវិញ ដែលអាចកើតមានទៅលើមាត្រាស្ទើរតែទាំងអស់នៃច្បាប់នេះ ដើម្បីបន្សុីឲ្យកាន់តែប្រសើរជាមួយនឹងស្តង់សារច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ការវិភាគនេះបានលើកឡើងពីក្តីបារម្ភលើការប្រកាន់ខ្ជាប់របស់ច្បាប់LANGO ទៅនឹងរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងការប្តេជ្ញាចិត្តជាអន្តរជាតិទៅនឹងអនុសញ្ញាសិទ្ធិមនុស្សមួយចំនួន (រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។

- ទីមួយ បានលើកឡើងអំពីហានិភ័យនៃការបកស្រាយដែលអាចកើតមានជាច្រើនស្ថិតក្រោមសេចក្តីព្រាងច្បាប់នេះ ដែលធ្វើចរាចរណ៍នៅពេលនោះ (ក្នុងឆ្នាំ២០១១) ពោលគឺជាចំណុចមួយដែលភាគច្រើននៅតែមានសុពលភាពទាក់ទងទៅនឹង (ច្បាប់ដែលត្រូវបានអនុ ម័ត) នាពេលបច្ចុប្បន្ន។
- ទីពីរ (OHCHR) បានបង្ហាញក្តីបារម្ភអំពីដំណើរការចុះបញ្ជី ខណៈដែល "យន្តការសិទ្ធិមនុស្សអន្តរជាតិមើលឃើញថា សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិឯកជនរបស់អង្គការសង្គមស៊ីវិលត្រូវបានការពារប្រសើរជាងនេះតាមរយៈប្រព័ន្ធជូនដំណឹងស្ម័គ្រចិត្ត"។
- ទីបី បានកត់សម្គាល់ថា "ភាពស្មុគស្មាញជំពាក់ជំពិនជាច្រើននៃច្បាប់ សម្រាប់បរិយាកាសសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា នឹងគាំទ្រ (និងទទួលផលប្រយោជន៍ពី) ការប្រឹក្សាយោបល់ និងការពិភាក្សាស៊ីជម្រៅកាន់តែខ្លាំង" ដែលជាបញ្ហាមួយនៃក្តីបារម្ភអំពីច្បាប់សមាគម និងអង្គការដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធជាច្រើនដែលត្រូវបានពិគ្រោះយោបល់។

អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានពិគ្រោះយោបល់ ដែលបានអនុវត្តការចុះបញ្ជី ឬចុះបញ្ជីឡើងវិញនៅចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ បានទទួលស្គាល់ថា លក្ខន្តិកៈអង្គការរបស់ខ្លួនបានទទួលរងឥទ្ធិពល និងត្រូវបានផ្លាស់ប្តូរ ("ដែលត្រូវបានស្នើ" និង "ត្រូវបានទាមទារ") ដោយមន្ត្រីដែលទទួលបន្ទុកការិយាល័យចុះបញ្ជីរបស់ក្រសួងមហាផ្ទៃ ដើម្បីបន្សុីទៅនឹងទម្រង់លក្ខន្តិកៈរបស់ក្រសួងមហាផ្ទៃ និងការកែប្រែអត្ថបទ ដែលត្រូវបានតម្រូវដោយក្រសួងមហាផ្ទៃ រួមទាំងការបញ្ចូលអនុប្រយោគ/សេចក្តីថ្លែងនានាដូចជា៖

- ...(ឈ្មោះ) អង្គការគឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ មិនប្រកាន់បក្ខពួក មិនប្រកាន់សាសនា មិនមែននយោបាយ មិនធ្វើនយោបាយ មិនផ្តល់សម្ភារ ឬថវិកាសម្រាប់នយោបាយណាមួយ និងមិនគាំទ្រគណបក្សនយោបាយ ឬបេក្ខភាពនយោបាយ...

[57] OHCHR, PHNOM PENH (11 August 2015), finalized and shared with the Constitutional Council its human rights analysis of the Law on Associations and NGOs, which hold profound implications for the ability of persons to exercise through associations and NGO's their internationally and constitutionally recognized rights to freedom of expression and association. The report is available at: https://cambodia.ohchr.org/en/news/ohchr-issues-its-analysis-lango (accessed on 16th July 2019)

- (តម្រូវឲ្យរៀបចំ) សមាជ ឬមហាសន្និបាតប្រចាំឆ្នាំ មិនថាតូច ឬធំ មិនថាជាអង្គការសមាជិកភាពឬមិនមែនជាអង្គការសមាជិកភាព។ អង្គការត្រូវធ្វើឲ្យសមាជ/មហាសន្និបាទ ក្លាយជាស្ថាប័នធ្វើសេចក្តីសម្រេចចិត្តកំពូលនៅក្នុងរចនាសម្ព័ន្ធរបស់អង្គការ។
- រាល់សេចក្តីសម្រេច ឬការសម្រេចចិត្តទាំងអស់ដោយសមាជ ឬមហាសន្និបាត មានភាពជំពាក់ជំពិនផ្នែកច្បាប់ដែលកើតមាននៅតាមក្រោយ។
- ទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់បន្ទាប់ពីសងបំណុលស្របច្បាប់របស់អង្គការរួចត្រូវផ្ទេរទៅ.......(ប៉ុន្តែត្រូវរួមបញ្ចូល) កាកបាតក្រហមកម្ពុជា ឬ........

## បទពិសោធចុះបញ្ជីអង្គការសង្គមស៊ីវិល

អ្នកតំណាងរបស់អង្គការសង្គមស៊ីវិលមួយចំនួនបានសង្កេតឃើញថា បើទោះជាច្បាប់ចែងអំពីការដាក់ពាក្យថាត្រូវចំណាយពេល ៤៥ ថ្ងៃក៏ដោយ ក៏ការដាក់ពាក្យភាគច្រើនចំណាយពេលយូរជាងនេះ និងថា ពេលវេលាវាយការណ៍ទំនងជាសម្រាប់ការអនុម័តការដាក់ពាក្យសុំដោយមន្ត្រីថ្នាក់លើនៅក្រសួងមហាផ្ទៃ។

អ្វីដែលកើតឡើងពិតប្រាកដគឺថា ការងារឯកសារដាក់ពាក្យសុំ ស្ថិតក្នុងដំណើរការបុរេដាក់ពាក្យសុំមិនផ្លូវការ។

នេះគឺជាសំណើ/ការទាមទារផ្លូវការដែលអង្គការមិនមែនរដ្ឋាភិបាល ដាក់ពាក្យសុំ បន្ទឹលក្ខន្តិកៈ និងឯកសារផ្សេងទៀតរបស់ខ្លួនទៅនឹងទម្រង់ដែលកំណត់ជាមុនផ្លូវការ ហើយប្រសិនបើអង្គការមួយចង់ឲ្យឯកសារការងាររបស់ខ្លួនទទួលបានការអនុម័ត អង្គការនោះត្រូវតែអនុលោមតាម។ ដំណើរការក្រៅផ្លូវការពិសេសយ៉ាងច្បាស់ក្រឡែតនេះ គឺជាបញ្ហានៃក្តីបារម្ភមួយសម្រាប់អង្គការមួយចំនួន។

## ទស្សនៈផ្លូវការពីដំណើរការចុះបញ្ជីអង្គការសង្គមស៊ីវិល




បទសម្ភាសជាមួយមន្ត្រីរបស់រដ្ឋាភិបាលអំពីបញ្ហានេះ បានបង្ហាញថា មន្ត្រីរដ្ឋាភិបាលមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បានទទួលស្គាល់ "តម្រូវការត្រូវសម្របសម្រួលការបន្ស៊ី និងការសម្របសម្រួលកិច្ចប្រឹងប្រែងនានា ដើម្បីឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការឈានទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍របស់ប្រទេស ព្រមទាំងការបន្ស៊ីជាមួយនឹងច្បាប់ LANGO និងបទប្បញ្ញត្តិនានារបស់កម្ពុជា"។

## ការវិភាគអំពីការបង្កើតអង្គការសង្គមស៊ីវិល

យោបល់ត្រលប់ភាគច្រើនរបស់អង្គការសង្គមស៊ីវិល ប្រាប់ពីរឿងរ៉ាវនៃដំណើរការដ៏លំបាកមួយដែលបណ្តាលមកពីកម្សោយនៃការសម្របសម្រួល និងការយល់ដឹង។ អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ ក៏បានសង្កត់ធ្ងន់ផងដែរថា បញ្ហាប្រឈមធំជាមួយនឹងការចុះបញ្ជីមានការពាក់ព័ន្ធទៅនឹងដំណើរការស្មុគស្មាញ។ "សម្រាប់អង្គការសង្គមស៊ីវិលក្នុងខេត្ត វាចំណាយពេលវេលា និងលុយកាសច្រើន"។ អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត បានលើកឡើងពីបញ្ហានេះ ការចុះបញ្ជីធ្វើឡើងនៅតែទីក្រុងភ្នំពេញដែលតម្រូវឲ្យពួកគេធ្វើដំណើរការជាច្រើនដង ដើម្បីទទួលបានទម្រង់សមស្របសម្រាប់ការដាក់ពាក្យសុំ ដើម្បីចុះបញ្ជីអង្គការ។ ក្រោយមកត្រូវតាមដាន និងផ្លាស់ប្តូរឯកសារ ដើម្បីឆ្លើយតបទៅតាមការទាមទារដែលស្នើឡើង ដែលចំណាយធនធានហិរញ្ញវត្ថុដែលមានកម្រិត។ យោបល់ត្រលប់ពីអង្គការសង្គមស៊ីវិល ដែលចូលរួមក្នុងការសិក្សានេះមានភាពច្បាស់លាស់អំពីដំណើរការដាក់ពាក្យសុំដែលថាមានការលំបាក។

ទាក់ទងនឹងសមាគម ឬអង្គការបរទេស ដំណើរការច្បាប់ LANGO ត្រូវបានបញ្ជាក់ថាមានប្រហាក់ប្រហែលទៅនឹងមុនដំណើរការដែលមានក្នុងច្បាប់ LANGO។ អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) និងបន្តអនុស្សរណៈនៃការយោគយល់របស់ខ្លួនជាមួយរដ្ឋាភិបាលរៀងរាល់បីឆ្នាំម្តង។

ទោះជាយ៉ាងណា យោងតាមក្រុមប្រឹក្សាភិបាលរបស់អង្គការសង្គមស៊ីវិលបរទេសមួយចំនួន លក្ខណ្ឌនៃកាចុះអនុស្សរណៈនៃការយោគយល់របស់ក្រសួងការបរទេស ត្រូវបានកែសម្រួល ហើយខចែងខាងក្រោមត្រូវបានបន្ថែម "ការងាររបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវមានភាពស្របគ្នាជាមួយយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាលកម្ពុជា"។ អង្គការទាំងនេះក៏បានលើកឡើងផងដែរថា ការពិនិត្យមើល និងវាយតម្លៃឯកសារដែលបានដាក់ជូន (ទៅកាន់ក្រសួងការបទេស) សម្រាប់ការចុះបញ្ជីបច្ចុប្បន្នមានភាពលម្អិតខ្លាំង។ ក៏ទំនងជាមានបញ្ហាមួយចំនួនផងដែរសម្រាប់អង្គការបរទេស ដែលផ្តោតការងារជាសំខាន់ផ្នែកជំនឿ និងសម្រាប់អង្គការដែលមិនកំពុងធ្វើការងារដោយផ្ទាល់ជាមួយប្រជាជនកម្ពុជា (ដូចជា អង្គការដែលធ្វើការងារតាមរយៈការផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់អង្គការសង្គមស៊ីវិលកម្ពុជា)។

ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលមានបទពិសោធន៍ម្នាក់បានចាត់ទុកថា *"ការចុះបញ្ជីនៅតែមានភាពស្មុគស្មាញជាមួយនឹងលក្ខខណ្ឌតម្រូវឯកសារដែលមានការរឹតបន្តឹង (ដូចជា អាសយដ្ឋានការិយាល័យ ត្រូវតែទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន ផែនទីរបស់ទីតាំងការិយាល័យ និងរចនាសម្ព័ន្ធបុគ្គលិក ដែលត្រូវតែផ្តល់ជូន) ព្រមទាំងមានការចំណាយក្រៅផ្លូវការសម្រាប់មន្ត្រី សម្រួលការងារនេះ។ ចំណុចសំខាន់បំផុតនោះគឺថា មន្ត្រីដែលទទួលខុសត្រូវលើការចុះបញ្ជី ចម្លងនិងដាក់ចូលវិញ (Copy and Paste) នូវមាត្រាមួយចំនួនទៅក្នុងបទបញ្ញាផ្ទៃក្នុង/លក្ខន្តិកៈរបស់អង្គការមិនមែនរដ្ឋា*

*ភិបាលដែលកំពុងចុះបញ្ជី។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលដែលត្រូវបានចុះបញ្ជី ត្រូវរាយការណ៍ជាផ្លូវការនូវស្ថានភាពរបស់អង្គការរបស់ពួកគេជាប្រចាំឆ្នាំ រួមទាំងការផ្លាស់ប្តូរនាយកប្រតិបត្តិ សមាជិកក្រុមប្រឹក្សាភិបាល និងមុខតំណែងបុគ្គលិកជាន់ខ្ពស់ ឈ្មោះអង្គការ អាសយដ្ឋាន និងបទប្បញ្ញត្តិ ទៅកាន់ក្រសួងមហាផ្ទៃ។*

*លើសពីនេះទៀត អង្គការទាំងនោះបានកត់សម្គាល់ថា ដំណើរការចុះបញ្ជីមានការលំបាកកាន់តែខ្លាំងសម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលតូចៗ ដែលមានមូលដ្ឋាននៅតាមខេត្ត ដោយសារអង្គការទាំងនោះត្រូវធ្វើដំណើរមកកាន់រាជធានី ដើម្បីចុះបញ្ជី និងដើម្បីបំពេញការចុះបញ្ជី យ៉ាងហោចណាស់ពី ៣ ទៅ ៥ ដងសម្រាប់ជួបជាមួយមន្ត្រីដែលទទួលបន្ទុកការចុះបញ្ជី ដើម្បីផ្តល់ការគាំទ្រ"។*

ច្បាប់ LANGO ត្រឹមតែបែងចែងអង្គការសង្គមស៊ីវិលថា ជាអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ខណៈដែលក្របខ័ណ្ឌច្បាប់ខ្វះការកំណត់និយមន័យច្បាស់លាស់។ ក្រសួងមហាផ្ទៃចាត់ទុកអង្គការសង្គមស៊ីវិលដែលបម្រើការងារដល់សង្គមថាជាអង្គការមិនមែនរដ្ឋាភិបាល ហើយអង្គការសង្គមស៊ីវិល ដែលបម្រើការងារដល់តែសមាជិករបស់ខ្លួនថាជាសមាគម។ អង្គការសហគមន៍ជាច្រើន និងប្រហែលជាភាគច្រើនប្រតិបត្តិការដោយមានការចុះបញ្ជីផ្លូវការ[58] បើទោះជាការណ៍នេះមិនត្រូវបានតម្រូវដោយច្បាប់ក្តី។ ទោះជាយ៉ាងណា ដោយសារអង្គការមិនទាន់ចុះបញ្ជីមិនត្រូវបានទទួលស្គាល់ថាជាអង្គភាពស្របច្បាប់ អង្គការទាំងនោះប្រឈមនឹងការដាក់កម្រិតមួយចំនួន។ ឧទាហរណ៍ អង្គការទាំងនោះមិនអាចធ្វើកិច្ចសន្យានានាបាន។

វិញ្ញាបនបត្រចុះបញ្ជី (លិខិត) ត្រូវបានគេមើលឃើញថាជាអ្វីមួយដែលវិជ្ជមាន ដោយសារវាបញ្ជាក់សិទ្ធិរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលមានវត្តមាន និងភស្តុតាងបញ្ជាក់។ បញ្ហាគឺថា ដំណើរការចុះបញ្ជីមានការលំបាកខ្លាំង និងទាមទារឲ្យមានកិច្ចប្រឹងប្រែងដោយសារកំហុសត្រូវបានបង្កើតឡើង ហើយជាចុងក្រោយ ខ្ជះខ្ជាយទាំងលុយ និងពេលវេលា។

## ការបង្កើតដោយរដ្ឋាភិបាលនូវវេទិកាសម្ព័ន្ធសង្គមស៊ីវិល (CSAF) ក្នុងឆ្នាំ២០១៦ និងគណៈកម្មាធិការអន្តរក្រសួង ដើម្បីជានាបាននូវការអនុវត្តច្បាប់ LANGO ក្នុងឆ្នាំ២០១៨។

ក្នុងខែមិថុនា ឆ្នាំ២០១៦ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី (CoM) រដ្ឋាភិបាលបានបង្កើត**វេទិកាសម្ព័ន្ធសង្គមស៊ីវិល (អនុក្រឹត្យលេខ ១២៨)**។ មានការរាយការណ៍ថា **គោលបំណងរបស់ស្ថា ប័ននេះ គឺ "ដើម្បីគាំទ្រកិច្ចអភិវឌ្ឍន៍ប្រទេសតាមរយៈអង្គការសង្គមស៊ីវិល ស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិកម្ពុជា។** គោលបំណងរបស់វេទិកានេះ គឺដើម្បី "ជំរុញកិច្ចសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល សមាគម សហគមន៍ និងសហជីព ជាមួយរដ្ឋាភិបាល (និងដើម្បី) សម្របសម្រួលការងារ

58 CBOs are (rightly) currently outside the scope of LANGO. Though a number of those involved with natural resources issues (fisheries and forestry groups) or irrigation are required to seek recognition by the responsible ministries.

របស់ពួកគាត់ ជាមួយអាជ្ញាធរដែនដី លើកទឹកចិត្ត និងជំរុញការបង្កើនកិច្ចសហការ និងការចែករំលែកបទពិសោធរវាងស្ថាប័នទាំងអស់ នៅក្នុងវិស័យសង្គមស៊ីវិល ដើម្បីឈានទៅសម្រេចបាននូវការអភិវឌ្ឍកម្ពុជាដ៏ឆាប់រហ័ស"[59]។

នៅទីកន្លែងផ្សេងទៀត[60] មានសេចក្តីរាយការណ៍ថា គោលដៅនិងគោលបំណងរបស់វេទិកានេះ "គឺដើម្បីបម្រើជាវេទិកាប្រកបដោយស្ថាបនា សម្រាប់ដោះដូរទស្សនៈ ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបង្កើតសំណើគោលនយោបាយសាធារណៈ ដែលមានភាពរឹងមាំ និងអាចអនុវត្តបាន តាមរយៈការស្រាវជ្រាវបែបវិទ្យាសាស្រ្ត និងការពិភាក្សាស៊ីជម្រៅផ្ទៃក្នុង"។ ភាគីពាក់ព័ន្ធការអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលចាត់ទុកវេទិកានេះថាជាស្ថាប័នរបស់រដ្ឋាភិបាលមួយ ដែលត្រូវបានបង្កើតឡើងដើម្បី "អនុវត្ត" ព្រឹត្តិការណ៍សង្គមស៊ីវិលដោយរួមបញ្ចូលអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ដែលគាំទ្ររដ្ឋាភិបាលផ្សេងៗ។

តួនាទីមួយសម្រាប់វេទិកានេះ គឺដើម្បីជំនួសអង្គការសង្គមស៊ីវិលផ្សេងទៀត ដែលបានធ្វើពហិការក្នុងការផ្តល់អ្នកសង្កេតការណ៍សម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៨។ វេទិកានេះ ត្រូវបានរាយការណ៍ថាបានដាក់ពង្រាយអ្នកសង្កេតការណ៍ជាតិចំនួន ១.០៣៦នាក់ (ពីអង្គការដែលត្រូវបានរាយការណ៍ថាមានចំនួន៩៣) និងអ្នកសង្កេតការណ៍អន្តរជាតិចំនួន ២២០ នាក់ (ពីអង្គការអន្តរជាតិយ៉ាងហោចណាស់ចំនួន ២១) ពីអង្គការជាច្រើន ដើម្បី "បោះត្រា" ដល់ដំណើរការថ្ងៃបោះឆ្នោតនៅខែកក្កដាឆ្នាំ២០១៨[61]។ ការគ្របដណ្តប់របស់ប្រព័ន្ធផ្សព្វផ្សាយលើបណ្តាញទូរទស្សន៍ខ្មែរដែលត្រូវបានពិនិត្យមើល បានបង្ហាញថា "ការពិគ្រោះយោបល់អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត" ដែលត្រូវបានធ្វើជាសហប្រធានមកពីគណរដ្ឋមន្ត្រី បានបង្កើតវេទិកានេះ ដើម្បីផ្តល់វត្តមានយ៉ាងសកម្មក្នុងការចូលរួមរបស់អង្គការសង្គមស៊ីវិល។ ទោះជាយ៉ាណា នឹងទំនងជាមានភស្តុតាងតិចតួចដែលបង្ហាញពីបំណងប្រាថ្នាខ្លាំងដែលត្រូវបានរាយការណ៍សម្រាប់អង្គការនេះទាក់ទង នឹងការចូលរួមគោលនយោបាយនានាដូចជាអ្វីដែលបានលើកឡើងខាងលើ។

ថ្មីៗនេះក្នុងខែធ្នូ ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានបង្កើត[62]គណៈកម្មាធិការអន្តរក្រសួងថ្មីមួយដែលមានសមាជិកចំនួន ៣៣ ដើម្បីធានាបាននូវការអនុវត្តច្បាប់ LANGO និងដើម្បីកំណត់ភារកិច្ចរបស់ក្រសួងនីមួយៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចក្នុងការពិនិត្យមើលកាតព្វកិច្ចពន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយធនាគារជាតិមានភារកិច្ចតាមដានប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គការទាំងនេះ។ គណៈកម្មាធិការនេះត្រូវបានដឹកនាំដោយអ្នកតំណាងបីរូប មកពីក្រសួងមហាផ្ទៃ

---

59 CSAF website-http://csaf.org.kh/en/about-csaf-2
60 https://www.facebook.com/CSAForum/
61 http://m.en.freshnewsasia.com/index.php/en/10442-2018-07-31-08-43-42.html
62 MoI Decision No. 110 SSR, dated 5 December 2017, on Creation of Inter-Ministerial Commission for Managing the Work Activities of Foreign NGO.

(MoI) និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFA/IC)[63] តួនាទី មុខងារ និងសកម្មភាពរបស់គណៈកម្មាធិការនេះនៅតែមិនច្បាស់លាស់។

មានការសង្កេតឃើញថា ក្នុងអំឡុងពេលស្ថិតក្នុងការសិក្សានេះ (ឆ្នាំ២០១៥-២០១៩) អង្គការសិទ្ធិមនុស្ស និងតស៊ូមតិមួយចំនួន និងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនានា បានស្ថិតក្រោមការវាយតម្លៃអនុលោមភាពកាន់តែខ្លាំង និការពិនិត្យមើលដោយទីភ្នាក់ងាររបស់រដ្ឋ (ក្រសួងមហាផ្ទៃ ក្រសួងការបរទេស នាយកដ្ឋានពន្ធដារ នាយដ្ឋានការងារ។ល។) ដែលបានបង្កឲ្យមានការបិទស្ថាប័នមួយចំនួន (វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) កាសែតខេមបូឌាដេលី ព្រមទាំងស្ថានីយវិទ្យុឯករាជ្យចំនួនពី ១៥-១៩ ស្ថានីយ៍[64] ដែលបានចាក់ផ្សាយបន្តជាភាសាខ្មែររបស់វិទ្យុអាស៊ីសេរី វិទ្យុសំឡេងសហរដ្ឋអាមេរិក វិទ្យុសំឡេងប្រជាធិបតេយ្យ) ហើយស្ថាប័នមួយចំនួនក្នុងចំណោមស្ថាប័នទាំងនេះត្រូវបានបិទដោយសារមានការរាយការណ៍ថាមិនបានអនុលោមតាមលក្ខខណ្ឌតម្រូវពន្ធ[65]។

## *ក្របខ័ណ្ឌប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល*

(ក) **តើច្បាប់អ្វីដែលគ្រប់គ្រងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលដោយផ្ទាល់?**

ច្បាប់ LANGO គឺជាឧបករណ៍ច្បាប់ដ៏សំខាន់។ ច្បាប់នេះធ្វើការងារជាចម្បងជាមួយនឹងលក្ខខណ្ឌតម្រូវចុះបញ្ជី និងរាយការណ៍របស់អង្គការសង្គមស៊ីវិល។ ទោះជាយ៉ាងណា បទប្បញ្ញត្តិច្បាប់បន្ថែមនានាត្រូវយកមកពិចារណា ដោយសារមានខចែងនៅក្នុងច្បាប់ស្តីពីពន្ធដារ និងឧបករណ៍នានាដូចជា ប្រកាសលេខ៤៦៤ ស្តីពីពន្ធដារសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ដែលត្រូវបានចេញផ្សាយដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងខែមេសា ឆ្នាំ២០១៨) ច្បាប់ស្តីពីសុខុមាលភាពសង្គម ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ស្តីពីរដ្ឋបាលសាធារណៈ ដែលចាំបាច់ត្រូវយកមកពិចារណាដោយអង្គការសង្គមស៊ីវិលក្នុងប្រតិបត្តិការរបស់ខ្លួន។

(ខ) តើច្បាប់ណាផ្សេងទៀតដែលប៉ះពាល់ ឬជះឥទ្ធិពលដល់ប្រតិបត្តិការអង្គការសង្គមស៊ីវិល?

មានការកើនឡើងនូវច្បាប់ និងអនុក្រឹត្យផ្សេងៗ នាពេលបច្ចុប្បន្ន ដែលត្រូវយកមកពិចារណា ហើយ "ត្រូវតែអនុលោមតាម" ដោយអង្គការសង្គមស៊ីវិល ប៉ុន្តែអនុក្រឹត្យ និងច្បាប់ទាំងនេះមិនកំណត់ត្រឹមច្បាប់ LANGO ច្បាប់ស្តីពីពន្ធដារ ច្បាប់ស្តីពីការងារ និងអនុក្រឹត្យផ្សេងៗទៀតដែលពាក់ព័ន្ធនឹងបេឡាជាតិរបបសន្តិសុខសង្គម (NSSF) ដែលមានឥទ្ធិពលលើប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលក្នុងកម្រិតផ្សេងៗគ្នា។

អង្គការសង្គមស៊ីវិលបច្ចុប្បន្នក៏ចាំបាច់ត្រូវពិចារណាលើច្បាប់ផ្សេងៗទៀតផងដែរ ដូចជា ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលគ្របដណ្តប់លើបញ្ហានានាដែលអាចត្រូវបានជះឥទ្ធិពល

[63] Phnom Penh Post (15/01/2018 New Lango committee formed http://www.phnompenhpost.com/national/new-lango-committee-formed
[64] https://www.phnompenhpost.com/national/no-relaunch-shuttered-radio-stations, https://www.cambodiadaily.com/news/anger-mounts-as-radio-purge-knocks-19-stations-off-air-134077/
[65] https://www.khmertimeskh.com/82702/radio-free-asia-shuts-phnom-penh-office-20-years/

ដោយអង្គការសង្គមស៊ីវិល។ ក្នុងចំណោមក្តីបារម្ភខ្លាំងបំផុត គឺខចែងក្នុងក្រមព្រហ្មទណ្ឌ ពោលគឺជាបទប្បញ្ញត្តិស្តីពី "ការជេរប្រមាថជាសាធារណៈ" (មាត្រា ៣០៧) និង "ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍" (មាត្រា ៤៩៥) ដែលឃ្លាទូលំទូលាយមិនច្បាស់លាស់ទាំងនេះ បច្ចុប្បន្នជាញឹកញាប់ត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹងអ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាជាសកម្មជនប្រឆាំងនឹងរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ បទប្បញ្ញត្តិដែលត្រូវបានដាក់ចូលបន្ថែមនាពេលថ្មីៗនេះ (ខែកុម្ភៈ ឆ្នាំ ២០១៨) គឺបទប្បញ្ញត្តិស្តីពី "ការជេរប្រមាថព្រះមហាក្សត្រ" (មាត្រា ៤៣៧)។ មានឧទាហរណ៍អំពីការរំលោភបំពានបទប្បញ្ញត្តិទាំងនេះដែលត្រូវបានចេញផ្សាយជាច្រើន ដើម្បីរឹតបន្តឹង និង/ឬឃាត់ឃាំងសកម្មភាពរបស់អង្គការសង្គមស៊ីវិល។

**(គ) តើអង្គការសង្គមស៊ីវិលត្រូវបានតម្រូវឲ្យជូនដំណឹងដល់រដ្ឋាភិបាលអំពីសកម្មភាព ឬកិច្ចប្រជុំណាមួយដែរឬទេ?**

ពីខែតុលា ឆ្នាំ២០១៧ ដល់ ខែវិច្ឆិកា ឆ្នាំ២០១៨[66] ក្រសួងមហាផ្ទៃបានចេញសារាចរណ៍ណែនាំមួយដែលតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ជូនដំណឹងដល់ក្រសួងមហាផ្ទៃ ឬអាជ្ញាធរមូលដ្ឋានអំពីបំណងរបស់ខ្លួនក្នុងការអនុវត្តសកម្មភាពយ៉ាងហោចណាស់បីថ្ងៃមុន មុនពេលអនុវត្តសកម្មភាព។ ទោះជាយ៉ាងណា លក្ខខណ្ឌតម្រូវឲ្យជូនដំណឹងនេះ ជាញឹកញាប់ត្រូវបានបកស្រាយខុសដោយអាជ្ញាធរមូលដ្ឋាន ដែលមានន័យថាតម្រូវឲ្យសុំការអនុញ្ញាតជាមុន។

ទោះជាយ៉ាងណា អង្គការមួយចំនួន ដែលត្រូវបានពិគ្រោះយោបល់បានលើកឡើងពីលក្ខខណ្ឌតម្រូវពិសេសដោយអាជ្ញាធរថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត ស្រុក និងឃុំ) ដែលតម្រូវឲ្យពួកគេជូនដំណឹង និងរាយការណ៍អំពីសកម្មភាពនៅពេលវេលាផ្សេងៗ។ លក្ខខណ្ឌតម្រូវទាំងនេះបានកើតមាន ហើយជាញឹកញាប់ទាមទារដោយកន្លែងផ្សេងៗ ទោះបីជាមិនដឹង ស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ណាមួយក៏ដោយ។

**(ឃ) តើអង្គការសង្គមស៊ីវិលត្រូវបានតម្រូវឲ្យដាក់របាយការណ៍បន្តបន្ទាប់ជូនរដ្ឋាភិបាលដែរឬទេ?**

បាទ/ចាស។ ច្បាប់ LANGO (មាត្រា២៥) តម្រូវឲ្យអង្គកាមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដាក់ជូនរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចាំបាច់ត្រូវដាក់ជូនមិនឲ្យហួសពីដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់ ហើយប្រសិនបើអង្គការទាំងនោះទទួលបានមូលនិធិពីបរទេស ត្រូវផ្ញើក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ។ ឯកសាររបាយការណ៍ទាំងនេះត្រូវរក្សាទុកយ៉ាងហោចណាស់ប្រាំឆ្នាំ។

66 Phnom Penh Post 928/11/2018) 'NGOs may operate without restriction' https://www.phnompenhpost.com/national/ngos-may-operate-without-restriction

សម្រាប់សមាគម ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំប្រសិនបើចាំបាច់ (មាត្រា២៥)។

សមាគមបរទេសត្រូវដាក់ជូនរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងអំឡុងពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ។

រដ្ឋបាលថ្នាក់ក្រោមជាតិជាញឹកញាប់តម្រូវឲ្យអង្គការសង្គមស៊ីវិល ដែលប្រតិបត្តិការក្នុងដែនដីរបស់ពួកគេត្រូវផ្តល់របាយការណ៍ជាបន្តបន្ទាប់។

(ង) តើប្រភេទរបាយការណ៍អ្វី ឧ. **របាយការណ៍បូកសរុបសកម្មភាពការងារ ឬរបាយការណ៍ហិរញ្ញវត្ថុ និងផ្តល់ញឹកញាប់ប៉ុណ្ណា?**

សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក របាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានតម្រូវឲ្យដាក់ជូន។

ខណៈដែលអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ដែលផ្ញើទៅកាន់ម្ចាស់ជំនួយ។

អង្គការមិនមែនរដ្ឋាភិបាលបរទេស "ត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារច្បាប់ដើម ដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីផ្ញើទៅម្ចាស់ជំនួយ"។

អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវដាក់ជូន "ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ទៅកាន់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

**(ច) តើអង្គការសង្គមស៊ីវិលជាកម្មវត្ថុចំពោះសវនកម្ម ឬការធ្វើអធិការកិច្ចរបស់រដ្ឋាភិបាលដែរឬទេ?**

មាត្រា ២៥ ចែងថា "ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល"។

**(ឆ) តើលក្ខខណ្ឌតម្រូវរដ្ឋបាលអ្វីដែលជះឥទ្ធិពលដល់ប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាល?**

ក្រៅពីលក្ខខណ្ឌតម្រូវឲ្យរាយការណ៍ មានតែលក្ខខណ្ឌតម្រូវមួយចំនួនប៉ុណ្ណោះ។ នៅខែតុលា ឆ្នាំ២០១៧ រដ្ឋាភិបាលបានដាក់ចេញឧបករណ៍បទប្បញ្ញត្តិមួយ ដោយតម្រូវឲ្យមានការជូនដំណឹងជាមុនមុនពេលអង្គការមិនមែនរដ្ឋាភិបាលធ្វើសកម្មភាពក្នុងសហគមន៍។ ឧបករណ៍/សារាចរណ៍ណែនាំនេះ ត្រូវបានលុបចោលវិញនៅខែវិច្ឆិកា ឆ្នាំ២០១៨។

ទោះជាយ៉ាងណា ការទាមទារតាមតែអំពើចិត្តឲ្យមានការសុំអនុញ្ញាត ដើម្បីប្រតិបត្តិការក្នុងតំបន់នានាទាំងមុន និងបន្ទាប់ពីការបោះឆ្នោតជាតិ កំពុងត្រូវបានរាយការណ៍ដោយអង្គការសង្គមស៊ិវិលថានៅតែកើតមាន។

**(ជ) តើអង្គការសង្គមស៊ីវិលមានកាតព្វកិច្ចត្រូវបន្ស៊ីសកម្មភាពរបស់ពួកគេទៅនឹងអាទិភាពនានារបស់រដ្ឋាភិបាល ដែលមានកំណត់ក្នុងផែនការអភិវឌ្ឍន៍ជាតិដែរឬទេ?**

ច្បាប់ LANGO លើកទឹកចិត្តឲ្យអង្គការមិនមែនរដ្ឋាភិបាល បន្ស៊ីជាមួយនឹងគោលបំណងអភិវឌ្ឍន៍ជាតិ ប៉ុន្តែវាមិនមែនជាកាតព្វកិច្ច ឬជាធរមាននោះទេ។

**(ឈ) តើឈរលើមូលដ្ឋានអ្វី ដែលរដ្ឋាភិបាលត្រូវបានច្បាប់អនុញ្ញាតឲ្យបញ្ចប់ ឬរំលាយអង្គការសង្គមស៊ីវិលមួយ?**

ជំពូកទី៧៖ វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

មាត្រា ៣០ ចែងថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា១០ ឬមាត្រា២៤ ឬកថាខណ្ឌទី១ ឬកថាខណ្ឌទី២ នៃមាត្រា២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្តោះអាសន្នរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី"។

"សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី"។

ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

មាត្រា ៣២៖ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ក្នុងករណីមិនរាងចាល សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយក្រសួងមហាផ្ទៃ។ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពបន្តទៀត អាជ្ញាធរមានសមត្ថកិច្ច ត្រូវប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមច្បាប់ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣៣៖ ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា ២៤ ឬកថាខណ្ឌទី៣ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ។

មាត្រា ៣៤៖ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានាការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណា ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបន្ថែមទាក់ទងនឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណាដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលប្រព្រឹត្តល្មើសខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

មាត្រា ៣៥៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈ ដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា។

មាត្រា ៣៦៖ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

(ញ) តើមានដំណើរការ/នីតិវិធីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចចិត្តបញ្ចប់/រំលាយដែរឬទេ?

បាទ/ចាសមាន។ មាត្រា ៣២៖ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យ ទៅតុលាការក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេច។

## ការវិភាគអំពីប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល

ប្រតិបត្តិការរបស់អង្គកាសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ ត្រូវបានកាត់បន្ថយក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ដោយសារបរិយាកាសនយោបាយ។ ការកាត់បន្ថយនេះអាចមើលឃើញតាមរយៈការរួមផ្សំចូលគ្នានេះ

- **ការធ្លាក់ចុះលំហរពលរដ្ឋដែលមើលឃើញ។** ក្នុងការធ្លាក់ចុះនោះ អង្គការសង្គមស៊ីវិលដំបូងឡើយមានភាពស្ទាក់ស្ទើរក្នុងការប្រឈមមុខ ជាមួយអាជ្ញាធរមូលដ្ឋាន ដោយសារមានការកើនឡើងការបញ្ឈប់ ឬមិនអនុញ្ញាតឲ្យមានសកម្មភាព និងកិច្ចប្រជុំរបស់អង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលភាគច្រើនស្ថិតក្នុងហានិភ័យ ហើយប្រសិនបើបុគ្គលិកត្រូវបានប្រាប់ឲ្យបញ្ឈប់សកម្មភាព ឬមិនអនុញ្ញាតឲ្យបង្កើតសកម្មភាព ជាទូទៅ ពួកគេអនុវត្តតាម។ មូលហេតុដែលអាជ្ញាធរមូលដ្ឋាន (ឃុំនិងនគរបាល) ជាធម្មតា បានបញ្ឈប់ គឺមិនដឹងជាមានបង្អែកលើយុត្តាធិការណាច្បាស់លាស់។ អង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ បានលើកឡើងពីការដែលត្រូវបានសួររកព័ត៌មានបន្ថែម ឬការអនុញ្ញាតឲ្យអនុវត្តសកម្មភាពរបស់ពួកគេ និង/ឬឲ្យសុំការអនុញ្ញាតមុនពេលធ្វើសកម្មភាព (កម្រិតនៃការស្នើសុំទាំងនេះបានកើនឡើងយ៉ាងច្បាស់ក្នុងអំឡុងឆ្នាំ២០១៦/២០១៧)។
- **ការរឹតបន្តឹងផ្នែកស្ថាប័ន។** ក្រសួងមហាផ្ទៃចេញផ្សាយសារាចរណ៍ណែនាំមួយនៅខែតុលា ឆ្នាំ ២០១៧ (ចុះកាលបរិច្ឆេទថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ និងត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ) ដែលតម្រូវឲ្យ "សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងអនុវត្តសកម្មភាពក្នុងដែនដីរបស់ទីក្រុង ឬខេត្តជាក់លាក់មួយ ត្រូវជូនដំណឹងទៅកាន់ក្រសួងមហាផ្ទៃអំពីចរិកលក្ខណៈនៃសកម្មភាព ឬជូនដំណឹងដោយផ្ទាល់ទៅកាន់រដ្ឋបាលក្នុងរយៈពេលបីថ្ងៃមុនពេលសកម្មភាពចាប់ផ្តើម និងដែលចែងថា "ប្រសិនបើមិនមានការជូនដំណឹង ឬប្រសិនបើក្រសួងមហាផ្ទៃ ឬអាជ្ញាធរមូលដ្ឋានជឿថា សកម្មភាពនោះជះឥទ្ធិពលដល់ "សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ" អាជ្ញាធរពាក់ព័ន្ធមានសិទ្ធិអំណាចហាមឃាត់សកម្មភាពនោះ ហើយតម្រូវឲ្យជូនដំណឹងទៅកាន់ក្រសួងមហាផ្ទៃអំពីសកម្មភាពដែលស្នើឡើងភ្លាមៗ។ សារាចរណ៍ណែនាំនេះមិនបានរួមបញ្ចូលនិយមន័យសម្រាប់វាក្យស័ព្ទ "សណ្តាប់ធ្នាប់សាធារណៈ" ឬ "សន្តិសុខជាតិ" ទេ។
  - ការណែនាំរបស់ក្រសួងមានគោលបំណងទីពីរ ដែលចែងថា "រដ្ឋបាលថ្នាក់ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ត្រូវចាត់វិធានការភ្លាម ដើម្បីបិទសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានណាមួយ ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីស្របច្បាប់នៅក្រសួង និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណា ដែលត្រូវបានសម្រេចលុបឈ្មោះចេញពីបញ្ជីរបស់ក្រសួងមហាផ្ទៃ ឬមិនមានសកម្មភាព ហើយនៅតែធ្វើសកម្មភាព។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការផ្លូវច្បាប់ ហើយរាយការណ៍មកកាន់ក្រសួងមហាផ្ទៃ"។

នៅចន្លោះឆ្នាំ២០១៦ដល់ឆ្នាំ២០១៩ ក៏មានព្រឹត្តិការណ៍ដែលត្រូវបានរាយការណ៍មួយចំនួនផងដែរទាក់ទងនឹងអង្គការសង្គមស៊ីវិល ជាពិសេសអង្គការដែលធ្វើការងារលើកកម្ពស់សិទ្ធិមនុស្ស ដែលបានក្លាយជាកម្មវត្ថុចំពោះការបៀតបៀនដោយក្រុមមន្ត្រីរបស់រដ្ឋាភិបាល។ ក៏មានព្រឹត្តិការណ៍ដែលត្រូវបានរាយការណ៍ផងដែរ ជាអាទិ៍ក្រុមមន្ត្រីរបស់រដ្ឋាភិបាលបានបញ្ជាឲ្យអង្គការសង្គមស៊ីវិលបញ្ឈប់សកម្មភាពរបស់ខ្លួន។ ជាពិសសេសក្នុងអំឡុងពេលស្ថិតក្រោមការពិនិត្យមើលច្បាប់ LANGO មានការរាយការណ៍ថា អាជ្ញាធររដ្ឋាភិបាលបានប្រើប្រាស់ ដើម្បីបំបែកកិច្ចប្រជុំ និងការបណ្តុះបណ្តាលដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានសម្ភាសបានបង្ហាញថា អាជ្ញាធរបានអះអាងថា ច្បាប់ LANGO តម្រូវឲ្យអង្គការទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន មុនពេលរៀបចំកិច្ចប្រជុំ ការបណ្តុះបណ្តាល និងព្រឹត្តិការណ៍ផ្សេងៗ។ ទោះជាយ៉ាងណាច្បាប់LANGO មិនមានចែងអំពីការតម្រូវឲ្យចាត់វិធានការបែបនេះណាមួយនោះទេ។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានចេញផ្សាយកំណត់សម្គាល់មួយផ្សេងទៀតទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យបញ្ចប់រាល់លក្ខខណ្ឌតម្រូវដែលចែងថា អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ត្រូវជូនដំណឹងរដ្ឋបាលមូលដ្ឋានអំពីសកម្មភាពរបស់ខ្លួន។ ទោះជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បន្តរាយការណ៍ថា អាជ្ញាធរមូលដ្ឋាននៅតែតម្រូវឲ្យពួកគេជូនដំណឹង និងទទួលបានការអនុញ្ញាតមុនពេលអនុវត្ត/រៀបចំសកម្មភាពនានា។ អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានសម្ភាស បានយល់ឃើញថា លក្ខខណ្ឌតម្រូវឲ្យស្នើសុំ/ជូនដំណឹងអំពីសកម្មភាពរបស់ពួកគេ បានផ្តល់ឲ្យអាជ្ញាធរមូលដ្ឋាននូវវិធានការមួយ ដើម្បីគ្រប់គ្រងប្រតិបត្តិការ/សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលនៅដែនដីរបស់អាជ្ញាធរទាំងនោះ។

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ មិនតម្រូវឲ្យមានការសុំអនុញ្ញាតជាមុន ដើម្បីរៀបចំការធ្វើបាតុកម្មមួយឡើយ ប៉ុន្តែតម្រូវឲ្យជូនដំណឹង។ ទោះជាយ៉ាងណា ក្នុងការអនុវត្ត ការសុំអនុញ្ញាតជាមុន ដើម្បីរៀបចំការប្រមូលផ្តុំមួយ ត្រូវបានតម្រូវ ហើយស្ទើរតែមិនធ្លាប់ទទួលបានការផ្តល់ការអនុញ្ញាតឡើយ។ ការណ៍នេះបង្អាក់ទឹកចិត្តរបស់អ្នកដែលនឹងរៀបចំបាតុកម្ម ដោយភ័យខ្លាចថាពួកគេនឹងត្រូវបានស៊ើបអង្កេតដោយមន្ត្រីរដ្ឋបាលមូលដ្ឋាន ឬសូម្បីតែត្រូវបានចាប់ខ្លួនដោយនគរបាលមូលដ្ឋាន ប្រសិនបើពួកគេបន្តរៀបចំធ្វើ។ ក្នុងឆ្នាំ២០១៤ រដ្ឋាភិបាលបានចាប់ផ្តើមពិនិត្យមើលគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនឹងភាពជាប់គាំងផ្នែកនយោបាយដែលមានទំនាក់ទំនងទៅនឹងគណបក្សប្រឆាំង។ ជាលទ្ធផល ការធ្វើបាតុកម្មត្រូវបានបញ្ឈប់ ជាញឹកញាប់មានអំពើហិង្សា ហើយសកម្មជនមួយចំនួនត្រូវបានចាប់ខ្លួន (CSOSI ឆ្នាំ២០១៤)[67]។

67 CSO Sustainability Index For Asia Report, 2014 (Cambodia, page 10-11).

67 Colin Meyn,' Cambodia's controversial NGO law snares its first victim', 31 August 2017, (accessed on 11 July 2019) available at: https://www.devex.com/news/cambodia-s-controversial-ngo-law-snares-its-first-victim-9094

អង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់យ៉ាងច្រើន បានលើកឡើងថា ដំណើរការនេះមិនដូចគ្នាទេសម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលទាំងឡាយណាដែលប្រតិបត្តិការនៅក្នុងវិស័យកសិកម្ម ការអប់រំ និងសុខាភិបាល និងវិស័យសង្គមផ្សេងទៀត បានរាយការណ៍ពីការជួបបញ្ហាតិចតួច ខណៈដែលអង្គការសង្គមស៊ីវិលដែលធ្វើការងារខាងផ្នែកតស៊ូមតិសម្រាប់ពលរដ្ឋ/សិទ្ធិមនុស្ស និងសិទ្ធិបរិស្ថាន ជាញឹកញាប់យល់ឃើញថា ពួកគេស្ថិតក្នុងជម្លោះដោយគ្រាន់តែដោយសារចរិកលក្ខណៈនៃបេសកកម្មរបស់ពួកគេ។ ក៏មានតម្រូវការផងដែរឲ្យមានការបញ្ជាក់ច្បាស់លាស់អំពីនីតិវិធី ដំណើរការ និងការបកស្រាយអំពីច្បាប់ ដែលត្រូវបានចុះបញ្ជីថាជាតម្រូវការមួយដែលត្រូវបានលើកឡើងដោយអង្គការសង្គមស៊ីវិលភាគច្រើនដែលបានចូលរួមក្នុងការសិក្សានេះ។

*ការគំរាមកំហែងចំពោះអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល*

សម្ពាធរបស់រដ្ឋទៅលើអង្គការសង្គមស៊ីវិលបានកើនឡើងខ្លាំងនៅក្នុងឆ្នាំ២០១៧។ ទាំងអង្គការសង្គមស៊ីវិលបរទេស និងក្នុងស្រុក បានក្លាយជាទិសដៅចំពោះការចោទប្រកាន់ថាមានការពាក់ព័ន្ធទៅនឹងបដិវត្តន៍ពណ៌ (CSOSI ឆ្នាំ២០១៧)។ ច្បាប់ LANGO ដែលចាប់តាំងពីត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ មក បានបង្កការគំរាមកំហែងកាន់តែខ្លាំងឡើងដោយស្ងៀមស្ងាត់។ មុនពេលមានការអនុម័តច្បាប់ LANGO ក្រុមអង្គការសង្គមស៊ីវិលបានព្រមានថា ច្បាប់នេះត្រូវបានបង្កើតឡើងដើម្បីបិទអង្គការទាំងឡាយណាដែលមិនត្រូវនឹងរដ្ឋាភិបាល។ វាគ្រាន់តែជាចម្ងល់មួយប៉ុណ្ណោះ ថាតើបិទនៅពេលណា[68]។ យោងតាមរបាយការណ៍ CSOSI ឆ្នាំ២០១៧ រដ្ឋាភិបាលបានចោទប្រកាន់ថា អង្គកាសង្គមស៊ីវិលដែលត្រូវបានធ្វើទុកបុកម្ទេញទាំងនេះ គឺជាផ្នែកមួយនៃ "បណ្តាញជ្រៀតជ្រែករបស់សហរដ្ឋអាមេរិក" ដោយបានផលិតវីដេអូមួយ ដែលលម្អិតអំពីការចោទប្រកាន់ទាំងនេះ និងបានចែកចាយបញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាលមួយនៅទូទាំងរដ្ឋាភិបាល។ អ្នកបង្កើតច្បាប់ម្នាក់មកពីគណបក្សប្រជាជនកម្ពុជា បានធ្វើបទបង្ហាញមួយទៅកាន់រដ្ឋសភាជាតិ ដែលនៅក្នុងនោះគាត់បានចោទប្រកាន់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) វិទ្យាស្ថានសាធារណៈរដ្ឋអន្តរជាតិ (IRI) និងអង្គការ National Endowment for Democracy (NED) អង្គការ Freedom House និងអង្គការ Open Society Institute ថាញុះញង់ឲ្យមាន បដិវត្តន៍ពណ៌ដែលត្រូវបានចោទប្រកាន់ (CSOSI ឆ្នាំ២០១៧)។ យោងតាមរបាយការណ៍ CSOSI ឆ្នាំ២០១៧ អង្គការសង្គមស៊ីវិលនិងអង្គភាពព័ត៌មានមួយចំនួនត្រូវបានបិទ ឬផ្អាកប្រតិបត្តិការរបស់ខ្លួន ខណៈដែលអង្គការ និងអង្គភាពទាំងនោះស្ថិតក្រោមការស៊ើបអង្កេត។ លើសពីនេះទៀត ក្នុងឆ្នាំ២០១៦ រដ្ឋាភិបាលក៏បានបង្កើតស្ថាប័ន ដែលមានឈ្មោះថា វេទិកាសម្ព័ន្ធសង្គមស៊ីវិល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ វត្តមានរបស់ស្ថាប័ននេះបានបង្កឲ្យមានក្តីបារម្ភយ៉ាងខ្លាំងអំពីឯករាជ្យ និងសំឡេងរបស់អង្គការសង្គមស៊ីវិលពិតប្រាកដ។ ដូច

68 Colin Meyn,' Cambodia's controversial NGO law snares its first victim', 31 August 2017, (accessed on 11 July 2019) available at: https://www.devex.com/news/cambodia-s-controversial-ngo-law-snares-its-first-victim-90947

គ្នានេះដែរ អង្គការសង្គមស៊ីវិលមួយផ្សេងទៀត ដែលមានឈ្មោះថា សហភាពសហព័ន្ធយុវជន កម្ពុជា ត្រូវបានគេមើលឃើញថាមានការពាក់ព័ន្ធខ្លាំងទៅនឹងរដ្ឋាភិបាល ហើយបានប្រើប្រាស់ស្ថាប័នទាំងនេះ ដើម្បីអះអាងថា ខ្លួនមានការចូលរួមជាមួយនឹងសង្គមស៊ីវិល។ ទន្ទឹមនឹងនេះដែរ អង្គការសង្គមស៊ីវិលដែលធ្លាប់និយាយខ្លាំងៗជាច្រើនត្រូវបានស្ងើ ឬរំលឹកមើលខ្លួនឯង។ លើសពីនេះទៀត អាជ្ញាធរបានបន្តចាប់ខ្លួនសកម្មជនបរិស្ថាន រួមទាំងសកម្មជនមកពីអង្គការមាតាធម្មជាតិ ពីបទរំលោភច្បាប់ឯកជន តាមរយៈការប្រើប្រាស់យន្តហោះដ្រូន ដើម្បីបង្ហាញសកម្មភាពបូមខ្សាច់ខុសច្បាប់[69]។

| **អង្គការ/អង្គភាពព័ត៌មាន** | **ទម្រង់នៃការបៀតបៀន និងការបង្ក្រាប** |
|---|---|
| វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) | អង្គការវិទ្យាស្ថានជាតិប្រជាធិបតេយ្យ គឺត្រូវបានបិទដោយសារការចោទប្រកាន់ថាខកខានមិនទទួលបាន អនុស្សរណៈនៃការយោគយល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានតម្រូវដោយច្បាប់ LANGO។ អង្គការនេះត្រូវបានផ្តល់ពេលវេលាប្រាំពីរថ្ងៃដើម្បីបិទ និងបញ្ជូនបុគ្គលិកបរទេសរបស់ខ្លួនត្រលប់ទៅផ្ទះវិញ។<br>យោងតាមនាយករដ្ឋមន្ត្រី អង្គការនេះបានបំពានច្បាប់ដែលតម្រូវឲ្យមានអព្យាក្រឹត្យភាពផ្នែកនយោបាយ តាមរយៈការធ្វើការងារជាមួយគណបក្សប្រឆាំង ដើម្បីផ្តួលរំលំគណបក្សកាន់អំណាច។ ការប្រកាសនេះបានកើតមានត្រឹមតែប៉ុន្មានសប្តាហ៍បន្ទាប់ពីនាយករដ្ឋមន្ត្រី បានព្រមានអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិថា ពួកគេបច្ចុប្បន្នស្ថិតនៅក្រោមការគំរាមកំហែង ដោយសារច្បាប់ដាច់ដោយឡែកមួយ។ "សូមទីភ្នាក់ងារ និងអង្គការបរទេសដែលទទួលមូលនិធិបរទេស សូមដកចេញទៅ។ យើងកំពុងមើលអ្នក។ NGOs របស់អ្នកអាចត្រូវរំលាយចោលតាមរយៈច្បាប់ស្តីពីគណបក្សនយោបាយ"[70]។ |
| អង្គការសមធមិកម្ពុជា | ត្រូវបានផ្អាករយៈពេលមួយខែក្នុងខែកញ្ញា ឆ្នាំ២០១៧ ដោយរង់ចាំការស៊ើបអង្កេតដោយក្រសួងមហាផ្ទៃពីបទរំលោភច្បាប់ LANGO រួមទាំងរំលោភបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងមិនដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ និងឯកសារផ្សេងៗឲ្យបានទាន់ពេលវេលា។ ជាចុងក្រោយ អង្គការនេះត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមប្រតិបត្តិការឡើងវិញនៅខែកុម្ភៈ ឆ្នាំ២០១៨។ |

[69] CSOSI, 2017, page 33.

| | |
|---|---|
| កាសែតខេមបូឌាដេលី<br>វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) | អង្គភាពព័ត៌មានទាំងនេះត្រូវបានដាក់ឲ្យស្ថិតក្រោមការស៊ើបអង្កេត ភាគច្រើនដោយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវបានចោទប្រកាន់ពីបទមិនបំពេញកាតព្វកិច្ចពន្ធ។ |
| វិទ្យុអាស៊ីសេរី (RFA)<br>និងវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) | អង្គភាពត្រូវបានបង្ខំឲ្យបិទការិយាល័យរបស់ខ្លួននៅក្នុងប្រទេស។<br>ម្ចាស់កាសែត ខេមបូឌាដេលីត្រូវបានចោទប្រកាន់ពីបទបរិហាកេរ្តិ៍ និងត្រូវបានឃុំខ្លួនមុនជំនុំជម្រះ។ |
| មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | នាយករដ្ឋមន្ត្រីបានព្រមានអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជាសាធារណៈអំពីលទ្ធភាពនៃការស៊ើបអង្កេត "ពីព្រោះពួកគេបានដើរតាមបរទេស" ប្រហែលជាដោយសារអង្គការនេះត្រូវបានបង្កើតឡើងដោយលោក កឹម សុខា។ |
| អង្គការមេត្រីអន្តរជាតិ (AIM) | អាជ្ញាធរបានគំរាមបិទអង្គការមេត្រីអន្តរជាតិ ដោយចោទប្រកាន់ពីបទធ្វើឲ្យប៉ះពាល់ដល់វប្បធម៌របស់ប្រទេសក្នុងការផ្សាយព័ត៌មានអំពីការជួញដូរមនុស្ស។ |
| បន្ទប់ស្ថានការណ៍ដែលជាបណ្តុំរបស់អង្គការសង្គមស៊ីវិល | បណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បានរួមបញ្ចូលគ្នាដើម្បីតាមដាន និងរាយការណ៍ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតផ្សេងទៀត។ ប៉ុន្តែការរាយការណ៍ដំលេចធ្លោស្ថិតក្រោម "ឈ្មោះ" របស់ខ្លួននេះ បានបង្កឲ្យមានការខឹងសម្បារពីសំណាក់រដ្ឋាភិបាល ដែលបានគំរាមបិទបន្ទប់ស្ថានការណ៍នេះពីបទចូលរួមធ្វើសកម្មភាពដោយមិនបានចុះបញ្ជីស្ថិតក្រោមច្បាប់ LANGO និងពីបទញុះញង់ឲ្យមាន "បដិវត្តន៍ពណ៌"។ |

<u>បទពិសោធជាក់ស្តែង ធៀបនិង លក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃការដាក់របាយការណ៍ប្រចាំឆ្នាំ</u>

មុនពេលអនុម័តច្បាប់ LANGO ក្នុងឆ្នាំ២០១៥ មិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ ទៅកាន់រដ្ឋាភិបាលកម្ពុជាឡើយ។ ក្នុងឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹង (សេចក្តីប្រកាស) ចំនួនពីរ ដោយស្នើឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលចុះបញ្ជីទាំងអស់ ឲ្យដាក់ជូនព័ត៌មានអំពីកិច្ចព្រមព្រៀងមូលនិធិ គណនីធនាគារ និងរបាយការណ៍ ទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រោយមកនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងមួយដែលគោលបំណងរបស់សេចក្តីជូនដំណឹងនេះ គឺដើម្បីធានាឲ្យមានការចូលរួមរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្ត និងការផ្តោតការយកចិត្តទុកដាក់លើកាតព្វកិច្ចដែលត្រូវបានដាក់ចេញដោយមាត្រា ១០ និង ២៥ នៃច្បាប់ LANGO។

នៅខែវិច្ឆិកា ឆ្នាំ២០១៧ មានសេចក្ដីរាយការណ៍ថា អង្គការរាប់ពាន់បានខកខានមិនបានឆ្លើយតបទៅនឹងកាលបរិច្ឆេទកំណត់ (ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧) សម្រាប់ការដាក់ជូនរបាយការណ៍ហិរញ្ញវត្ថុស្ថិតក្រោមច្បាប់ LANGO នេះបើយោងតាមមន្ត្រីក្រសួង[71]។ នាយកនៃនាយកដ្ឋានសមាគម និងគណបក្សនយោបាយរបស់ក្រសួងមហាផ្ទៃ បានឲ្យដឹងថា ក្នុងចំណោមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៥.១៩៩ ដែលបានចុះបញ្ជីនៅក្រសួង (ក្នុងឆ្នាំ២០១៧) មានត្រឹមតែចំនួន ៦២១ សមាគម/អង្គការ (សមាគមចំនួន ១៩៦ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤២៥) ប៉ុណ្ណោះ ដែលបានដាក់ឯកសារ។ នៅត្រឹមឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានរាយការណ៍ថា បានទទួលរបាយការណ៍ប្រចាំឆ្នាំតែពីអង្គការសង្គមស៊ីវិល ចំនួនប្រហែល ២.០០០ ប៉ុណ្ណោះ ក្នុងចំណោមអង្គការជាង ៥.៥០០ ដែលបានចុះបញ្ជី។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ឆ្នាំ២០១៣* | *ក្នុងអំឡុងពេលសិក្សា និងសសេររបាយការណ៍ (ឆ្នាំ២០១៨-២០១៩)* |
|---|---|
| ការចុះបញ្ជីអង្គការសង្គមស៊ីវិលមុនពេលមានច្បាប់ LANGO ឆ្នាំ២០១៥ ត្រូវបានចាត់ទុកថាមានភាពសាមញ្ញ សម្រាប់អង្គការមិនមែន រដ្ឋាភិបាលកម្ពុជា ប៉ុន្តែចំណាយពេលយូរពីព្រោះវាទាមទារឲ្យមានការអនុម័តពីគ្រប់កម្រិតរដ្ឋបាលទាំងអស់ (ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង) និងនៅថ្នាក់ជាតិនៃក្រសួងមហាផ្ទៃ។ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវទាំងនេះ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលស្វែងរកការចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវដែល អាចផ្ដល់ឲ្យអាជ្ញាធរមូលដ្ឋាននូវការគ្រប់គ្រងបន្ថែមទៀតលើអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលបានចុះបញ្ជី។ បើទោះជាមានឧបសគ្គការិយាល័យធិបតេយ្យទាំងនេះក្ដី ក៏អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលជាទូទៅអាចចុះបញ្ជីបាន។<br>ទោះជាយ៉ាងណា មិនមានការរាយការណ៍អំពីការពិនិត្យមើល និងការជះឥទ្ធិពល | ដំណើរការចុះបញ្ជីតាមច្បាប់ LANGO ត្រូវបានកាត់បន្ថយនីតិវិធីទាក់ទងនឹងការកាត់បន្ថយការអនុម័ត ដោយសារតម្រូវធ្វើឡើងតែនៅកម្រិតឃុំ/សង្កាត់។<br>ទោះជាយ៉ាងណា ការចុះបញ្ជីបន្តចំណាយពេលយូរនៅក្រសួងមហាផ្ទៃ ពីព្រោះមន្ត្រីទទួលបន្ទុកត្រូវពិនិត្យមើលឯកសារ។ លើសពីនេះទៀត ច្បាប់ LANGO បានបន្ថែមលក្ខខណ្ឌតម្រូវមួយចំនួនសម្រាប់បទបញ្ជាផ្ទៃក្នុង/លក្ខន្តិកៈដែលត្រូវចុះបញ្ជី។<br>លើសពីនេះទៀត នៅពេលក្រសួងមហាផ្ទៃអនុម័តការចុះបញ្ជី វាមិនទាន់គ្រប់គ្រាន់នៅឡើយទេ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការប្រតិបត្តិការ។<br>ដោយសារបច្ចុប្បន្នអង្គការទាំងនេះត្រូវបានតម្រូវឲ្យចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ ដែលដំណើរការចំណាយពេលយូរ ហើយតម្រូវឲ្យមានបញ្ជីឯកសារដ៏វែងមួយ ដើម្បីគាំទ្រដល់ការចុះបញ្ជីពន្ធ។ បើគ្មានការចុះបញ្ជីពន្ធ គណនីធនាគារ |

71 Phnom Penh Post, Kong Meta and Leonie Kijewski, 'Few NGO compliant with law', 02 November 2017. Available at: https://www.phnompenhpost.com/national/few-ngos-compliant-law (accessed on 16 July 2019)

| | |
|---|---|
| ទៅលើបទបញ្ញាផ្ទៃក្នុង/លក្ខន្តិកៈរបស់អង្គការទេ។ មិនមានភាពខុសគ្នាឡើយរវាងពាក្យថា សមាគម និងអង្គការ។ សម្រាប់ការចុះបញ្ជីត្រូវបានហៅថា "អង្គការ"។<br><br>កន្លងមក សម្រាប់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា មិនមានការតម្រូវឲ្យធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទៅកាន់រដ្ឋាភិបាលឡើយ។ | របស់អង្គការមិនមែនរដ្ឋាភិបាលនៅធនាគារណាមួយនឹងត្រូវបានបញ្ចប់។<br><br>អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នត្រូវរាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន និងដាក់ជូនរបាយការណ៍ទាំងនេះទៅកាន់រដ្ឋាភិបាលរៀងរាល់ឆ្នាំ។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

ដោយមិនគិតពីបញ្ហានៃការរឹតបន្តឹងសង្គមស៊ីវិលដែលអាចកើតមាន អង្គការសង្គមស៊ីវិលក៏បារម្ភអំពីច្បាប់ LANGO ដែលជាច្បាប់ជាតិ ហើយចាំបាច់ត្រូវតែអនុវត្តតាម។ ទោះជាយ៉ាងណា បទប្បញ្ញត្តិនៃច្បាប់ LANGO ទំនងជាត្រូវបានបកស្រាយខុស និងត្រូវបានយល់ច្រឡំ និងត្រូវបានរំលោភបំពានទាក់ទងនឹងការដែលត្រូវបានប្រើប្រាស់ដើម្បីរឹតបន្តឹង និងផ្អាកអង្គការសង្គមស៊ីវិល និងដាក់កម្រិតដល់សកម្មភាពរបស់អង្គការទាំងនេះតាមរយៈការដាក់លក្ខខណ្ឌតម្រូវស្នើសុំការអនុញ្ញាត។

មានការលើកឡើងនូវបញ្ហាមួយចំនួនក្នុងដំណើរការចុះបញ្ជីអង្គការសង្គមស៊ីវិល ដោយសារៈ

| បញ្ហាប្រឈម | ការផ្តល់យោបល់ |
|---|---|
| • វានៅតែតម្រូវឲ្យធ្វើតែនៅក្នុងរាជធានីភ្នំពេញ ដែលបង្កការលំបាកសម្រាប់អង្គការតូចៗ និងអង្គការដែលមានទីតាំងនៅតាមខេត្ត ដោយសារអង្គការទាំងនោះត្រូវធ្វើដំណើរញឹកញាប់មកកាន់រាជធានីភ្នំពេញក្នុងអំឡុងពេលដំណើរការចុះបញ្ជី។<br>• ដំណើរការចុះបញ្ជីមិនច្បាស់លាស់ ចំណាយពេលច្រើន និងបើកចំហរចំពោះការជ្រៀតជ្រែកនិងឥទ្ធិពល។<br>• មានកង្វះការណែនាំជាឯកសារអំពីដំណើរការ និងលក្ខខណ្ឌតម្រូវ។<br>ទាក់ទងនឹងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល។ | • ប្តូរដំណើរការចុះបញ្ជីទៅជាអនឡាញដើម្បីផ្តល់លទ្ធភាព និងធ្វើប្រតិភូកម្ម និងអនុញ្ញាតឲ្យមាន "ការិយាល័យច្រកចេញចូលតែមួយ" ដើម្បីចេញឯកសារចុះបញ្ជី ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការងារវិមជ្ឈការ។<br>o កំណត់ខ្នាតគម្រូដំណើរការទាក់ទងនឹងការការកំណត់ពេលវេលានៃជំហានដំណើរការនីមួយៗ។<br>• បង្កើតគោលការណ៍ណែនាំឯកសារចុះបញ្ជីអង្គការសង្គមស៊ីវិល ដែលអាចបញ្ជាក់ច្បាស់លាស់អំពីបញ្ហា និងមានឧទាហរណ៍និងគម្រូ (template) និងយុត្តាធិការសម្រាប់ការប្រើ |

| | |
|---|---|
| • មានភាពមិនច្បាស់លាស់ខ្លាំងក្នុងពាក្យសុំរបស់ច្បាប់ LANGO ហើយឧបករណ៍ច្បាប់ផ្សេងទៀត ដែលបាននិងកំពុងត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយសកម្មភាពរបស់អង្គការសង្គមស៊ីវិល។<br>• មានកង្វះយន្តការគោលបំណង ដើម្បីពិនិត្យ ឧបករណ៍ច្បាប់ឲ្យបានទាន់ពេលវេលា និងបញ្ជាក់ពីបញ្ហាច្បាស់លាស់។ | ប្រាស់ពាក្យពេជន៍/ឃ្លាដែលចង់បានឬដែលស្នើឲ្យប្រើប្រាស់។<br>• លើកកម្ពស់ការឃោគយល់ទៅវិញទៅមកដោយអង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានអំពីឧបករណ៍ច្បាប់ និងពាក្យសុំរបស់ពួកគេ បង្កើតមគ្គុទ្ទេសក៍បទប្បញ្ញត្តិដែលមិនច្បាស់លាស់ដើម្បីឲ្យអាជ្ញាធរមូលដ្ឋានយល់ដឹងបានកាន់តែប្រសើរ។<br>• ចូលរួមក្នុងការពិគ្រោះយោបល់ជាមួយក្រសួង និងអ្នកធ្វើសេចក្ដីសម្រេចចិត្តនានា ដើម្បីព្យាយាមធ្វើឲ្យកាន់តែប្រសើរ និងបញ្ជាក់ច្បាស់លាស់ក្នុងក្របខ័ណ្ឌ និងប្រព័ន្ធច្បាប់ និងតស៊ូមតិជាមួយអ្នកផ្សេងទៀតសម្រាប់ការផ្លាស់ប្តូរដែលចាំបាច់។ |

# សេរីភាពបញ្ចេញមតិ

## ទិដ្ឋភាពរួម

ជាមួយនឹងការបើកចំហរ និងលំហរពលរដ្ឋចម្រុះ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត អាចក្លាយជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយស្ថាប័នសាធារណៈនៅគ្រប់កម្រិត និងនៅទូទាំងគ្រប់វិស័យ ដើម្បីចូលរួមចំណែកដល់ការធានា បាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ទាក់ទងនឹងតម្លៃភាពជាដៃគូ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានតម្រូវឲ្យមាន ហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ វាជាស្នូលចំពោះការធានាអត្ថិភាព និងមុខងារប្រកបដោយប្រសិទ្ធភាពនៃការបើកចំហរ និងលំហរពលរដ្ឋចម្រុះ។

**អ្វីគឺជាសេរីភាពក្នុងការបញ្ចេញមតិ?**

មាត្រា ១៩ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ធានានូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងគំនិតយោបល់សម្រាប់មនុស្សគ្រប់គ្នា ដោយចែងថា "សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវ ព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន"។

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានធានាស្ថិតក្រោមអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួល និងរួមបញ្ចូលទៅក្នុងច្បាប់ជាតិរបស់ខ្លួន រួមទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) (មាត្រា ១៩) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)[72]។ តួនាទីរបស់អង្គការសហប្រជាជាតិគឺថា សេរីភាពក្នុងការបញ្ចេញមតិការពារសិទ្ធិផ្សេងៗ រួមទាំងសិទ្ធិទទួលបានព័ត៌មាន សិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជាដើម។

**មាត្រា ៤១៖** ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់។

*ប្រភព៖រដ្ឋធម្មនុញ្ញ*

បើទោះជាកម្ពុជាបានទទួលស្គាល់ការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិមនុស្សអន្តរជាតិក្នុងរដ្ឋធម្មនុញ្ញ និងក្នុងឯកសារផ្សេងទៀតក្តី

72 http://cambodia.ohchr.org/en/civil-society-fund-freedoms/freedom-expression

ក៏ការការពារដ៏សកម្ម និងជាក់ស្តែង និងអនុលោមទៅនឹងសិទ្ធិនេះដោយអ្នកតំណាងរបស់អាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន ត្រូវបានចាត់ទុកថានៅមាន កង្វះខាត និងមិនគ្រប់គ្រាន់។

ការស្រាវជ្រាវ[73] បង្ហាញថា ការបង្កើតឲ្យមានបរិយាកាសអនុគ្រោះសម្រាប់ក្រុមមនុស្សមកពីចំណាប់អារម្មណ៍នយោបាយផ្សេងៗ និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងដំណើរការអភិវឌ្ឍន៍អាចជួយឲ្យមានតម្លាភាព និងគណនេយ្យភាពបន្ថែមទៀតចំពោះលទ្ធផល (Vaduva, Wilt, Fotea &Vaduva ឆ្នាំ ២០១៩)។ ហើយករណីនេះអវត្តមាននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ខណៈដែលស្ថានភាពបច្ចុប្បន្នកំពុងតែប្រែក្លាយឲ្យមានការរួមបញ្ចូលគ្នាកាន់តែខ្លាំង និងរួសរាយ ទទួលយកទស្សនៈនិងយោបល់ផ្សេងទៀត រួមទាំងទស្សនៈនិងយោបល់ដែលប្រឆាំងទស្សនៈរបស់គណបក្សនយោបាយមួយផងដែរ។ មនុស្សត្រឹមតែសម្លឹងមើលទៅកាន់ប្រទេសមីយ៉ាន់ម៉ា ជាទីដែលក្រុមយោធាគាំទ្ររដ្ឋាភិបាលតំណាង ក្នុងឆ្នាំ២០១០ បានអនុញ្ញាតឲ្យមានការបោះឆ្នោត ដែលកាន់តែមានភាពចំហរ (ឆ្នាំ ២០១៥) ដែលបានមើលឃើញក្រុមយោធានេះចាញ់ឆ្នោត។ ដំណើរការផ្លាស់ប្តូរនេះដែលបានចាប់ផ្តើមនៅឆ្នាំ២០១០ រួមមានទាំងការដោះលែងមេដឹកនាំគណបក្សប្រឆាំង ដែលត្រូវបានឃុំខ្លួនក្នុងផ្ទះរយៈពេលយូរសម្រាប់ជាឧទាហរណ៍ដែលកំពុងវិវឌ្ឍន៍អំពីបញ្ហានេះ។

ការវិភាគបន្ថែមអំពី៖

- តើអ្វីគឺបទប្បញ្ញត្តិច្បាប់ក្នុងស្រុកដែលមាន ដើម្បីធានាដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាជន?
- តើបទប្បញ្ញត្តិច្បាប់ជាធរមានរបស់កម្ពុជា ឆ្លើយតបទៅនឹងស្តង់ដារ និងការអនុវត្តអន្តរជាតិសម្រាប់ការលើកកម្ពស់និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិបានដល់កម្រិតណា?
- តើបញ្ហាប្រឈម និងបញ្ហាអ្វីដែលអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលដែលធ្វើការងារក្នុងប្រទេសកម្ពុជាកំពុងជួបប្រទះក្នុងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេ?

សម្រាប់ទាំងអស់នេះ ប្រជាពលរដ្ឋកម្ពុជាទាំងអស់ទទួលបានអត្ថប្រយោជន៍ពីការការពារដោយរដ្ឋធម្មនុញ្ញ ដែលចែងក្នុងមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ។ ទោះជាយ៉ាងណា ការអនុវត្ត ការប្រើប្រាស់ និងអនុលោមតាមបទប្បញ្ញត្តិច្បាប់របស់កម្ពុជាពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិមិនឈានដល់ស្តង់ដារនិងការប្រតិបត្តិអន្តរជាតិ (ដែលត្រូវបានទទួលស្គាល់) (CCHRឆ្នាំ២០១៧)។

សិទ្ធិតស៊ូមតិផ្សេងៗ[74] រួមទាំង UNOHCHR បានលើកឡើងពីការកើនឡើងការប្រើប្រាស់/ការរំលោភបំពានក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន ដើម្បីទប់ស្កាត់ និងកាត់បន្ថយសេរីភាពក្នុងការបញ្ចេញមតិ។

73 For example.https://en.wikipedia.org/wiki/Freedom_of_speech ; https://papers.ssrn.com/sol3/papers.cfm?abstract_id=285432, ; https://freedomhouse.org/issues/freedom-expression

74 https://www.icj.org/cambodia-ongoing-misuse-of-law-to-silence-opponents-further-deepens-impunity-and-undermines-the-rule-of-law/ ,; https://www.icj.org/hrc37cambodia/

ករណីនេះត្រូវបានរួមផ្សំបន្ថែមទៀត ដោយការបកស្រាយច្បាប់តាមតែទំនើងចិត្តដោយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិមនុស្សផ្សេងទៀតរបស់បុគ្គលិកនីមួយៗ និងរបស់ក្រុមមនុស្សនានា ដោយទទួលបានការការពារពីច្បាប់តិចតួច ឬមិនមានសោះក៏មាន។

អង្គភាពព័ត៌មានមួយចំនួន អង្គការសង្គមស៊ីវិល (ដូចជាគម្រោងពិនិត្យតាមដានសេរីភាពមូលដ្ឋានរបស់អង្គការ CCHR)[75] និងផ្លែតហ្វមផ្សេងទៀត បានកត់ត្រា និងបានរាយការណ៍ពីបណ្ដឹងរបស់ក្រុមមនុស្សផ្សេងៗអំពីករណីរំលោភសិទ្ធិដោយអាជ្ញាធរសាធារណៈ។ អ្នកតំណាងរបស់អង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរាយការណ៍ពីបទពិសោធជួបប្រទះប្រភេទផ្សេងៗនៃលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាល ដែលមានលក្ខណៈដូចទៅនឹងច្បាប់ ការជ្រៀតជ្រែក និងការរឹតបន្តឹងនានា ដែលបានកាត់បន្ថយសិទ្ធិក្នុងការប្រតិបត្តិសេរីភាពជាមូលដ្ឋានរបស់ពួកគេ រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិផងដែរ។

## លទ្ធផលរកឃើញ និងការវិភាគ

ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន ៦ ដែលបានឆ្លើយតបទៅនឹងការអង្កេតក្នុងឆ្នាំ២០១៨ អង្គការសង្គមស៊ីវិលជាងពាក់កណ្ដាល (៥៨%) បានជឿថា ស្ថានភាពសម្រាប់សេរីភាពក្នុងការបញ្ចេញមតិបានធ្លាក់ចុះនៅពេលធៀបនឹងឆ្នាំ២០១៥។ មួយភាគប្រាំ (២១%) បានជឿថា ស្ថានភាពសេរីភាពក្នុងការបញ្ចេញមតិបានប្រសើរឡើង (នៅខាងឆ្វេងដៃ)។

នៅក្នុងការតាមដាន (following up) អ្នកតំណាងរបស់អង្គការសង្គមស៊ីវិលត្រូវបានសួរថា តើពួកគេបានឯកភាពឬយ៉ាងណាជាមួយសេចក្ដីថ្លៃការណ៍ដែលថា "បុគ្គលិករបស់ពួកគេយល់ឃើញថាមានសុវត្ថិភាពក្នុងការបញ្ចេញទស្សនៈរបស់ខ្លួននៅទីសាធារណៈ ឬនៅតាមប្រព័ន្ធផ្សព្វផ្សាយ"។ ជិតបីភាគបួន (៧៣%) មិនយល់ស្របនឹងសេចក្ដីថ្លែងការណ៍នេះ ហើយមានតែមួយភាគដប់ (១១%) ប៉ុណ្ណោះដែលបានឯកភាពជាមួយនឹងសេចក្ដីថ្លែងការណ៍នេះ (នៅខាងស្ដាំដៃ)។

អ្នកដែលបានពិគ្រោះយោបល់ភាគច្រើន បានយល់ឃើញថា ក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន អាចត្រូវបានរំលោភបំពាន ក្នុងការបកស្រាយខុស នូវអ្វីដែលពួកគេនិយាយក្នុងកិច្ចប្រជុំសាធារណៈ ឬក្នុងប្រព័ន្ធផ្សព្វផ្សាយ។ ពួកគេក៏បានចែករំលែកផងដែរនូវបទពិសោធរបស់ខ្លួនដែលទទួលបានពីខេត្ត និងស្រុកផ្សេងៗ ខណៈដែលអាជ្ញាធរសាធារណៈនៅកម្រិតផ្សេងៗ បានបកស្រាយ និងអនុវត្តក្របខ័ណ្ឌច្បាប់ខុសគ្នាអំពីអង្គការសង្គមស៊ីវិល និងបញ្ហាផ្សេងៗទៀតក្នុងការអនុវត្តសិទ្ធិសេរីភាពក្នុង

[75] https://cchrcambodia.org

ការបញ្ចេញមតិរបស់ពួកគេ។ អ្នកដែលបានពិគ្រោះយោបល់ភាគច្រើនជាអង្គការសង្គមស៊ីវិល បានបង្ហាញថា អ្នកតំណាងជាន់ខ្ពស់មួយចំនួនរបស់អាជ្ញាធរសាធារណៈ បានប្រើប្រាស់វោហាសាស្ត្រអវិជ្ជមាននៅក្នុងព្រឹត្តិការណ៍សាធារណៈ "ដើម្បីបង្កឲ្យមានការលំបាកដល់សកម្មជនសិទ្ធិមនុស្ស និងអ្នកតំណាងរបស់អង្គការសង្គមស៊ីវិល" ដែលរិះគន់រដ្ឋាភិបាល ឬគ្រឹះស្ថាននយោបាយ។ ការណ៍នេះមានភាពស្របគ្នាជាមួយនឹងលទ្ធផលរកឃើញ ពីគម្រោងពិនិត្យតាមដានសេរីភាពមូលដ្ឋានដែលកំពុងធ្វើឡើងរបស់អង្គការ CCHR ដែលបានរាយការណ៍ពីការកើតមានសេចក្តីថ្លែងការណ៍បែបរំលោភបំពានដោយក្រុមមន្ត្រីក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះដែលជាញឹកញាប់បានធ្វើឲ្យអង្គការសង្គមស៊ីវិលប្រែក្លាយទៅជាអាក្រក់[76]។







ភាពភ័យខ្លាចនៃការកើតមានឡើងដោយសារការនិយាយដោយសេរី ត្រូវបានលើកឡើងយ៉ាងខ្លាំងដោយអង្គការសង្គមស៊ីវិលដែលបានពិគ្រោះយោបល់ ពិសេសធ្វើការងារលើវិស័យសិទ្ធិមនុស្ស អភិវឌ្ឍន៍សហគមន៍ និងការតស៊ូមតិ។ ទោះជាយ៉ាងណា ការណ៍នេះមិនមែនជាករណីសម្រាប់ទាំងអស់ឡើយ។ អង្គការសង្គមស៊ីវិលដែលប្រតិបត្តិការក្នុងវិស័យសុខាភិបាល កសិកម្ម និងការអប់រំ ជាទូទៅបានរាយការណ៍ថាមិនបានប្រឈមនឹងបញ្ហាឡើយ។ ការយល់ឃើញរបស់ពួកគេគឺថា បរិយាកាសអំណោយផលសម្រាប់វិស័យរបស់ពួកគេ កំពុងមានភាពប្រសើរឡើងកាន់តែល្អជាងមុន។ វិស័យអប់រំគឺជាឧទាហរណ៍ល្អមួយនៃការផ្លាស់ប្តូរដែលកើតមានឡើង។ កម្រិតផ្សេងមួយទៀតនៃការប្តេជ្ញាចិត្តពីរដ្ឋាភិបាលឆ្ពោះទៅវិស័យនេះ ត្រូវបានទទួលស្គាល់ចាប់តាំងពីមានការតែងតាំងរដ្ឋមន្ត្រីក្រសួងអប់រំថ្មីក្នុងឆ្នាំ២០១៣ (ការពិពណ៌នាលម្អិតបន្ថែមអំពីថាតើផ្លាស់ប្តូរយ៉ាងដូចម្តេចនោះ ត្រូវបានពិភាក្សាបន្ថិចទៀតនៅក្នុងរបាយការណ៍នេះ)។

76 https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=130&id=5

នៅថ្នាក់ក្រោមជាតិ អារម្មណ៍ជាទូទៅគឺថា រយៈពេលពីរបីឆ្នាំមុនការបោះឆ្នោតជាតិឆ្នាំ២០១៨ គឺជាឆ្នាំដ៏លំបាក។ មានការទទួលស្គាល់ថា បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលត្រូវបានទទួលរងឥទ្ធិពលប្រកបដោយភាពមិនអំណោយផល ដោយសារតម្រូវការរបស់រដ្ឋាភិបាលដើម្បីរក្សាតួនាទីអំណាចរបស់ខ្លួន បន្ទាប់ពីប៉ិះនឹងចាញ់ការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៣[77]។ លើសពីនេះទៀត អង្គការសង្គមស៊ីវិលមួយចំនួន បានបង្ហាញពីការយល់ឃើញរបស់ពួកគេអំពីបរិយាកាសអំណោយផល ដែលមានភាពប្រសើរឡើងសម្រាប់អង្គការសង្គមស៊ីវិលមុនពេលមានការដាក់ដំណើរការច្បាប់ថ្មីនេះ (ច្បាប់ LANGO ឆ្នាំ២០១៥)។

ទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលមួយចំនួន បានចង្អុលបង្ហាញអំពីរបៀបដែលស្ថានភាពបានកើតមានឡើងកាន់តែប្រសើរក្នុងរយៈកាលប៉ុន្មានខែថ្មីៗនេះ ចាប់តាំងពីបញ្ចប់ការបោះឆ្នោតជាតិឆ្នាំ២០១៨មក និងការបង្កើតរដ្ឋាភិបាលក្នុងខែកញ្ញា ឆ្នាំ២០១៨។ ខណៈដែលបទប្បញ្ញត្តិដែលតម្រូវឲ្យជូនដំណឹងដល់អាជ្ញាធរអំពីការប្រមូលផ្តុំត្រូវបានរាយការណ៍ថាត្រូវបានលុបចោល ហើយមានការយល់ឃើញថា សម្ពាធបំភិតបំភ័យនិងការកៀបសង្កត់ត្រូវបានលុបចោល (សម្រាប់ពេលបច្ចុប្បន្ន)។

បើទោះជាប្រទេសកម្ពុជាបានអភិវឌ្ឍន៍ និងបានវិវឌ្ឍក្របខ័ណ្ឌច្បាប់ស្នូលរបស់ខ្លួនពីចក្ខុវិស័យច្បាប់មួយក្តី ក៏កម្ពុជានៅតែមានការងារច្រើនថែមទៀតដែលត្រូវធ្វើ។ ច្បាប់ជាធរមានជាញឹកញាប់ត្រូវការការបញ្ជាក់បំភ្លឺ ការពិនិត្យមើលឡើងវិញ និងការកែលម្អ។ ក្របខ័ណ្ឌច្បាប់ក៏ត្រូវការឧបករណ៍ច្បាប់បន្ថែម និងការណែនាំផងដែរ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់។ នៅពេលបច្ចុប្បន្ន មានឱកាសឬវិសាលភាពតិចតួច ដើម្បីស្នើសុំឲ្យមានការពិភាក្សាអំពី ឬជំរុញឲ្យមានការពិនិត្យមើលច្បាប់ឡើងវិញ។

អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិដែលត្រូវបានពិគ្រោះយោបល់ និងសូម្បីតែអង្គការសង្គមស៊ីវិលដែលមានភាពស្វាក់ស្ទើរក្នុងការរិះគន់រដ្ឋាភិបាល បានបង្ហាញច្បាស់លាស់អំពីភាពមិនសប្បាយចិត្តជាមួយស្ថានភាពបច្ចុប្បន្ន (ឆ្នាំ២០១៨) ទាក់ទងនឹងកង្វះលំហរសម្រាប់សេរីភាពបញ្ចេញមតិ។ ព្រឹត្តិការណ៍នានាដែលឈានទៅរកការបោះឆ្នោត ដូចជា ការបិទកាសែតខេមបូឌាដេលី ដែលត្រូវបានចោទប្រកាន់ថាមិនបង់ពន្ធ ការរំលាយគណបក្សប្រឆាំងឈានមុខគេដោយតុលាការកំពូលក្នុងឆ្នាំ២០១៧។ ការបណ្តេញវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ក្នុងឆ្នាំ២០១៧ ដែលយោងទៅតាមរដ្ឋាភិបាលថា អង្គការនេះបាន "ប្រតិបត្តិការ (ជាអង្គការមិនមែនរដ្ឋាភិបាលមួយ) ដោយគ្មានការចុះបញ្ជីជាមួយរដ្ឋាភិបាល"[78]។ ព្រមទាំងការចាប់ឃុំឃាំង និងកាត់ទោសមន្ត្រីរបស់អង្គការ ADHOC ចំនួន

77 Reuters (August 12, 2018). Cambodia election crisis deepens as opposition rejects results. Available at: https://www.reuters.com/article/us-cambodia-election-count/cambodia-election-crisis-deepens-as-opposition-rejects-results-idUSBRE97B02I20130812

78 Khmer Times (23/08/2017) Government to close NDI, expel foreign staff https://www.khmertimeskh.com/79516/government-close-ndi-expel-foreign-staff/

៥នាក់នៅចន្លោះឆ្នាំ២០១៧-២០១៨ និងការផ្អាកប្រតិបត្តិការរបស់អង្គការសមធមិកម្ពុជាដោយក្រសួងមហាផ្ទៃ[79] ក្នុងខែកញ្ញា ឆ្នាំ២០១៧។

ទាំងនេះហាក់ដូចជាមានផលប៉ះពាល់យ៉ាងខ្លាំងលើប្រជាជន និងអារម្មណ៍របស់អង្គការសង្គមស៊ីវិលដោយសារការបង្ក្រាបផ្សេងៗ។ យោងតាមសន្ទស្សន៍និរន្តរភាពអង្គការសង្គមស៊ីវិល (CSOSI ឆ្នាំ២០១៧) ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយភ្នាក់ងារ USAID "លំហរប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាបានបន្តធ្លាក់ចុះក្នុងឆ្នាំ២០១៧ បន្ទាប់ពីរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច បានរំលាយគណបក្សសង្គ្រោះជាតិ" ហើយត្រូវបានជឿថា "រដ្ឋាភិបាលក៏បានដាក់ដំណើរការយុទ្ធនាការធំមួយប្រឆាំងនឹងអង្គការសង្គមស៊ីវិល ដែលត្រូវបានចោទប្រកាន់ថាជាផ្នែកមួយនៃបដិវត្តន៍ពណ៌ដែលត្រូវបានចោទប្រកាន់"។

អង្គការសង្គមស៊ីវិល និងអង្គភាពព័ត៌មានមួយចំនួនត្រូវបានបិទទ្វា ផ្អាក ឬដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេត។ លើសពីនេះទៀត រដ្ឋាភិបាលបានបំភិតបំភ័យ បៀតបៀន និងចាត់ទុកអង្គការសង្គមស៊ីវិលថាអាក្រក់ "និងបានកាត់បន្ថយរូបភាព (visibility) របស់អង្គការសង្គមស៊ីវិល"[80]។ ពួកគេក៏បានជឿផងដែរថា "និរន្តរភាពរបស់អង្គការសង្គមស៊ីវិលកម្ពុជា បានបន្តធ្លាក់ចុះនៅក្នុងឆ្នាំ២០១៧ ដោយកត់សម្គាល់ឃើញមានក្នុងសមាសភាគនិរន្តរភាពទាំងអស់ លើកលែងសមត្ថភាពស្ថាប័ន"។ បន្ទាប់ពីនេះ ភាពភ័យខ្លាចក្នុងការបញ្ចេញមតិ ដែលប្រឆាំងនឹងមតិនយោបាយទូទៅបច្ចុប្បន្ន បានកើនឡើង។




ពីការអង្កេត និងការពិភាក្សារបស់អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលឆ្លើយតបចំនួន ៦៧ ក្នុងឆ្នាំ២០១៨ វានឹងទំនងត្រូវបានបែងចែកប្រហែលគ្នា ដោយជាងមួយភាគបី (៣៧%) នៃអង្គការសង្គមស៊ីវិល ពេញចិត្តឬពេញចិត្តខ្លាំងនឹងបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិលនាពេលបច្ចុប្បន្ន ខណៈដែលក្រោយមួយភាគបី (៣១%) មិនពេញចិត្ត ឬមិនពេញចិត្តខ្លាំងនឹងបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល។ ចំណែកមួយភាគបីទៀតដែលនៅសល់ (៣២%) នៃអង្គការសង្គមស៊ីវិល បានបង្ហាញភាពអព្យាក្រឹត្យចំពោះសំណួរអំពីការពេញចិត្តជាមួយនឹងបរិយាកាសអំណោយផលថាតើពេញចិត្ត ឬមិនពេញចិត្ត។

79 Phnom Penh (28/09/2017) Land rights NGO suspended https://www.phnompenhpost.com/national/land-rights-ngo-suspended
80 USAID/FHI/ICNL (November 2018 ) Civil Society Organization Sustainability Index, For Asia, 2017, 4th Edition - November 2018, https://www.usaid.gov/asia-civil-society

លទ្ធផលរកឃើញទាំងនេះ បង្ហាញឲ្យឃើញពីកម្រិតមិនពេញចិត្តខ្លាំងជាងអ្វីដែលត្រូវបានរកឃើញតាមរយៈបទសម្ភាសស៊ីជម្រៅជាលក្ខណៈបុគ្គល ដែលបានរកឃើញគម្លាតយល់ស្របកាន់តែខ្លាំង[81] ពីបទសម្ភាស "ទល់មុខ"។ លទ្ធផលពិតជាបង្ហាញឲ្យឃើញពីឱកាសច្រើនសម្រាប់ការកែលម្អ។ និយាមវប្បធម៌អាស៊ី ក៏ត្រូវបានលើកឡើងផងដែរថាជាឧបសគ្គដែលអាចកើតមានមួយលើឆន្ទៈរបស់ប្រជាជនក្នុងការចូលរួមក្នុងការជជែកដេញដោលនយោបាយ៖ "ការនិយាយពីអារម្មណ៍របស់អ្នកចេញមកជានិច្ចកាលមិនត្រូវបានទទួលយកឡើយ ជាពិសេសមិនមែន ទីសាធារណៈ។ មធ្យោបាយត្រឹមត្រូវគឺត្រូវពិភាក្សាអំពីបញ្ហារសើបនៅទីកន្លែងឯកជន មិនមែនទីសាធារណៈឡើយ"។ ការណ៍នេះទំនងជាបង្ហាញឲ្យឃើញពីអាកប្បកិរិយាមួយរបស់មនុស្សមួយចំនួន ដែលធ្វើការងារដើម្បីកសាងសង្គមស៊ីវិល។ វាមានភាពចាំបាច់ដែលត្រូវពិចារណាលើវិធីនានា ដើម្បីជម្នះអាកប្បកិរិយានេះ។

មតិយោបល់របស់អង្គការសង្គមស៊ីវិលក្រោយការបោះឆ្នោតឆ្នាំ២០១៨ គឺថា ចំពោះពួកគេវាហាក់ដូចជាថា មានការបើកចំហរ និងលំហរពលរដ្ឋ ហើយបច្ចុប្បន្នមានសេរីភាពជាងមុនអំពីការងាររបស់ពួកគេជាងពេលកន្លងមក។ ប្រសិនបើការណ៍នេះគឺជាការចាប់ផ្ដើមការផ្លាស់ប្ដូរអចិន្ត្រៃយ៍ វានឹងជាសញ្ញានៃការអភិវឌ្ឍប្រកបដោយវិជ្ជមានមួយ។ ទោះជាយ៉ាងណា ក៏មានការកត់សម្គាល់ពីចម្ងល់មួយចំនួនផងដែរ ទាក់ទងទៅនឹងថាតើការផ្លាស់ប្ដូរទាំងនេះគឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែង ដើម្បីធ្វើឲ្យប្រសើរឡើងនូវការយល់ឃើញរបស់អង្គការសង្គមស៊ីវិលអំពីបរិយាកាសអំណោយផល ដែលកំពុងវិវឌ្ឍន៍ឬយ៉ាងណា។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ឆ្នាំ២០១៣* | *ក្នុងអំឡុងពេលសិក្សា និងសរសេររបាយការណ៍ (ឆ្នាំ២០១៨-២០១៩)* |
|---|---|
| របាយការណ៍ EENA ឆ្នាំ ២០១៣ បានសង្ខេបស្ថានភាពទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិថាជាឧបសគ្គចំពោះសេរីភាពក្នុងការបញ្ចេញមតិក្នុងប្រទេសកម្ពុជា ហើយឧបសគ្គទាំងនេះមានកម្រិតខ្លាំង និងមានក្ដីបារម្ភធ្ងន់ធ្ងរចំពោះតួអង្គសង្គមស៊ីវិល និងអ្នកសង្កេតការណ៍ផ្សេងទៀត។ មានការជឿថា អង្គការសង្គមស៊ីវិលហាក់ | អង្គការសង្គមស៊ីវិលភាគច្រើន ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធ បានចាត់ទុកថា លំហរពលរដ្ឋសម្រាប់សេរីភាពបញ្ចេញមតិ បានធ្លាក់ចុះខ្លាំងក្នុងពេលពីរបីឆ្នាំចុងក្រោយនេះ។ ពួកគេបានចាត់ទុកស្ថានភាពនេះថា បណ្ដាលមកពីបរិយាកាសនយោបាយក្នុងប្រទេស។ ការណ៍នេះជះឥទ្ធិពលមកពីសេចក្ដីសម្រេចរបស់គណបក្សប្រជាជនកម្ពុជា ក្នុងដំណើរការកម្ទេច និងទប់គណបក្សប្រឆាំងនិងអ្នកគាំទ្រ។ បញ្ហាមូលដ្ឋាននានាដែលជះឥទ្ធិពលដល់ការដាក់កម្រិតសេរីភាពបញ្ចេញមតិបន្តកើតមានភាពមិនច្បាស់លាស់ ដែល កង្វះខាតក្នុងក្របខ័ណ្ឌច្បាប់នៅតែមាន ហើយអាច |

81 Acquiescence bias is when people are more likely to agree than disagree regardless of their actual opinion. This is often a result of a cultural influence where disagreeing with someone, or criticizing something is considered rude. In surveys this often results in a higher percentage of non-critical or neutral responses.

| | |
|---|---|
| ដូចជាមានជំនាញក្នុងការបញ្ចៀសស្ថានភាពលំបាកនេះ។ | ត្រូវបានអនុវត្តឡើងវិញ/"ត្រូវបានប្រើប្រាស់ធ្វើជាអាវុធ"នៅគ្រប់ពេលវេលា។<br>លើសពីនេះទៀត ការការពារដោយនីតិរដ្ឋនៅតែត្រូវបានចាត់ទុកថា អវត្តមាន ដើម្បីការពារអង្គការសង្គមស៊ីវិលសហជីព និងសាធារណៈ។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

| បញ្ហាប្រឈម | ការផ្តល់យោបល់ |
|---|---|
| ▪ បន្តកើតមានភាពមិនច្បាស់លាស់ក្នុងក្របខ័ណ្ឌច្បាប់ ដោយបទប្បញ្ញត្តិជាច្រើនក្នុងច្បាប់ផ្សេងៗ (ក្រមព្រហ្មទណ្ឌ ច្បាប់ LANGO ទូរគមនាគមន៍ សហជីព....) និងឧបករណ៍នានា ដែលអាចត្រូវបានប្រើប្រាស់ដើម្បីដាក់កម្រិត និងរឹតបន្តឹងដល់សេរីភាពក្នុងការបញ្ចេញមតិ។<br>o ការរំលោភបំពានប្រព័ន្ធច្បាប់តាមរយៈការបកស្រាយខុសដោយអាជ្ញាធរនៅកម្រិតផ្សេង ដើម្បីដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ។<br>▪ កង្វះប្រព័ន្ធផ្សព្វផ្សាយ (បោះពុម្ព ទូរទស្សន៍ វិទ្យុ) និងអ៊ីនធឺណិត ដែលឯករាជ្យ។<br>o កើនឡើងការបំភិតបំភ័យអ្នកកាសែតដែលឈានទៅរកអវត្តមានការរាយការណ៍តាមគោលបំណងប្រកបដោយសមធម៌អំពីបញ្ហានានាក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។<br>▪ បន្តរំលោភបំពាន និងនិទណ្ឌភាពនៃ និងចំពោះច្បាប់ដោយសមាជិករបស់ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការរបស់រដ្ឋាភិបាល ដើម្បីរារាំងបុគ្គល និងអង្គការដែលបញ្ចេញទស្សនៈផ្ទុយនឹងរដ្ឋាភិបាល ដោយបន្តនិងពង្រឹងបរិយាកាសត្រួតពិនិត្យបរិយាកាសនៃការរិះគន់។ | ➢ បង្កើតផ្លែតហ្វមអង្គការសង្គមស៊ីវិលមួយដើម្បីភ្ជាប់រដ្ឋាភិបាលឲ្យបានកាន់តែប្រសើរទៅនឹងបញ្ហាសេរីភាពក្នុងការបញ្ចេញមតិ។<br>➢ ផ្តួចផ្តើមគំនិតបង្កើតយុទ្ធនាការសម្រាប់ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌច្បាប់។<br>o បង្កើនការយល់ដឹងនិងយុទ្ធនាការតស៊ូមតិលើសិទ្ធិសេរីភាពបញ្ចេញមតិនិងសិទ្ធិផ្សេង<br>➢ ធ្វើឲ្យប្រសើរឡើងនូវការរក្សាទុកឯកសារ និងកំណត់ត្រាសំណុំរឿងរំលោភសិទ្ធិមនុស្ស និងការគាបសង្កត់សិទ្ធិ។<br>➢ ពិនិត្យតាមដាន និងបន្ស៊ីសកម្មភាពជាមួយនឹងក្របខ័ណ្ឌ CSDG ដែលត្រូវបានអនុម័ត (ខែធ្នូ ឆ្នាំ២០១៨) រួមទាំង៖<br>o គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងនិងក្នុងចំណោមបណ្តាប្រទេសនានា<br>o ទិសដៅដែលត្រូវបានអនុម័តចំនួនពីរ នៃ CSDG ទី១៦"លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន ដើម្បីអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័ន ដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត"។ |

# ការជួបជុំដោយសន្តិវិធី

## ទិដ្ឋភាពរួម

សិទ្ធិប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិបង្កើតសមាគម គឺជាសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ដោយច្បាប់ និងចែងក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងស្ថិតក្រោមមាត្រា ៣១ មាត្រា ៤១ និងមាត្រា ៤២[82] ដែលខ្លឹមសារផ្ទាល់ទៅនឹងច្បាប់របស់កម្ពុជា។ រដ្ឋធម្មនុញ្ញទទួលស្គាល់ និងធានាច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលយោងយ៉ាងជាក់លាក់ទៅនឹងសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិបង្កើតសមាគមស្ថិតក្រោម៖

- មាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)។
- មាត្រា ២១ & ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និង
- មាត្រា១៥ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

ការប្រមូលផ្តុំដោយសន្តិវិធី គឺជាពាក្យទូលំទូលាយមួយដែលគ្រប់ដណ្តប់លើគ្រប់ប្រភេទទាំងអស់នៃការប្រមូលផ្តុំ រួមទាំងការធ្វើបាតុកម្មដោយសន្តិវិធីផងដែរ។ សិទ្ធិប្រមូលផ្តុំដោយសន្តិវិធី ត្រូវបានទទួលស្គាល់ថាជាសិទ្ធិមូលដ្ឋានមួយ ដែលត្រូវបានធានាស្ថិតក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ វិធានទូទៅគឺថា "ការរឹតបន្តឹងណាមួយដែលបានដាក់លើសេរីភាពបែបនេះ ត្រូវបានហាមឃាត់ លុះត្រាតែការរឹតបន្តឹងនោះមានចែងដោយច្បាប់ ជាកម្មវត្ថុចំពោះការធ្វើតេស្តតឹងរ៉ឹងនៃភាពចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ និងត្រូវបានដាក់ដើម្បីតែប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាព និងសីលធម៌សាធារណៈ ឬការការពារសិទ្ធិសេរីភាពរបស់អ្នកដទៃ" (UN ឆ្នាំ២០១៩)។

ទោះជាយ៉ាងនេះក្តី វាគឺជាចំណុចចុងក្រោយ ដែលជាញឹកញាប់ត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជា ដើម្បីដាក់កម្រិត និងកាត់បន្ថយសេរីភាព។ ក្នុងឆ្នាំ២០០៩ កម្ពុជាបានអនុម័តច្បាប់ជាតិមួយស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលកំណត់អ្វីដែលត្រូវបានចាត់ទុកថាជាការធ្វើបាតុកម្មដោយសន្តិវិធីក្នុងប្រទេស។ ច្បាប់នេះក៏បានបង្កើតបណ្តុំនីតិវិធីមួយផងដែរសម្រាប់ការជូនដំណឹងទៅកាន់អាជ្ញាធរ។ ស្ថិតក្រោមមាត្រា ៤ នៃច្បាប់នេះ ការធ្វើបាតុកម្មដោយសន្តិវិធីត្រូវបានទទួលស្គាល់ថាជា៖

១. ការប្រមូលផ្តុំ ឬការដើរជាក្បួនដោយសន្តិវិធី ដែលធ្វើឡើងដោយមនុស្សមួយក្រុម។
២. ដើម្បីទាមទារជាសាធារណៈ ឬបញ្ចេញអារម្មណ៍ ទស្សនៈ ឬឆន្ទៈរបស់ពួកគេ។
៣. តាមរយៈការប្រើប្រាស់ទម្រង់ ឬមធ្យោបាយផ្សេងៗដោយសន្តិវិធី។

---

82 http://cambodia.ohchr.org/en/civil-society-fund-freedoms/freedom-peaceful-assembly-association

ការវិភាគនេះមានបំណងពិនិត្យមើលទូទៅនូវការបកស្រាយ និងការអនុវត្តមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ក្នុងច្បាប់ជាតិក្នុងប្រទេសកម្ពុជាតាមរយៈបទប្បញ្ញត្តិនៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ ការវិភាគនេះសម្លឹងមើលការអនុវត្តសិទ្ធិ និងច្បាប់លើប្រជាពលរដ្ឋរបស់ខ្លួនដែលជាបុគ្គល និងក្រុម ដើម្បីអនុវត្តសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំរបស់ពួកគេ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងអនុលោមតាមស្តង់ដារអន្តរជាតិ និងការប្រតិបត្តិដ៏ប្រសើរលើសេរីភាពមូលដ្ឋាន និងសិទ្ធិមនុស្ស។

រដ្ឋធម្មនុញ្ញទទួលស្គាល់ឧបករណ៍សិទ្ធិមនុស្សអន្តរជាតិនានាដូចជា ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)។ រដ្ឋធម្មនុញ្ញធានាថា *"ប្រជាពលរដ្ឋមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"* (រដ្ឋសភាជាតិកម្ពុជាឆ្នាំ១៩៩៣)។ ពិសេសជាងនេះទៀត មាត្រា ៤១នៃរដ្ឋធម្មនុញ្ញធានាថា *"ប្រជាពលរដ្ឋមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ*។ ដោយប្រកាន់ខ្ជាប់ទៅនឹងបទប្បញ្ញត្តិច្បាប់នេះ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ"។

គម្រោងពិនិត្យតាមដានសេរីភាពមូលដ្ឋាន (ឆ្នាំ២០១៧) ដែលកំពុងធ្វើឡើង ដែលជាគំនិតផ្តួចផ្តើមរួមគ្នាមួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) មជ្ឈមណ្ឌលអាមេរិកកាំងដើម្បីសាមគ្គីភាពការងារអន្តរជាតិ (ACILS) បានសន្និដ្ឋានថា ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីរបស់កម្ពុជា អនុលោមតាមជាខ្លាំងទៅនឹងស្តង់ដារ និងការប្រតិបត្តិអន្តរជាតិ។ ទោះជាយ៉ាងណា ការបកស្រាយខុសនិងភាពមិនច្បាស់លាស់ផ្នែកទស្សនទាននៃបទប្បញ្ញត្តិច្បាប់ក្នុងស្រុក ដែលបង្កឡើងដោយអ្នកតំណាងរបស់អាជ្ញាធរសាធារណៈ បង្កឲ្យមានការរំលោភសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិផ្សេងៗទៀត។

លើសពីនេះទៀត ការសិក្សាបានរកឃើញថា លក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលកាន់តែតឹងរ៉ឹង ការរឹតបន្តឹង និងការជ្រៀតជ្រែក ត្រូវបានជួបប្រទះដោយអ្នកតំណាងរបស់អង្គការសង្គមស៊ីវិល បន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈ (ការជូនដំណឹងបីថ្ងៃអំពីការប្រមូលផ្តុំសាធារណៈ) ត្រូវបានដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងខែតុលា ឆ្នាំ២០១៧។

## លទ្ធផលរកឃើញ និងការវិភាគ

បទប្បញ្ញត្តិច្បាប់មួយចំនួននៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ ទំនងជាត្រូវបានបកស្រាយខុសជាញឹកញាប់ និងអនុវត្តតាមតែទំនើងចិត្តដោយតំណាងរបស់អាជ្ញាធរសាធារណៈនៅកម្រិតផ្សេងៗ និងនៅទីតាំងផ្សេងៗ។ ការបកស្រាយខុស និងភាពមិនច្បាស់លាស់ផ្នែកទស្សនទានកើតមានឡើងដោយសារភាសាក្នុងច្បាប់មិនច្បាស់លាស់ (មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១១)។ ការណ៍នេះជាញឹកញាប់បង្កឲ្យអ្នកតំណាងរបស់អាជ្ញាធរសាធារណៈរំលោភសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិមនុស្សផ្សេងទៀតរបស់បុគ្គល និងក្រុមមនុស្ស។ ប្រព័ន្ធផ្សព្វផ្សាយ និងផ្លែតហ្វមផ្សេងៗជាញឹកញាប់បានរាយការណ៍ថា សកម្មជនសិទ្ធិមនុស្ស និងអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលបានជួបប្រទះប្រភេទផ្សេងៗនៃលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាល ការទន្ទ្រាន ការជ្រៀតជ្រែក ការរំលោភបំពាន ការរឹតបន្តឹង ការគាបសង្កត់ទាក់ទងនឹងការអនុវត្តសេរីភាពជាមូលដ្ឋាន។ ការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើការយល់ឃើញរបស់អ្នកតំណាងអង្គការសង្គមស៊ីវិលដែលភាគច្រើនធ្វើការងារក្នុងវិស័យសង្គម ដូចជាការអប់រំ សុខាភិបាល កសិកម្ម និងវិស័យអភិវឌ្ឍន៍ផ្សេងទៀតដូចដែលមានបង្ហាញក្នុងទំព័រកន្លងមកនៃរបាយការណ៍នេះ។

ការបកស្រាយខុសនៃបទប្បញ្ញត្តិច្បាប់ក្នុងស្រុកទាក់ទងនឹងសេរីភាពជាមូលដ្ឋាន ដោយអ្នកតំណាងរបស់ស្ថាប័នសាធារណៈ បានរាយការណ៍ថាបានបង្កឲ្យមានការរំលោភសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី។ សេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី គ្រប់គ្រងដំណើរការមួយដើម្បីធានាអត្ថិភាពនិងមុខងារនៃការប្រមូលផ្តុំដោយសន្តិវិធី។ ម្យ៉ាងវិញទៀត ការយល់ដឹងសាធារណៈអំពីសេរីភាពមូលដ្ឋានក្នុងការប្រមូលផ្តុំរបស់ពួកគេនៅតែមានកម្រិត (គម្រោងពិនិត្យតាមដានសេរីភាពជាមូលដ្ឋាន (FFMP) ឆ្នាំ២០១៨)។ ការអនុវត្តបទប្បញ្ញត្តិច្បាប់នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានរាយការណ៍ថាមានភាពខុសគ្នាដោយខេត្តផ្សេងៗនៅទូទាំងប្រទេស។

តំណាងរបស់អង្គការសង្គមស៊ីវិល ដែលបានពិគ្រោះយោបល់ បានជួបប្រទះប្រភេទផ្សេងៗនៃលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាល ការទន្ទ្រាន ការជ្រៀតជ្រែក ការរំលោភបំពាន ការរឹតបន្តឹង និងការគាបសង្កត់ទាក់ទងការរៀបចំផែនការ ការផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម និងការរៀបចំការប្រមូលផ្តុំសាធារណៈ។ នៅពេលត្រូវបានសួរ អ្នកតំណាងរបស់អង្គការសង្គមស៊ីវិល មួយភាគប្រាំ (ប្រហែល ២១%) បានយល់ឃើញថា សេរីភាពក្នុងការប្រមូលផ្តុំ និងសិទ្ធិរៀបចំព្រឹត្តិការណ៍សាធារណៈមានភាពប្រសើរឡើងធៀបនឹងឆ្នាំ២០១៥។ ទោះជាយ៉ាងណា ៥៩% បានជឿថា វាបានធ្លាក់ចុះ (នៅខាងឆ្វេងដៃ)។

អង្គការសង្គមស៊ីវិល ៨៩ភាគរយ បានរាយការណ៍ពីការព្យាយាមជូនដំណឹងដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬទាំងពីរទម្រង់ទៅកាន់អាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំសកម្មភាព។ គួរចាំថា ការជូនដំណឹងគឺជាកាតព្វកិច្ចច្បាប់ចាប់ពីខែតុលា ឆ្នាំ២០១៧។ អ្នកតំណាងមកពីផ្នែកផ្សេងៗនៃប្រទេសជាញឹកញាប់បានរាយការណ៍ពីការត្រូវបានតម្រូវដោយអាជ្ញាធរមូលដ្ឋាន (នៅថ្នាក់ស្រុក និងថ្នាក់ឃុំ)

ឲ្យសុំ "ការអនុញ្ញាត/ការអនុម័ត" ជាមុនទៅតាមសេចក្តីណែនាំរបស់ក្រសួងឆ្នាំ២០១៧។ អង្គការសង្គមស៊ីវិល១០ភាគរយ បានរាយការណ៍ពីការមិនជួបប្រទះការតម្រូវឲ្យជូនដំណឹងទៅកាន់អាជ្ញាធរជាមុន។







ការពិភាក្សាក្រុមគោលដៅ (FGDs) បានអះអាងថា ភាគច្រើននៃសកម្មភាពដែលត្រូវបានរៀបចំដោយអង្គការសង្គមស៊ីវិល រួមទាំងការអប់រំ និងសុខាភិបាលដែលត្រូវមានការប្រមូលផ្តុំ ត្រូវបានចូលរួមដោយអាជ្ញាធរមូលដ្ឋាននៅក្នុងន័យថា ពួកគេសង្កេតមើលសកម្មភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងដែនដីមូលដ្ឋានរបស់ពួកគេ។ អង្គការសង្គមស៊ីវិលមួយចំនួនបានរាយការណ៍ថា លក្ខខណ្ឌតម្រូវឲ្យជូនដំណឹងទៅកាន់អាជ្ញាធរបានចាប់ផ្តើមកើនឡើងចាប់ពីឆ្នាំ២០១៣ទៅ។

របាយការណ៍ប្រចាំឆ្នាំចំនួនបីរបស់គម្រោងពិនិត្យតាមដានសេរីភាពជាមូលដ្ឋាន (FFMP) ចាប់ពីឆ្នាំ២០១៦មក ចែករំលែកភស្តុតាងមួយចំនួននៃបទពិសោធអង្គការសង្គមស៊ីវិលដែលបានជួបប្រទះការរំលោភបំពានសិទ្ធិក្នុងការជួបជុំ ចាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០១៨។ កាលពីឆ្នាំ២០១៧ រហូតដល់ត្រីមាសទីមួយឆ្នាំ២០១៩ គម្រោង FFMP បានរាយការណ៍ថា យ៉ាងហោចណាស់មានព្រឹត្តិការណ៍រំលោភសិទ្ធិក្នុងការជួបជុំចំនួន២១០ លើក ត្រូវបានរាយការណ៍ទៅកាន់ស្ថាប័នដែលពាក់ព័ន្ធ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ក្រសួងមហាផ្ទៃបានលុបចោលលក្ខខណ្ឌតម្រូវឲ្យជូនដំណឹងជាមុន សម្រាប់សកម្មភាពរបស់អង្គការសង្គមស៊ីវិល។ បើទោះជាមានការវិវឌ្ឍវិជ្ជមាននេះក្តី ក៏គម្រោង FFMP បានកត់ត្រាព្រឹត្តិការណ៍ចំនួនប្រាំមួយ (រហូតដល់ខែមីនា ឆ្នាំ២០១៩) ដែលអាជ្ញាធរបានរារាំងសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដោយស្វែងរកភស្តុតាងដែលបញ្ជាក់ពីការបានជូនដំណឹង ឬការអនុញ្ញាតឲ្យរៀបចំសកម្មភាព បើទោះជាបន្ទាប់ពីមានការលុបចោលការតម្រូវឲ្យជូនដំណឹងនេះក៏ដោយ។

ការអង្កេតលើអ្នកឆ្លើយតបជាអង្គការសង្គមស៊ីវិលចំនួន ៦៧អង្គការក្នុងការសិក្សានេះ បានរកឃើញថា ក្នុងអំឡុងពេលស្រាវជ្រាវនេះ (ពីឆ្នាំ២០១៥-២០១៩) ៦៤% បានរាយការណ៍ថា ពួកគេបានជួបប្រទះទម្រង់នៃការរឹតបន្តឹងមួយចំនួន ដែលត្រូវបានដាក់ដោយអាជ្ញាធរសាធារណៈទៅលើការរៀបចំការប្រមូលផ្តុំសាធារណៈឬដោយសន្តិវិធី។ មាន១៥% បានរាយការណ៍ថា ពួកគេមិនបានជួប

ប្រទះការរឹតបន្តឹង ដោយអាជ្ញាធរសាធារណៈទៅលើការរៀបចំការប្រមូលផ្តុំសាធារណៈ ឬដោយសន្តិវិធីឡើយ។ ២១% មិនបានផ្តល់មតិយោបល់ណាមួយឡើយទាក់ទងនឹងការរឹតបន្តឹងដែលត្រូវបានដាក់ដោយអាជ្ញាធរសាធារណៈនៅក្នុង ភូមិសាស្ត្រខេត្តនៃអង្គការទាំងនោះ។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងឆ្នាំ២០១៣* | *ស្ថានភាពក្នុងឆ្នាំ២០១៥-២០១៩* |
|---|---|
| លក្ខខណ្ឌតម្រូវរបស់ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ ដាក់ការរឹតបន្តឹងលើលទ្ធភាពរបស់អង្គការសង្គមស៊ីវិលក្នុងការរៀបចំការប្រមូលផ្តុំ និងព្រឹត្តិការដោយសន្តិវិធីនានា។<br>ការរំលោភបំពានអំណាច និងការរឹតបន្តឹង បានកើតមានឡើងក្នុងឆ្នាំ២០១៣ បើទោះជាវាមានភាពខុសគ្នាទៅតាមទីតាំងក៏ដោយ។។<br>លក្ខខណ្ឌតម្រូវបែបកាតព្វកិច្ចឲ្យអ្នករៀបចំត្រូវបានកំណត់អត្តសញ្ញាណ និងអាចកំណត់អត្តសញ្ញាណបាន គឺជាប្រភពនៃការបំភិតបំភ័យដែលអាចកើតមាន។ | ភាពញឹកញាប់និងព្រឹត្តិការណ៍កើតមានការរឹតបន្តឹងលើការប្រមូលផ្តុំ និងបាតុកម្មជា សាធារណៈ មានកម្រិតខ្ពស់ជាងនាពេលកន្លងមក ខណៈដែលរដ្ឋាភិបាលបានដាក់ចេញឧបករណ៍ច្បាប់មួយដែលតម្រូវឲ្យមានការជូនដំណឹងជាមុនអំពីសកម្មភាព (ក្នុងភូមិ) ដែលត្រូវបានរៀបចំឡើងដោយអង្គការសង្គមស៊ីវិល។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

| បញ្ហាប្រឈម | ការផ្តល់យោបល់ |
|---|---|
| ➢ អាជ្ញាធរបន្តទាមទារឲ្យមានលក្ខខណ្ឌតម្រូវ "អនុម័ត" នៅក្នុងតំបន់មួយចំនួន<br>➢ កង្វះការយល់ដឹងដោយអាជ្ញាធរ អង្គការសង្គមស៊ីវិល និងសាធារណៈជនអំពីសិទ្ធិរបស់ពួកគេ<br>➢ ការអនុវត្ត/អនុលោមភាពខ្សោយចំពោះនីតិរដ្ឋនៅក្នុងការបកស្រាយតាមតែទំនើងចិត្តនូវក្របខ័ណ្ឌច្បាប់ជាធរមាន ឈានទៅរកការរឹតបន្តឹងដែលខុសច្បាប់<br>➢ កង្វះយន្តការគណនេយ្យភាពឬយន្តការកែតម្រូវ<br>➢ កង្វះប្រព័ន្ធត្រួតពិនិត្យតាមដានទូលំទូលាយការរំលោភសិទ្ធិមនុស្សដែលមានតម្លាភាពនៅទូទាំងប្រទេស ។ | ➢ លើកកម្ពស់ការផ្សព្វផ្សាយ និងការប្រកាន់ខ្ជាប់ទៅនឹងក្របខ័ណ្ឌច្បាប់ដោយមន្ត្រីទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងមន្ត្រីអនុវត្តច្បាប់មូលដ្ឋាន។<br>➢ ពង្រីកសកម្មភាពកសាងសមត្ថភាព ដើម្បីបង្កើតការយល់ដឹងអំពីច្បាប់និងសិទ្ធិដោយមន្ត្រី អង្គការសង្គមស៊ីវិលនិងសាធារណៈ។<br>➢ ស្នើសុំឲ្យរដ្ឋាភិបាលបង្កើតប្រព័ន្ធគណនេយ្យភាពនិងកែតម្រូវមួយ ដើម្បីតាមដានការយល់ដឹងខុស និងការរំលោភសិទ្ធិ និងក្របខ័ណ្ឌច្បាប់។<br>➢ លើកកម្ពស់ការពិនិត្យតាមដានការរំលោភសិទ្ធិដោយឯករាជ្យ។ |

# *ពន្ធដារ*

## ទិដ្ឋភាពរួម

គ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកអនុវត្តរបបពន្ធដារតាមទម្រង់ផ្សេងៗ។ ផ្នែកនេះរុករកស្ថានភាព ដែលកំពុងវិវឌ្ឍន៍ទាក់ទងនឹងការអនុវត្តច្បាប់ពន្ធ និងលក្ខខណ្ឌតម្រូវចំពោះអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ ផ្នែកនេះផ្តោតការយកចិត្តទុកដាក់លើថាតើពន្ធអ្វីដែលត្រូវបានដាក់លើធនធានហិរញ្ញវត្ថុ និងប្រាក់ចំណូលរបស់អង្គការសង្គមស៊ីវិល? តើពន្ធទាំងនោះប៉ះពាល់ដល់ប្រាក់ចំណូលដែលរកបាន ជំនួយឥតសំណង ការវិនិយោគ ឬទំនិញនិងសេវាកម្មដែលបានទិញរបស់អង្គការទាំងនោះ ដែរឬទេ? តើអង្គការសង្គមស៊ីវិលគឺជា កម្មវត្ថុចំពោះពន្ធថ្នាក់មូលដ្ឋាន ប្រាក់កម្រៃ ឬការចំណាយនានា ក្រៅពីពន្ធថ្នាក់ជាតិ? តើអ្វីគឺជាលក្ខខណ្ឌតម្រូវផ្នែកពន្ធ និងបទប្បញ្ញត្តិចំពោះអង្គការសង្គមស៊ីវិល ដែលមានការពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច? តើអង្គការសង្គមស៊ីវិលត្រូវបានផ្តល់ករលើកលែងពន្ធ ពិសេសណាមួយដែរឬទេ? តើច្បាប់/បទប្បញ្ញត្តិស្តីពីពន្ធត្រូវបានអនុវត្តក្នុងកម្រិតណា? តើពន្ធត្រូវបានបង់ទៀងទាត់ដែរឬទេ?

## លទ្ធផលរកឃើញ និងការវិភាគ

### *របបពន្ធដែលកំពុងវិវឌ្ឍន៍*

ពន្ធគឺជាប្រភពប្រាក់ចំណូលដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលទាំងអស់ ដែលអាចឲ្យរដ្ឋាភិបាលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសក្នុងការធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាព ការអប់រំ និងកាត់បន្ថយភាពក្រីក្រក្នុងប្រទេស។ ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកមូលដ្ឋានពន្ធរបស់ខ្លួន ខណៈដែលប្រទេសជាតិអភិវឌ្ឍទៅមុខ។ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ មានចែងអំពីក្របខ័ណ្ឌពន្ធបឋម និងការប៉ុនប៉ងបឋម ដើម្បីប្រមូលប្រាក់ចំណូលពន្ធ។ រដ្ឋាភិបាលបានពង្រីកនិយមន័យនៃវាក្យស័ព្ទទាំងឡាយណា ដែលច្បាប់ស្តីពីសារពើពន្ធនឹងត្រូវអនុវត្ត និងអ្នកដែលនឹងត្រូវបង់ពន្ធ។ ស្ថិតក្រោម "ពាក្យ នីតិបុគ្គល" ពាក្យនេះអាចមានន័យថាជាសហគ្រាស ឬអង្គការណាមួយដែលអនុវត្តអាជីវកម្មមិនថាត្រូវបានទទួលស្គាល់ជាផ្លូវការដោយស្ថាប័ន មានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលឬអត់នោះទេ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលស្ថាប័នរបស់រដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ សម្រាប់អនិវាសនជន ពាក្យ "នីតិបុគ្គល" មានន័យថាជាគ្រឹះស្ថានអចិន្ត្រៃយ៍ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។ ពាក្យ "នីតិបុគ្គល" មិនរួមបញ្ចូលក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គលឡើយ[83]។ ដូច្នេះចាប់ពីឆ្នាំ ១៩៩៧មក អង្គការសង្គមស៊ីវិលទទួលខុសត្រូវលើការបង់ពន្ធ។

ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ពិតជាបានរួមបញ្ចូលបទប្បញ្ញត្តិសម្រាប់ការលើកលែងពន្ធលើប្រាក់ចំណូល រួមទាំងប្រាក់ចំណូលរបស់អង្គការ (មាត្រា ៩.២) ជាមួយនឹងលក្ខខណ្ឌតម្រូវថា (ក) អង្គការដែលត្រូវបានលើកលែងពន្ធ ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ (ខ) និងថា គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់

---

83 RGC (1997) Law on Taxtation, Article3.2, 24/2/1997 http://www.bigpond.com.kh/Council_of_Jurists/Fiscal/fsc001g.htm

ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន (មាត្រា ៩.១ ក)។ ច្បាប់នេះមានចែងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្សរួមបញ្ចូលទាំងការចាត់ទុកអង្គការមិនស្វែងរកប្រាក់ចំណេញ ថាជានិយោជក (មាត្រា ៤២) ដើម្បីដកហូតពន្ធលើនិយោជិត។ ច្បាប់នេះក៏អនុញ្ញាតឲ្យមានការលើកលែងពន្ធលើប្រាក់បៀវត្សផងដែរចំពោះបុគ្គលិកការទូត និងបុគ្គលិកប្រទេសផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ បើទោះជាទទួលស្គាល់ផ្នែកការទូតបែបនេះត្រូវធ្វើឡើង ដោយឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធក្តី (មាត្រា ៤៣)។

មូលដ្ឋានពន្ធរបស់កម្ពុជាបានកើនឡើង ប៉ុន្តែនៅតែត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់។ មានការរាយការណ៍ថា ពន្ធដែលប្រមូលបានក្នុងឆ្នាំ២០១៨ បានកើនឡើង ១៧% ធៀបនឹងឆ្នាំ២០១៧[84] ខណៈដែលអគ្គនាយកដ្ឋានពន្ធដារ បានអនុវត្តជំនាញដែលកំពុងកើនឡើងរបស់ខ្លួន។ ការពិតក្នុងរយៈពេលថ្មីៗបំផុតនេះ រដ្ឋាភិបាលបានប្រកាសថា ខ្លួនបានប្រមូលពន្ធបានចំនួន ១,៩ពាន់លានដុល្លារអាមេរិកក្នុងអំឡុងត្រីមាសទីមួយឆ្នាំ២០១៩។ ការកើនឡើងមូលធនពន្ធទាំងនេះ គឺជាលទ្ធផលនៃការកើនឡើងសេដ្ឋកិច្ច និងកំណែទម្រង់របស់រដ្ឋាភិបាលដែលកំពុងធ្វើឡើង។ កំណែទម្រង់ពន្ធបានកំពុងត្រូវបានអនុវត្តឡើងជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៤មក[85] ដែលបានដាក់ចេញប្រព័ន្ធរបបស្វ័យប្រកាស។ កំណែទម្រង់ខ្លាំងក្នុងឆ្នាំ ១៩៩៧ នោះគឺនៅពេលដែលច្បាប់ស្តីពីសារពើពន្ធត្រូវបានដាក់ឲ្យអនុវត្ត។

ក្នុងឆ្នាំ២០១៦[86] កំណែទម្រង់ធំៗផ្សេងទៀតត្រូវបានដាក់ចេញដោយរដ្ឋាភិបាល រួមទាំងការលុបចោលរបបពន្ធម៉ៅការ និងការផ្លាស់ប្តូរទៅជារបបពន្ធពិត។ កំណែទម្រង់ទាំងនេះរួមមានទាំងកំណែទម្រង់នីតិវិធីចុះបញ្ជីពន្ធ ការធ្វើឲ្យមានភាពសាមញ្ញចំពោះវិធានគណនេយ្យសម្រាប់អ្នកបង់ពន្ធ បង្កើនកម្រិតកំណត់អប្បបរមាសម្រាប់ពន្ធលើប្រាក់បៀវត្ស និងអាករលើតម្លៃបន្ថែមលើឧស្សាហកម្មជាក់លាក់ និងពន្ធអាករ។

រដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចប្រឹងប្រែងប្រមូលពន្ធប្រកបដោយនិរន្តរភាពរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ហើយមានការសង្កេតឃើញថា ប្រាក់ឈ្នួល។ល។ ក្នុងអង្គការសង្គមស៊ីវិលមានកម្រិតខ្ពស់ខ្លាំងជាងប្រាក់ចំណូលជាមធ្យម។ ដូច្នេះ រដ្ឋាភិបាលបានចាប់ផ្តើមធានាថា អង្គការមិនមែនរដ្ឋាភិបាល និងសមាគមអនុលោមយ៉ាងពេញលេញតាមច្បាប់ពន្ធដែលកំពុងវិវឌ្ឍន៍នេះ។ ទោះជាយ៉ាងណាដំណើរការនេះដែលរួមបញ្ចូលទាំងការធ្វើសវនកម្មលើកិច្ចការហិរញ្ញវត្ថុ របស់អង្គការសង្គមស៊ីវិលជួនកាលបានផ្តោតទិសដៅលើអង្គការមួយចំនួន ដែលរដ្ឋយល់ឃើញថាទទួលរងការគំរាមកំហែងពីអង្គការទាំងនោះ។ ខណៈដែលអង្គការជាច្រើនយល់ដឹងថា ច្បាប់ពន្ធត្រូវបានអនុវត្តទូទាំងសកលលោក (ដោយសារក្រុមហ៊ុនសវនកម្មភាគច្រើនបានជូនដំណឹងដល់អង្គការនានាចាប់តាំងពីច្បាប់នេះត្រូវបានដាក់ដំណើរការក្នុងឆ្នាំ១៩៩៧) អង្គការមួយចំនួនបានជំទាស់ទៅនឹងការអនុលោមតាមច្បាប់នេះ។

84 B2B Business (22/10/2018) Tax Collection Up 17.5 Percent, https://www.b2b-cambodia.com/news/tax-collection-up-17-5-percent/
85 Mr. Um SeihaDeputy Director General,General Department of Taxation, Cambodia, 2012. Cambodia: Tax Revenue Reform: Issues, Further reforms, IMF-High Level Tax Conference For Asian and Pacific Countries, Tokyo, JAPAN
86 Eurocham Cambodia, 2016. Whit Book: Trade and investment Policy Recommendation. Phnom Penh

ក្នុងឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសថ្មីមួយ (លេខ៤៦៤) ដែលគោលបំណងរបស់ប្រកាសនេះគឺដើម្បីពង្រឹងអនុលោមភាពពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈការផ្តល់ការណែនាំបន្ថែមអំពីអនុលោមភាពពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ និងច្បាប់ LANGO ជាធរមាន។ ច្បាប់តម្រូវថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវចុះបញ្ជីនៅរដ្ឋបាលពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិពន្ធជាធរមាន។ ច្បាប់ក៏អះអាងជាថ្មីផងដែរថា មូលនិធិសម្រាប់សមាគម និងអង្គការមិនមែន រដ្ឋាភិបាលត្រូវបានលើកលែងពន្ធ ប៉ុន្តែការលើកលែងពន្ធបែបនេះបច្ចុប្បន្នចាំបាច់ត្រូវអនុវត្តឡើងសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយដាក់ពាក្យ និងភ្ជាប់ឯកសារចុះបញ្ជី និងឯកសារគាំទ្រផ្សេង។

ក្នុងខែមិថុនា ឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីជូនដំណឹង (លេខ ៣៨៣៥) ដោយតម្រូវថា រាល់សហគ្រាសទាំងអស់ត្រូវដោះស្រាយបំណុលពន្ធមុនដំណាច់ខែមិថុនា ឆ្នាំ២០១៥ បើមិនដូច្នេះទេគណនីធនាគាររបស់សហគ្រាសទាំងនោះនឹងត្រូវបានបង្កក ឬដកយកទ្រព្យសម្បត្តិជាការធានា (Martin Gemsell ឆ្នាំ២០១៧)។ វិធានការខ្លាំងដើម្បីទារបំណុលចាស់ ដែលធ្វើឡើងចំពោះសហគ្រាសនេះ មិនទំនងជាផាត់ចេញអង្គការមិនមែនរដ្ឋាភិបាល ដែលនឹងទទួលបានការព្រឹត្តិផ្សេងឡើយ ជាពិសេសក្នុងស្ថានភាព ដែលអាជ្ញាធរមានលទ្ធភាពពេញលេញក្នុងការទទួលបានរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាល/សមាគម[87]។ ស្ថិតក្រោមមាត្រា ២៥ នៃច្បាប់ LANGO ច្បាប់នេះតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាល ដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ ឬរបាយការណ៍ហិរញ្ញវត្ថុទាក់ទងនឹងគម្រោង។ ច្បាប់នេះក៏តម្រូវឲ្យផ្តល់អំណាចដល់អាជ្ញាធរនានា ដើម្បីស្នើសុំរបាយការណ៍ហិរញ្ញវត្ថុ និងធ្វើសវនកម្មលើអង្គការមិនមែនរដ្ឋាភិបាល/សមាគម។

អ្នកឆ្លើយតបមួយចំនួនបានបង្ហាញក្តីបារម្ភអំពីហានិភ័យ នៃការបង់ពន្ធប្រតិសកម្ម ដែលត្រូវបានអនុវត្តលើអង្គការមិនមែនរដ្ឋាភិបាល។ បើទោះជាមិនទាន់មានអ្នកឆ្លើយតបណាមួយជួបប្រទះការស្នើសុំឲ្យបង់ពន្ធត្រលប់ថយក្រោយ ដែលគិតចាប់ពីពេលដែលអង្គការត្រូវបានចុះបញ្ជីដំបូងក៏ដោយ ក៏បទសម្ភាសបញ្ជាក់ពីភាពតាមតែទំនើងចិត្តក្នុងការទាមទារដែលត្រូវបានធ្វើឡើងដោយមន្ត្រីពន្ធ នៅពេលអង្គការមិនមែនរដ្ឋាភិបាលព្យាយាមចាប់ផ្តើមបង់ពន្ធរបស់ខ្លួន។ ជួនកាលអាជ្ញាធរមិនតម្រូវឲ្យបងពន្ធប្រតិសកម្មណាមួយទាល់តែសោះ ខណៈដែលអាជ្ញាធរខ្លះទៀតបានទាមទារឲ្យបង់ពន្ធក្នុងទឹកប្រាក់ស្មើនឹងការបង់ពន្ធត្រលប់ថយក្រោយវិញរយៈពេលមួយឆ្នាំ។ ក្តីបារម្ភអំពីការជាសះស្បើយឡើងវិញដ៏លំបាកពីការទូទាត់បំណុលពន្ធត្រលប់ថយក្រោយ អាចគំរាមកំហែងដល់អត្ថិភាពរបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើន ជាពិសេសអង្គការដែលមានអាយុកាលកាន់តែច្រើន ប្រសិនបើបំណុលត្រូវតែទូទាត់គិតពីពេលចុះបញ្ជីដំបូង (Martin Gemsell ឆ្នាំ២០១៧)។ ការពិត ការទាមទាររបស់រដ្ឋាភិបាលឲ្យទូទាត់បំណុលពន្ធត្រលប់ថយក្រោយ ត្រូវបានប្រើប្រាស់ ដើម្បីបិទកាសែតខេមបូឌាដេលីក្នុងឆ្នាំ២០១៧ ហើយមានការរាយការណ៍ពីការធ្វើបែបនេះចំពោះការិយាល័យរបស់វិទ្យុ

87 Ibid

អាស៊ីសេរីនៅកម្ពុជា ដោយស្ថាប័នទាំងពីរនេះច្បាស់ណាស់មិនបានអនុលោមតាមកាតព្វកិច្ចពន្ធ។

ច្បាប់ស្តីពីសារពើពន្ធ (LOT) ឆ្នាំ១៩៩៧ ផ្តល់ជូនការលើកលែងពន្ធលើប្រាក់ចំណូលដល់អង្គការសង្គមស៊ីវិល រួមទាំងប្រាក់ចំណូលពីសកម្មភាពសេដ្ឋកិច្ច និងកិច្ចសន្យារដ្ឋាភិបាល។ ទោះជាយ៉ាងណា ការលើកលែងបែបនេះតម្រូវឲ្យមានការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ ២០១៧ ច្បាប់ស្តីពីសារពើពន្ធត្រូវបានអនុវត្តកាន់តែតឹងរ៉ឹង ហើយអង្គការសង្គមស៊ីវិល បានយល់ឃើញថា កាន់តែលំបាកក្នុងការទទួលបានការលើកលែងពន្ធ។ អង្គការសង្គមស៊ីវិលមួយចំនួនជឿថា ការណ៍នេះត្រូវបានធ្វើឡើងដើម្បីបង្កើនចំណូលពន្ធ។ លើសពីនេះទៀត អង្គការសង្គមស៊ីវិល ដែលប្រតិបត្តិការសហជីពឥណទានដោយមិនបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ដែលលក្ខខណ្ឌតម្រូវនេះមិនត្រូវបានយល់ដឹង ឬអនុវត្តនាពេលកន្លងមក ទទួលបានលិខិតដែលតម្រូវឲ្យអង្គការបិទទ្វារ។ ច្បាប់ពន្ធឆ្នាំ១៩៩៧ មានបទប្បញ្ញត្តិមួយដែលមានចែងអំពីការដាត់ចេញនូវវិភាគទានសប្បុរសធម៌រហូតដល់ ៥% នៃប្រាក់ចំណេញជាប់ពន្ធ (មាត្រា ១៦ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧)

*ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មឆ្នាំ២០១៦*

ក្នុងខែមករា ឆ្នាំ២០១៦ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីគណនេយ្យ និងសវនកម្មថ្មីមួយដែលគ្រប់គ្រងនីតិវិធីគណនេយ្យ និងសវនកម្មសម្រាប់អង្គការផ្សេងៗ ដែលបច្ចុប្បន្នច្បាប់នេះកំពុងរង់ចាំការអនុម័តពីព្រឹទ្ធសភា។ នៅតែមានការមើលឃើញថា តើច្បាប់នេះនឹងត្រូវបានអនុវត្តយ៉ាងដូចម្តេច និងថាតើច្បាប់នេះនឹងពង្រីកលក្ខខណ្ឌតម្រូវទៅលើអង្គការឲ្យអនុវត្តសវនកម្មខាងក្រៅឬយ៉ាងណា (Gemsell ឆ្នាំ២០១៧)។

*កម្រិតយល់ដឹងអំពីរបបពន្ធដោយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល*




ការសិក្សានេះបានសាកសួរអ្នកឆ្លើយតបដែលជាអង្គការសង្គមស៊ីវិលចំនួន៦៧ អំពីផលប៉ះពាល់នៃការបង់ពន្ធលើអង្គការរបស់ពួកគេ។ ខណៈដែលមួយភាគបី (៣៦%) នៃអ្នកឆ្លើយតបបានជឿថា ពួកគេទទួលរងផលប៉ះពាល់តិចតួចនោះ អ្នកឆ្លើយតបមួយភាគបី (៣៤%) ទៀតបានជឿថា កាតព្វកិច្ច ពន្ធមានឥទ្ធិពលខ្លះទៅលើអង្គការរបស់ពួកគេ។ ៣០% នៃអង្គការទាំងនេះជឿថា កាតព្វកិច្ចពន្ធមានផលប៉ះពាល់ខ្លាំង ឬខ្លាំងណាស់លើអង្គការរបស់ខ្លួន។ ជាធម្មតាអង្គការទាំងនេះគឺជាអង្គការសង្គមស៊ីវិលតូចៗ ដោយមានធនធានហិរញ្ញវត្ថុមានកម្រិត និងជាញឹកញាប់មានហិរញ្ញវត្ថុមិននឹងនរ ហើយកាតព្វកិច្ចពន្ធបានដាក់បន្ទុកបន្ថែមលើពួកគេ។

ពីបទសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) និងការពិភាក្សាក្រុមគោលដៅ (FGDs) សមាគម និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយចំនួន មិនទាន់បានយល់ដឹងពេញលេញ និងមិនបានយកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាពន្ធនៅឡើយទេ។ សមាគម និងអង្គការមួយចំនួនបានសន្មត់ទាំងខុសពីលក្ខខណ្ឌច្បាប់ថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលមិនស្វែងរកប្រាក់ចំណេញទាំងអស់ត្រូវបានលើកលែងពន្ធដោយស្វ័យប្រវត្តិ ដោយសារសកម្មភាពមនុស្សធម៌ ដែលជាការយល់នេះត្រូវបានក្រុមហ៊ុនសវនកម្មបាននិងកំពុងព្យាយាមកែតម្រូវការអស់ពេលមួយរយៈហើយ។ យោងតាមព្រឹត្តិប័ត្រច្បាប់ BNG ចេញផ្សាយខែតុលា ឆ្នាំ២០១៥ "ប្រសិនបើសវនករពន្ធរកឃើញថា អង្គការមិនមែនរដ្ឋាភិបាលមិនមិនអនុលោមតាមច្បាប់ពន្ធ ពួកគេត្រូវបានតម្រូវឲ្យមានការធានាថា អង្គការមិនមែនរដ្ឋាភិបាលបង់ពន្ធត្រលប់ថយក្រោយ បង់ពិន័យ និងអត្រាប្រាក់លើបរិមាណប្រាក់ពន្ធដែលមិនទាន់បង់គិតចាប់ពីថ្ងៃទីមួយនៃពន្ធដែលជំពាក់"[88]។

អង្គការមិនមែនរដ្ឋាភិបាលជាច្រើន មិនយល់ពេញលេញអំពីតម្រូវការឲ្យអនុលោមតាមបទប្បញ្ញត្តិពន្ធឡើយ។ ការយល់ខុសថា អង្គការមិនមែនរដ្ឋាភិបាលគឺជាអង្គភាពដែលត្រូវបានលើកលែងពន្ធ អាចបង្កឲ្យមានទ្វេគ្រោះនៃការមានបន្ទុកបំណុលពន្ធ បន្ទាប់ពីរកឃើញថា អង្គការទាំងនោះត្រូវបានតម្រូវឲ្យទូទាត់ពន្ធដែលមិនទាន់បង់ទាំងអស់ រួមទាំងប្រាក់ពិន័យ និងការប្រាក់[89]។ ឧទាហរណ៍ឆ្លើយតបទៅនឹងការធ្លាក់ចុះលំហរ និងបរិយាកាសច្បាប់ដែលរឹតបន្តឹងសម្រាប់សង្គមស៊ីវិល អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) សហការជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ក្រុមហ៊ុនច្បាប់ DFDL នៅកម្ពុជា បានផ្តល់ជំនួយផ្នែកច្បាប់ទាក់ទងនឹងច្បាប់ LANGO ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីការងារ ទៅដល់សមាជិក និងដៃគូ រួមទាំងបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត។ ទោះជាយ៉ាងណា ការអនុលោមតាមច្បាប់នៅតែមានការលំបាក ដោយសារការបកស្រាយច្បាប់មិនស៊ីចង្វាក់គ្នាដោយក្រុមមន្ត្រី (CSOSI ឆ្នាំ២០១៧)។

យោងតាមច្បាប់ LANGO និងបទប្បញ្ញត្តិផ្សេងទៀត ដែលពាក់ព័ន្ធនឹងពន្ធ ក្រៅពីពន្ធលើប្រាក់ចំណូល សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលត្រូវបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធកាត់ទុកលើប្រាក់បៀវត្ស ស្ថិតក្រោមមាត្រា២៥ មាត្រា២៦(១) និងមាត្រា៣១ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ និងបង់ពន្ធលើប្រាក់បៀវត្ស និងពន្ធផ្សេងៗទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិពន្ធបច្ចុប្បន្ន។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បច្ចុប្បន្នត្រូវធ្វើការប្រកាសប្រចាំខែអំពីពន្ធកាត់ទុករបស់ខ្លួន និងពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិក មិនថាជាអង្គការធំ ឬតូចឡើយ។

នៅពេលត្រូវបានសួរអំពីថា តើការដកហូតពន្ធនឹងត្រូវបានចាត់ទុកថាមានយុត្តិធម៌ដែរឬយ៉ាងណានោះ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនជឿថា វាមិនយុត្តិធម៌ឡើយដែលដកហូតពន្ធលើមូលនិធិដែលត្រូវបានប្រមូលពីការផ្តល់ជំនួយ ដោយសារម្ចាស់ជំនួយជាញឹកញាប់គឺជាប្រជាពលរដ្ឋឯក

[88] BNG Legal Newsletter, October 2015, page 1.
[89] Ibid

ជន ដែលបានបង់ពន្ធលើប្រាក់ចំណូលទៅតាមការតម្រូវរួចហើយ។ ទោះជាយ៉ាណា ពន្ធលើការជួលរថយន្ត និងប្រាក់បៀវត្ស ត្រូវបានយល់ឃើញថាមានភាពយុត្តិធម៌។ អ្នកចូលរួមក្នុងការសិក្សាមួយចំនួនបានលើកឡើងថា ពួកគេចង់មើលឃើញតម្លាភាពជាងនេះទាក់ទងនឹងពន្ធដែលត្រូវបានបង់ និងរបៀបដែលប្រាក់ពន្ធទាំងនោះត្រូវបានប្រើ។ មូលនិធិសោធនត្រូវបានលើកឡើងថាជាសកម្មភាពធម្មតាមួយដែលប្រាក់ចំណូលពន្ធគួរបញ្ចប់។ នៅពេលត្រូវបានសួរអំពីថាតើម្ចាស់ជំនួយមានអារម្មណ៍យ៉ាងដូចម្តេចអំពីការដកហូតពន្ធ ចម្លើយមានភាពខុសគ្នា ប៉ុន្តែសរុបមក ពន្ធហាក់ដូចជាមិនមែនជាក្តីបារម្ភធំឡើយសម្រាប់ម្ចាស់ជំនួយ (ដូចដែលបានមើលឃើញដោយអង្គការសង្គមស៊ីវិល)។

## *ការរំលោភបំពានដែលអាចកើតមានលើលក្ខខណ្ឌតម្រូវពន្ធសម្រាប់អង្គការមិនមែនរដ្ឋាភិបាល*

ដូចដែលបានលើកឡើង អ្នកសង្កេតការណ៍មួយចំនួនជឿថា លក្ខខណ្ឌតម្រូវបង់ពន្ធបានក្លាយជាឧបករណ៍នៃការគាបសង្កត់ចាប់ពីឆ្នាំ២០១៧មក។ យ៉ាងហោចណាស់មានអង្គការមិនមែនរដ្ឋាភិបាលធ្វើការខាងផ្នែកសិទ្ធិមនុស្សក្នុងស្រុកចំនួនបី (អង្គការ ADHOC អង្គការ COMFREL និងអង្គការ LICAHDO) ត្រូវបានកោះហៅទៅសាកសួរដោយនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំភ្លឺស្ថានភាពពន្ធរបស់ពួកគេ ក្នុងគ្រាដែលមានយុទ្ធនាការប្រមូលពន្ធខ្លាំង ដែលថ្មីៗនេះបានបាត់ទៅវិញ បន្ទាប់អង្គភាពព័ត៌មានខេមបូឌាដេលី វិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី[90]។ ខណៈពេលដែលរដ្ឋាភិបាលបានព្យាយាមជាយូរមកហើយ ដើម្បីកែលម្អការប្រមូលពន្ធរបស់ខ្លួន អង្គការសង្គមស៊ីវិលជាច្រើនដែលបានទទួលការកោះហៅពីនាយដ្ឋានពន្ធដារ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក៏បានបង្កឲ្យរដ្ឋាភិបាលខឹងសម្បារកាលពីអតីតកាលផងដែរ។ ក្នុងឆ្នាំ២០១៧ នាយករដ្ឋមន្ត្រីបានណែនាំអាជ្ញាធរពន្ធដារឲ្យស៊ើបអង្កេតថា តើអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាបានកំពុងបង់ពន្ធលើប្រាក់ចំណូលសម្រាប់បុគ្គលិករបស់ខ្លួនដែរឬយ៉ាងណា[91]។ ចាប់តាំងពីពេលបោះឆ្នោតឃុំ/សង្កាត់នៅខែមិថុនា ឆ្នាំ២០១៧ មក នាយករដ្ឋមន្ត្រីក៏បានចោទប្រកាន់បន្ទប់ស្ថានការណ៍ដែលជាសម្ព័ន្ធតាមដានការបោះឆ្នោត ដែលអង្គការទាំងបីនេះគឺជាសមាជិករបស់សម្ព័ន្ធនេះថាប្រតិបត្តិការដោយខុសច្បាប់[92]។ ខណៈពេលដែលអង្គភាពវិទ្យុ ដែលគាំទ្រដោយសហរដ្ឋអាមេរិកគឺវិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី ដែលត្រូវបានចោទប្រកាន់ជាយូរមកហើយដោយរដ្ឋាភិបាលថាមានភាពលម្អៀងទៅរកគណបក្សប្រឆាំងនោះ ក៏បានក្លាយជាចំណាប់អារម្មណ៍នៅសប្តាហ៍នេះផងដែរ បន្ទាប់ពីក្រសួងហិរញ្ញវត្ថុបានស្នើទៅកាន់ក្រសួងព័ត៌មានឲ្យជំរុញអង្គភាពព័ត៌មានទាំងនេះបង់ពន្ធរបស់ខ្លួន។

---

90 Leonie Kijewski and Niem Chheng, Phnom Penh Post 'Tax Department reaches out to NGOs', 15 August 2017, available at: https://www.phnompenhpost.com/national/tax-department-reaches-out-ngos

91 ibid

92 PPP (30/6/2017) Government probing 'Situation Room' https://www.phnompenhpost.com/national/government-probing-situation-room

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ ឆ្នាំ២០១៣* | *ក្នុងអំឡុងពេលពិនិត្យការសិក្សា (ឆ្នាំ២០១៥-២០១៩)* |
|---|---|
| បញ្ហាពន្ធមិនត្រូវបានគ្រប ដណ្តប់ឡើយក្នុងរបាយការណ៍ ឆ្នាំ២០១៣។ | ➢ ការពង្រីកសមត្ថភាពប្រមូលពន្ធរបស់រដ្ឋាភិបាលបានចាប់ផ្តើមបង្កើតឲ្យមានការប្រមូលចំណូលពន្ធកាន់តែប្រសើរពីអង្គការមិនមែនរដ្ឋាភិបាល។<br>➢ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានគេចវេសមិនបង់ពន្ធអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែបានបញ្ចប់ចាប់ពីឆ្នាំ២០១៨មកនៅពេលដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតម្រូវឲ្យអង្គការសង្គមស៊ីវិលទាំងអស់ចុះបញ្ជីពន្ធ និងបង់ពន្ធរបស់ពួកគេ។<br>➢ មានការសង្កេតឃើញថា អង្គការមិនមែនរដ្ឋាភិបាលដែលរិះគន់រដ្ឋាភិបាល ត្រូវបានកំណត់ទិសដៅសម្រាប់អនុលោមភាពពន្ធ ក្នុងឆ្នាំ២០១៧ ហើយក្រោយមកបង្ហាញឲ្យឃើញពីកង្វះភាពមិនលម្អៀងក្នុងនីតិរដ្ឋ និងការអនុវត្តរបស់ខ្លួន។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

| **បញ្ហាប្រឈម** | **ការផ្តល់យោបល់** |
|---|---|
| ➢ បន្តខ្វះការយល់ដឹងអំពី ការអនុវត្តច្បាប់ពន្ធដោយភាគីពាក់ព័ន្ធខាងអភិវឌ្ឍន៍រួមទាំងអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល និងសាធារណៈ។<br>➢ ការអនុវត្តច្បាប់ពន្ធមិនស្មើភាពដែលត្រូវបានបើប្រាស់ដើម្បីកំណត់ទិសដៅលើអង្គការសង្គមស៊ីវិលដែលរិះគន់រដ្ឋាភិបាល។<br>➢ មានហានិភ័យនៃការបងពន្ធត្រលប់ថយក្រោយដែលមិនត្រូវបានប្រកាសដោយអង្គការសង្គមស៊ីវិលរហូតដល់ការចាប់ផ្តើមរបបពន្ធបច្ចុប្បន្ន (ឆ្នាំ១៩៩៧) ខណៈដែលការមិនយល់ដឹងអំពីពន្ធ និងកង្វះខាតរបស់ស្ថាប័នបានដាក់កម្រិតការប្រមូលពន្ធ។ | ➢ បន្តដាក់ចេញសកម្មភាពរៀនសូត្រ និងអភិវឌ្ឍន៍សកម្មភាពដើម្បីលើកកម្ពស់ការយល់ដឹងពីតម្រូវការអនុលោមតាមច្បាប់ពន្ធដែលកំពុងវិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល។<br>➢ អភិវឌ្ឍ និងបន្តមគ្គុទ្ទេសក៍ពន្ធ និងបណ្ណាល័យធនធានមូលដ្ឋានលើកុំព្យូទ័រខ្លោដ (Cloud) អំពីអនុលោមភាពរបស់អង្គការសង្គមស៊ីវិលជាមួយច្បាប់និងបទប្បញ្ញត្តិពន្ធដែលកំពុងវិវឌ្ឍន៍។<br>➢ តស៊ូមតិសម្រាប់ការអនុវត្តដោយមិនលម្អៀងនូវច្បាប់ពន្ធចំពោះគ្រប់ផ្នែកទាំងអស់នៃសង្គម។<br>➢ ពិនិត្យតាមដានការអនុវត្តនិងបទពិសោធរបស់អង្គការសង្គមស៊ីវិលជាមួយការិយាល័យពន្ធ ដើម្បីធានាថា អង្គការទាំងនោះទទួលបានការប្រព្រឹត្តដោយស្មើភាព។<br>➢ តស៊ូមតិសម្រាប់ការលើកលែងពន្ធ និងការអនុវត្តប្រតិសកម្មអតិបរមានូវលក្ខខណ្ឌតម្រូវច្បាប់ពន្ធសម្រាប់គ្រប់វិស័យ។<br>➢ លើកកម្ពស់ការយល់ដឹងសាធារណៈអំពីការអនុវត្តពន្ធលើប្រាក់ចំណូលតាមរយៈ "គំនិតផ្តួចផ្តើមថវិកាបើកចំហរ" និងតម្លាភាព។ |

## ***ការទទួលបានធនធាន (រួមទាំងវិស័យឯកជន)***

### ទិដ្ឋភាពរួម

សម្រាប់គោលបំណងនៃការសិក្សានេះ លទ្ធភាពទទួលបានធនធានសំដៅលើលទ្ធភាពរបស់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការទទួលបាន និងកៀរគរធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗជាច្រើន។ ប្រភពបែបនេះ រួមមាន (ប៉ុន្តែមិនកំណត់ត្រឹម) ម្ចាស់ជំនួយអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងជំនួយទ្វេភាគី វិស័យរដ្ឋាភិបាលនិងឯកជន និងការធ្វើទាន និងសកម្មភាពបង្កើតប្រាក់ចំណូលក្នុងស្រុករួមទាំងសហគ្រាសសង្គមផងដែរ។

មានការយល់ឃើញជាទូទៅមួយក្នុងចំណោមអង្គការសង្គមស៊ីវិលដែលថា លទ្ធភាពទទួលបានធនធាន (ហិរញ្ញវត្ថុ) កំពុងធ្លាក់ចុះ ដោយសារការពឹងផ្អែករបស់អង្គការសង្គមស៊ីវិលលើ "ការផ្តល់ជំនួយតាមរគម្រោងរយៈពេលខ្លី" និង "មិនមានលទ្ធភាពទទួលបានការគាំទ្រអង្គការទូទៅ" (CSOSI ឆ្នាំ២០១៧)។ នៅទូទាំងពិភពលោក មានការបង្ហាញមួយចំនួនអំពីការធ្លាក់ចុះនេះ ខណៈដែល "ជំនួយបរទេសពីម្ចាស់ជំនួយផ្លូវការក្នុងឆ្នាំ២០១៨ បានធ្លាក់ចុះ ២,៧% ធៀបនឹងឆ្នាំ២០១៧ ដោយចំណែកដែលកំពុងធ្លាក់ចុះនេះបានធ្លាក់ទៅកាន់ប្រទេសដែលត្រូវការខ្លាំងបំផុត" (អង្គការកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច "OECD" ឆ្នាំ២០១៩)[93]។ ប៉ុន្តែការធ្លាក់ចុះនេះមួយផ្នែកធំដោយសារ "ជំនួយកាន់តែតិចត្រូវបានចំណាយលើការទទួលជនភៀសខ្លួនចេញពីថវិកាជំនួយផ្លូវការ"។ ទោះជាយ៉ាងណា បើយោងតាមការឲ្យដឹងពីប្រធានអង្គការ OECD ជំនួយពិភពលោកទំនងជាកំពុងនៅទ្រឹង។ ការណ៍នេះទំនងជាករណីដូចដែលមានការលើកឡើងថា "ជំនួយអភិវឌ្ឍន៍បរទេសកំពុងធ្លាក់ចុះជាបន្តបន្ទាប់ ខណៈដែលចំណែកនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)"[94] ជាញឹកញាប់ត្រូវបានបកស្រាយខុស។ ជំនួយដែលជាផ្នែកនៃ ផ.ស.ស គួរធ្លាក់ចុះ ដោយសារតែសេដ្ឋកិច្ចដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័សរបស់កម្ពុជា ដែល "រក្សាបាននិរន្តរភាពអត្រាកំណើនជាមធ្យម ៧,៧% នៅចន្លោះពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៨ ដែលធ្វើឲ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់លឿនបំផុតក្នុងពិភពលោក" [95]។

*បរិបទប្រទេស*

ទោះជាយ៉ាងណា ការរាយការណ៍អំពីលំហូរជំនួយមកកាន់ប្រទេសកម្ពុជាដោយគណៈកម្មការជំនួយអភិវឌ្ឍន៍ (DAC) នៃអង្គការកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) បង្ហាញរូបភាពខុសគ្នាតិចតួច។ លំហូរ "ជំនួយ" សរុប[96] ពីប្រទេសចំនួន៣០ OECD/DAC មកកាន់ប្រទេសកម្ពុជា

---

[93] Development aid drops in 2018, especially to neediest countries, http://www.oecd.org/newsroom/development-aid-drops-in-2018-especially-to-neediest-countries.htm

94 OECD (2018), OECD Investment Policy Reviews: Cambodia 2018, https://www.oecd.org/finance/oecd-investment-policy-reviews-cambodia-9789264309074-en.htm

[95] https://www.worldbank.org/en/country/cambodia/overview

[96] which incorporates; 'Official Development Assistance (ODA), other official bilateral transactions which are not concessional or which, have concessional elements, often trade facilitating in character, i.e. "Other Official Flows" (OOF); as well as including changes in bilateral long-term support to private non-monetary and monetary sectors, in particular guaranteed export credits, private direct investment, portfolio investment',

(សូមមើលឧបសម្ព័ន្ធ ១.២) បានកើនឡើងជាបន្តបន្ទាប់រហូតជិតដល់ ១ពាន់លានដុល្លារអាមេរិក សម្រាប់ឆ្នាំខ្លះ។ ជាងពាក់កណ្តាលនៃទឹកប្រាក់នេះ (ប្រហែល ៥៩% ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ) គឺជា "សម្បទាន" ជំនួយអភិវឌ្ឍន៍ផ្លូវការ "ហិរញ្ញប្បទាន" ។




ចំពោះលំហូរជំនួយទាំងនេះ ត្រូវបន្ថែមជំនួយមកពីប្រទេស/ប្រភពផ្សេងៗ ដែលរួមមានវិភាគទានមកពីស្ថាប័នពហុភាគី និងប្រទេស (ដែលមិនមែនជាសមាជិករបស់អង្គការ OECD) ផ្សេងទៀត ដែលផ្តល់ព័ត៌មាន (សូមមើលតារាងខាងក្រោម)។ ក្នុងឆ្នាំ២០១៦ និង២០១៧ ដែលជាឆ្នាំចុងក្រោយដែលព័ត៌មានអាចរកបាន (នៅពេលសរសេររបាយការណ៍) លំហូរដែលត្រូវបានរាយការណ៍ទាំងនេះមានចំនួន ២២៣លានដុល្លារអាមេរិក (ឆ្នាំ២០១៦) និងចំនួន ២៣៦លានដុល្លារអាមេរិក (ឆ្នាំ២០១៧)។ "លំហូរជំនួយ" ដែលកើនឡើងជាបន្តបន្ទាប់ដែលត្រូវបានរាយការណ៍សរុបសម្រាប់ប្រទេសកម្ពុជា មានចំនួនប្រហែល ១,១ពាន់លានដុល្លារអាមេរិក (ឆ្នាំ២០១៦) និង ១,៣ពាន់លានដុល្លារអាមេរិក (ឆ្នាំ២០១៧)។

លើសពីនេះទៀត មានការកើនឡើងតម្រូវការឲ្យពិចារណា លើលំហូរជំនួយពីប្រទេស (ដែលមិនមែនជាសមាជិករបស់អង្គការOECD/DAC) ផ្សេងទៀតឧទាហរណ៍ពីប្រទេសចិន ឥណ្ឌានិងប្រទេសផ្សេងទៀត ព្រមទាំងគំនិតផ្តួចផ្តើម តំបន់ប៉ែកខាងត្បូង "South-South Initiatives" ដែលកម្ពុជាអាចទទួលប្រយោជន៍បានពីគំនិតផ្តួចផ្តើមនេះ។

**Other Reported Aid Sources, US$ million** *(Source OECD/DAC)*

| | 2013 | 2014 | 2015 | 2016 | 2017 |
|---|---|---|---|---|---|
| EU institutions | $ 30.6 | $ 55.6 | $ 45.2 | $ 63.3 | $ 51.9 |
| IBRD | | | | | |
| IDA | $ 23.0 | $ 28.5 | $ -9.1 | $ -7.2 | $ 0.7 |
| IFC | $ 8.0 | | | | |
| IMF | | | | | |
| Regional Development Banks | $ 136.6 | $ 142.5 | $ 82.4 | $ 98.0 | $ 80.6 |
| UN Agencies | $ 29.9 | $ 34.1 | $ 36.7 | $ 26.9 | $ 23.3 |
| Global Fund | $ 39.5 | $ 47.2 | $ 24.1 | $ 23.2 | $ 32.6 |
| Other Multilateral | $ 21.1 | $ 24.7 | $ 54.9 | $ 14.7 | $ 37.2 |
| Other providing Countries | $ 2.5 | $ 4.5 | $ 3.8 | $ 4.4 | $ 10.6 |
| | **$ 291.2** | **$ 337.1** | **$ 238.0** | **$ 223.3** | **$ 236.9** |

សូមបញ្ជាក់ជាថ្មីថា ប្រទេសកម្ពុជានៅតែត្រូវបានចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ចំនួន៤៧ ក្នុងពិភពលោក ហើយរដ្ឋាភិបាលបានបង្ហាញគោលបំណងរបស់ខ្លួន ដើម្បីចាប់ផ្តើមដំណើរការរយៈពេលប្រាំមួយឆ្នាំដើម្បីបញ្ចប់ ដោយចាប់ផ្តើមពីឆ្នាំ២០២១ ទៅ។ ឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចមានន័យថា អាចផ្តល់លទ្ធភាពកាន់តែខ្លាំងក្នុងការទទួលបានជំនួយអភិវឌ្ឍន៍ ដែលគួរតែត្រូវបានទាញយកប្រយោជន៍ឲ្យបានកាន់តែប្រសើរ ដើម្បីទាក់ទាញធនធានដើម្បីកំណត់ទិសដៅលើវិស័យដែលងាយរងគ្រោះ និងវិស័យផ្សេងៗទៀតដូចជាអភិបាលកិច្ចជាដើម ដើម្បីលើកកម្ពស់ការប្រើប្រាស់ និងតម្លាភាពមូលនិធិដែលត្រូវបានផ្តល់មកឲ្យកម្ពុជា។

បើទោះជាត្រឹមតែមួយផ្នែកនៃជំនួយនេះអាចរកបានចំពោះអង្គការសង្គមស៊ីវិលក៏ដោយ ក៏ការអនុវត្ត និងប្រើប្រាស់មូលនិធិទាំងនេះអាចប្រើប្រាស់ជាអត្ថប្រយោជន៍ចំពោះសង្គមស៊ីវិលបាន ដើម្បីធានាថា លំហូរជំនួយដែលត្រូវបានគាំទ្រ កំពុងត្រូវបានអនុវត្តបានយ៉ាងល្អ។

## លទ្ធផលរកឃើញ និងការវិភាគ

គណៈកម្មាធិការស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ដើរតួនាទីផ្លូវការជាស្ថាប័នសម្របសម្រួលជំនួយរបស់រដ្ឋាភិបាល។ គណៈកម្មាធិការនេះរាយការណ៍ថា លំហូរជំនួយទៅកាន់អង្គការមិនមែនរដ្ឋាភិបាលក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះមានចំនួនប្រហែល ៣០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ បរិមាណនេះជាផ្នែកមួយនៃទឹកប្រាក់រួមគ្នាសរុប ដែលអង្គការមិនមែនរដ្ឋាភិបាល កៀរគរធនធនបានដោយខ្លួនឯង និងមូលនិធិដែលទទួលបានពីដៃគូអភិវឌ្ឍន៍។

ដូចដែលអាច ត្រូវបានមើលឃើញ មានការធ្លាក់ចុះនូវការផ្តល់មូលនិធិដល់ អង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៥% ក្នុងឆ្នាំ ២០១៧ នៅទូទាំងប្រភេទមូលនិធិទាំងពីរនេះ។ អ្វីដែលបានកើតមានឡើងនេះមិនមានលក្ខខណៈសម្បត្តិសមស្រប ខណៈដែលថា ការផ្តល់ជំនួយទៅឲ្យអង្គការមិនមែនរដ្ឋាភិបាលបាននិងកំពុងកើនឡើងនៅឆ្នាំកន្លងមក។ ហើយវាត្រូវបានចាត់ទុកថាឆាប់ពេកក្នុងការសន្និដ្ឋានថា លំហូរជំនួយកំពុងធ្លាក់ចុះនោះ។



អង្គការសង្គមស៊ីវិលកម្ពុជាទទួលបានមូលនិធិភាគច្រើនពីម្ចាស់ជំនួយបរទេស។ អង្គការមួយចំនួនក៏មានលទ្ធភាពទទួលបានធនធានក្នុងទម្រង់ជាអ្នកស្ម័គ្រចិត្តផងដែរ ខណៈដែលអង្គការមួយ

ចំនួនទៀតចូលរួមក្នុងការរៃអង្គាសមូលនិធិក្នុងស្រុក និងដំណោះស្រាយនវានុវត្តន៍កាន់តែច្រើនដូចជាពីប្រភពចម្រុះផ្សេងៗតាមអនឡាញ (online crowdsourcing)។ យោងតាមសន្ទស្សន៍និរន្តរភាពអង្គការសង្គមស៊ីវិល (CSOSI ឆ្នាំ២០១៧) ហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា នៅតែរប៉ាត់រប៉ាយ និងចាំបាច់ត្រូវមានការសម្របសម្រួល។ ដូច្នេះ ដោយពិចារណាលើចំនួនអង្គភាព និងកម្រិតនៃភាពរប៉ាត់រប៉ាយ ជាបញ្ហាប្រឈមនៃការសម្រេចបានអត្ថប្រយោជន៍សង្គម ចាប់តាំងពីមួយដុល្លារ ដែលកំពុងលេចឡើង ឬការកើនឡើងនៃការផ្តល់តម្លៃលើថវិកានេះ កំពុងកើនឡើង។ ការណ៍នេះត្រូវបានរួមផ្សំដោយកង្វះប្រព័ន្ធពិនិត្យតាមដានផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីកំណត់បរិមាណ កំណត់លក្ខណៈសម្បត្តិ និងរាយការណ៍អំពីផលប៉ះពាល់នៃការវិនិយោគដែលត្រូវបានធ្វើឡើង។

រដ្ឋាភិបាលទទួលស្គាល់ថា "អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកចូលរួមចំណែកយ៉ាងធំមួយទៅនឹងការអភិវឌ្ឍជាតិរបស់កម្ពុជា ជាពិសេសតាមរយៈលទ្ធភាពរបស់ពួកគេក្នុងការកៀរគរមូលនិធិ និងធ្វើការងារលើវិស័យផ្សេងៗ ដែលកម្មវិធីបំពេញបន្ថែម ដោយរដ្ឋបាលថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍"[97]។ ការផ្តល់មូលនិធិសម្រាប់អង្គការសង្គមស៊ីវិល បានធ្លាក់ចុះ។ ការធ្លាក់ចុះក្នុងការផ្តល់មូលនិធិសម្រាប់អង្គការសង្គមស៊ីវិលទំនងជាដោយសារកត្តារួមផ្សំមួយចំនួន ដូចជា៖

- វឌ្ឍនភាពការអភិវឌ្ឍរួមរបស់កម្ពុជា ដោយបានមើលឃើញកម្រិតនៃភាពក្រីក្រត្រូវបានកាត់បន្ថយពាក់កណ្តាល។
- កំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងការកើនឡើងយ៉ាងឆាប់រហ័សនៃឱកាសឧស្សាហកម្ម។
- តម្រូវការដែលត្រូវបានបំពេញនៅទូទាំងពិភពលោក និងក្នុងតំបន់ ដោយចាប់ផ្តើមជាមួយនឹងការបើកចំហររបស់ប្រទេសមីយ៉ាន់ម៉ា និងក្រោយមកជាមួយនឹងវិបត្តិមនុស្សធម៌រ៉ូហ៊ីងយ៉ា។
- អ្នកណាក៏អាចពិចារណាបានផងដែរ ពីការកាត់ជំនួយពីម្ចាស់ជំនួយ ខណៈពេលដែលកម្ពុជាមានលទ្ធភាពទាក់ទាញកម្រិតសំខាន់ៗនៃការគាំទ្រពីម្ចាស់ជំនួយអស់រយៈពេលប្រហែល ២០ ឆ្នាំមកនេះ។
- ការផ្លាស់ប្តូរទម្រង់ និងលក្ខខណ្ឌតម្រូវនៃការផ្តល់ជំនួយ។

គួរកត់សម្គាល់ថា ការផ្តល់មូលនិធិសរុបដល់អង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ២០១៧ បានធ្លាក់ចុះ ១៥% ធៀបនឹងឆ្នាំ២០១៦។ លើសពីនេះទៀត បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗ គឺជាការប្រមូលផ្តុំនៃការផ្តល់មូលនិធិ ក្នុងឆ្នាំ២០១៥

- ➢ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១៥ ស្មើនឹង ៧៥% នៃការចំណាយរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

[97] CRDB/ CRC (2018) Development Cooperation and Partnerships Report 2017

➢ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន១៥ ស្មើនឹងជាង ៥០% នៃការផ្តល់មូលនិធិរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិទាំងអស់។

ក្នុងឆ្នាំ២០១៧ អង្គការមិនមែនរដ្ឋាភិបាលធំៗជំនួន ២៥ មានចំណែកស្មើនឹងប្រហែល ៦០% នៃការចំណាយសរុប។

ដូចដែលត្រូវបានមើលឃើញ មានការធ្លាក់ចុះ ដែលអាចមើលឃើញនូវការផ្តល់មូលនិធិដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥ ភាគរយ ក្នុងឆ្នាំ២០១៧ នៅទូទាំងប្រភេទមូលនិធិទាំងពីរនេះ (មូលនិធិផ្ទាល់ខ្លួន និងមូលនិធិដែលបានកៀរគរពីដៃគូអភិវឌ្ឍន៍)។ អ្វីដែលជាការណ៍បានកើតមានឡើងនេះមិនមានលក្ខខណៈសម្បត្តិសមស្រប ខណៈដែលការផ្តល់ជំនួយទៅឲ្យអង្គការមិនមែនរដ្ឋាភិបាលបាននិងកំពុងកើនឡើងនៅឆ្នាំកន្លងមក។ វាត្រូវបានចាត់ទុកថា វាឆាប់ពេកក្នុងការសន្និដ្ឋានថា លំហូរជំនួយកំពុងធ្លាក់ចុះនោះ។

ប៉ុន្តែ វាអាចត្រូវត្រឹមត្រូវក្នុងការជឿថា វាកំពុងកាន់តែមានការលំបាកខ្លាំងឡើងក្នុងការទទួលបានមូលនិធិ ដោយសារកត្តារួមផ្សំមួយចំនួន ដូចជាការផ្លាស់ប្តូរចរិកលក្ខខណ្ឌជំនួយ (ការផ្លាស់ប្តូរឆ្ពោះទៅរករបៀបវារៈឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ដោយចរីភាព (SDGs) របស់ខ្លួន និងបណ្តាញឆ្ពោះទៅរក/តាមរយៈវិស័យឯកជន) និងការកើនឡើងលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់លទ្ធផលដែលមានគុណភាព។ល។




ការណ៍នេះទំនងជាបង្ហាញឲ្យឃើញពីការកើនឡើង នៃការប្រមូលផ្តុំធនធាននៅក្នុងអង្គការដែលមានចំនួនកាន់តែតិចជាងមុន **បើទោះជាមានការកត់សម្គាល់ឃើញថា អង្គការមិនមែនរដ្ឋាភិបាលធំៗជាច្រើនផ្តល់ធនធានទៅកាន់អង្គការមិនមែនរដ្ឋាភិបាលតូចៗ តាមរយៈការរៀបចំជាដៃគូជាច្រើនក្តី។** ទោះជាយ៉ាងណា ការរៀបចំជាដៃគូទាំងនេះអាចជាផ្នែកមួយនៃបញ្ហាដែលត្រូវបានមើលឃើញក្នុងការធ្លាក់ចុះធនធាន ខណៈដែលធនធានទាំងនេះជាញឹកញាប់ ត្រឹមតែគ្របដណ្តប់លើសកម្មភាពប្រតិបត្តិការជាក់លាក់ ហើយអាចមិនគ្របដណ្តប់លើការចំណាយស្នូលនានា ឬផ្តល់ "ការគាំទ្រអង្គការ" ដែលបានលើកឡើងខាងលើ។

| របាយមូលនិធិអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលត្រូវបានរាយការណ៍ ឆ្នាំ២០១៥-២០១៧ (CRDB/CDC) | របាយមូលនិធិអង្គការសង្គមស៊ីវិល ទិន្នន័យរបស់ CRDB/CDC |
| --- | --- |

Distribution of Funding for NGOs 2015-2017 (in US$ Million) *(Source CRDB/CDC)*

| Categories | 2015 | | | 2016 | | | 2017 | | |
| --- | --- | --- | --- | --- | --- | --- | --- | --- | --- |
| | NGO own funds | Development Partners | Total | NGO own funds | Development Partners | Total | NGO own funds | Development Partners | Total |
| Total 25 Largest NGOs | $ 99.3 | $ 55.4 | **$ 154.7** | $ 112.1 | $ 66.4 | **$ 178.4** | $ 118.6 | $ 65.2 | **$ 183.8** |
| Total 435 other NGOs | $ 138.4 | $ 46.6 | **$ 184.9** | $ 138.2 | $ 42.3 | **$ 180.6** | $ 92.7 | $ 29.4 | **$ 122.1** |
| | $ 237.7 | $ 102.0 | **$ 339.6** | $ 250.3 | $ 108.7 | **$ 359.0** | $ 211.3 | $ 94.6 | **$ 305.9** |



មានការរាយការណ៍ថា មានសក្តានុពលដ៏ល្អសម្រាប់ការពង្រឹង និងការពង្រីកលទ្ធភាពទទួលបានមូលនិធិរបស់អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងដើម្បីលើកកម្ពស់ការបន្ស៊ីដែលកើនឡើងទៅនឹងអាទិភាពជាតិ[98] ជាពិសេសតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) (ឆ្នាំ២០១៩-២០២៣) និងជាមួយក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា (CSDGs)។ ទោះជាយ៉ាងណាបញ្ហាប្រឈមនឹងកំពុងព្រមព្រៀង និងផ្តល់លក្ខណៈសម្បត្តិសម្រាប់ធាតុចូល និងលទ្ធផល ដែលត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។

មានការដឹងឮតិចតួចអំពីការកៀងគរធនធានពីវិស័យឯកជន។ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ អនុញ្ញាតឲ្យមានការដាត់ចេញ ៥ភាគរយនៃប្រាក់ចំណូលប្រតិបត្តិការដែលត្រូវបានប្រកាសដែលទទួលបានពីជំនួយសប្បុរសធម៌។ ប៉ុន្តែមានការដឹកឮកាន់តែតិចតួចថែមទៀតអំពីថាតើជំនួយសប្បុរសទាំងនេះកំពុងត្រូវបានប្រើប្រាស់អស់ប៉ុន្មាន និងប្រើប្រាស់នៅទីកន្លែងណាខ្លះ។ ភាគច្រើននៃជំនួយសប្បុរសធម៌ក្នុងប្រទេស ត្រូវបានផ្តោតទិសដៅលើព្រះវិហារព្រះពុទ្ធសាសនា ឬព្រឹត្តិការណ៍សាសនាផ្សេងទៀត ព្រមទាំងលើជំនួយមនុស្សធម៌ និងក្រុមអ្នកងាយរងគ្រោះដូចជាកុមារ/ការអប់រំ ជនពិការ និងស្ត្រីជាដើម។ ការធ្វើទានអន្តរជាតិត្រូវបានរាយការណ៍ (OECD/DAC ឆ្នាំ២០១៩) មានប្រហែល ៥,៤លានដុល្លារអាមេរិកក្នុងមួយឆ្នាំនៅចន្លោះពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧។

*អនាគត*

ដោយសម្លឹងមើលទៅមុខ រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ជឿថា ការផ្តល់ហិរញ្ញប្បទានសរុបដែលអាចមានសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍជាតិ មានជាងទ្វេដងក្នុងអំឡុងពេលនេះដល់ចំនួន ១៨ពាន់លានដុល្លារអាមេរិកនៅត្រឹមឆ្នាំ២០២៥។

មានការព្យាករថា កម្រិតរួមនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល នឹងទំនងជានៅមានដែលនឹងប្រែប្រួលក្នុងប្រហែល ២២៥លានដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់អនាគតរយៈពេលខ្លីរហូតដល់ឆ្នាំ២០១៥។

[98] CRDB/CDC (2017) Cambodia Development Finance Assessment

| ការព្យាករណ៍ពីហិរញ្ញវត្ថុអភិវឌ្ឍន៍<br>(*ប្រភព CRDB/CDC ឆ្នាំ២០១៧*) | លំហូរហិរញ្ញវត្ថុអភិវឌ្ឍន៍ធំៗ និងការព្យាករណ៍ សម្រាប់ឆ្នាំ២០២៥ (% នៃ ផ.ស.ស)<br>(*ប្រភព CRDB/CDC ឆ្នាំ២០១៧*) |
|---|---|
|  |  |

*ក្តីបារម្ភអំពីប្រភពមូលនិធិនាពេលអនាគត*

នៅពេលត្រូវបានសួរថាតើលក្ខខណ្ឌសម្រាប់ការប្រមូលមូលនិធិមានភាពកាន់តែប្រសើរ ឬកាន់តែអាក្រក់នោះ ភាគច្រើននិយាយថា ស្ថានភាពកាន់តែអាក្រក់។ ខណៈពេលដែលអង្គការសង្គមស៊ីវិលបានបង្កើតទំនាក់ទំនងផ្ទាល់ជាមួយម្ចាស់ជំនួយ ដែលបានប្តេជ្ញាចិត្តដល់ការអភិវឌ្ឍរយៈពេលវែង និន្នាការជាទូទៅបច្ចុប្បន្ន ហាក់ដូចជា មានការប្រកួតប្រជែងកាន់តែខ្លាំង ក្នុងចំណោម អង្គការសង្គមស៊ីវិល ស្របពេលថវិកាកាន់តែថយចុះ។ សូមបញ្ជាក់ថា ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីប្រទេស "មានប្រាក់ចំណូលទាប" ទៅជាប្រទេស "មានប្រាក់ចំណូលមធ្យមកម្រិតទាប" ហើយជាលទ្ធផល ម្ចាស់ជំនួយកំពុងបង្វែងមូលនិធិរបស់ពួកគេទៅកាន់ប្រទេសត្រូវការមូលនិធិខ្លាំងជាងកម្ពុជា។ អ្នកចូលរួមក្នុងការសិក្សាម្នាក់បានឲ្យដឹងថា ក្តីបារម្ភត្រូវបានកត់សម្គាល់ឃើញថា ស្ថានភាពនេះនឹងបន្តវិវឌ្ឍទៅមុខ និងថា ការប្រមូលមូលនិធិគ្រប់គ្រាន់នឹង កាន់តែលំបាក ខណៈដែលសេដ្ឋកិច្ចបន្តវិវឌ្ឍ "ប្រហែលជានឹងកាន់តែលំបាកជាងនេះសម្រាប់អង្គការសង្គមស៊ីវិលដែលធ្វើការជាមួយវិស័យសប្បុរសធម៌"។

អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិលើកឡើងពី តម្រូវការសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីបង្ហាញលទ្ធផលនានា ដើម្បីឲ្យពួកគេអាចបង្ហាញវឌ្ឍនភាព ហើយដូច្នេះកែសម្រួលតម្រូវការសម្រាប់ការបន្តកម្មវិធី។ តម្រូវការ ដល់បុគ្គលិករបស់អង្គការសង្គមស៊ីវិល លើកកម្ពស់ជំនាញរបស់ពួកគេក្នុងការសរសេរសំណើឲ្យបានល្អ នៅពេលដាក់ពាក្យសុំមូលនិធិ និងដើម្បីធ្វើរបាយការណ៍អំពីវឌ្ឍនភាពឲ្យបានកាន់តែប្រសើរ ក៏ត្រូវបានលើកឡើងផងដែរ។

*ការផ្តល់មូលនិធិតាមរយៈរដ្ឋាភិបាល*

ការសិក្សាបានបង្ហាញថា មានអ្នកឆ្លើយតបដែលជឿថា រដ្ឋាភិបាលនឹងក្លាយជាប្រភពផ្តល់មូលនិធិនាពេលអនាគត ខណៈដែលមូលដ្ឋានចំណូលរបស់រដ្ឋាភិបាលត្រូវបានពង្រីក និងកើនឡើង។ ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលកម្ពុជាបានរៀបគោលនយោបាយ ដែលមានស្រាប់

សម្រាប់ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ខ្លួនដល់អង្គការសង្គមស៊ីវិល ប៉ុន្តែខ្វះខាតមូលនិធិកាលពីអតីតកាល។ រដ្ឋាភិបាលបានផ្តល់ការគាំទ្រមូលនិធិដល់អង្គការសង្គមស៊ីវិល តាមរយៈគម្រោងឧទាហរណ៍ គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន (DFGG) ដែលមូលនិធិក្នុងគម្រោងនេះដែលធនាគារពិភពលោកបានផ្តល់ទៅឲ្យរដ្ឋាភិបាល ត្រូវបានគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។ ថ្មីៗនេះ រដ្ឋាភិបាលដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ បានផ្តល់មូលនិធិដល់អង្គការសង្គមស៊ីវិលសម្រាប់ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)។ ឧទាហរណ៍ផ្សេងទៀតមាននៅក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល និងសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែខណៈពេលដែលរដ្ឋាភិបាលបានចូលរួមក្នុងគម្រោងនានាដែលមានគោលបំណងជួយកសាងសង្គមស៊ីវិល រដ្ឋាភិបាលកម្រផ្តល់មូលនិធិដល់សកម្មភាពទាំងនេះ ដោយគ្មានការចូលរួមវិភាគទានសំខាន់ៗពីម្ចាស់ជំនួយអន្តរជាតិឡើយ។

*កញ្ចប់មូលនិធិ (Trust Fund) សម្រាប់អង្គការសង្គមស៊ីវិល*

មានការអំពាវនាវឲ្យបង្កើតកញ្ចប់មូលនិធិ (Trust Fund) សម្រាប់អង្គការសង្គមស៊ីវិលក្នុងទម្រង់មួយ ហើយអង្គការ គ.ស.ក បានរួមបញ្ចូលការបង្កើតមូលនិធិនេះទៅក្នុងដំណាក់កាលថ្មីនៃកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP ឆ្នាំ២០១៧-២០២១) របស់ខ្លួន។ ទោះជាយ៉ាងណា របៀបដែលត្រូវបង្កើត និងគោលបំណងនៅក្នុងប្រតិបត្តិការ និងការធានាឲ្យបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ ហើយនឹងជាបញ្ហាប្រឈម។ ដោយបញ្ហានៃការធានាថា មូលនិធិនេះត្រូវបន្សុីជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលត្រូវបានកំណត់ និងព្រមព្រៀង និងត្រូវបានអនុម័តលើអាទិភាពទាំងនោះ បង្កបញ្ហាប្រឈមផ្សេងទៀត។ លើសពីនេះទៀត របៀបដើម្បីត្រូវផ្តោតទិសដៅលើមូលនិធិទាំងនេះ និងដើម្បីធានាបានលទ្ធផល ដែលមានគុណភាព និងមានបរិមាណ អាចត្រូវបានប្រមូលពីការវិនិយោគ ដែលអាចត្រូវបានចាត់ទុកថា ជាបញ្ហាប្រឈមទីបី។ ម្ចាស់ជំនួយមួយចំនួនបាននិងកំពុងផ្តល់មូលនិធិដើម្បីលើកកម្ពស់ និងពង្រឹងអង្គការសង្គមស៊ីវិល ដើម្បីឲ្យអង្គការទាំងនេះមានការយល់ដឹងកាន់តែប្រសើរ និងមានលទ្ធភាពចូលទៅកាន់ធនធានថវិកាដែលមាន។

*សហគ្រាសសង្គម*

គំនិតដែលយល់ឃើញសហគ្រាសសង្គមថា ជាជម្រើសមួយដែលអាចមាន/ឬជាប្រភពចូលរួមចំណែកដល់ការរៃអង្គាសមូលនិធិ ក៏ត្រូវបានកត់សម្គាល់ផងដែរ។ ប៉ុន្តែការបង្កើតសហគ្រាសសង្គមបង្កើតឲ្យមានបញ្ហាផ្សេងៗ ដោយសារសហគ្រាសសង្គមស្ថិតក្នុងដែនសកម្មភាពសហគ្រាសពាណិជ្ជកម្ម ដូច្នេះវិធានការពន្ធផ្សេងៗមួយចំនួនដែលនឹងចូលមក និងដែលធានាឲ្យមានការបែងចែកគ្នានៃការផ្តល់មូលនិធិដែលត្រូវបានលើកលែងពន្ធបច្ចុប្បន្ន និងកន្លងមកពីការវិនិយោគនិងប្រាក់ចំណូលលក្ខណៈពាណិជ្ជកម្ម ទំនងជាលំបាកក្នុងការរក្សាបាន? អេកូទេសចរណ៍ ការអភិរក្ស និងសិប្បកម្ម គឺជាវិស័យដែលអាចធ្វើទៅបាន ដែលជាញឹកញាប់ត្រូវបានលើកឡើង ប៉ុន្តែថាតើវិស័យទាំងនេះពិតជាមានសក្តានុពលក្នុងការបង្កើតប្រាក់ចំណូលឲ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមចំណែកដល់ប្រាក់ចំណូល

គ្រប់គ្រាន់ក្នុងការគាំទ្រដល់អង្គការសង្គមស៊ីវិលជាច្រើននៅទូទាំងប្រទេសនោះ គឺជាបញ្ហាចោទ។ វាអាចធ្វើទៅបានសម្រាប់សហគ្រាសសង្គមមួយចំនួន ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមទាំងពីរ ប៉ុន្តែមិនមែនគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងចំនួនដ៏ច្រើនមួយនោះទេ។ ក៏មានគម្លាតសមត្ថភាពដ៏ធំផងដែររវាងអង្គការសង្គមស៊ីវិល និងប្រតិបត្តិការលក្ខណៈពាណិជ្ជកម្ម។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ឆ្នាំ ២០១៣* | *ក្នុងអំឡុងពេលសិក្សានិងសរសេររបាយការណ៍ (ឆ្នាំ២០១៨-២០១៩)* |
|---|---|
| ឧបសគ្គចំពោះលទ្ធភាពទទួលបានមូលនិធិហាក់ដូចជាភាគច្រើនមានការពាក់ព័ន្ធទៅនឹងសមត្ថភាពកាន់តែទាបរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធៀបនឹងអង្គការមិនមែនរដ្ឋាភិ បាលអន្តរជាតិ ក្នុងការកំណត់ម្ចាស់ជំនួយសមស្របការប្រាស្រ័យទាក់ទងជាភាសាអង់គ្លេស ជាមួយម្ចាស់ជំនួយ ការកសាងទំនាក់ទំនងដែលទុកចិត្តជាមួយពួកគេ និងការដាក់ជូនសំណើ (ស្នើគស្នាញ) ដែលមានភាពច្បាស់លាស់និងអាចសម្រេចបានដើម្បីទទួលបានការផ្តល់មូលនិធិ។ អវត្តមានការធ្វើទានក្នុងស្រុកមានន័យថា ការរៃមូលនិធិក្នុងស្រុកក៏ជួបឧបសគ្គផងដែរ។ | ការវិវឌ្ឍនៃស្ថាបត្យកម្មជំនួយពិភពលោក បាននិងកំពុងមើលឃើញការផ្លាស់ប្តូរលក្ខណៈ និងប្រភេទជំនួយដែលត្រូវបានផ្តល់ទៅឲ្យប្រទេសនានា។ លក្ខខណ្ឌតម្រូវផ្តល់មូលនិធិរបស់ម្ចាស់ជំនួយកាន់តែមានភាពស្មុគស្មាញខ្លាំងឡើង ដោយសារម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ចង់មើលឃើញតម្លៃកាន់តែខ្លាំងសម្រាប់មូលនិធិដែលត្រូវបានវិនិយោគរបស់ពួកគេ។<br><br>ឧទាហរណ៍មួយនៃការផ្លាស់ប្តូរដែលត្រូវបានស្នើឡើងជាញឹកញាប់ពីម្ចាស់ជំនួយ ឬទីភ្នាក់ងាររបស់ពួកគេ គឺការតម្រូវឲ្យមានសំណើជាបណ្តុំជាជាងសំណើពីអង្គការនីមួយៗ។ លក្ខខណ្ឌតម្រូវផ្លាស់ប្តូរទាំងនេះ ជាញឹកញាប់លើសពីសមត្ថភាពរបស់អង្គការសង្គមស៊ីវិលតូចៗដើម្បីទទួលបានមូលនិធិ។ ពួកគេក៏បង្ហាញផងដែរនូវការបន្តកើតមានលក្ខណៈរប៉ាត់រប៉ាយនៃវិស័យអង្គការសង្គមស៊ីវិលជាច្រើន។<br><br>ទាំងនេះប្រហែលជាបានចូលរួមចំណែកដល់ការប្រមូលផ្តុំធនធានសម្រាប់អង្គការសង្គមស៊ីវិលដែលសង្កេតឃើញមានក្នុងប្រទេសកម្ពុជា ដែលធ្លាក់ទៅលើអង្គការសង្គមស៊ីវិលមួយចំនួនតូចដែលជាមធ្យមមានចំនួន ៥២% នៃការគាំទ្រអង្គការសង្គមស៊ីវិលទាំងអស់ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ បានធ្លាក់ទៅលើអង្គការតែ ២៥ប៉ុណ្ណោះ។ ទោះជាយ៉ាងណា បាតុភូតនេះមិនត្រឹមតែកំពុងកើតមានឡើងក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែកំពុងកើតមាននៅទីកន្លែងផ្សេងទៀតផងដែរ។ សូមបញ្ជាក់ឡើងវិញថា មូលនិធិភាគច្រើនបានផ្តល់ការគាំទ្រដល់បណ្តាញអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ជាញឹកញាប់ការណ៍ដែលមានលក្ខណៈប្រមូលផ្តុំនេះ ជាការចំណាយបបែបសេដ្ឋកិច្ច។ |

## បញ្ហាប្រឈម និងការផ្ដល់យោបល់

| បញ្ហាប្រឈម | ការផ្ដល់យោបល់ |
|---|---|
| • ការផ្លាស់ប្ដូរយន្តការ/វិធីសាស្ត្រជំនួយរបស់ម្ចាស់ជំនួយទំនងជាដាក់កម្រិតដល់លទ្ធភាពទទួលបានធនធានរបស់អង្គការសង្គមស៊ីវិលកម្ពុជា។<br>• គួបផ្សំដោយការផ្លាស់ប្ដូរអាទិភាពរបស់ម្ចាស់ជំនួយនិងប្រសិទ្ធភាពចំណាយ និងការសម្រេចបានលទ្ធផលក្នុងកម្រិតដែលចង់បាន។<br>• ការកើនឡើងការប្រកួតប្រជែងសម្រាប់ធនធានដែលមាន ខណៈដែលអង្គការសង្គមស៊ីវិលជាតិជាញឹកញាប់ត្រូវការប្រកួតប្រជែង។<br>• កម្រិតមូលនិធិសម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដែលមានចំពោះអង្គការសង្គមស៊ីវិលត្រូវបានព្យាករថានឹងនៅតែមានកម្រិតជាទឹកប្រាក់ដដែលប៉ុន្តែធ្លាក់ចុះបើគិតជាភាគរយនៃ ផ.ស.ស។<br>• អ្វីដែលកំពុងអាចរកបានជាញឹកញាប់ត្រូវបានប្រមូលផ្ដុំនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលធំៗមួយចំនួន។<br>• សមត្ថភាពនៅបន្តមានកម្រិតរបស់អង្គការសង្គមស៊ីវិលមួយផ្នែកធំ ដើម្បីមានលទ្ធភាពទទួលបានធនធានមូលនិធិប្រកបដោយប្រសិទ្ធភាព និងដោះស្រាយ<br>o ខ្វះការយល់ដឹងអំពីទម្រង់ជំនួយដែលកំពុងវិវឌ្ឍន៍។ | • ក្រុមអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលចាំបាច់ត្រូវតស៊ូមតិដើម្បីធ្វើឲ្យរបាយមូលនិធិ មានភាពប្រសើរឡើង តាមរយៈអង្គការសង្គមស៊ីវិលក្នុងតំបន់អាទិភាពដែលបានព្រមព្រៀង ដែលត្រូវបានបន្សុីជាមួយនឹងគោលដៅ និងអាទិភាពអភិវឌ្ឍន៍ជាតិ។<br>• វាយតម្លៃពីការចំណាយ និងអត្ថប្រយោជន៍ដែលអាចកើតមានពីការបង្កើត និងគាំទ្រកញ្ចប់មូលនិធិ បណ្ដុំអង្គការសង្គមស៊ីវិល/ពហុម្ចាស់ជំនួយ។<br>o រួមទាំងតំបន់សកម្មភាព ទំហំមូលនិធិលក្ខខណៈប្រតិបត្តិការ វិស័យអាទិភាពជាដើម ដើម្បីមើលថាតើវានឹងផ្ដល់តម្លៃសម្រាប់ការវិនិយោគធៀបនឹងជម្រើសមូលនិធិដែលអាចមានផ្សេងទៀតដែរឬយ៉ាងណា។<br>• បង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិលដើម្បីវាយតម្លៃធនធាន ដោយធានាបាននូវការបន្សុីឲ្យបានទាន់ពេលវេលា និងសកម្មស្របជាមួយនឹងការអភិវឌ្ឍដែលផ្លាស់ប្ដូរ/អាទិភាពរបស់ម្ចាស់ជំនួយ និងវិធីសាស្ត្រ។<br>• លើកកម្ពស់ការចូលរួមរបស់ម្ចាស់ជំនួយរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីទាញយកប្រយោជន៍ពីគោលដៅអភិវឌ្ឍន៍ជាតិការប្ដេជ្ញាចិត្តរបស់ CSDG/SDG ក្នុងការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច។<br>o រុករកសក្ដានុពលសម្រាប់មូលនិធិអង្គការសង្គមស៊ីវិល ដើម្បីចូលរួមចំណែកដល់កិច្ចការទាំងនេះពីប្រភពទាំងនេះ។ |

# សិទ្ធិទទួលបានព័ត៌មាន

## ទិដ្ឋភាពរួម

ក្នុងឆ្នាំ២០១៩ មានប្រជាជនកម្ពុជាតែ ៣០០.០០០ នាក់ប៉ុណ្ណោះដែលមានលទ្ធភាពទទួលបានអ៊ីនធឺណិតប្រើប្រាស់។ ទោះជាយ៉ាងណា នៅត្រឹមឆ្នាំ២០១៣ ចំនួននេះបានកើនឡើងដល់ជិតបួនលាននាក់ ឬប្រហែលមួយភាគបួននៃប្រជាជនប្រហែល ១៥លាននាក់។ បច្ចុប្បន្នមានអ្នកប្រើប្រាស់ហ្វេសប៊ុក (Facebook) ចុះបញ្ជីចំនួន ១,៧ លាននាក់[99]។ ថ្មីៗនេះ ប្រជាជនកម្ពុជាសាមញ្ញ រួមទាំងអ្នកដែលរស់នៅទីជនបទ មានឱកាសទទួលបានដំណឹង និងព័ត៌មានកាន់តែបើកចំហរ។ លទ្ធភាពទទួលបាន និងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដែលកើនឡើងខាងលើ បានកើតមានដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍យ៉ាងឆាប់រហ័ស ដែលបន្ទាប់មកបានឈានទៅរក "ការកើនឡើងខ្លាំង" នៃបណ្តាញទូរស័ព្ទចល័ត និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISPs) នៅក្នុងប្រទេសក្នុងអំឡុងពេល ១៥ឆ្នាំចុងក្រោយនេះ។

គិតត្រឹមឆ្នាំ២០១៣ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័តមានចំនួន ១៣,៨ លាននាក់ ដែលជាប់ចំណាត់ថ្នាក់ទី៥៨ នៅក្នុងពិភពលោក ដែលប្រហែល ៩២នាក់ក្នុងចំណោម ១០០នាក់មានទូរស័ព្ទប្រើប្រាស់[100] ទិន្នន័យចុងក្រោយបំផុត ដែលកត់ត្រាក្នុងក្រដាសព័ត៌មានឆ្នាំ២០១៥ របស់ក្រសួងទូរគមនាគមន៍កម្ពុជា បានអះអាងថា ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទសរុបមានចំនួន ២០,៥លាននាក់ ដែលមានន័យថា ប្រជាជនកម្ពុជាភាគច្រើនមានទូរស័ព្ទដៃ/ទូរស័ព្ទលើតុលើសពីមួយគ្រឿង[101]។

ជាមួយនឹងការកើនឡើងខ្លាំងនៃហេដ្ឋារចនាសម្ព័ន្ធទូរស័ព្ទចល័ត និងការតភ្ជាប់ខ្ពស់ដែលបានរៀបរាប់ខាងលើ ប្រទេសកម្ពុជាអាចត្រូវបានចាត់ទុកថាជាមូលដ្ឋានដ៏ល្អដែលកំពុងស្ទុះដើបខ្លាំងមួយសម្រាប់ប្រេវ៉ាឡង់ខ្ពស់នៃឧក្រិដ្ឋកម្មអ៊ីនធឺណិត។ ខណ:ដែលឧក្រិដ្ឋកម្មអ៊ីនធឺណិតមិនត្រូវបានតាមដានជាលក្ខណ:ប្រព័ន្ធ និងរាយការណ៍ដោយបើកចំហរដោយរដ្ឋ ឬវិស័យឯកជន មានការយល់ឃើញថា ឧក្រិដ្ឋកម្មទាំងនេះកំពុងក្លាយជាក្តីបារម្ភដែលកំពុងវិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា។

សិទ្ធិទទួលបានព័ត៌មាន (A2I) ក្នុងការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើថា តើអ្វីដែលច្បាប់ និង/ឬបទប្បញ្ញត្តិអ្វីដែលគ្រប់គ្រង ឬជះឥទ្ធិពលលើសិទ្ធិទទួលបានព័ត៌មានរបស់អង្គការសង្គមស៊ីវិល? ប្រភពព័ត៌មានដែលត្រូវបានស្វែងរក? ដំណើរការប្តឹងឧទ្ធរណ៍សម្រាប់ព័ត៌មាន? តើមន្ត្រីរដ្ឋាភិបាលខ្លួនឯងផ្ទាល់មានលទ្ធភាពទទួលបានព័ត៌មានកម្រិតណាជាសាធារណ:? តើឱកាសអ្វីដែលមានសម្រាប់សាធារណ: រួមទាំងអង្គការសង្គមស៊ីវិល ដើម្បីជួបជាមួយមន្ត្រីរដ្ឋាភិបាលជជែកអំពីអត្ថប្រយោជន៍និងតម្រូវការផ្ទាល់ខ្លួន ឬស្ថាប័ន? តើមានសេចក្តីព្រាងច្បាប់ ឬបទប្បញ្ញត្តិ (ប្រសិនបើអនុម័ត)

[99] Internet world Statistics on Cambodia – June 2016.
[100] Cambodia, World Factbook, U.S. Central Intelligence Agency. Retrieved 24 October 2013
[101] Cambodia Ministry of Posts and Telecommunication Factsheet December 2015.

ដែលនឹងរឹតបន្តឹង ឬបន្ធូរបន្ថយសិទ្ធិទទួលបានព័ត៌មានរបស់អង្គការសង្គមស៊ីវិលដែរឬទេ? ប្រសិនបើដូច្នេះ សូមសង្ខេបខ្លឹមសាររបស់បទប្បញ្ញត្តិសំខាន់ៗ និងដំណាក់កាលនៃដំណើរការច្បាប់ដែលមានបច្ចុប្បន្ន។ តើដំណើរការទទួលបានព័ត៌មានរបស់រដ្ឋាភិបាលមានតម្លាភាព រលូន ងាយស្រួល និងមានមូលដ្ឋានលើនីតិរដ្ឋ ឬមានការលំបាក (មានការសម្របសម្រួល) យឺត និងមានការពាក់ព័ន្ធនឹងការិយាល័យធិបតេយ្យដែរឬទេ?

សិទ្ធិទទួលបានព័ត៌មានគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន។ មាត្រា១៩ នៃសេចក្តីប្រកាសជាសកលអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងទស្សនៈ។ សិទ្ធិនេះរាប់ទាំងសេរីភាពក្នុងការប្រកាន់មតិ និងការសម្តែងមតិ ដោយគ្មានការជ្រៀតជ្រែក ព្រមទាំងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា តាមរយៈប្រព័ន្ធឃោសនាណាមួយក៏ដោយ និងដោយឥតគិតពីព្រំដែនអ្វីឡើយ" ខណៈពេលដែលមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

ប្រទេសកម្ពុជាមិនមានច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) និងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិតនៅឡើយ។ កម្ពុជាគឺជាប្រទេសមួយដែលជាក់ស្តែងលើកកម្ពស់សេរីភាពព័ត៌មាន រួមទាំងការប្រតិបត្តិក្នុងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម (តាមរយៈប្រព័ន្ធព័ត៌មានអនឡាញដូចជា អ៊ីនធឺណិត គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម។ល។)។ ពលរដ្ឋកម្ពុជាទាំងអស់ច្បាស់ណាស់រីករាយនឹងសិទ្ធិសេរីភាពក្នុងការបង្កើត និងប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម (ដូចជាគេហទំព័រ និងផ្សេងៗទៀត) ដែលអាចត្រូវបានដាក់ដំណើរការ ដើម្បីសម្តែងទស្សនៈរបស់ពួកគេដោយសេរីពីគ្រប់ទីកន្លែងនៅក្នុង និងក្រៅប្រទេសកម្ពុជា[102]។

អង្គការសង្គមស៊ីវិលជឿថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានមានសារៈសំខាន់ដើម្បីត្រួសត្រាយផ្លូវឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ លើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ។ ស្ថិតក្រោមភាពជាអ្នកដឹកនាំ និងការសម្របសម្រួលរបស់វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)[103] ក្នុងឆ្នាំ២០០៤ អង្គការសង្គមស៊ីវិលមួយក្រុម (អង្គការចំនួន១៩ ហើយបច្ចុប្បន្នមាន ២៨អង្គការមិនមែនរដ្ឋាភិបាល) បានចាប់ផ្តើមយុទ្ធនាការស្តីពីសេរីភាពទទួលបានព័ត៌មាន (សិទ្ធិទទួលបានព័ត៌មាន) ដើម្បីជំរុញឲ្យរដ្ឋាភិបាលកម្ពុជាអនុម័តច្បាប់នេះ។ ចន្លោះឆ្នាំ២០០៣ ដល់ឆ្នាំ២០១៧ ការរៀនសូត្រអំពីប្រតិបត្តិល្អ និងបទពិសោធពីប្រទេសជិតខាងផ្សេងទៀត ព្រមទាំងការយល់ដឹងអំពីអ្វីដែលយើងចង់សំដៅអំពីសិទ្ធិទទួលបានព័ត៌មាន (សេរីភាពក្នុងការទទួលបានព័ត៌មាន)។ ក្នុងឆ្នាំ២០០៤ រដ្ឋាភិបាល

102 Human Rights Council, Working Group on the Universal Periodic Review, Eighteenth session, 27 January – 7 February 2014
103 Sinthay NEB (Director of API)'s presentation

កម្ពុជាបានទទួលស្គាល់ពីតម្រូវការឲ្យមានច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន "ដើម្បីបង្កើនរដ្ឋាភិបាលមួយដែលមានតម្លាភាព កាត់បន្ថយអំពើពុករលួយ និងលើកកម្ពស់ទំនុកចិត្តក្នុងរដ្ឋាភិបាល"។ ក្នុងខែសីហា ឆ្នាំ២០០៧ ឯកសារគោលនយោបាយព្រាងមួយស្តីពីសិទ្ធិទទួលបានព័ត៌មានត្រូវបានបង្កើតឡើងដោយមានការគាំទ្រផ្នែកបច្ចេកទេសពីទីភ្នាក់ងារជំនួយអាមេរិក (USAID)។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅឯកិច្ចប្រជុំមួយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីបានប្រកាសជាផ្លូវការថា ការបង្កើតច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន នឹងចាប់ផ្តើម និងបានចាត់តាំងឲ្យរដ្ឋមន្ត្រីក្រសួងព័ត៌មានដឹកនាំ និងបើកចំហរឲ្យមានការពិគ្រោះយោបល់ជាមួយអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់មួយស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I)។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានត្រូវបានបញ្ចប់ក្នុងខែមីនា ឆ្នាំ២០១៨ ស្ថិតក្រោមការដឹកនាំរបស់ក្រសួងព័ត៌មាន ក្នុងភាពជាដៃគូជាមួយអង្គការយូណេស្កូ និងអង្គការសង្គមស៊ីវិល ដែលបានចូលរួម។

*ឧក្រិដ្ឋកម្ម និងសន្តិសុខអ៊ីនធឺណិត*

ដោយសារមានសេចក្តីរាយការណ៍ពីការកើនឡើងឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធនឹងអ៊ីនធឺណិតក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ រួមទាំងការវាយចូលលួចទិន្នន័យ ("Hack") របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងឆ្នាំ២០១៣ ដោយជនមួយក្រុម ដែលត្រូវបានកំណត់អត្តសញ្ញាណថាជា "ជនអនាមិកកម្ពុជា (Anonymous Cambodia)" ដែលក្រោយមកបានហេកគេហទំព័ររបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សរបស់គណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងស្ថានីយទូរទស្សន៍ជាតិកម្ពុជារបស់រដ្ឋាភិបាល[104]។ ខណៈពេលដែលទិសដៅភាគច្រើនគឺជាស្ថាប័នរដ្ឋ រដ្ឋាភិបាលកម្ពុជាបានបង្កើនសន្តិសុខអ៊ីនធឺណិត និងការត្រួតពិនិត្យមើលជិតដល់ ដែលអាចមានការដាក់កម្រិតទៅលើការគោរពសិទ្ធិមនុស្ស។

ថ្មីៗនេះចាប់ពីឆ្នាំ២០១៥ មក មនុស្សមួយក្រុមត្រូវបានចាប់ខ្លួនដោយសារបង្ហោះមតិយោបល់លើបណ្តាញទំនាក់ទំនងសង្គម ដោយការចាប់ខ្លួនពួកគេធ្វើឡើងយោងតាម ខចែងរបស់ច្បាប់ព្រហ្មទណ្ឌពីបទ "ការជេរប្រមាថ និង/ឬការញុះញង់" ដែលជាឧបករណ៍ដើម្បីចាប់ និងកាត់ទោសពួកគេ។ សរុបមក ពលរដ្ឋកម្ពុជាចំនួន ១០នាក់ ត្រូវបានចាប់ខ្លួន ឬឃុំឃាំងពីបទបង្ហោះសារនយោបាយលើបណ្តាញទំនាក់ទំនងសង្គម/ហ្វេសប៊ុក ដោយមួយចំនួនក្នុងចំណោមពួកគេបានរំលោភច្បាប់ស្តីពីការជេរប្រមាថព្រះមហាក្សត្រ ដែលត្រូវបានអនុម័តនៅខែកុម្ភៈ ឆ្នាំ២០១៨[105]។

ដោយសារបរិបទនយោបាយដែលត្រូវបានពិពណ៌នាខាងលើ និងឧទាហរណ៍ផ្សេងៗដូចដែលត្រូវបានដកស្រង់ជាក់ស្តែង ដែលជះឥទ្ធិពលដល់ទាំងវិស័យសាធារណៈ និងវិស័យឯកជន ប្រទេស

104 Joshua Wilwohl, 'Anonymous Hacks Government Websites' The Cambodia Daily (13 September 2013)
105 https://www.voacambodia.com/a/cambodia-takes-aim-at-critics-on-facebook/4835777.html

កម្ពុជាស្ថិតក្នុងស្ថានភាពលំបាក ដែលចាំបាច់ត្រូវមានច្បាប់ដែលអាចវាស់វែងការឆ្លើយតប ដើម្បីដោះស្រាយឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងអ៊ីនធឺណិត។ ហេតុដូច្នេះ ច្បាប់មានសក្តានុពលដ៏ធំ ដើម្បីដោះស្រាយ និងកាត់បន្ថយហានិភ័យអាជីវកម្ម និងទំនុកចិត្តសាធារណៈ តែវានៅតែមានភាពមិនច្បាស់លាស់ថា តើរដ្ឋាភិបាលនឹងធ្វើដូច្នេះសម្រាប់តែកាត់បន្ថយ និងកសាងទំនុកចិត្ត ឬសម្រាប់គោលបំណងនយោបាយ។ ប្រសិនបើធ្វើឡើងសម្រាប់គោលបំណងនយោបាយ នៅពេលនោះការបង្កើត និងការអនុវត្តច្បាប់នេះដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មអ៊ីនធឺណិត ដែលកំពុងកើនឡើង អាចបង្កឲ្យមានគ្រោះថ្នាក់ (ច្រើនជាងល្អ) សង្គម នយោបាយ និងសេដ្ឋកិច្ចកាន់តែខ្លាំង ក៏ដូចចំពោះប្រទេសជាតិទាំងមូល។

## លទ្ធផលរកឃើញ និងការវិភាគ

អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ជាញឹកញាប់ត្រូវការព័ត៌មានអំពីបទប្បញ្ញត្តិ ព្រំដែនច្បាប់ នីតិវិធី គោលនយោបាយ ផែនការអភិវឌ្ឍន៍ និងកំណត់ហេតុកិច្ចប្រជុំពីការប្រជុំសំខាន់ៗ ដែលជះ ឥទ្ធិពលដល់ពួកគេ ហើយព័ត៌មានទាំងនេះចាំបាច់ត្រូវធ្វើឲ្យអាចស្វែងរកបាន ដោយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅពេលព័ត៌មានមិនអាចរកបាន ឬពិបាកក្នុងការទទួលបាន អង្គការសង្គមស៊ីវិល/ប្រជាជន ប្រឈមនឹងហានិភ័យ ដែលកើនឡើងនៃការមិនអាចមានលទ្ធភាពបម្រើប្រជាជនកម្ពុជា និងអ្នកតំណាងរបស់ពួកគេបាន។

<u>ព័ត៌មានអំពីការចុះបញ្ជី</u>

តម្រូវការព័ត៌មាន មានការទាក់ទងនឹងព័ត៌មាន (ចុះបញ្ជី) អង្គការថ្មី ដោយរក្សាការជូនដំណឹងអំពីច្បាប់ ធ្វើបច្ចុប្បន្នភាពអំពីបទប្បញ្ញត្តិ រៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ។ល។ លើសពីនេះទៀត ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលថ្នាក់ក្រោមជាតិ ដែលធ្វើការងារលើវិស័យកសិកម្ម តម្រូវការព័ត៌មានអំពីការវិវឌ្ឍទីផ្សារ មានសារៈសំខាន់ ដោយសារកសិករពឹងផ្អែកលើព័ត៌មាននេះ ដើម្បីលក់ផលិផលរបស់ពួកគេ។ ព័ត៌មានពីរដ្ឋាភិបាលអំពីធនធានដែលមានសម្រាប់ការបណ្តុះបណ្តាល និងវគ្គរៀនសូត្រ ព័ត៌មានអំពីមូលនិធិដែលមាន សុទ្ធតែត្រូវបានលើកឡើងថាមានសារៈសំខាន់។

បញ្ហាប្រឈមធំជាងគេ ដែលអ្នកចូលរួមក្នុងការសិក្សាភាគច្រើនបានលើកឡើងគឺថា ព័ត៌មានអាចជាព័ត៌មានចាស់ និងហួសកាលបរិច្ឆេទ ព័ត៌មានមិនត្រឹមត្រូវ ឬក្លែងក្លាយ។ ការណ៍នេះជាញឹកញាប់គឺជាករណីដែលព័ត៌មានត្រូវបានបោះផ្សាយអនឡាញ ដែលទម្លាប់ធ្វើបច្ចុប្បន្នភាពសមស្រប ជានិច្ចកាលមិនត្រូវបានធ្វើឡើង។ អ៊ីនធឺណិតត្រូវបានគេមើលឃើញថាបានជួយលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ប៉ុន្តែបញ្ហាភាពជឿទុកចិត្តនៅតែមាន។ អ្នកចូលរួមក្នុងការសិក្សាទាំងអស់ ប្រើប្រាស់អ៊ីនធឺណិតជាប្រចាំ/ប្រចាំថ្ងៃ។ ពួកគេពឹងផ្អែកលើអ៊ីនធឺណិត ដើម្បីឲ្យខ្លួនឯងទទួលបានបច្ចុប្បន្នភាពដំណឹង/នយោបាយ និងដំណឹងនិងការអភិវឌ្ឍក្នុងស្រុក។ ពួកគេទាំងអស់និយាយថា មិនមែនដំណឹងទាំងអស់អាចទុកចិត្តបាននោះទេ។ អ្នកចូលរួមក្នុងការសិក្សាខ្លះនិយាយថា ៥០% អាចទុកចិត្តបាន ខណៈដែលអ្នកខ្លះនិយាយថា ៨០% នៃព័ត៌មានអនឡាញអាចទុកចិត្តបាន។ ប្រភពសម្រាប់ព័ត៌មាន

អនឡាញត្រូវបាននិយាយថាមានសារៈសំខាន់ ហើយគុណភាពរបស់ដំណឹងគឺជាពឹងផ្អែកទៅលើប្រភព ប៉ុន្តែជានិច្ចកាលមិនមានភាពច្បាស់លាស់ឡើយអំពីរបៀបដែលត្រូវបញ្ជាក់ពីភាពជឿទុកចិត្តរបស់ប្រភព។

អ៊ីនធឺណិតផ្តល់ព័ត៌មានជាច្រើន ហើយអារម្មណ៍ជាទូទៅក្នុងចំណោមអង្គការសង្គមស៊ីវិលគឺថារដ្ឋាភិបាលមិនអាចគ្រប់គ្រង/កាន់កាប់អ៊ីនធឺណិតបានទេ។ ការណ៍នេះត្រូវបានគេមើលឃើញថាជាការពិត ហើយកាន់តែពិតជាងនេះទៀតនោះ គឺក្នុងករណីបណ្តាញទំនាក់ទំនងសង្គម។ ទោះជាយ៉ាងណា មានការសង្កត់ធ្ងន់ដោយអ្នកចូលរួមក្នុងការសិក្សាភាគច្រើនថា បណ្តាញទំនាក់ទំនងសង្គមបង្កើនព័ត៌មានក្លែងក្លាយជាច្រើន។ "មនុស្សចាំបាច់ត្រូវប្រុងប្រយ័ត្ន កុំប្រើប្រាស់ និងចែករំលែកប្រភេទដំណឹងនេះឡើយ" ត្រូវបានលើកឡើងក្នុងក្រុមគោលដៅមួយក្នុងចំណោមក្រុមគោលដៅនានានៅថ្នាក់ក្រោមជាតិ។ ការលើកឡើងនេះត្រូវបានគាំទ្រដោយសមាជិកផ្សេងទៀតរបស់ក្រុម នៅទូទាំងក្រុម និងបទសម្ភាសបុគ្គលប្រហាក់ប្រហែលគ្នានេះ។

សិទ្ធិទទួលបានព័ត៌មាននៅថ្នាក់ជាតិ




បើទោះជាក្រសួងជាច្រើនមានគេហទំព័រ និងទំព័របណ្តាញទំនាក់ទំនងសង្គមកាន់តែច្រើនក្តី ក៏ការប្រើប្រាស់ប្រភពទាំងនោះ ធ្វើជាបណ្តាញផ្សព្វផ្សាយព័ត៌មាន ជានិច្ចកាលមិនមែនកើតមានឡើងឡើយ។ ព័ត៌មានស្ថិតិ ឯកសារច្បាប់ ស្ថិតក្រោមអាណត្តិរបស់ក្រសួង ជាញឹកញាប់មិនអាចរកបានទាន់ពេលវេលាឡើយនៅលើ គេហទំព័ររបស់ក្រសួង។ ការណ៍នេះដាក់កម្រិតដល់តួអង្គអភិវឌ្ឍន៍/ភាគីពាក់ព័ន្ធ និងលទ្ធភាពរបស់ប្រជាជនក្នុងការទទួលបានព័ត៌មានឲ្យបានទាន់ពេលវេលា។

*សិទ្ធិទទួលបានព័ត៌មាននៅថ្នាក់ក្រោមជាតិ*

សិទ្ធិទទួលបានព័ត៌មានមានសារៈសំខាន់សម្រាប់ការអនុវត្តគណនេយ្យភាពសង្គម។ ព័ត៌មានអំពីសេវាសាធារណៈ និងកម្រៃផ្លូវការ និងព័ត៌មានអំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ត្រូវបានផ្សព្វផ្សាយនៅទូទាំងសហគមន៍។ វិសាលភាពនៃការយល់ដឹងអំពីខ្លឹមសារ និងដំណើរការ ដើម្បីជួបអាជ្ញាធរ មានភាពខុសគ្នាពីទីកន្លែងមួយទៅកន្លែងមួយ។ ប្រសិទ្ធិភាពនៃការផ្សព្វផ្សាយព័ត៌មាន ពឹងផ្អែកលើវិធីសាស្ត្រ និងសមត្ថភាពរបស់អាជ្ញាធរឃុំ ស្រុក និងខេត្ត និងរបស់អង្គការសង្គមស៊ីវិល ដែលប្រាថ្នាមានសិទ្ធិទទួលបានព័ត៌មាន។ ពីបទសម្ភាសនានា មិនមែនមានត្រឹមតែថ្នាក់ឃុំ និងស្រុកប៉ុណ្ណោះទេ

ដែលមានកាតព្វកិច្ចចែកចាយព័ត៌មានទៅកាន់សហគមន៍ ប៉ុន្តែអង្គការសង្គមស៊ីវិល និងអង្គការសហគមន៍ក៏ចាំបាច់ត្រូវធ្វើការងារនេះផងដែរ។ ជាញឹកញាប់ អង្គការសហគមន៍រៀបចំកិច្ចប្រជុំក្នុងភូមិជាទីដែលអង្គការទាំងនេះមានឱកាសចែកចាយព័ត៌មានអំពីសេវាកម្មសាធារណៈ។ ប្រសិនបើអង្គការទាំងនោះអាចមានសិទ្ធិទទួលបានព័ត៌មាន ពួកគេក៏អាចប្រាស្រ័យទាក់ទង និងសម្របសម្រួលសំណើសុំព័ត៌មានដោយសហគមន៍បាន។

អង្គការមិនមែនរដ្ឋាភិបាលក៏ស្វែងរកការលើកទឹកចិត្តឲ្យមានការសម្របសម្រួល ក្នុងចំណោមរដ្ឋាភិបាល ប្រជាពលរដ្ឋ និងវិស័យឯកជនផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានទទួលស្គាល់ និងបានក្លាយជាដៃគូសំខាន់មួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាសភាក្នុងការដោះស្រាយតម្រូវការ និងក្តីបារម្ភរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសក្រុមដែលគេផាត់ចេញ និងក្រុមដែលងាយរងគ្រោះ។ ក្នុងរបៀបជាច្រើន អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីសំខាន់មួយក្នុងការសម្រេចបានគោលដៅប្រជាធិបតេយ្យនីយកម្ម ការចូលរួម អភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ គណនេយ្យភាពសង្គម និងការអភិវឌ្ឍ។

*ប្រភេទព័ត៌មានដែលស្វែងរកបំផុតដោយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសហគមន៍*

ការអង្កេតសម្រាប់ការសិក្សានេះដែលធ្វើឡើងក្នុងឆ្នាំ២០១៨ បានសួរអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលថា តើពួកគេបានស្វែងរកការទទួលបានព័ត៌មានពីអាជ្ញាធរសាធារណៈ៖ ៨៦% នៃអង្គការបានឆ្លើយថាបានព្យាយាមទទួលបានព័ត៌មាន និងទិន្នន័យពីអាជ្ញាធរនៅថ្នាក់ផ្សេងៗ។ អ្នកតំណាងរបស់អង្គការសង្គមស៊ីវិលត្រូវបានសួរថាតើពួកគេឯកភាព ឬមិនឯកភាពជាមួយនឹងចម្លើយអំពីភាពងាយស្រួលក្នុងការទទួលបានព័ត៌មាននៅថ្នាក់ជាតិ និងក្រោមជាតិ។ តិចជាងមួយភាគប្រាំនៃអង្គការ






សង្គមស៊ីវិល (១៨%) បានគិតថា ការទទួលបានព័ត៌មាន មានភាពងាយស្រួលនៅថ្នាក់ជាតិ ខណៈដែលជាងមួយភាគបីបានគិតថា មានការលំបាកដើម្បីទទួលបានព័ត៌មាន ហើយជិតពាក់កណ្ដាលទៀតមិនបានផ្ដល់ចម្លើយ ឬផ្ដល់ចម្លើយអព្យាក្រឹត។

នៅថ្នាក់ក្រោមជាតិ ការពេញចិត្តជាមួយនឹងការទទួលបានព័ត៌មានមានតិចតួច ដោយមានតែ ១៣% ប៉ុណ្ណោះនៃអ្នកឆ្លើយតប ដែលព្រមព្រៀងជាមួយនឹងការលើកឡើង ខណៈដែលមួយភាគបួននៃអ្នកឆ្លើយតប (២៥%) មិនពេញចិត្តនឹងការព្យាយាមទទួលបានព័ត៌មាន។ ទោះជាយ៉ាងណា ជាថ្មីម្ដងទៀត ចំនួនដ៏ច្រើននៃអ្នកឆ្លើយតបមិនបានផ្ដល់ចម្លើយ (៤២%) ឬបានបង្ហាញអាព្យាក្រឹតអំពីការទទួលបានព័ត៌មាននៅថ្នាក់ក្រោមជាតិ។ សូមមើលការសិក្សាថ្នាក់ក្រោមជាតិ CCC/API ឆ្នាំ២០១៥ ដែលបានកំណត់ប្រភេទព័ត៌មានដែលជាញឹកញាប់ត្រូវបានស្វែងរកនៅថ្នាក់ក្រោមជាតិ ដែលព័ត៌មានត្រូវបានប្រមូលក្នុងខេត្តចំនួនប្រាំ។




លើសពីនេះទៀត ក្នុងសំណួរតាមដានក្នុងឆ្នាំ២០១៥ ប្រភេទព័ត៌មានដែលលំបាកបំផុតក្នុងការទទួលបានគឺៈ

- ច្បាប់ចម្លងនៃច្បាប់និងបទប្បញ្ញត្តិជាតិ ដោយ ៦៩% នៃអ្នកឆ្លើយតបជឿថា វាមានការលំបាកក្នុងការទទួលបាននៅថ្នាក់ក្រោមជាតិ។
- ក្រៅពីច្បាប់និងបទប្បញ្ញត្តិជាតិ ការទទួលបានឯកសារអភិវឌ្ឍន៍មូលដ្ឋានក៏មានការលំបាកងដែរ
  - ឯកសារស្ដីពីថវិកាឃុំ ដែលមានអ្នកឆ្លើយតប ៤៧%
  - តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ដែលមានអ្នកឆ្លើយតប ៤៧%
  - លិខិតនិងឯកសាររដ្ឋបាលរបស់ក្រុមប្រឹក្សា ដែលអ្នកឆ្លើយតប ៤៧% ជឿថាមានការលំបាកក្នុងការទទួលបាន។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ឆ្នាំ ២០១៣* | *ក្នុងអំឡុងពេលសិក្សា (ឆ្នាំ២០១៥-២០១៩)* |
|---|---|
| សិទ្ធិទទួលបានព័ត៌មានមិនត្រូវបានគ្របដណ្តប់ឡើយដោយការវាយតម្លៃនៅឆ្នាំ២០១៣។ | ម្យ៉ាងវិញទៀត<br>➢ សិទ្ធិទទួលបានព័ត៌មានគឺជាសិទ្ធិមូលដ្ឋាន ដោយសារការមានលទ្ធភាពទទួលបានព័ត៌មានគឺចាំបាច់ ដើម្បីធ្វើការសម្រេចចិត្តដោយមានការយល់ដឹងច្បាស់លាស់។ ទោះជាយ៉ាងណា ការប្រតិបត្តិរបស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន ត្រូវបានរឹតបន្តឹងសិទ្ធិទទួលបានព័ត៌មាន។<br>➢ បើទោះជាស្ថាប័នរបស់រដ្ឋាភិបាលមានវត្តមានគេហទំព័រ និងទំព័របណ្តាញទំនាក់ទំនងសង្គមកាន់តែច្រើនក្តី ក៏ព័ត៌មាន និងស្ថិតិដែលស្ថាប័នទាំងនោះទទួលខុសត្រូវមិនត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំឡើយនៅក្នុងស្ថាប័នមួយចំនួន ឬត្រូវបានផ្តល់ជូនក្នុងទម្រង់ដែលពិបាកយកមកប្រើប្រាស់។<br>➢ លើសពីនេះទៀត ឯកសារច្បាប់ បទប្បញ្ញត្តិ និងស្ថាប័នជាញឹកញាប់មានការលំបាកទទួលបានឲ្យទាន់ពេលវេលា។<br>ម្យ៉ាងវិញទៀត<br>➢ អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមសាធារណៈ ដែលបង្ហាញទស្សនៈត្រូវបានផ្តោតទិសដៅ និងចោទប្រកាន់ពីបទឧក្រិដ្ឋ។<br>➢ ដំណើរការលើកកម្ពស់ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការពិគ្រោះយោបល់អំពី និងការបញ្ចប់ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត ចាំបាច់ត្រូវបញ្ចប់ ដោយសារច្បាប់ទាំងនេះមានការពាក់ព័ន្ធទៅនឹងការ "បិទ" នៅឆ្នាំ២០១៨ ពាក់ព័ន្ធនឹងការបោះឆ្នោតជាតិ។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

| បញ្ហាប្រឈម | ការផ្តល់យោបល់ |
|---|---|
| ➢ ក្រសួង និងស្ថាប័នភាគច្រើនរបស់រដ្ឋាភិបាល មិនធ្វើបច្ចុប្បន្នភាពព័ត៌មាន និងទិន្នន័យលើគេហទំព័ររបស់ខ្លួនឲ្យបានទៀងទាត់ឡើយ។ ការណ៍នេះបានរឹតបន្តឹងដល់ពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ក្នុងការទទួលបានព័ត៌មាន។<br>➢ កង្វះជាបន្ទូវច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) រឹតបន្តឹងសិទ្ធិទទួលបានព័ត៌មានរបស់សង្គមស៊ីវិល និងសាធារណៈ។<br>o ជំហុងក្រោយនៃការពិគ្រោះយោបល់របស់សាធារណៈនិងភាគីពាក់ព័ន្ធច្បាប់នេះត្រូវការជាចាំបាច់។<br>o ការអនុម័តច្បាប់នេះត្រូវការជាចាំបាច់ ដើម្បីពន្លឿនមគ្គុទ្ទេសក៍និងប្តេជាចិត្តបើកចំហររដ្ឋាភិបាល។<br>➢ ប្រភពទិន្នន័យមូលដ្ឋានកន្លងមកដូចជាមូលដ្ឋានទិន្នន័យឃុំ (ក្នុងទម្រង់ជាអេឡិចត្រូនិច) ដែលអាចជួយដល់ការរៀបចំផែនការនិងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន កាន់តែមានការលំបាកក្នុងការទទួលបាន និងទទួលបានដំណើរការអភិវឌ្ឍន៍ដែលមានកម្រិត។ | ➢ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតក្របខ័ណ្ឌសិទ្ធិទទួលបានព័ត៌មានមួយ ដើម្បីចូលរួមចំណែកដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបើកចំហររដ្ឋាភិបាល។<br>o ពិចារណាពីការកើនឡើងសង្គមឌីជីថល និង "ឆ្លាតវៃ" ដែលយើងរស់នៅ។<br>➢ ផ្តល់ទិន្នន័យយោងភូមិសាស្ត្រ រួមទាំងក្នុងទម្រង់ជាអេឡិចត្រូនិចឲ្យបានទាន់ពេលវេលាដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍មូលដ្ឋាន។<br>o បោះផ្សាយទិន្នន័យលទ្ធផលស្ថាប័ន ដើម្បីបង្កើតគណនេយ្យភាពសាធារណៈ។<br>➢ កសាងសមត្ថភាពស្ថាប័ន និងអនុម័តខ្នាតគំរូ ដើម្បីផ្តល់ព័ត៌មានទៅក្នុងដៃរបស់សាធារណៈឲ្យបានទាន់ពេលវេលា។<br>➢ ជំរុញឲ្យមានការបញ្ចប់ និងការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត។ |

## ទំនាក់ទំនង រវាងរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិល

### ទិដ្ឋភាពរួម

នៅក្នុងសង្គមប្រជាធិបតេយ្យ និងសេរីពហុបក្ស ការចូលរួមដ៏សកម្មពីប្រជាពលរដ្ឋ និងអង្គការសង្គមកស៊ីវិល ដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាតុល្យភាព និងជះឥទ្ធិពលដល់នយោបាយ និងសង្គម។ ដូច្នេះ សកម្មភាពនយោបាយ និងសកម្មភាពសង្គមស៊ីវិលពាក់ព័ន្ធនឹងប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការលើកកម្ពស់នីតិរដ្ឋ ដោយធានាឲ្យបាននូវតម្លាភាព និងគណនេយ្យភាពរបស់អាជ្ញាធរ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត មិនអាចត្រូវបានដាច់ចេញពីគ្នាឡើយ។ ខណៈដែលអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងស្ថាប័ននានា អាចមានទស្សនៈខុសគ្នា និងជំទាស់ ពួកគេ (ជាញឹកញាប់ជាជាងមិន) អត់អោន និងគោរពទស្សនៈគ្នាទៅវិញទៅមក។ នៅក្នុងសង្គមរីកចម្រើន (progressive society) ការពិចារណាលើទស្សនៈប្រឆាំង ចូលរួមចំណែកដល់ការពិភាក្សាដោយបើកចំហរនូវបញ្ហាក្តីបារម្ភ និងឈានទៅរកការផ្លាស់ប្តូរ (វិជ្ជមាន) ដើម្បីធ្វើឲ្យស្ថានភាពមានភាពប្រសើរឡើង ឬដូច្នេះ ការគិតក៏បន្តទៅមុខផងដែរ។ ទោះជាយ៉ាងណា ក្នុងប្រទេសមួយចំនួន អង្គការសង្គមកស៊ីវិល ដែលធ្វើការងារលើការស្តារ ជំរុញ និងលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពប្រជាធិបតេយ្យ ជាញឹកញាប់ស្ថិតក្នុងហានិភ័យនៃការបំភិតបំភ័យ គាបសង្កត់ ឬវាយប្រហារដោយក្រុម ឬបក្ស ដែលជំទាស់ ក្នុងការកាត់បន្ថយអំណាច ឬធ្វើឲ្យប្រសើរឡើងនូវស្ថានភាព ដែលពួកគេមិនអាចកេងប្រវ័ញ្ចបាន។

ស្ថានភាពរបស់ប្រទេសកម្ពុជាបានធ្លាក់ចុះ ទៅក្នុងចំណុចណាមួយរវាងចន្លោះនេះ ដោយស្ថិតិបង្ហាញឲ្យឃើញពីសេដ្ឋកិច្ចកំពុងកើនឡើងខ្លាំង និងស្ថានភាពសង្គម និងសេដ្ឋកិច្ចមានភាពប្រសើរឡើង។ ទោះជាយ៉ាងណា សិទ្ធិមនុស្សនិងស្ថានភាពប្រជាធិបតេយ្យបានធ្លាក់ចុះ ដែលទំនងជាដោយសារភាពជាប់គាំងផ្នែកនយោបាយ ដែលបានកើតមានឡើង និងអលទ្ធភាពរបស់គណបក្សកាន់អំណាចក្នុងការបោះបង់អំណាចនេះ ឬមើលឃើញថា អំណាចបានធ្លាក់ចុះ។ ស្ថានភាព និងអង្គការជាច្រើន[106] រួមទាំងអង្គការរបស់កម្ពុជា[107] ផងដែរនោះ បានសម្តែងក្តីបារម្ភអំពីការធ្លាក់ចុះសិទ្ធិមនុស្ស ដែលបានសង្កេតឃើញមានក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលពីឆ្នាំ២០១៥-២០១៨ បានប្រែក្លាយកាន់តែឈឺចាប់ ខណៈពេលដែលបរិយាកាសនយោបាយបានមានភាពកាន់តែអាក្រក់ ហើយលំហរប្រជាធិបតេយ្យ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋធ្លាក់ចុះ។ សេចក្តីថ្លែងការណ៍អំពីក្តីបារម្ភទាំងនេះជាញឹកញាប់ បានលើកឡើងពីបញ្ហាជាច្រើនរាប់ចាប់ពីការជារំលោភបំពានរហូតដល់ការបំភិតបំភ័យគណបក្សប្រឆាំង និងអង្គការសិទ្ធិមនុស្ស។ ទោះជាយ៉ាងណា ក្រៅពីមានការចេញសេចក្តីថ្លែងការណ៍បន្ថែម និងការគំរាមដាក់ទណ្ឌកម្ម (ដូចជាការដក

---

[106] Phnom Penh Post (28/03/2018) UN Council discuss deteriorating rights situation in Cambodia https://www.phnompenhpost.com/national/un-council-discuss-deteriorating-rights-situation-cambodia, International Comission of Jurists (21/6/2018) Cambodia: deteriorating situation for human rights and rule of law, Human Rights Watch, https://www.hrw.org/world-report/2018/country-chapters/cambodia

[107] Cambodian CSO statement to the US-ASEAN Summit February 2016 statement can be obtained at https://www.central-cambodia.org/archives/72 (accessed on 2 July 2019) Other statements can be accessed at: https://www.central-cambodia.org/archives/category/joint-statement

ប្រព័ន្ធអនុគ្រោះពន្ធ EBA ដែលផ្តល់លទ្ធភាពនាំចេញទៅកាន់ទីផ្សារអឺរ៉ុប ដែលនឹងទំនងជាត្រឹមតែជះឥទ្ធិពលដល់វិស័យឯកជន និងកម្មករប៉ុណ្ណោះ) មានការងារតិចតួចដែលអាចត្រូវបានធ្វើឡើង។

ស្ថានភាពបច្ចុប្បន្នគឺជាឧទាហរណ៍មួយផ្សេងទៀតអំពីវិធីសាស្ត្ររឹងមួយ ដែលរដ្ឋ/រដ្ឋាភិបាលឆ្លងកាត់ពេលវេលានៃការរិះគន់របស់អន្តរជាតិឲ្យវិលត្រលប់ទៅរក "ស្ថានភាពធម្មតា" វិញ ពេលគឺជាការតាត់បន្ថយតម្រូវការ និងការពឹងផ្អែកលើជំនួយអន្តរជាតិ និងមានភាពជំពាក់ជំពិនក្នុងការកាត់បន្ថយឥទ្ធិពលនេះ។ រដ្ឋាភិបាលបានលើកយកបញ្ហា និងការគាំទ្រមួយចំនួនមកពិចារណា ខណៈពេលដែលបញ្ហាទាំងនេះចូលរួមចំណែកដល់ការពង្រីកសេដ្ឋកិច្ច ព្រមទាំងបន្តដោះស្រាយកង្វះខាតផ្នែកសង្គម និងបរិយាកាសងាយរងគ្រោះនៅក្នុងសង្គម។ វាគឺជាការពិតដែលបច្ចុប្បន្នបង្កើតក្របខណ្ឌទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ការណ៍នេះវិលត្រលប់ទៅរកបទពិសោធក្នុងអំឡុងពេលស្តារនីតិសម្បទាក្នុងទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិ ជាញឹកញាប់មានឥទ្ធិពល ទៅលើរដ្ឋាភិបាល និងការចែកចាយសេវា ប៉ុន្តែអំឡុងពេលនោះ បច្ចុប្បន្នគឺជាប្រវត្តិសាស្ត្រទៅហើយ។

ក្នុងប្រទេសកម្ពុជា ទំនងជាមានការមិនទុកចិត្តគ្នាទៅវិញទៅមកដែលមិនទាន់ត្រូវបានរកឃើញរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលចោទប្រកាន់អង្គការសង្គមស៊ីវិលថាកំពុងព្យាយាមរារាំងតួនាទីរបស់ខ្លួន ហើយក្នុងអំឡុងពេលសិក្សានេះ អង្គការសង្គមស៊ីវិលទាំងអស់ទំនងជាទទួលរងផលប៉ះពាល់ដោយសារការចោទប្រកាន់នេះ។ ខណៈដែលអង្គការសង្គមស៊ីវិលជឿថា រដ្ឋាភិបាលកំពុងព្យាយាមគាបសង្កត់ និងគ្រប់គ្រងអង្គការសង្គមស៊ីវិល និងជាថ្មីម្តងទៀតក្នុងអំឡុងពេលសិក្សានេះ។ ខណៈពេលដែលមានឧទាហរណ៍អំពីបញ្ហាទាំងពីរនេះ មិនតំណាងឲ្យស្ថាប័នទូលំទូលាយនៃបទពិសោធរបស់អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលក្នុងការធ្វើការងារលើបញ្ហាអភិវឌ្ឍន៍នោះឡើយ។

## លទ្ធផលរកឃើញ និងការវិភាគ

### *ផែនការ និងយុទ្ធសាស្ត្រថ្នាក់ជាតិ*

### ឆ្នាំ២០១៣-២០១៨

សម្លឹងមើលថយក្រោយ នៅក្នុងអំឡុងពេលសិក្សា (ឆ្នាំ២០១៥-២០១៨) រដ្ឋាភិបាលបានបង្កើត និងអនុវត្តតាមក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិដែលត្រូវបានធ្វើសមាហរណកម្មកម្ម ដែលត្រូវបានបង្កើតឡើងដោយឯកសារដែលត្រូវបានធ្វើសុខដុមនីយកម្ម និងមានទំនាក់ទំនងគ្នាចំនួនបី (ក) កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាជាតិ (ខ) យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព ដំណាក់កាលទី ៣ និង (ខ) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០១៤-២០១៨)។ ឯកសារទាំងនេះមានចែងអំពីវិស័យអាទិភាព និងផែនការសកម្មភាពដែលអនុវត្តពេញមួយ

ជីវិតរបស់ផែនការនេះ និងផ្តល់ការបង្ហាញធនធាន ដែលត្រូវការដើម្បីសម្រេចបានវិស័យអាទិភាពនីមួយៗ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ទទួលស្គាល់ថា "ភាពជាដៃគូជាមួយភាគីពាក់ព័ន្ធទាំងអស់ត្រូវបានពង្រឹងបន្ថែម ជាពិសេសជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល តាមរយៈការដាក់ចេញយន្តការប្រកបដោយប្រសិទ្ធភាពផ្សេងៗ។ ការវិនិយោគពីចរិការជ្ឍរួមជាមួយនឹងហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និងលំហូរវិនិយោគឯកជន បានជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព"។

ជាការពិត ក្របខ័ណ្ឌសម្របសម្រួលនិងប្រសិទ្ធភាពជំនួយដែលមានភាពប្រសើរឡើង ដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានបង្កើតឡើង និងបានឯកភាពក្នុង "យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨" បានចូលរួមចំណែកដល់វឌ្ឍនភាព និងភាពប្រសើរឡើងនានាក្នុងអំឡុងពីឆ្នាំ២០១៥-២០១៨។ វាក៏អាចជួយឲ្យមានការរៀបចំផែនការហិរញ្ញវត្ថុអភិវឌ្ឍន៍នាពេលខាងមុខកាន់តែប្រសើរផងដែរ រួមទាំងវិភាគទានពីអង្គការសង្គមស៊ីវិល។

យុទ្ធសាស្ត្រនេះបានទស្សទាយ និងរៀបចំផែនការ "(១) ភាពចំបាច់ដើម្បីកំណត់ឡើងវិញនូវតួនាទីហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយសារការធ្លាក់ចុះនៅទូទាំងពិភពលោកនៃហិរញ្ញប្បទានជំនួយ ឥតសំណង និងការអភិវឌ្ឍក្នុងកិច្ចព្រមព្រៀងភាពជាដៃគូជាមួយដៃគូបុគ្គល និង (២) ការធ្លាក់ចុះហិរញ្ញប្បទានសម្បទានដែលត្រូវបានរំពឹងទុក ដោយសារប្រទេសកម្ពុជាបានឈានដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ យុទ្ធសាស្ត្រនេះក៏បានលើកឡើងផងដែរអំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះគោលការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលត្រូវបានព្រមព្រៀងក្នុងកិច្ចប្រជុំកំពូលផ្សេងៗ"។

## ឆ្នាំ២០១៩-២០២៣

ផ្នែកនេះសម្លឹងមើលទៅកាន់អនាគត។ ប្រទេសកម្ពុជាបានអនុវត្តតាមវិធីសាស្ត្ររបស់ក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ (NDF) ដោយបង្កើតយុទ្ធសាស្ត្រ និងផែនការមគ្គុទ្ទេសក៍សំខាន់ៗ។ ក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិធ្វើសុខដុមនីយកម្ម និងត្រូវបានភ្ជាប់ទៅនឹងយុទ្ធសាស្ត្រស្តីពី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (DCPS)។ ឯកសារសំខាន់ៗទាំងនេះ ធ្វើការសម្អាងចំពោះភាពសំខាន់នៃភាពជាដៃគូ។

| | |
|---|---|
| (i) កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាជាតិ | កម្មវិធីនេះមានចែងអំពីគោលដៅយុទ្ធសាស្ត្រ គោលនយោបាយអាទិភាព គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ និងវិធានការជាក់លាក់ ដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០១៩ ទៅ ដើម្បីធ្វើជាមគ្គុទ្ទេសក៍សម្រាប់សកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសេវាកម្មរបស់ខ្លួនចំពោះជាតិ និងប្រជាជនក្នុងនីតិកាលទី៦។ |
| (ii) យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ៤ (RSIV) | យុទ្ធសាស្ត្រនេះ ពឹងផ្អែកលើ "បទពិសោធនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណចំនួនបីដំណាក់កាលកន្លងមក។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផ្តោតអាទិភាពលើសរសរស្តម្ភចំនួន៤ (i) ការអភិវឌ្ឍន៍ធនធានមនុស្ស (ii) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (iii) វិស័យឯកជន និងការបង្កើតការងារ និង (iv) ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងដោយចីរភាព។ សរសរស្តម្ភស្នូលទីបួន គឺការពន្លឿនកំណែទម្រង់រដ្ឋាភិបាល ដែលសំដៅដល់ការកំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព ការពង្រឹងគណនេយ្យភាព និងសុចរិតភាពក្នុងរដ្ឋបាលសាធារណៈ ដោយធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពការងារ និងពង្រឹងអភិបាលកិច្ចវិស័យឯកជន។ |
| (iii) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP ឆ្នាំ២០១៩-២០២៣) ដែលតម្រង់ទិសឆ្ពោះទៅរកសកម្មភាព | ដោយត្រូវបានអនុម័តដោយរដ្ឋាភិបាលក្នុងខែមិថុនា ឆ្នាំ២០១៩ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានចែងអំពីគោលនយោបាយ និងសកម្មភាពអាទិភាពឆ្នាំ២០១៩-២០២៣ ដែលក្រសួងពាក់ព័ន្ធត្រូវអនុវត្ត និងបង្ហាញតម្លៃប៉ាន់ប្រមាណរួមទាំងការចំណាយ ធនធាន និងកម្មវិធីចំណាយ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានបង្ហាញក្របខ័ណ្ឌសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ដំណាក់កាលឆ្នាំ២០១៩-២០២៣ ផងដែរ និងបង្ហាញសេចក្តីសន្និដ្ឋានទូលំទូលាយ។ |
| ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា (CSDGs) ឆ្នាំ២០១៦-២០៣០ | រដ្ឋាភិបាលបានបន្សុំទៅនឹងគោលដៅ ទិសដៅ និងសូចនាករពិភពលោកចំពោះបរិបទជាតិ និងបង្កើតទិសដៅមួយចំនួនដែលត្រូវបានធ្វើឲ្យមានលក្ខណៈក្នុងស្រុក ពោលគឺជាគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) នៅកម្ពុជា ដែលនឹងដាក់បញ្ចូលទៅក្នុងដំណើរការរៀបចំផែនការ និងអភិវឌ្ឍន៍ជាតិ និងតាមវិស័យ។ |



យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (RSIV) ចែងថា "មូលដ្ឋានគ្រឹះខ្លាំងមួយសម្រាប់ការបែងចែកធនធានឆ្ពោះទៅរក អាទិភាពគោលនយោបាយ (ដែលត្រូវបានកំណត់) និងក្របខ័ណ្ឌដ៏ធំមួយសម្រាប់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល"។ យុទ្ធសាស្ត្រនេះចែងទៀតថា "ប្រទេសកម្ពុជាចាំបាច់ត្រូវពង្រឹងភាពជាម្ចាស់កម្មសិទ្ធិ ភាពជាដៃគូ និងយន្តការកិច្ចសហប្រតិបត្តិការ ដើម្បីប្រមូលធនធានហិរញ្ញវត្ថុ បច្ចេកទេស និងចំណេះដឹងក្នុងការគាំទ្រដល់ការអភិវឌ្ឍជាតិ។ រហូតមកដល់ពេលនេះ កម្ពុជាសម្រេចបានភាពជោគជ័យអភិវឌ្ឍន៍ដ៏ធំធេងតាមរយៈការបើកចំហរសេដ្ឋកិច្ច ។ វិធីសាស្ត្រនេះ នឹងបន្តកំណត់វឌ្ឍនភាពរបស់កម្ពុជា ដែលតម្រូវឲ្យគ្រប់គ្នាពង្រឹងសមត្ថភាព ដើម្បីធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក"។

ដូច្នេះ ក្នុងអាណត្តិទី៦នេះ រដ្ឋាភិបាលបានកំណត់អាទិភាពលើការ "ពង្រឹងភាពជាម្ចាស់កម្មសិទ្ធិ និងភាពជាដៃគូក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ" (នៅខាងស្តាំដៃថ្នាក់ទី២)។ មានការទទួលស្គាល់ថា "បើទោះជាមានភាពល្អប្រសើរចំពោះលទ្ធភាពហិរញ្ញវត្ថុផ្ទាល់របស់កម្ពុជាក្នុងការជំរុញការអភិវឌ្ឍរបស់ប្រទេសក្តី ក៏ជំនួយបច្ចេកទេសអន្តរជាតិ និងហិរញ្ញប្បទានអភិវឌ្ឍន៍ នៅតែបន្តមានសារៈសំខាន់ ជាពិសេសសម្រាប់គម្រោងធំៗ និងគម្រោងដែលមានភាពស្មុគស្មាញ។ ក្នុងន័យនេះ ប្រទេសកម្ពុជាត្រូវពង្រឹងភាពជាម្ចាស់កម្មសិទ្ធិរបស់ខ្លួនក្នុងភាពជាដៃគូពិភាក្សាគោលនយោបាយ រួមទាំងដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការខិតខំរបស់ខ្លួនឆ្ពោះទៅរកការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចដោយចីរភាព និងទូលំទូលាយ"។

ស្ថិតក្រោមសមាសភាគនេះនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ វិស័យមួយក្នុងចំណោមវិស័យផ្តោតចំនួន ៦ គឺ "ពង្រឹងបន្ថែមទៀតនូវភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលតាមរយៈការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការ"។

ខណៈពេលដែលយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ធ្វើការបង្ហាញដោយការកោតសរសើរ និងមានបំណងល្អអំពីភាពដៃគូ ហើយភាពជាដៃគូនេះ វាទំនងជានឹងមាន ផ្នែកមិនប្រសើរជាមួយនឹងការអនុវត្តច្បាប់ LANGO។ ដោយពិចារណា វិសាលភាពនៃច្បាប់ LANGO មានភាពតូចចង្អៀតគួរសម (លក្ខខណ្ឌតម្រូវចុះបញ្ជី និងការរាយការណ៍ប្រចាំឆ្នាំ និងមិនអនុលោមភាពជាមួយនឹងលក្ខខណ្ឌតម្រូវទាំងនេះ)។

## *ផែនការ និងយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិ*

ការណ៍នេះបានគ្របដណ្តប់ទាំងក្នុងអំឡុងពេលសិក្សាឆ្នាំ២០១៥-២០១៨ ហើយក៏នឹងជះឥទ្ធិពលលើអំឡុងពេលដែលនឹងមកដល់នាពេលខាងមុខ។

ការរៀបចំផែនការ និងដំណើរការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ស្ថិតនៅក្នុងកម្មវិធី និងដំណើរការកំណែទម្រង់វិសហមជ្ឈការនិងវិមជ្ឈការ (D&D) ដែលកំពុងវិវឌ្ឍន៍ដំយូរ ដែលជាផ្នែកនៃកម្មវិធីជាតិសម្រាប់ការភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដែលត្រូវបានណែនាំដោយចំណែកបឋមចំនួនពីររបស់ច្បាប់ឆ្នាំ២០០៨ គឺ "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" "ច្បាប់រៀបចំអង្គការ" និង "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១"។

ច្បាប់ទាំងនេះតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និង ៣ឆ្នាំ ដោយមានចែងអំពីផែនការវិនិយោគ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍមូលដ្ឋាន។ អាជ្ញាធរមូលដ្ឋានដែលត្រូវបានបង្កើតឡើង ក៏ត្រូវចូលរួមពិគ្រោះយោបល់ និងចូលរួមជាមួយភាគីពាក់ព័ន្ធដែលសកម្មផ្សេងៗទៀតនៅក្នុងតំបន់របស់ខ្លួន ដែលគួរតែរួមបញ្ចូលអង្គការសង្គមស៊ីវិលផងដែរ។

ប្រព័ន្ធរៀបចំផែនការ និងអនុវត្តថ្នាក់ក្រោមជាតិ ផ្តល់ឱកាសសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីចូលរួមនិងធ្វើការងារយ៉ាងសកម្មជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ខណៈដែលពួកគេត្រូវបានផ្ទេរនិងគាំទ្រជាបន្តបន្ទាប់ ដើម្បីផ្តល់សេវានានា។ លើសពីនេះ អាជ្ញាធរមូលដ្ឋានបានដើរតួនាទីសម្របសម្រួលកាន់តែខ្លាំង ឧទាហរណ៍ តាមរយៈគណៈកម្មការស្ត្រី និងកុមារនៅថ្នាក់ឃុំ ស្រុក និងខេត្ត។

សមាសធាតុបន្ថែមមួយនៃការរៀបចំផែនការ គឺការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF) ដែលជាឧទាហរណ៍ជាក់ស្តែងកំពុងធ្វើឡើងតាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល។ ការអនុវត្តក្របខ័ណ្ឌនេះបានចាប់ផ្តើមក្នុងឆ្នាំ២០១៣ និងបានរីកលូតលាស់ជាបន្តបន្ទាប់ ដែលរហូតមកដល់ពេលបច្ចុប្បន្ន គ្របដណ្តប់លើស្រុកនៅទីជនបទចំនួន ៩៨ ក្នុងចំណោមស្រុកចំនួន ១៥៦ នៅទូទាំងខេត្តចំនួន១៨។

វិធីសាស្ត្រអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិតាមរយៈក្រុមប្រឹក្សានៅមូលដ្ឋាន បានបង្កើតឲ្យមានយន្តការសម្របសម្រួលមួយ ដែលភាគីពាក់ព័ន្ធអភិវឌ្ឍន៍ អាចចូលរួមបង្កើតគំនិតផ្តួចផ្តើមសម្រាប់អនុវត្តរួមគ្នា។ គំនិតផ្តួចផ្តើមទាំងនេះគឺសិក្ខាសាលាសមាហរណកម្មស្រុក ជាទីដែលភាគីពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិល និងទីភ្នាក់ងាររដ្ឋាភិបាល អាចស្នើ ឬយល់ព្រមសហប្រតិបត្តិការ និងសហការលើសកម្មភាពនានា។ ខណៈដែលគំនិតផ្តួចផ្តើមទាំងនេះមានសក្តានុពលខ្ពស់ មិនថាអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល បង្កើតអនុវត្តការព្រមព្រៀង/ទំនាក់ទំនងឬយ៉ាងណានោះ?

របៀបដែលអង្គការសង្គមស៊ីវិលចូលរួម និងធ្វើការងារជាមួយអាជ្ញាធរមូលដ្ឋាន មានការកត់ត្រាឯកសារមិនបានល្អ និងមានភាពរប៉ាត់រប៉ាយ ខណៈដែលវាគឺជារឿងដែលអាជ្ញាធរមូលដ្ឋានមានការ

ទទួលខុសត្រូវកាន់តែខ្លាំងសម្រាប់ការរៀបចំផែនការ និងការអភិវឌ្ឍ ហើយរដ្ឋាភិបាលបានប្តេជ្ញាចិត្ត បង្កើនថវិកាអភិវឌ្ឍន៍របស់ខ្លួន ដែលជាកត្តាមួយក្នុងចំណោមកត្តាមានកម្រិតចម្បងៗ សម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ មានឧទាហរណ៍ជាច្រើនអំពីសកម្មភាពកិច្ចសហប្រតិបត្តិការ ដែលអង្គការសង្គមស៊ីវិលដែលមានធនធានធ្វើការងារជាមួយអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីពង្រឹង និងលើកកម្ពស់សេវា និងដើម្បីចូលរួមចំណែកដល់គោលបំណងអភិវឌ្ឍន៍ជាតិ។ ការរៀបចំកិច្ចសហប្រតិបត្តិការទាំងនេះជាញឹកញាប់បំផុតកើតមានក្នុងវិស័យសង្គម (សុខាភិបាល ការអប់រំ ការកាត់បន្ថយភាពក្រីក្រ ការការពារកុមារ យេនឌ័រ) និងវិស័យជីវភាពរស់នៅ (ការផ្សព្វផ្សាយកសិកម្ម និងសកម្មភាពនានា ការគ្រប់គ្រងធនធានធម្មជាតិនៅសហគមន៍ ការត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ/ភាពធន់នឹងបរិយាកាស)។ ទោះជាយ៉ាងណា មិនមានការកត់ត្រាថាតើជាអ្នកណា? កំពុងធ្វើអ្វី? ធ្វើក្នុងកម្រិតណា? និងនៅទីកន្លែងណា? នោះទេ។

អាជ្ញាធរមូលដ្ឋានបានសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល ដើម្បីឲ្យអង្គការសង្គមស៊ីវិលមានលទ្ធភាពអនុវត្តសកម្មភាពនានា ដែលញឹកញាប់ជាងមិនសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដែលត្រូវបានជំរុញដោយអង្គការសង្គមស៊ីវិល ដែលផ្តល់ ឬគាំទ្រសេវាកម្ម ខណៈដែលពួកគេមានធនធានសម្រាប់សកម្មភាពបែបនេះ ហើយអាជ្ញាធរមូលដ្ឋានភាគច្រើនស្វាគមន៍អង្គការសង្គមស៊ីវិល។ ប៉ុន្តែក្នុងអំឡុងពេលស្ថិតក្នុងការសិក្សានេះ អ្នកផ្តល់ព័ត៌មានសំខាន់ៗបានសង្កេតឃើញថា វាបានប្រែក្លាយកាន់តែលំបាកក្នុងការចូលរួមទៅក្នុងតំបន់ថ្មី។ ប្រសិនបើពួកគេគ្រាន់តែពង្រីកនៅក្នុងតំបន់ដែលមានស្រាប់របស់ខ្លួន មិនមានបញ្ហាទេ ប៉ុន្តែការបង្កើតទំនាក់ទំនងក្នុងតំបន់ថ្មី កាន់តែមានការលំបាក ដោយសារអាជ្ញាធរមូលដ្ឋានជាញឹកញាប់មានការស្ទាក់ស្ទើក្នុងការចូលរួម។

*វិធីសាស្ត្រទំនាក់ទំនង*

ដូចច្នេះរបៀបដែលស្ថាប័នរបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបង្កើតទំនាក់ទំនង នៅតែមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនច្បាស់លាស់ និងមិនត្រូវបានរាយការណ៍។

- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ជាទូទៅប្រើប្រាស់ការចុះបញ្ជីរបស់ខ្លួននៅក្រសួងមហាផ្ទៃ ដើម្បីភ្ជាប់ខ្លួនទៅនឹងស្ថាប័នជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីទទួលបានអនុស្សរណៈនៃការយោគយល់ (MoU) ដើម្បីអាចឲ្យពួកគេអនុវត្តសកម្មភាពនានាបាន ខណៈពេលដែលអង្គការអន្តរជាតិប្រើប្រាស់កេរ្តិ៍ឈ្មោះរបស់ខ្លួន និងបានស្នើសុំផ្តល់មូលនិធិ/វិនិយោគ ដើម្បីទទួលបានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលគាំទ្រឲ្យទទួលបានអនុស្សរណៈជាមួយក្រសួងសាមី ហើយអនុស្សរណៈទាំងនេះ អាចផ្តល់លទ្ធភាពឲ្យធ្វើការងារជាមួយមន្ទីរនានានៅតាមខេត្តរបស់ក្រសួងសាមី និងតាមរយៈមន្ទីរទាំងនេះដើម្បីធ្វើការងារជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ។

មានយន្តការផ្សេងទៀតសម្រាប់ការបន្សុីជាមួយនឹងរដ្ឋាភិបាល។ យន្តការទាំងនេះរួមមានប្រព័ន្ធរៀបចំផែនការថ្នាក់ក្រោមជាតិ ដែលអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ត្រូវបានសួរអំពីថាតើសកម្មភាពអ្វីដែលពួកគេកំពុងអនុវត្ត ឬរៀបចំផែនការអនុវត្ត និងនៅក្នុងតំបន់រដ្ឋបាលណា (ឃុំ ស្រុក និងខេត្ត) ដែលអាចត្រូវបានរួមបញ្ចូលទៅក្នុងការអភិវឌ្ឍតំបន់ (ជាធម្មតារៀងរាល់ ៥ ឆ្នាំម្តង ប៉ុន្តែត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំពីទស្សនវិស័យវិនិយោគមួយ) ។

អង្គការសង្គមស៊ីវិល ក៏អាចចូលរួមចំណែកផងដែរ តាមរយៈការចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មស្រុក (District Integration Workshop) ដែលគោលបំណងរបស់សិក្ខាសាលានេះ គឺដើម្បីផ្តល់លទ្ធភាពឲ្យមានការបន្សុីទៅនឹងសកម្មភាពអភិវឌ្ឍន៍តំបន់នានា ហើយពួកគេអាចបង្កើតកិច្ចព្រមព្រៀងនានាជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ ឬគាំទ្រសេវាកម្ម។ (គោលបំណងបែបទ្រឹស្តី)។

កង្វះការបន្សុីរវាងអាជ្ញាធរនៅថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលតូចៗ ត្រូវបានចង្អុលបង្ហាញទៅកាន់តម្រូវការឲ្យមានប្រព័ន្ធដែលត្រូវបានធ្វើឲ្យមានភាពប្រសើរមួយ ដែលឯកសារនានាបានរួមបញ្ចូលគ្នានូវកិច្ចប្រឹងប្រែង ដែលយុទ្ធសាស្រ្តបង្កើតបានជារចនាសម្ព័ន្ធមួយសម្រាប់ដំណើរការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពកាន់តែខ្លាំង។ កម្មវិធីនានាដូចជា ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពដោយចីរភាព (ISAF) បង្ហាញឲ្យឃើញពីសារៈសំខាន់នៃទំនាក់ទំនង និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សម្រាប់ការអភិវឌ្ឍប្រកបដោយជោគជ័យ។ ហើយបើទោះជាភាពជោគជ័យមួយចំនួនក្នុងចំណោមភាពជោគជ័យរបស់កម្មវិធីបែបនេះ អាចកើតមានឡើងដោយសារថវិកាច្រើន និងមានកម្រិតតម្លាភាពខ្ពស់ក្តី ក៏មានមេរៀនដែលត្រូវរៀនសូត្រសម្រាប់គម្រោងតូចៗផងដែរ។

បញ្ហានានាក៏ត្រូវបានបង្ហាញផងដែរអំពីអប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ។ ការប្រាស្រ័យទាក់ទងត្រូវបានទទួលស្គាល់ថាជាបញ្ហាប្រឈមខ្លាំងមួយសម្រាប់អង្គការសង្គមស៊ីវិលជាច្រើន ដោយសារអង្គការទាំងនេះជាញឹកញាប់ខ្វះលទ្ធភាពក្នុងការរក្សាតួនាទីខ្លួនឯងផ្ទាល់នៅក្នុងចង្វាក់តម្លៃ។ ជាមួយនឹងចំនួនដ៏ច្រើននៃអង្គការសង្គមស៊ីវិលនាពេលបច្ចុប្បន្ន និងដោយពិចារណាលើអវត្តមាននៃព័ត៌មានអំពីលទ្ធភាពពិតប្រាកដនៃអង្គការសង្គមស៊ីវិល អាចមានការមើលឃើញអំពីរបៀបដែលអាជ្ញាធរមូលដ្ឋានអាចសួរអំពីតម្រូវការឲ្យមានការធ្វើអន្តរាគមន៍។ ប្រសិនការយល់ដឹងអំពីយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិសម្រាប់អាជ្ញាធរមូលដ្ឋានត្រូវធ្វើឲ្យប្រសើរឡើង ហើយអង្គការសង្គមស៊ីវិលមានលទ្ធភាពកាន់តែប្រសើរក្នុងការបង្ហាញរបៀបដែលពួកគេចូលរួមចំណែកចំពោះការអនុវត្តដោយជោគជ័យនូវយុទ្ធសាស្រ្តបែបនេះ នោះការប្រាស្រ័យទាក់ទងរវាងភាគីទាំងពីរ នឹងកាន់តែមានភាពងាយស្រួល។

កង្វះការគ្រប់គ្រងដែលតម្រង់ទិសឆ្ពោះទៅរកគោលដៅ និងយុទ្ធសាស្រ្តរៀនសូត្រ គឺជាចរិកលក្ខណៈមួយ ដែលមិនត្រឹមតែសម្រាប់អង្គការសង្គមស៊ីវិលតូចៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់អង្គការធំៗដែលធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ (DPs) ផងដែរ។ ខណៈពេលដែលដៃគូ

អភិវឌ្ឍន៍ ពិតជាបាននាំយករចនាសម្ព័ន្ធមួយចំនួនទៅកាន់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន (IPs) នោះ វាមានសារៈសំខាន់ដើម្បីធានាបាននូវការផ្ទេរសមត្ថភាពទៅកាន់ដៃគូក្នុងស្រុក ជាពិសេសទាក់ទងនឹងការគ្រប់គ្រងគម្រោង/កម្មវិធីឲ្យបានសមស្រប។ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) គឺជាឧទាហរណ៍ល្អមួយអំពីការផ្ទេរសមត្ថភាពបែបនេះ និងមានលទ្ធភាពក្នុងការរក្សាតួនាទីខ្លួនឯងឲ្យស្ថិតនៅជាដៃគូក្នុងស្រុកខ្លាំងមួយសម្រាប់កម្មវិធីអភិវឌ្ឍន៍ការអប់រំ ពោលគឺជាតួនាទីមួយដែលស្ថិតនៅក្នុងអារម្មណ៍របស់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍អន្តរជាតិផងដែរ។

ការទាញយកសក្តានុពលរបស់វិស័យឯកជន ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍត្រូវបានមើលឃើញថាមានការលំបាក ប្រសិនបើអាច ដោយភាគីពាក់ព័ន្ធភាគច្រើនក្នុងការអភិវឌ្ឍ លើកលែងតែអង្គការ Australian Aid។ ជាមួយនឹងកម្មវិធីវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធ (3i) ព្រមទាំងកម្មវិធីចង្វាក់តម្លៃកសិកម្ម (CAVAC) របស់ខ្លួន ពួកគេអាចភ្ជាប់វិស័យឯកជនដោយជោគជ័យទៅក្នុងការអភិវឌ្ឍ និងបង្កើតបានជាឧទាហរណ៍នៃជម្រើសដ៏ល្អមួយ ហើយប្រហែលជាវិធីសាស្ត្រដែលមានមុខងារច្រើនឆ្ពោះទៅរកយុទ្ធសាស្ត្រ។

### *ធ្វើល្អ = រូបភាពអាក្រក់*

នៅពេលត្រូវបានសួរអំពីថា តើអង្គការសង្គមស៊ីវិលកំពុងធ្វើការងារល្អដែរឬយ៉ាងណា អ្នកឆ្លើយសម្ភាសទាំងអស់ ដែលតំណាងឲ្យអាជ្ញាធរថ្នាក់ជាតិ ទទួលស្គាល់ពីការចូលរួមចំណែកប្រកបដោយវិជ្ជមានរបស់អង្គការសង្គមស៊ីវិល ទាក់ទងនឹងការអភិវឌ្ឍ។ បើទោះជាមានបញ្ហាប្រឈមក្នុងការសួរអាជ្ញាធរអំពីកង្វះខាតផ្ទាល់របស់ពួកគេក្តី ក៏អាជ្ញាធរមួយចំនួនដែលត្រូវបានជ្រើសរើសដើម្បីសាកសួរពិតជាបានចង្អុលបង្ហាញទៅកាន់តម្រូវការឲ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀត រវាងភាគីពាក់ព័ន្ធនានា ដែលមានមូលដ្ឋានលើការយល់ពីគោលបំណងរបស់គ្នាទៅវិញទៅមកកាន់តែប្រសើរ។ នៅក្នុងអំឡុងពេលស្រាវជ្រាវ វាកាន់តែច្បាស់ថា មានគម្លាតមួយរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ទាក់ទងនឹងការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ខណៈពេលដែលចំណេះដឹងអំពីសេចក្តីលម្អិតនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅថ្នាក់ជាតិ មានកម្រិតល្អនោះ ការយល់ដឹងនៅថ្នាក់ក្រោមជាតិមិនតែងតែល្អនោះឡើយ ពោលគឺត្រលប់មកវិញ ការណ៍នេះធ្វើឲ្យទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន កាន់តែមានការលំបាកឡើង ដោយសារវាមិនតែងតែច្បាស់លាស់ឡើយថា ពួកគេកំពុងធ្វើការងារឆ្ពោះទៅរកគោលដៅដូចគ្នា។ ដោយពិចារណាទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិចំនួនជាង ៥.០០០ អង្គការដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា (CSOSI ឆ្នាំ២០១៧) ដែលអង្គការទាំងអស់ដែលមានទស្សនៈជាក់លាក់ខ្លាំងអំពីរបៀបចូលរួមចំណែកដល់ការអភិវឌ្ឍ យើងអាចមើលឃើញរបៀបដែលបញ្ហាប្រឈមនៃការគ្រប់គ្រងកិច្ចប្រឹងប្រែងដែលត្រូវបានសម្របសម្រួលមួយ ចាប់ផ្តើមលេចចេញឡើង។

ខណៈពេលដែលឱកាសភាគច្រើន កើតចេញមកពីការជម្នះនឹងបញ្ហាប្រឈមដែលមានស្រាប់នោះ មិនមានភាពខុសគ្នាដែលនឹងត្រូវបានធ្វើឡើងរវាងភាគីទាំងពីរនោះឡើយ។ ឱកាសសម្រាប់អង្គការសង្គមស៊ីវិលកម្ពុជា ដើម្បីលើកកម្ពស់បរិយាកាសអំណោយផលរបស់ខ្លួន ស្ថិតនៅលើការប្រឈមនឹងបញ្ហាដែលមានស្រាប់ និងបង្កើតដំណោះស្រាយ។ អនុសាសន៍មួយចំនួនអំពីអ្វីដែលនឹងត្រូវធ្វើ ដើម្បីសម្រេចបានកិច្ចការនេះ នឹងត្រូវបានផ្តល់ជូនលម្អិតនៅផ្នែកខាងក្រោមស្តីពីអនុសាសន៍។

## *ការយល់ឃើញអំពីទំនាក់ទំនងបច្ចុប្បន្ន*

ការអង្កេតសម្រាប់ការសិក្សានេះ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៨ បានសួរអ្នកតំណាងរបស់អង្គការសង្គមស៊ីវិល (៦៧នាក់) អំពីការយល់ឃើញរបស់ពួកគេក្នុងការធ្វើការងារជាមួយរដ្ឋាភិបាលនៅថ្នាក់ផ្សេងៗ។ វិធីសាស្ត្រដែលយកមកប្រើប្រាស់គឺថា តើពួកគេបានឯកភាព ឬក៏យ៉ាងណាចំពោះសេចក្តីថ្លែងការណ៍ "តើទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចាប់តាំងពីឆ្នាំ២០១៥មក មានភាពប្រសើរឡើងដែរឬទេ?"។ ដូចដែលត្រូវបានឃើញ ជិតពាក់កណ្តាលនៃអង្គការសង្គមស៊ីវិល (៤៦%) បានជឿថា ទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ មិនបានមានភាពប្រសើរឡើងឡើយចាប់ពីឆ្នាំ២០១៥មក។







ខណៈមួយភាគប្រាំនៃអ្នកឆ្លើយតប (២០%) បានជឿថា ទំនាក់ទំនងមានភាពល្អប្រសើរ។ គួរកាត់សម្គាល់ថា មួយភាគបីនៃអ្នកឆ្លើយតបនៅតែមានភាពអព្យាក្រឹតចំពោះបញ្ហានេះ។ នៅថ្នាក់ក្រោមជាតិ ជិតមួយភាគបួននៃអ្នកឆ្លើយតបដែលជាអង្គការសង្គមស៊ីវិល (២២%) ជឿថា ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានបានប្រសើរឡើង ខណៈពេលដែលជាងពីភាគប្រាំ (៤១%) បានជឿថា ទំនាក់ទំនងមិនបានមានភាពប្រសើរឡើងឡើយ។ ជាថ្មីម្តងទៀត មួយភាគបីនៃអ្នកឆ្លើយតប (៣៦%) នៅតែមានភាពអព្យាក្រឹត។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ឆ្នាំ២០១៣* | *ក្នុងអំឡុងពេលសិក្សា (ឆ្នាំ២០១៥-២០១៩)* |
|---|---|
| របាយការណ៍បានលើកឡើងថា មិនមានឧបសគ្គផ្នែកច្បាប់ចំពោះធាតុចូលរបស់សង្គមស៊ីវិលទៅក្នុងដំណើរការនយោបាយ និងការបោះឆ្នោត ឬដំណើរការគោលនយោបាយក្នុងប្រទេសកម្ពុជាឡើយ។ ក្រៅពីនេះ កាតព្វកិច្ចសីលធម៌មិនបានដាក់ទៅលើអង្គការសង្គមស៊ីវិលមិនឲ្យប្រកាន់បក្សពួក។<br><br>សង្គមស៊ីវិលមានទំនោរឆ្ពោះទៅរកការរាយការណ៍អំពីទំនាក់ទំនងកាន់តែមានភាពវិជ្ជមានជាមួយ រដ្ឋបាលថ្នាក់ទាប និងថ្នាក់មធ្យម។ ក្នុងឧទាហរណ៍ជាច្រើន តួអង្គសង្គមស៊ីវិល ក៏បានរាយការណ៍ពីទំនាក់ទំនងវិជ្ជមានផងដែរជាមួយក្រសួងសាមី ដែលពួកគេធ្វើការងារជាមួយ បើទោះជាការណ៍នេះមានភាពខុសគ្នាសម្រាប់ក្រសួងផ្សេងៗក្តី។ ក្រសួងសាមីមួយចំនួនអនុវត្តកិច្ចប្រជុំប្រចាំឆ្នាំជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលក្រសួងរក្សាអនុស្សរណៈនៃការយោគយល់ជាមួយ។<br><br>ការពិគ្រោះយោបល់ដែលដឹកនាំដោយរដ្ឋាភិបាលជាមួយសង្គមស៊ីវិល ពិតជាកើតមានឡើងនៅពេលខ្លះ ឧទាហរណ៍ ដើម្បីពិភាក្សាអំពីសេចក្តីព្រាងច្បាប់ LANGO។ ព្រឹត្តិការណ៍បែបនេះ ត្រូវបានមើលឃើញដោយមនុស្សមួយចំនួនថាជាកិច្ចប្រឹងប្រែងដើម្បីធ្វើឲ្យតួអង្គសង្គមស៊ីវិលមានភាពស្ងប់ចិត្តតាមរយៈការចូលរួម "ជានិមិត្តសញ្ញា"។ ឧទាហរណ៍ ព្រឹត្តិការណ៍ពិគ្រោះយោបល់ មិនរួមបញ្ចូលវគ្គសំណួរ និងចម្លើយ។ | លំហរសង្គមស៊ីវិលដើម្បីចូលរួមដោយឥតលម្អៀងក្នុងវេទិកានយោបាយបានបាត់បង់ ដោយសារការប៉ុនប៉ុងណាមួយអាចនាំឲ្យឈានទៅរកការកាត់ទោសឧក្រិដ្ឋពីបទញុះញង់។ ដូច្នេះមានការអត់អោនតិចតួចសម្រាប់គោលបំណងដែលចូលរួមដោយសង្គមស៊ីវិលក្នុងនយោបាយ។<br><br>នៅក្នុងអំឡុងពេលពិនិត្យមើល ទំនាក់ទំនងរវាងអង្គកាសង្គមស៊ីវិល និងរដ្ឋាភិបាលបានធ្លាក់ចុះ ដោយសារមន្ត្រីរដ្ឋាភិបាលមានភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយអង្គការសង្គមស៊ីវិល។<br><br>ការណ៍នេះត្រូវបានគួបផ្សំបន្ថែមទៀតដោយការដាក់ចេញលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិរបស់រដ្ឋាភិបាល (នៅខែតុលា ឆ្នាំ២០១៧) សម្រាប់អង្គការសង្គមស៊ីវិល ដោយតម្រូវឲ្យជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានមុនពេលរៀបចំសកម្មភាពក្នុងសហគមន៍។ វាបានប្រែក្លាយយ៉ាងច្បាស់ថា "ការជូនដំណឹង" ត្រូវបានបកស្រាយថាជាការទទួលបានការអនុញ្ញាត ដែលជាញឹកញាប់ត្រូវបានអូសបន្លាយពេល ឬមិនត្រូវបានផ្តល់ជូន ហើយក្រុមសន្តិសុខភូមិ និងនគរបាល ត្រូវបានណែនាំឲ្យស្វែងរកភស្តុតាងដែលបង្ហាញពីការដែលត្រូវបានអនុញ្ញាត/អនុម័ត។<br><br>បទពិសោធជាមួយទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល/រដ្ឋាភិបាល មានភាពខុសគ្នាខ្លាំងទៅតាមទីតាំងនិងវិស័យ។ តួរអង្គនានានៅក្នុងវិស័យមិនសូវមានភាពចម្រូងចម្រាស់ បានរាយការណ៍ថាកើតមានបញ្ហាតិចតួច និងមិនមានបញ្ហាចំពោះការពាក់ព័ន្ធរបស់ខ្លួនជាមួយនឹងតួអង្គរដ្ឋាភិបាល |

| | |
|---|---|
| កន្លងមកក៏មានបុគ្គលមួយចំនួននៅក្នុងរដ្ឋាភិបាលដែលបានចូលរួមក្នុងការជ្រើសរើសបែបជ្រើសរើស (Selective) អង្គការមិនមែនរដ្ឋាភិបាលជាក់លាក់ ដើម្បីតំណាងឲ្យសង្គមស៊ីវិលកម្ពុជា ក្នុងការអនុវត្តការពិគ្រោះយោបល់ នានាផងដែរ ជាពិសេសនៅក្នុងវេទិកាអន្តរជាតិ ជំនួសឲ្យការអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលជ្រើសតាំងអ្នកតំណាងផ្ទាល់របស់ពួកគេ។ | ឡើយ។ ទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលផ្សេងទៀតនៅក្នុងវិស័យមានភាពចម្រូងចម្រាស់ខ្លាំង រាយការណ៍ពីការកើតមានបញ្ហាខ្លាំងក្នុងការព្យាយាមអនុវត្តសកម្មភាពរបស់ខ្លួន។<br>ក៏មានការរាយការណ៍ផងដែរថា រដ្ឋាភិបាលបានចាប់ផ្ដើមបង្កើត និងគាំទ្រអង្គការសង្គមស៊ីវិល និងបណ្ដាញដែលគាំទ្ររដ្ឋាភិបាល ដែលមានលទ្ធភាពអនុវត្តសកម្មភាពនានា ខណៈដែលអង្គការផ្សេងទៀតមានការលំបាក។ |

## បញ្ហាប្រឈម និងការផ្ដល់យោបល់

| បញ្ហាប្រឈម | ការផ្ដល់យោបល់ |
|---|---|
| ➢ ភាពមិនទុកចិត្ត មិនមានព័ត៌មានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពអំពីអ្នកណាម្នាក់? កំពុងធ្វើអ្វី? នៅទីកន្លែងណា? ក្នុងកម្រិតណា? និងជាមួយអ្នកណា?<br>  ➢ ការណ៍នេះដាក់កម្រិតដល់ទាំងអង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ក្នុងការសម្របសម្រួលធាតុចូល និងផ្ដោតទិសដៅកាន់តែប្រសើរលើការធ្វើអន្តរាគមន៍នៅទីកន្លែងណាដែលមានតម្រូវការខ្លាំងបំផុត។<br>➢ កង្វះយន្តការ ឬយន្តការនៅមានកម្រិត ដើម្បីចែករំលែក និងសម្របសម្រួលសកម្មភាព និងការធ្វើអន្តរាគមន៍ រវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។<br>➢ ការយល់ដឹងនៅមានកម្រិតអំពីតួនាទី និងការទទួលខុសត្រូវទៅវិញទៅមក និងសកម្មភាពដែលពួកគេត្រូវធ្វើ។<br>➢ បង្កើត និងពង្រឹងទំនាក់ទំនងការប្រាស្រ័យទាក់ទងរួមគ្នា ដោយបង្កើតយន្តការ ដើម្បីសម្របសម្រួលកាន់តែប្រសើររវាងគូភាគី។ | ➢ បង្កើតប្រព័ន្ធផែនទី និងឯកសារដែលមានមូលដ្ឋានលើកុំព្យូទ័រ (cloud) ប្រភពចំហរមួយ (GIS)។<br>➢ រៀបចំព្រឹត្តិការណ៍រៀនសូត្រ និងចែករំលែកតាមដំណាក់កាល (ពីរ ឬបួនដងក្នុងមួយឆ្នាំ) នៅថ្នាក់ក្រោមជាតិ ដោយនាំយករួមគ្នានូវអ្នកតំណាងរបស់រដ្ឋាភិបាល និងរបស់អង្គការសង្គមស៊ីវិល។<br>➢ លើកកម្ពស់យន្តការសម្របសម្រួល ថ្នាក់មូលដ្ឋាន ដើម្បីកសាងទំនុកចិត្តនិងការយល់ដឹង។<br>➢ គំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍សមត្ថភាពរួមគ្នា ដើម្បីកសាងសមត្ថភាព។ |

# ភាពជាដៃគូប្រកបដោយបរិយាប័ន្ន

## ទិដ្ឋភាពរួម

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិចែងថា "ភាពជាដៃគូប្រកបដោយបរិយាប័ន្នបង្កើតឡើងដោយឈរលើគោលការណ៍ និងគុណតម្លៃ (ដែលមានការព្រមព្រៀង) ដោយមានទស្សនៈវិស័យ និងគោលដៅរួមគ្នា និងត្រូវការជាចាំបាច់នៅកម្រិតសកលថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន[108]"។ មានកង្វះការមូលមតិគ្នាលើចំណុចទាំងនេះ ដែលអាចកំពុងរារាំងដល់ការចាប់ដៃគូប្រកបដោយបរិយាប័ន្ននៅកម្ពុជា។ ថ្មីៗនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានលើកឡើងថា[109] "ភាពជាដៃគូ" គឺជាការប្រាស្រ័យទាក់ទង/ការទំនាក់ទំនងដ៏ស្មោះត្រង់មួយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ និងអង្គការសង្គមស៊ីវិល និង/ឬវិស័យឯកជន ដើម្បីអនុវត្តសកម្មភាពសម្រាប់ជាប្រយោជន៍ដល់ប្រជាជន។ ជាទូទៅ ការអនុវត្តភាពជាដៃគូអាចទទួលបានជោគជ័យ លុះត្រាណាបណ្តាភាគីចូលរួមជាមួយគ្នានៅគ្រប់ដំណាក់កាលទាំងអស់នៃការដោះស្រាយវិវាទរួមគ្នា។ បណ្តាភាគីនៃភាពជាដៃគូ ចាំបាច់ត្រូវជឿទុកចិត្តគ្នា គាំទ្រគ្នា អាចរកគ្នា និងយល់ស្របគ្នាទៅវិញទៅមក ដើម្បីរៀនសូត្រ និងចែករំលែកបទពិសោធន៍ដើម្បីសម្រេចគោលបំណងរួមមួយ[110]។

ផ្តើមចេញពីទស្សនវិស័យទូលំទូលាយមួយ រដ្ឋាភិបាលបានអនុម័ត និងដាក់បញ្ចូលចំណុចដៅមួយនៃទិសដៅភាពជាដៃគូសកល (SDG ១៧.១៧) ទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) ដែលបានធ្វើមូលដ្ឋានីយកម្ម និងបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៨ ពោលគឺដើម្បី "លើកទឹកចិត្ត និងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព រវាងសាធារណៈនិងផ្នែកឯកជន និងជាមួយសង្គមស៊ីវិល កសាងភាពជាដៃគូផ្អែកលើបទពិសោធ និងយុទ្ធសាស្ត្រផ្តល់ធនធាននៃភាពជាដៃគូ"[111]។ យើងអាចរកឃើញចំណុចស្រដៀងគ្នាមួយចំនួនរវាងនិយមន័យខាងលើ និងនិយមន័យសកលដែលបានយកចេញពីគោលដៅទី១៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បី "ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព"។

ភាពជាដៃគូប្រកបដោយបរិយាប័ន្នពាក់ព័ន្ធនឹងទំនាក់ទំនងគ្នាទៅវិញទៅមក និងគួរឲ្យទុកចិត្តក្នុងចំណោមតួអង្គអភិវឌ្ឍន៍ដែលពាក់ព័ន្ធទាំងអស់ ដែលមានសារៈសំខាន់ក្នុងការធានា *"របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពដ៏ជោគជ័យមួយ តម្រូវឲ្យមានភាពជាដៃគូរវាងរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ ភាពជាដៃគូប្រកបដោយបរិយាប័ន្នទាំងនេះ បង្កើតឡើងដោយផ្អែកលើគោលការណ៍ និងគុណតម្លៃ ដែលមានទស្សនៈវិស័យ និងគោលដៅរួម ដែលដាក់មនុស្ស និងភពផែនដីឲ្យ*

108 https://www.un.org/sustainabledevelopment/globalpartnerships/

109 Sar Kheng, deputy prime minister and minister of MoI, speech at the Partnership Forum between Government and NGOs on 17th January 2019, page 1 & 2.

110 ibid

111 For this SDG (#17) RGC has adopted eight of the 19 targets, as most of the targets in SDG 17 related to international cooperation.

*នៅចំកណ្តាល (ដោយសារភាពជាដៃគូប្រកបដោយបរិយាប័ន្ននេះ) ត្រូវការជាចាំបាច់នៅកម្រិតសកល ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន"*[112]។ ការបង្កប់ក្នុងទស្សនទាននៃភាពជាដៃគូប្រកបដោយបរិយាប័ន្នគឺជាគោលការណ៍ស្នូលនៃគណនេយ្យភាព និងការគោរពគ្នាទៅវិញទៅមក។ នេះមានន័យថា ដៃគូនីមួយៗតម្កល់គុណតម្លៃទាំងនេះប្រកបដោយសមធម៌ និងភាពស្មោះត្រង់ ដើម្បីធ្វើការងារក្នុងភាពជាដៃគូ ក្នុងរបៀបមួយដែលផ្តល់រង្វាន់ដល់ភាគីនីមួយៗក្នុងភាពជាដៃគូ ដោយមិនឲ្យភាគីណាមួយបាត់បង់ ដែលត្រូវបានប្រើប្រាស់ ឬត្រូវបានបំផ្លាញឡើយ។

## លទ្ធផលរកឃើញ និងការវិភាគ

### *បរិបទជាតិសម្រាប់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន*

រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អភិវឌ្ឍន៍ (ម្ចាស់ជំនួយ) បានទទួលស្គាល់សារៈសំខាន់នៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដោយសារវាបង្កើតបានជាសមាសភាគដ៏សំខាន់មួយនៃការផ្តល់មតិបែបស្ថាបនាប្រកបដោយប្រសិទ្ធភាពនៃជំនួយអន្តរជាតិនៅ ក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស (ឆ្នាំ២០០៥)[113] កិច្ចព្រមព្រៀងទីក្រុងអាក្រា (ឆ្នាំ២០០៨)[114] និងកិច្ចព្រមព្រៀងទីក្រុងប៊ូសាន (ឆ្នាំ២០១២)[115] ដែលជាឧបករណ៍រួមគ្នាក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍រួម និងលទ្ធផលអភិវឌ្ឍន៍ចុងក្រោយ។

រដ្ឋាភិបាលនៅគ្រប់ដំណាក់កាលទាំងអស់ (I-IV) នៃយុទ្ធសាស្ត្រចតុកោណ បានលើកឡើងថាខ្លួនស្វែងរកកិច្ចសហប្រតិបត្តិការទាំងជាមួយវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីសម្រេចបាននូវផែនការនិងគោលដៅអភិវឌ្ឍន៍របស់ខ្លួន។ ដៃគូអភិវឌ្ឍន៍ និងអង្គការសហប្រជាជាតិដ៏ដូចគ្នាដែរ។ សហគមន៍អឺរ៉ុប (EC) អង្គការ SIDA ភ្នាក់ងារUSAID អង្គការ SDC និងអ្នកផ្តល់ការអភិវឌ្ឍន៍ផ្សេងទៀតផ្តល់ការលើកទឹកចិត្តជាទៀងទាត់ ប្រសិនបើមិនត្រូវការដៃគូអភិវឌ្ឍន៍ឲ្យធ្វើការក្នុងសម្ព័ន្ធភាពជាដៃគូ ឬដោយការសហការជាមួយគ្នាទៅវិញទៅមក។ ទោះបីជាមានភស្តុតាងបញ្ជាក់ពីកំណើនកិច្ចសហប្រតិបត្តិការក្នុងវិស័យនានាក៏ដោយ ក៏ប៉ុន្តែកិច្ចសហប្រតិបត្តិការឆ្លងវិស័យនៅតែមានការរាយការណ៍ថាមានកម្រិតទាបនៅឡើយ (អង្គការ គ.ស.ក ឆ្នាំ២០១៣)។

បច្ចុប្បន្ន មានវេទិកាហ្វមសម្របសម្រួលដៃគូមានស្រាប់មួយចំនួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលផ្តល់ឧទាហរណ៍អំពីលំហរ ដើម្បីជះឥទ្ធិពល និងចូលរួមក្នុងការជជែកវែកញែកអំពីគោលនយោបាយជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។ វេទិកាទាំងនេះរួមបញ្ចូលទាំងវេទិការដ្ឋាភិបាល-វិស័យឯកជន (G-PSF) ក្រុមការងារបច្ចេកទេស (២១) ដែលបច្ចុប្បន្ន

112 https://sdg-tracker.org/global-partnerships
113 https://www.oecd.org/dac/effectiveness/parisdeclarationandaccraagendaforaction.htm
114 https://www.oecd.org/dac/effectiveness/45827311.pdf
115 https://www.oecd.org/dac/effectiveness/busanpartnership.htm

មាន ១៩ ដែលភាគច្រើននៃក្រុមការងារទាំងនេះ មានកម្រិតសកម្មខុសៗគ្នា ហើយក្រុមការងារខ្លះសកម្មជាងក្រុមការងារផ្សេងទៀត។

បន្ថែមពីលើនេះ មានយន្តការសម្របសម្រួលជាច្រើនផ្សេងទៀត ដែលត្រូវបានបន្សុីជាមួយអាណត្តិរបស់ក្រសួង/វិស័យ។ យន្តការមួយក្នុងចំណោមយន្តការទាំងនេះ អាចឲ្យមានការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF) និងការតស៊ូមតិដើម្បីឲ្យដាក់ដំណើរការវេទិកាពហុភាគីពាក់ព័ន្ធដើម្បីជួយធានាថា តួអង្គអភិវឌ្ឍន៍/ភាគីពាក់ព័ន្ធទាំងអស់មានលំហរប្រកបដោយបរិយាប័ន្ន ដើម្បីនិយាយអំពីរបៀបវារៈផ្ទាល់របស់ខ្លួន ក៏ដូចជាចែករំលែកទស្សនវិស័យមួយចំនួន ដើម្បីជម្នះឲ្យបាននូវបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍរួម។

យោងតាមយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូឆ្នាំ ២០១៩-២០២៣ (ខែមករា ឆ្នាំ២០១៩) របស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ភាពជាដៃគូផ្តោតយ៉ាងខ្លាំងទៅលើថ្នាក់ខ្ពស់ (រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) ដោយឡែកវេទិកាភាពជាដៃគូ រវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផ្តោតតែនៅថ្នាក់កណ្តាល (ក្រសួងមហាផ្ទៃ-អង្គការមិនមែនរដ្ឋាភិបាល) និងថ្នាក់ក្រោមជាតិ (រដ្ឋបាលថ្នាក់ខេត្ត-អង្គការមិនមែនរដ្ឋាភិបាល)។ CRDB/CDC បានអនុម័តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដែលមានគោលដៅ "កៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រើប្រាស់ធនធានទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅឈានទៅសម្រេច គោលដៅអភិវឌ្ឍន៍កម្ពុជា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក៏ដូចជាយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល"។

**ទិសដៅជាយុទ្ធសាស្ត្រទី ១៖** ភាពជាម្ចាស់។ ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរ និងគ្រប់គ្រងធនធាន។

**ទិសដៅជាយុទ្ធសាស្ត្រទី ២៖** ភាពជាដៃគូ។ ការគាំទ្រប្រកបដោយសង្គត់ភាព និងការសម្របសម្រួល ដើម្បីលើកកម្ពស់ការផ្តល់សេវា និងពង្រឹងប្រព័ន្ធជាតិ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៣៖** លទ្ធភាព។ ប្រព័ន្ធតាមដានរឹងមាំ និងគោលការណ៍ស្តីពីគណនេយ្យភាពទ្វេទិស គឺជាមូលដ្ឋានសម្រាប់ពង្រឹងភាពជាដៃគូដោយផ្អែកលើសក្ខីកម្ម។

យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាលាយលក្ខណ៍អក្សរ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដោយឡែករដ្ឋាភិបាល-អង្គការមិនមែនរដ្ឋាភិបាល មានគោលការណ៍ណែនាំអំពីរបៀបដែលត្រូវរៀបចំវេទិកា។

### គោលការណ៍ណែនាំសម្រាប់ការគាំទ្រកិច្ចពិភាក្សាអំពីភាពជាដៃគូ

ពេលថ្មីៗនេះ រដ្ឋាភិបាល និងដៃគូ បានដោះស្រាយកំណើនតម្រូវការនៃភាពចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ រាប់ទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជន។ ដោយសារកិច្ចសហប្រតិបត្តិការមួយចំនួន បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គោលការណ៍ណែនាំចំនួន៤ រហូតមកដល់ពេលនេះត្រូវបានអនុម័ត (នៅខែមេសា ២០១៩)[116]៖

1. គោលបំណងនៃ**<u>យន្តការកិច្ចពិភាក្សាពហុភាគីពាក់ព័ន្ធតាមវិស័យ</u>** គឺដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា យុទ្ធសាស្ត្រ/ផែនការតាមវិស័យ កម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ។ គោលបំណងនេះមានគោលដៅគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំក្នុងការអនុវត្តផែនការ និងកំណែទម្រង់តាមវិស័យ។ ដើម្បីឲ្យអាច និងធានាបាននូវភាពជាដៃគូក្នុងការកៀរគរ និងការសម្របសម្រួលធនធាន និងផ្ដល់លទ្ធផលនៃ ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា យុទ្ធសាស្ត្រ/ផែនការតាមវិស័យ។
2. គោលបំណងនៃ**<u>កិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល</u>** ត្រូវធ្វើឡើងដើម្បីធានាថា ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល គឺមានសង្គត់ភាព និងប្រសិទ្ធភាព ស្របតាមអាទិភាពអភិវឌ្ឍន៍ជាតិសំខាន់ៗ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) យុទ្ធសាស្ត្រតាមវិស័យ/កម្មវិធីកំណែទម្រង់។
3. **<u>ក្រុមការងារបច្ចេកទេស (TWGs)</u>** តាមវិស័យ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីឆ្នាំ២០០៤ មក ដើម្បីបម្រើជាស្ថាប័នសម្របសម្រួល និងយន្តការកិច្ចពិភាក្សាភាពជាដៃគូ ដែលនាំយកមករួមគ្នានូវរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ដែលត្រូវបានអញ្ជើញ) ដើម្បីគាំទ្រដល់ការសម្រេចបានអាទិភាពអភិវឌ្ឍន៍ជាតិដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ/កម្មវិធីកំណែទម្រង់។ រហូតមកដល់ពេលនេះ ក្រុមការងារបច្ចេកទេស (២០) បច្ចុប្បន្នត្រូវបានទទួលស្គាល់នៅទូទាំងវិស័យជាច្រើន កម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ តាមវិស័យ។ គោលបំណងនៃក្រុមការងារបច្ចេកទេស គឺដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្របសម្រួលកិច្ចពិភាក្សាបច្ចេកទេស សម្របសម្រួល និងកៀរគរ

[116] http://www.cdc-crdb.gov.kh/dcps/guidelines/default.htm

ជំនួយខាងក្រៅ ដើម្បីអនុវត្តយុទ្ធសាស្ត្រ/ផែនការកំណែទម្រង់/តាមវិស័យ ដែលមានការពាក់ព័ន្ធនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ យន្តការទាំងនេះមិនមានបំណងជំនួសឲ្យ ឬដើម្បីត្រួតស៊ីគ្នានូវមុខងាររបស់ក្រសួង/ទីភ្នាក់ងារនានានោះទេ។

4. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងលេខ ៥៩៨ ក្នុងគោលបំណងបង្កើតរដ្ឋបាលថ្នាក់ខេត្ត និងក្រុង ដើម្បីរៀបចំ**<u>កិច្ចពិភាក្សាភាពជាដៃគូថ្នាក់ក្រោមជាតិ</u>**។ គោលបំណងរបស់កិច្ចពិភាក្សាភាពជាដៃគូថ្នាក់ក្រោមជាតិទាំងនេះ គឺដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈ ជួយឲ្យមានការគាំទ្រដល់ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល ៣ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គោលការណ៍ណែនាំនីមួយៗមានចែងអំពីគោលបំណង គោលការណ៍ណែនាំ វិស័យអាទិភាព ការរៀបចំស្ថាប័នសម្រាប់អ្នកចូលរួម និងយន្តការគាំទ្រសម្រាប់ការអនុវត្តការរៀបចំនានា ព្រមទាំងពិនិត្យតាមដាន និងវាយតម្លៃកិច្ចពិភាក្សាអំពីភាពជាដៃគូ។

ទាំងនេះមានសក្តានុពល និងអាចផ្តល់ឱកាសសម្រាប់ការចូលរួម និងភាពជាដៃគូកាន់តែខ្លាំងនៅទូទាំងវិស័យជាច្រើន។ វានឹងអាស្រ័យលើតួអង្គអភិវឌ្ឍន៍ រួមទាំងអង្គការសង្គមស៊ីវិល ដើម្បីទាញយកអត្ថប្រយោជន៍ និងប្រើប្រាស់ការណែនាំ ដើម្បីផ្តល់លទ្ធភាពឲ្យមានភាពជាដៃគូប្រកបដោយបរិយាប័ន្ននៅទូទាំងវិស័យ។

*កង្វះចំណេះដឹង និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន*

នៅទូទាំងការសិក្សានេះ ទាំងអាជ្ញាធរ និងអង្គការសង្គមស៊ីវិលបង្ហាញឲ្យឃើញពីចំណេះដឹងនៅមានកម្រិតអំពីភាពជាដៃគូប្រកបដោយបរិយាប័ន្ន (IPs)។ នៅពេលដែលត្រូវបានស្នើឲ្យលើកឡើងនូវឧទាហរណ៍អំពីគម្រោង ឬកម្មវិធី ដែលទាមទារឲ្យមានកិច្ចសហប្រតិបត្តិការនោះ ពួកគេត្រឹមតែអាចផ្តល់ការឆ្លើយតបដែលមានកម្រិត។ ប្រសិនបើអង្គការសង្គមស៊ីវិលមានទំនាក់ទំនងការងារផ្លូវការ ដែលពួកគេត្រូវបានតម្រូវឲ្យចូលរួមចំណែកចំពោះគោលបំណងជាក់លាក់មួយ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង/ឬគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គួរមានការដាក់ដំណើរការប្រព័ន្ធមួយ ដែលវាស់វែងផលប៉ះពាល់នៃការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ដែលលើសពីវិធីសាស្ត្រគណនេយ្យ/ហិរញ្ញប្បទាន។ ទោះជាយ៉ាងណា ការណ៍នេះមិនទំនងនឹងជាលក្ខខណ្ឌតម្រូវនោះទេ ហើយក៏មិនមានការដាក់ដំណើរការយន្តការដើម្បីគាំទ្របញ្ហានេះ (នៅឡើយដែរ)។

សម្រាប់អាជ្ញាធរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក្យថា "ភាពជាដៃគូប្រកបដោយបរិយាប័ន្ន

(IP)″ មិនមានការពាក់ព័ន្ធនឹងកម្មវិធី និងគម្រោងជាក់លាក់នោះទេ។ អវត្តមាននៃការឆ្លើយតប ឬការទទួលស្គាល់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន អាចបង្ហាញឲ្យឃើញពីទំនាក់ទំនងខ្សោយសម្រាប់អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ក្នុងនាមជាអ្នកចូលរួមចំណែករួមគ្នាចំពោះការអភិវឌ្ឍ។ មានឧទាហរណ៍តាមវិស័យអំពីភាពជាដៃគូរយៈពេលវែង និងប្រកបដោយប្រសិទ្ធភាពដូចជា៖

- នៅក្នុងវិស័យអប់រំ ដែលពាក់ព័ន្ធនឹងអង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល (NEP)[117] និងក្រុមការងារផ្នែកអប់រំថ្នាក់ជាតិ និងថ្នាក់ខេត្ត។
- ភាពជាដៃគូសម្រាប់ត្រៀមបង្ការគ្រោះមហន្តរាយនៅកម្ពុជា (PPC)[118] និងយន្តការសម្របសម្រួលជំនួយ ដែលពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និងយន្តការរបស់ភាគីពាក់ព័ន្ធផ្សេងទៀត (ក្រុមធ្វើសកម្មភាពរួម ‶JAG″ វេទិកាឆ្លើយតបមនុស្សធម៌ ‶HRF″ និងវេទិកាមនុស្សធម៌កម្ពុជា ‶CHF″)។
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (CARD) ដែលជាក្រុមការងារទទួលបន្ទុកលើការផ្គត់ផ្គង់ទឹកស្អាត អនាម័យ (WASH) និងវិស័យអាហារូបត្ថម្ភ។

ហេតុដូច្នេះ អង្គការសង្គមស៊ីវិល គួរអាចទទួលបានអត្ថប្រយោជន៍ពីការរក្សាតួនាទីរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងគំនិតរបស់រដ្ឋាភិបាលទាក់ទងនឹងការបង្ហាញអំពីរបៀប ដែលអង្គការសង្គមស៊ីវិល ឬសំខាន់ជាងនេះទៀងនោះគឺរបៀបដែលកម្រងអង្គការសង្គមស៊ីវិល អាចចូលរួមចំណែកដល់ការអភិវឌ្ឍ ឬចង្វាក់តម្លៃតាមវិស័យ។ ទោះជាយ៉ាងណា ភាពប្រសើរឡើងបែបនេះក្នុងការប្រាស្រ័យទាក់ទង នឹងតម្រូវឲ្យអង្គការសង្គមស៊ីវិលកំណត់យកផ្នត់គំនិតដែលមានការសហប្រតិបត្តិការជាងនេះ ដែលអង្គការមួយចំនួននិយាយថាកំពុងខ្វះខាត។

## *ការចូលរួមរបស់រដ្ឋាភិបាល*

កិច្ចសហប្រតិបត្តិការ និងការចូលរួមរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលកម្ពុជា ជាញឹកញាប់មិនមានលក្ខណៈបរិយាប័ន្ន ស្ថិរភាព ឬអាចទស្សទាយបានឡើយ[119]។ មានការកត់សម្គាល់ថា កិច្ចសហប្រតិបត្តិការកាន់តែមានផលិតភាពក្នុងនិងសម្រាប់វិស័យសង្គមសម្រាប់ការផ្តល់សេវា ខណៈដែលកិច្ចសហប្រតិបត្តិការក្នុងវិស័យសើបផ្សេងទៀត ដូចជាវិស័យសិទ្ធិមនុស្ស បរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការតស៊ូមតិ កម្រកើតមានឡើងណាស់។ តាមរយៈសមាជិកភាព ដែលមានមូលដ្ឋានលើផ្លែតហ្វមសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដូចជាអង្គការ គ.ស.ក អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និងអង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល បានប្រឹងប្រែងក្នុងការធានាថាសំឡេងសមាជិករបស់ខ្លួនព្រមទាំងអង្គការសង្គមស៊ីវិលផ្សេងទៀត ត្រូវបានគេឮ និងដោះស្រាយដោយរដ្ឋាភិបាលតាមរយៈបណ្តាញរៀងៗខ្លួន។

---

117 http://www.nepcambodia.org/
118 https://app.adpc.net/index.php/news/cambodia-humanitarian-forum-convenes-2019-annual-review-workshop
119 CCC's Government Engagement, accessed on 12 July 2019, available at: http://www.ccc-cambodia.org/en/what-we-do/multi-stakeholder-engagement-and-inclusive-partnership/government-engagement

**នៅថ្នាក់ជាតិ** ភាគីពាក់ព័ន្ធអភិវឌ្ឍន៍បានចង្អុលបង្ហាញថា យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (DCPS ឆ្នាំ២០១៤-២០១៨) ត្រូវបានអនុម័តដោយរដ្ឋាភិបាល ជាយន្តការមួយក្នុងចំណោមយន្តការសំខាន់ៗ ក្នុងការលើកកម្ពស់ភាពជាដៃគូទៅវិញទៅមកសម្រាប់ការអភិវឌ្ឍ។ មានការរំពឹងថា យុទ្ធសាស្ត្រ DCPS នឹងធ្វើការងាររួមគ្នាជាមួយនឹងយន្តការដែលមានស្រាប់ផ្សេងទៀត ដូចជាក្រុមការងារបច្ចេកទេស (TWGs) វេទិកាស្តីពីការអភិវឌ្ឍកម្ពុជា (CDF) គណៈកម្មាធិការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រដ្ឋាភិបាល (GDCC) និងយន្តការផ្សេងៗទៀតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងណា មុខងារប្រកបដោយប្រសិទ្ធភាពរបស់យន្តការទាំងនេះ នៅតែចោទជាបញ្ហា ខណៈដែលមានកិច្ចប្រជុំមិនញឹកញាប់មួយចំនួនដែលត្រូវបានរៀបចំធ្វើឡើង។

គិតត្រឹមពេលបច្ចុប្បន្ន អង្គការសមាជិកភាពនានា (អង្គការ គ.ស.ក អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល អង្គការ HACC អង្គការ FACT។ល។) ចូលរួមជាសមាជិករបស់ក្រុមការងារបច្ចេកទេសផ្សេងៗ។ អង្គការមិនមែនរដ្ឋាភិបាលនានា ត្រូវតែពង្រឹងធាតុចូលពីសមាជិកនិងដៃគូរបស់ខ្លួនដើម្បីបញ្ចូលទៅក្នុងផែនការ/គោលនយោបាយអភិវឌ្ឍន៍ជាតិជាតិច្រើន ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងផ្សេងៗទៀត ប៉ុន្តែឥទ្ធិពលនិងការពិចារណានៃធាតុចូលទាំងនេះ ជាញឹកញាប់នៅតែមិនត្រូវបានស្គាល់។

**នៅថ្នាក់ក្រោមជាតិ** ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាកម្មវិធីជាតិរបស់រដ្ឋាភិបាល បាននិងកំពុងអនុវត្តផែនការអនុវត្តរយៈពេលបីឆ្នាំលើកទីពីររបស់ខ្លួន (IP3-III) និងផែនការអនុវត្តសម្រាប់ក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)។ គណៈកម្មការដឹកនាំភាពជាដៃគូ (PSC) ថ្នាក់ជាតិ និងថ្នាក់ខេត្ត នៃក្របខ័ណ្ឌ ISAF ផ្តល់លំហរសម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់សំឡេង និងលំហររបស់អង្គការសង្គមស៊ីវិល និងពលរដ្ឋនៅទូទាំងដំណើរការនេះទាំងមូល។

យន្តការចាប់ដៃគូប្រកបដោយសក្តានុពលមួយផ្សេងទៀត គឺជា និងគួរតែជាដំណើរការរៀបចំផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការណ៍នេះ (ជាទ្រឹស្តី) ផ្តល់ឱកាសឲ្យមានការចូលរួម និងសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងសុខដុមនីយកម្មធាតុចូល ដើម្បីធ្វើលទ្ធផលមានភាពប្រសើរឡើង។ ក៏មានឱកាសចាប់ដៃគូជាក់លាក់ផងដែរ តាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក (DIW) ដែលជាធម្មតាត្រូវបានរៀបចំធ្វើឡើងនៅត្រីមាសចុងក្រោយនៃឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាលនានាដូចជាអង្គការតម្លាភាពអន្តរជាតិ (TI) បានចូលរួមក្នុងភាពជាដៃគូប្រកបដោយបរិយាប័ន្ន (IPs) ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អង្គការទាំងនេះសហប្រតិបត្តិការជាមួយរដ្ឋាភិបាលស្តីពីការអភិវឌ្ឍតាមរយៈក្រុមការងារបច្ចេកទេស (TWGs) និងគាំទ្រកម្មវិធីជាក់លាក់នានាដូចជាគម្រោង "សាលារៀនអភិបាលកិច្ច" ជាដើម។ សម្រាប់អង្គការតម្លាភាពអន្តរជាតិ គោលបំណងគឺដើម្បីធានាបានឥទ្ធិពលតាមរយៈការកសាងភាពជាដៃគូ ដែលរដ្ឋាភិបាល និងអង្គការ

សង្គមស៊ីវិល ធ្វើការងាររួមគ្នាឆ្ពោះទៅរកគោលដៅរួម។ ក្នុងពេលជាមួយគ្នានេះដែរ កិច្ចគាំទ្រពីអង្គការនានាដូចជា អង្គការ គ.ស.ក ឲ្យមានការចូលរួមលើកកម្ពស់ការអនុវត្តកម្មវិធីបែបនេះ និងតស៊ូមតិឲ្យដាក់ដំណើរការវេទិកាពហុភាគីពាក់ព័ន្ធ ដើម្បីធានាការកើតមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន។

ទាក់ទងនឹងភាពជាដៃគូខ្សែស្រប (horizontal partnerships) (អង្គការសង្គមស៊ីវិលធ្វើការងាររួមគ្នាឆ្លងវិស័យ) ភាគីពាក់ព័ន្ធមួយចំនួនដែលត្រូវបានពិគ្រោះយោបល់ បាននិយាយថា វាឆាប់រហ័សពេកសម្រាប់អង្គការសង្គមស៊ីវិលដើម្បីសហប្រតិបត្តិការ។ "មានការប្រកួតប្រជែងគ្នាខ្លាំងនៅក្នុងចំណោមអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលនាពេលសព្វថ្ងៃ"។ ភាគីពាក់ព័ន្ធទាំងនេះបានលើកឡើងថា ការយល់ឃើញរបស់ពួកគេគឺថា អង្គការសង្គមស៊ីវិលស្ថិតនៅរប៉ាត់រប៉ាយជាញឹកញាប់ស្ថិតក្នុងលក្ខណៈមួយដែលធ្វើការជាលក្ខណៈបុគ្គល/ដោយឯករាជ្យ ដើម្បីដោះស្រាយបញ្ហាដូចគ្នា។ ភាគីពាក់ព័ន្ធទាំងនេះក៏បានលើកឡើងផងដែរ អំពីកង្វះខាតជាញឹកញាប់នៃការចែករំលែកព័ត៌មានរវាងអង្គការសង្គមស៊ីវិលទាក់ទងនឹងថាតើអ្នកណា? កំពុងធ្វើអ្វី? នៅទីកន្លែងណា? ដែលអាចបង្កឲ្យអង្គការជាច្រើនធ្វើការងារក្នុងតំបន់មួយចំនួន ខណៈដែលតំបន់ជិតខាងមិនមានការធ្វើសកម្មភាពដោយអង្គការសង្គមស៊ីវិល។

ដូចដែលបានលើកឡើងហើយថា គោលការណ៍ណែនាំភាពជាដៃគូដែលត្រូវបានកំណត់យកនាពេលថ្មីៗនេះផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធនោះ រដ្ឋាភិបាលថ្នាក់ជាតិអាចលើកទឹកចិត្តឲ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិទាំងអស់ឲ្យរៀបចំវេទិការដ្ឋាភិបាលនិងភាពជាដៃគូជាប្រចាំនៅក្នុងខេត្តនីមួយៗ ហើយអង្គការសង្គមស៊ីវិលគួររៀបចំផ្លែតហ្វមដែលត្រូវបានព្រមព្រៀង ខណៈដែលវេទិកាភាពជាដៃគូផ្តល់លំហរសម្រាប់អង្គការសង្គមស៊ីវិលទាំងអស់ដើម្បីលើកឡើងពីបញ្ហា និងពិភាក្សាជាមួយស្ថាប័នរបស់រដ្ឋាភិបាលដោយបើកចំហរ និងដោយសេរី?

*វេទិកាភាពជាដៃគូរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល*

គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការកសាងឡើងវិញនូវទំនុកចិត្តចំពោះលទ្ធភាពរបស់ខ្លួន ក្នុងការចូលរួមជាមួយអង្គការសង្គមស៊ីវិល គឺដើម្បីបង្កើតយន្តការវេទិកាភាពជាដៃគូរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល។ រហូតមកដល់ពេលនេះ វេទិកាភាពជាដៃគូរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលចំនួនពីរត្រូវបានរៀបចំធ្វើឡើងដោយក្រសួងមហាផ្ទៃដោយមានការសហការជាមួយអង្គការសង្គមស៊ិវិល និងអង្គការ គ.ស.ក។

- វេទិកាភាពជាដៃគូលើកទីមួយត្រូវបានរៀបចំឡើងនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីពិនិត្យមើលស្ថានភាពនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងដើម្បីកំណត់បញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិល និងដើម្បីស្វែងរកដំណោះស្រាយ។ អ្នកចូលរួមចំនួន៤០០ នាក់ ដែលមកពីក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាលទាំងអស់ មន្ត្រីថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលចំនួន២០០ មានវត្តមានក្នុងវេទិកានេះ។

- o លទ្ធផលមួយក្នុងចំណោមលទ្ធផលរបស់វេទិកានេះ គឺការបង្កើតក្រុមការងាររដ្ឋាភិបាលមួយ (ដោយសេចក្តីសម្រេចរបស់រដ្ឋាភិបាលលេខ ៨៤ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨) ដើម្បីសម្របសម្រួល និងដោះស្រាយសំណើ និងក្តីបារម្ភរបស់អង្គការសង្គមស៊ីវិល។ ការណ៍នេះត្រូវមានសមាជិកមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC)។ ក្នុងពេលជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានចេញសារាចរណ៍លេខ ០៤០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិជាមួយសង្គមស៊ីវិល និងសមាគមក្នុងស្រុក និងអង្គការសហគមន៍។

- វេទិកាទីពីរដែលត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ មានអ្នកចូលរួមចំនួន ៥០០ នាក់ រួមមានអ្នកចូលរួមចំនួន ២០០នាក់មកពីអង្គការសង្គមស៊ីវិល និងអ្នកចូលរួមផ្សេងទៀតមកពីស្ថាប័នរបស់រដ្ឋាភិបាលនៅគ្រប់កម្រិត។
  - o អង្គការ គ.ស.ក ក្នុងនាមជាអ្នកតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បានបង្ហាញរបៀបវារៈចំនួន១២ ចំណុច ដែលមានមូលដ្ឋានលើការពិគ្រោះយោបល់ជាមុន។ មានការឆ្លើយតបជាវិជ្ជមានមួយពីឧបកនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលជាអ្នកបើកវេទិកានេះ។
  - o លទ្ធផលរបស់វេទិកានេះគឺជាអនុសាសន៍ចំនួន៧ ដែលចាំបាច់ត្រូវដោះស្រាយ។ ក្នុងចំណោមអនុសាសន៍ទាំងនោះ គឺជាសំណើសុំឲ្យ៖
    - ▪ រដ្ឋាភិបាលពន្លឿនការអនុវត្តវិធីសាស្ត្រភាពជាដៃគូពហុភាគី (រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន) តាមរយៈការពង្រឹង និងលើកកម្ពស់គុណភាពនៃក្រុមការងារបច្ចេកទេស (TWG) និងគណៈកម្មការដឹកនាំគម្រោង (PSC) ទទួលបន្ទុកក្របខ័ណ្ឌគណនេយ្យភាពសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
    - ▪ រដ្ឋាភិបាលពិនិត្យមើល និងធ្វើវិសោធនកម្មច្បាប់ LANGO ជាពិសេសមាត្រា ៨, ៩, ២៤ និងមាត្រាផ្សេងទៀត។ លើសពីនេះទៀត ឃ្លាជាច្រើននៅក្នុងច្បាប់ LANGO គួរត្រូវបានបញ្ជាក់បំភ្លឺដើម្បីជៀសវាងការបកស្រាយខុស។

ដោយភ្ជាប់ទៅនឹងគំនិតផ្តួចផ្តើមវេទិកាភាពជាដៃគូរដ្ឋាភិបាល និងសង្គមស៊ីវិល ក្រសួងមហាផ្ទៃក៏បានចេញសេចក្តីជូនដំណឹងលេខ ៥៩៨ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ដោយណែនាំឲ្យរដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ក្រុងឲ្យរៀបចំវេទិកាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៩ ដោយមានការចូលរួមដោយមន្ទីរសាមី និងអាជ្ញាធរផ្សេងទៀត ដែលមានការពាក់ព័ន្ធនឹងរដ្ឋបាលក្រុង ស្រុក និងឃុំ ព្រមទាំងមានការចូលរួមពីសំណាក់អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍។

## *ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍*

អង្គការសមាជិកភាព ដូចជាអង្គការ គ.ស.ក[120] អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងទៀត ធានាឲ្យមានការចូលរួម/ភាពជាដៃគូដ៏សកម្មក្នុងនាមជាអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលដែលជាសមាជិក រួមជាមួយដៃគូអភិវឌ្ឍន៍ (DPs) ជាច្រើន[121] និងក្រុមការងារបច្ចេកទេសផ្សេងៗ ដែលពួកគេបានកសាងទំនាក់ទំនងល្អជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ធាតុចូលរបស់អង្គការសង្គមស៊ីវិលទៅក្នុងគោលនយោបាយថ្នាក់ជាតិនានា តាមរយៈការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងយន្តការអភិវឌ្ឍន៍។ អ្នកតំណាងរបស់អង្គការសង្គមស៊ីវិលដែលជាអង្គការសមាជិកភាព ជាញឹកញាប់ចូលរួមក្នុងការពិគ្រោះយោបល់និងការពិភាក្សាអំពីការអភិវឌ្ឍជាតិ ដែលត្រូវបានរៀបចំឡើងដោយដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល។

អង្គការសង្គមស៊ីវិលដែលជាអង្គការសមាជិកភាព ក៏បានចូលរួមជាមួយដៃគូអភិវឌ្ឍន៍ផងដែរក្នុងការតស៊ូមតិអំពីផលប៉ះពាល់នៃច្បាប់ LANGO និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)។ អង្គការទាំងនេះជាញឹកញាប់បានសម្របសម្រួល និងបានគាំទ្រដល់ការពិគ្រោះយោបល់និងកិច្ចពិភាក្សាអំពីបរិយាកាសអំណោយផល ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ភាពជាដៃគូប្រកបដោយបរិយាប័ណ្ណសម្រាប់ការអភិវឌ្ឍ។ល។ ការចូលរួមចំណែកទាំងនេះជាញឹកញាប់ត្រូវបានយកមកពិចារណា និងត្រូវបានឆ្លុះបញ្ចាំងដោយដៃគូអភិវឌ្ឍន៍មួយចំនួន ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេស។ ឧទាហរណ៍ សហភាពអឺរ៉ុបបានបង្កើតយុទ្ធសាស្ត្រមួយហៅថា ផែនទីបង្ហាញផ្លូវសហភាពអឺរ៉ុបសម្រាប់ការចូលរួមជាមួយសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា (ឆ្នាំ២០១៤-២០១៨) ដែលអន្តរាគមន៍ជាច្រើនដែលបានលើកឡើងត្រូវបានបន្សុីជាមួយនឹងអន្តរាគមន៍ ដែលត្រូវបានស្នើឡើងដោយអង្គការសង្គមស៊ីវិលដែលជាអង្គការសមាជិកភាព។

តួនាទីរបស់ដៃគូអភិវឌ្ឍន៍អន្តរជាតិ (DPs) មានភាពខុសគ្នា។ ដៃគូអភិវឌ្ឍន៍មួយចំនួនមានភាពសកម្ម/ចូលរួមយ៉ាងសកម្ម ខណៈដែលដៃគូអភិវឌ្ឍន៍មួយចំនួនជ្រើសរើសយកវិធីសាស្ត្រមិនពាក់ព័ន្ធ។ ដៃគូអភិវឌ្ឍន៍ភាគច្រើនមានការចូលរួមផ្ទាល់ និងបានផ្តល់ការគាំទ្រនៅមានកម្រិតសម្រាប់អង្គការសង្គមស៊ីវិល។ ដោយមិនគិតពីវិធីសាស្ត្រផ្តល់មូលនិធិ ដៃគូអភិវឌ្ឍន៍ហាក់ដូចជាស្ថិតក្នុងស្ថានភាពកក់ក្តៅក្នុងទំនាក់ទំនងបច្ចុប្បន្នរបស់ខ្លួនជាមួយរដ្ឋាភិបាលកម្ពុជា។ ដៃគូអភិវឌ្ឍន៍ភាគច្រើនបានប្តេជ្ញាចិត្តចំពោះការគាំទ្រដល់ការអភិវឌ្ឍរយៈពេលកាន់តែវែង។

## *ការចូលរួមរបស់វិស័យឯកជន*

ស្ទើរគ្រប់ឯកសារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិទាំងអស់ បច្ចុប្បន្នលើកឡើងពីសក្តានុពលដ៏ធំធេងនៃការចូលរួមរបស់វិស័យឯកជន។ អ្នកតំណាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែល

---

120 CCC's Development Partner Engagement, accessed on 12 July 2019, available at: http://www.ccc-cambodia.org/en/what-we-do/multi-stakeholder-engagement-and-inclusive-partnership/development-partner-engagement

121 like the United Nations, the European Union, USAID, the bilateral countries others

ត្រូវបានពិគ្រោះយោបល់ លើកឡើងពីការធ្វើការងារជាមួយវិស័យឯកជនថា មានការលំបាក ដែលទំនង ដោយសារតែកង្វះបទពិសោធជាមួយនឹងការងារបែបនេះ។ អង្គការ គ.ស.ក និងអង្គការផ្សេងទៀតទទួលស្គាល់ថា វិស័យឯកជននៅកម្ពុជាមានសក្តានុពលចំពោះការផ្តល់វិភាគទានយ៉ាងខ្លាំងដល់វិបុលភាពសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ប្រទេសជាតិ។ ទោះជាយ៉ាងណា ការសិក្សានេះនៅមានកម្រិតនៅឡើយ សម្រាប់ការពិនិត្យមើល/ការចូលរួមដែលត្រូវបានវាយតម្លៃដោយអង្គការសង្គមស៊ីវិល និងវិស័យឯកជន។ ប៉ុន្តែមានភស្តុតាងកាន់តែច្រើនឡើងដែលបង្ហាញថា វិស័យឯកជនកំពុងចាប់ផ្តើមទទួលយកតួនាទីទទួលខុសត្រូវ ក្នុងការផ្តល់មូលនិធិដល់អង្គការសង្គមស៊ីវិលដែលត្រូវបានចាប់ដៃគូមួយចំនួន។

<u>ការពង្រឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន</u>

ក្នុងខែមីនា ឆ្នាំ២០១៩ អង្គការសង្គមស៊ីវិលមួយក្រុមដែលមានចំនួន ១១ អង្គការ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ បានរៀបចំទិវាសង្គមស៊ីវិលស្ថិតក្រោមប្រធានបទ "ភាពជាដៃគូប្រកបដោយបរិយាប័ន្នសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាព" ដោយមានអ្នកចូលរួមប្រហែល ៣០០ នាក់ដែលជាអ្នកតំណាងរបស់អង្គការសង្គមកស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ រដ្ឋាភិបាល អង្គការសហគមន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។ នៅចុងបញ្ចប់នៃទិវាសង្គមស៊ីវិល សេចក្តីថ្លែងការណ៍មួយត្រូវបានបង្កើតឡើង។

## ការប្រៀបធៀបលទ្ធផលសិក្សាឆ្នាំ២០១៣ និងឆ្នាំ២០១៨

| *ស្ថានភាពក្នុងរបាយការណ៍ ឆ្នាំ២០១៣* | *ក្នុងអំឡុងពេលសិក្សា និងសរសេររបាយការណ៍ (ឆ្នាំ២០១៨-២០១៩)* |
|---|---|
| សមាសភាពនេះមិនត្រូវបានគ្របដណ្តប់ឡើយស្ថិតក្រោមរបាយការណ៍មុន។ | នៅទូទាំងពិភពលោក មានការទទួលស្គាល់ថា យើងមិនអាចធ្វើដំណើរទៅតែម្នាក់ឯងបានឡើយ។ ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងប្រភេទភាពជាដៃគូពហុភាគីផ្សេងទៀត ត្រូវការជាចាំបាច់ដើម្បីបង្កើតធនធាន ដែលត្រូវការជាចាំបាច់ ដើម្បីចាប់ផ្តើមដោះស្រាយបញ្ហា ដែលត្រូវបានកំណត់រកឃើញនៅទូទាំងពិភពលោកតាមរយៈក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។<br><br>ភាពជាដៃគូក៏មានសក្តានុពលផងដែរ ដើម្បីបង្កើតការរួមកម្លាំងគ្នារវាង និងនៅទូទាំងភាគីពាក់ព័ន្ធ និងតំបន់ភូមិសាស្ត្រផ្សេងៗ។ |

## បញ្ហាប្រឈម និងការផ្តល់យោបល់

| បញ្ហាប្រឈម | ការផ្តល់យោបល់ |
| --- | --- |
| ➢ ខណៈពេលដែលមានយន្តការចាប់ដៃគូ និងសហប្រតិបត្តិការជាច្រើន ភាគច្រើនស្ថិតនៅថ្នាក់ជាតិ<br>o យន្តការជាច្រើនមានការពាក់ព័ន្ធនឹងការសម្របសម្រួលជំនួយ (ដូចជា TWG) ប៉ុន្តែការតំណាងរបស់អង្គការសង្គមស៊ីវិលនៅក្នុងយន្តការទាំងនោះ ជាញឹកញាប់នៅមានកម្រិត។<br>o មន្ត្រីរដ្ឋាភិបាលភាគច្រើន អង្គការសង្គមស៊ីវិល និងសាធារណៈ មានចំណឹងដឹងតិចតួច ឬមិនមានចំណេះដឹងអំពីអ្វីដែលពួកគេធ្វើ និងរបៀបដែលពួកគេធ្វើការ ឬអ្វីគឺជាលទ្ធផលចេញពីពួកគេ។<br>➢ នៅថ្នាក់ក្រោមជាតិ<br>o យន្តការចាប់ដៃគូ និងសម្របសម្រួលដែលមានឥទ្ធិពលភាគច្រើនមានការប្រមូលផ្តុំខ្លាំងពេកនៅរាជធានីភ្នំពេញ។<br>➢ យន្តការចាប់ដៃគូ/សម្របសម្រួលភាពជាតំណាង<br>o អង្គការសង្គមស៊ីវិលស្ថិតនៅរប៉ាត់រប៉ាយ ហើយមិនមានការយន្តការចូលរួម និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពមួយ ដែលរួមគ្នាតំណាងឲ្យអង្គការសង្គមស៊ីវិល។<br>o រដ្ឋាភិបាលបានបង្កើតបណ្តាញអ្នកតំណាងអង្គការសង្គមស៊ីវិលផ្ទាល់របស់ខ្លួន ហើយមានក្តីបារម្ភអំពីតួនាទីអនាគតរបស់បណ្តាញទាំងនេះ។ | ➢ បច្ចុប្បន្នមានតម្រូវក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃយន្តការចាប់ដៃគូ និងសម្របសម្រួលដែលមានស្រាប់ និងអនាគត ដើម្បីជូនដំណឹងកាន់តែប្រសើរទៅកាន់សាធារណៈ។<br>o ប្រមូល និងបោះផ្សាយព័ត៌មានអំពីអ្វីដែលត្រូវបានរៀបចំផែនការ និងពិភាក្សា និងអំពីលទ្ធផលកិច្ចប្រជុំដែលត្រូវបានរៀបចំធ្វើឡើង និងអំពីផលប៉ះពាល់នៃយន្តការដែលបានព្រមព្រៀង។<br>➢ រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវធានាថា ទស្សនៈ និងសំឡេងរបស់ប្រជាជនថ្នាក់ក្រោមជាតិត្រូវបានគេឮនិងយកមកពិចារណាកាន់តែប្រសើរ។<br>➢ យន្តការភាពជាដៃគូ និងសម្របម្រួល ចាំបាច់ត្រូវបង្កើនការតំណាងរបស់ភាគីពាក់ព័ន្ធអភិវឌ្ឍន៍ រួមទាំងអង្គការសង្គមស៊ីវិល/ក្រុមអ្នកតំណាង។<br>o អង្គការសង្គមស៊ីវិលចាំបាច់ត្រូវរួបរួមគ្នាស្ថិតក្រោមបណ្តាញឆ័ត្រដើម្បីតំណាងឲ្យពួកគេ។<br>o ពួកគេចាំបាច់ត្រូវពិភាក្សា និងព្រមព្រៀងលើគោលជំហរ/ផ្លែតហ្វមរួម។<br>o មានតម្រូវការដែលចាំបាច់ត្រូវជៀសវាង និងប្រឆាំងនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅលើការតំណាងរបស់អង្គការសង្គមស៊ីវិលអំពីយន្តចាប់ដៃគូ និងសម្របសម្រួល។ |

| | |
|---|---|
| (i) អង្គការសង្គមស៊ីវិលមានក្តីបារម្ភថា រដ្ឋាភិបាលអាចនឹងចាត់តាំងបណ្តាញរបស់ខ្លួនឲ្យអង្គុយលើយន្តការភាពជាដៃគូ។<br>➢ មានតម្រូវការយន្តការចាប់ដៃគូ និងសម្របសម្រួលដែលរៀបចំផែនការជាក់លាក់មួយ ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។<br>o ដើម្បីសម្របសម្រួលកាន់តែប្រសើរ និងវាស់វែងប្រកបដោយបរិមាណលើវឌ្ឍនភាពនិងផលប៉ះពាល់របស់ធាតុចូល។<br>➢ កង្វះវេទិកាអភិវឌ្ឍន៍របស់ពហុភាគីពាក់ព័ន្ធ (ដែលមានការចូលរួមពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍)។<br>➢ កង្វះការយល់ដឹង និងការប្តេជ្ញាចិត្តចំពោះការសម្របសម្រួល និងភាពជាដៃគូ។ | ➢ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងផ្សេងៗទៀត គួរពិចារណាបង្កើត/រៀបចំវេទិកាសម្របសម្រួលអភិវឌ្ឍន៍ពហុភាគីពាក់ព័ន្ធ ដែលរួមបញ្ចូលគ្នាមួយ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលកាន់តែប្រសើរ និងអាចឲ្យមានភាពជាដៃគូសម្រាប់ការអភិវឌ្ឍ។<br>➢ មានតម្រូវការកសាងសមត្ថភាព និងការយល់ដឹងអំពីវិធីសាស្ត្រភាពជាដៃគូប្រកបដោយបរិយាប័ន្នចំពោះភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចាប់ផ្តើមពន្លឿន និងលើកទឹកចិត្តឲ្យមានការរួមបញ្ចូលគ្នា ដើម្បីអាចឲ្យមានភាពជាដៃគូ។ |

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៨ ដើម្បីរុករកបរិយាកាសអំណោយផលដែលកំពុងផ្លាស់ប្តូរចាប់តាំងពីការសិក្សាកន្លងមកចំនួនពីរ គឺការសិក្សាថ្នាក់ជាតិនៅឆ្នាំ២០១៣ និងការសិក្សាថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៥។ ការធ្វើអន្តរាគមន៍ នៅប្រទេសកម្ពុជាបានដំណើការ ទោះជាមានការផ្លាស់ប្តូរមិនប្រក្រតីប្រជាមួយចំនួន ទាក់ទងនឹងទិដ្ឋភាព ដែលត្រូវបានមើលឃើញសម្រាប់សិទ្ធិមនុស្សជាមូលដ្ឋាន និងទិដ្ឋភាពច្បាប់ ដែលមានផលប៉ះពាល់លើបរិយាកាសអំណោយផលរបស់អង្គការសង្គមស៊ីវិល និងសង្គមជាទូទៅ។ បរិយាកាសអំណោយផលត្រូវបានវាយតម្លៃដោយប្រើប្រាស់ក្របខ័ណ្ឌពហុសមាសភាពវិនិច្ឆ័យមួយ ដែលត្រូវបានកែសម្រួលចេញពី CIVICUS ដើម្បីពិនិត្យមើលកត្តាដែលជះឥទ្ធិពលលើបរិយាកាសអំណោយផល។ ក្របខ័ណ្ឌនេះសម្លឹងមើលសមាសភាពចំនួន៧ (ក) ការបង្កើត និងប្រតិបត្តិការ (ខ) សេរីភាពក្នុងការបញ្ចេញមតិ (គ) ការប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពក្នុងការជួបប្រជុំ (ឃ) ពន្ធដារ (ង) លទ្ធភាពទទួលបានធនធាន (ច) សិទ្ធិទទួលបានព័ត៌មាន (ឆ) ទំនាក់ទំនងរវាងអាជ្ញាធរនិងអង្គការសង្គមស៊ីវិល ដែលក៏ត្រូវបានដាក់បញ្ចូលផងដែរ (ជ) ភាពជាដៃគូប្រកបដោយបរិយាប័ន្ន។

ដំណើរការកំណែទម្រង់របស់រដ្ឋាភិបាលដែលកំពុងធ្វើឡើង បានបង្កើនកម្រិតអនុម័តច្បាប់ដែលជាញឹកញាប់ហួសពេលយូរ រួមទាំងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ក្នុងឆ្នាំ២០១៥ ដោយកង្វះការពិគ្រោះយោបល់បន្ថែម ដែលត្រូវបានស្នើឡើងដោយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។ ច្បាប់ LANGO បានបង្កើតលក្ខខណ្ឌតម្រូវ និងដំណើរការចុះបញ្ជីសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុក និងបរទេស ព្រមទាំងលក្ខខណ្ឌតម្រូវរាយការណ៍ប្រចាំឆ្នាំបែបកាតព្វកិច្ច។

អ្នកសង្កេតការណ៍អន្តរជាតិ និងជាតិ និងភាគីពាក់ព័ន្ធជាច្រើនបានលើកឡើងពីការធ្លាក់ចុះស្ថានភាពសិទ្ធិក្នុងប្រទេសកម្ពុជា ដោយការធ្លាក់ចុះនេះបានកើតមានខ្លាំងក្នុងអំឡុងពេលស្ថិតក្រោមការពិនិត្យមើលចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ ពីការយល់ឃើញ និងការសង្កេតឃើញរបស់ពួកគេ បរិយាកាសប្រតិបត្តិការរបស់វិស័យនេះបានធ្លាក់ចុះ ហើយការណ៍នេះត្រូវបានគេមើលឃើញថាជាឥទ្ធិពលនយោបាយ ជាចំណែកនៃការឆ្លើយតបលើការកើនឡើងសម្លេងគាំទ្រលើគណបក្សប្រឆាំងពីការបោះឆ្នោតជាតិឆ្នាំ២០១៣ និងការបោះឆ្នោតក្រុមប្រឹក្សា ថ្នាក់ក្រោមជាតិឆ្នាំ២០១៧។ មុនពេលកម្ទេចគណបក្សប្រឆាំងនេះ គណបក្សកាន់អំណាចបានកំណត់ទិសដៅ បានបំភិតបំភ័យ និងបានបិទអង្គភាពប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលដែលរិះគន់ ហើយការបៀតបៀននេះមួយផ្នែកមានមូលដ្ឋានលើការដកហូតពន្ធតឹងរឹង និងការទាមទារបំណុលពន្ធដែលជំពាក់ចាប់ពីឆ្នាំ១៩៩៧មក។

ដំណើរការចុះបញ្ជី និងលក្ខខណ្ឌតម្រូវឲ្យរាយការណ៍ថ្មីទាំងនេះ ជះឥទ្ធិពលយ៉ាងខ្លាំងដល់សមាសភាពទីមួយនៃក្របខ័ណ្ឌបរិយាកាសអំណោយផលដែលត្រូវបានកែសម្រួលស្តីពី "**ការបង្កើត និងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល**"។ មានសេចក្តីរាយការណ៍ថា អង្គការសង្គមស៊ីវិលដែលប៉ុនប៉ង់ចុះបញ្ជី ជាញឹកញាប់ត្រូវបានតម្រូវឲ្យពិនិត្យមើលឯកសារ និងលក្ខន្តិកៈរបស់ខ្លួនឡើងវិញ ដើម្បីឲ្យមានអត្ថបទដែលតម្រូវដោយមន្ត្រីក្រសួងមហាផ្ទៃ។ លើសពីនេះទៀត ដំណើរការចុះបញ្ជីមានរយៈពេលយូរជាងរយៈពេលដែលមានចែងក្នុងច្បាប់ LANGO។ អង្គការសង្គមស៊ីវិលមួយចំនួនបានរាយការណ៍ថាត្រូវបានស្នើឲ្យបង់ប្រាក់ក្រៅផ្លូវការ ដើម្បីសម្របសម្រួល និងពន្លឿនការចុះបញ្ជី។ ចាប់ពីមានការដាក់ចេញច្បាប់នេះមក ក្រសួងមហាផ្ទៃបានកំណត់ទិសដៅលើអង្គការសង្គមស៊ីវិលមួយចំនួនទាក់ទងនឹងអនុលោមតាមលក្ខខណ្ឌតម្រូវរាយការណ៍របស់ខ្លួន ហើយការមិនអនុលោមតាមអាចបណ្តាលឲ្យមានការផ្អាក ឬបិទទ្វារ ហើយសំណើអនុលោមភាពទាំងនេះ បានកើនឡើងក្នុងឆ្នាំ២០១៧។ ភាគច្រើននៃអង្គកាសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានពិគ្រោះយោបល់បានយល់ឃើញថា លក្ខខណ្ឌតម្រូវសម្រាប់បង្កើត និងប្រតិបត្តិការបង្កឲ្យមានភាពលំបាកកាន់តែខ្លាំងសម្រាប់អង្គការសង្គមស៊ីវិល។

ស្របជាមួយនឹងបញ្ហាបង្កើត និងបញ្ហាប្រតិបត្តិការ "**សេរីភាពក្នុងការបញ្ចេញមតិ**" ត្រូវបានរារាំងកាន់តែខ្លាំងចាប់ពីឆ្នាំ២០១៥មក។ ៥៨% នៃអង្គការសង្គមស៊ីវិលដែលត្រូវបានពិគ្រោះយោបល់ បានយល់ឃើញថា សិទ្ធិសេរីភាពក្នុងការនិយាយស្តីដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ត្រូវបានរារាំង និងថា បុគ្គលិករបស់អង្គការសង្គមស៊ីវិលមានការប្រុងប្រយ័ត្នកាន់តែខ្លាំង (ឆ្ងាយ) ចំពោះអ្វីដែលពួកគេបាននិយាយចាប់តាំងពីឆ្នាំ២០១៥ មក ដោយសារការបំភិតបំភ័យ។

សិទ្ធិជាមូលដ្ឋានផ្សេងទៀត ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ក៏បានធ្លាក់ចុះផងដែរ។ សមាសភាគទីបីនិយាយអំពី "**ការប្រមូលផ្តុំដោយសន្តិវិធី/សេរីភាពក្នុងការបង្កើតសមាគម**"។ ការយល់ស៊ីជម្រៅអំពីការណ៍នេះ មានភាពខុសគ្នាខ្លាំងនៅទូទាំងការឆ្លើយតបរបស់អង្គការសង្គមស៊ីវិល ដោយផ្អែកលើកត្តាទីតាំង និងវិស័យសកម្មភាព ខណៈដែលវិស័យដែលបង្កឲ្យមានភាពចម្រោងចម្រាស់កាន់តែតិច(វិស័យអប់រំនិងសុខាភិបាល។ល។)បានទទួលរងគ្រោះកាន់តែតិច។ ក្នុងអំឡុងពេលសិក្សា រដ្ឋាភិបាលបានអនុវត្តលក្ខខណ្ឌតម្រូវស្ថាប័ន (ក្នុងខែតុលា ឆ្នាំ២០១៧) ដែលបានរារាំងដល់សេរីភាពក្នុងការជួបប្រជុំ បើទោះជាលក្ខខណ្ឌតម្រូវទាំងនេះត្រូវបានដកចេញវិញក្នុងខែតុលា ឆ្នាំ២០១៨ ក្តី។ អង្គការសង្គមស៊ីវិលក៏បានលើកឡើងផងដែរពីការបន្តកង្វះ "**សិទ្ធិទទួលបានព័ត៌មាន**" ខណៈដែលអង្គការសង្គមស៊ីវិល និងសាធារណៈជននៅតែមានបញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានមូលដ្ឋាន។ វាបានបង្ហាញកាន់តែច្បាស់ក្នុងអំឡុងពេលពិនិត្យមើលដែលថា "**ពន្ធ**" ត្រូវបាន "ប្រើប្រាស់ធ្វើជាអាវុធ" និងត្រូវបានប្រើប្រាស់ធ្វើជាឧបករណ៍មួយសម្រាប់ការបំភិតបំភ័យ និងការគ្រប់គ្រងអង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។

យោបល់ត្រលប់អំពី "**ទំនាក់ទំនងរវាងអាជ្ញាធររដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល**" ក៏មានភាពខុសគ្នាផងដែរ ខណៈពេលដែលបទពិសោធដែលត្រូវបានរាយការណ៍មានភាពចម្រុះ។ ភាគច្រើននៃអង្គការសង្គមស៊ីវិល បានរាយការណ៍ពីការធ្លាក់ចុះលក្ខណៈទំនាក់ទំនងរបស់ខ្លួនជាមួយអាជ្ញាធរ ហើយការធ្លាក់ចុះនេះមានកាន់តែខ្លាំងនៅថ្នាក់ជាតិជាងនៅថ្នាក់ក្រោមជាតិ។ ប៉ុន្តែអង្គការសង្គមស៊ីវិលទាំងអស់បានរាយការណ៍ពីការមានទម្រង់ទំនាក់ទំនងមួយចំនួនជាមួយអាជ្ញាធររដ្ឋាភិបាល ខណៈដែលអង្គការសង្គមស៊ីវិលជាច្រើនបានដឹងថា បញ្ហាដែលកើតមានជាមួយនឹងទំនាក់ទំនងរបស់ពួកគេត្រូវបង្កឡើងមកពីលើ ហើយអាចមិនជះឥទ្ធិពលដល់ភាពពិតប្រាកដនៃទំនាក់ទំនងនេះឡើយ។

ភាគច្រើននៃអង្គការសង្គមស៊ីវិលបានរាយការណ៍ថាមានធនធានមានកម្រិត ដើម្បីចែកចាយ និង/ឬពង្រីកអាណត្តិ ហើយ**លទ្ធភាពទទួលបានធនធានបន្ថែម**កាន់តែមានការលំបាកជាងពេលមុន។ ការណ៍នេះគឺដោយសារកត្តារួមផ្សំនៃនីតិវិធីអនុវត្តស្មុគស្មាញកាន់តែខ្លាំង ការប្រកួតប្រជែងកាន់តែខ្លាំង កង្វះសមត្ថភាពទទួលបានមូលនិធិ និងមូលនិធិកាន់តែមានតិច/ធនធានសមស្របដែលមាន។

## អនុសាសន៍

អនុសាសន៍ទាំងនេះ ត្រូវបានពង្រឹងពីការផ្តល់យោបល់ ដែលត្រូវបានធ្វើឡើងសម្រាប់សមាសភាពផ្សេងៗនៃបរិយាកាសអំណោយផល និងក្របខ័ណ្ឌវិភាគភាពជាដៃគូប្រកបដោយបរិយាប័ន្ន។

| អនុសាសន៍អំពីសមាសធាតុ | ត្រូវបានជម្រុញដោយ |
|---|---|
| **1. ការបង្កើត និងប្រតិបត្តិការ** | |
| 1.1. ប្តូរដំណើរការចុះបញ្ជីទៅជាអនឡាញ ដើម្បីផ្តល់លទ្ធភាព និងធ្វើប្រតិភូកម្ម និងអនុញ្ញាតឲ្យមាន "ការិយាល័យច្រកចេញចូលតែមួយ" ដើម្បីចេញឯកសារចុះបញ្ជី ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះវិមជ្ឈការ។ | រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ |
| 1.2. កំណត់ខ្នាតគំរូដំណើរការទាក់ទងនឹងការកំណត់ពេលវេលានៃជំហានដំណើរការនីមួយៗ។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 1.3. បង្កើតគោលការណ៍ណែនាំឯកសារចុះបញ្ជីអង្គការសង្គមស៊ីវិល ដែលអាចបញ្ជាក់ច្បាស់លាស់អំពីបញ្ហា និងមានឧទាហរណ៍និងពុម្ពគំរូ (template) និងយុត្តាធិការសម្រាប់ការប្រើប្រាស់ពាក្យពេជន៍/ឃ្លា ដែលចង់បានឬដែលស្នើឲ្យប្រើប្រាស់។ | រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ |
| 1.4. លើកកម្ពស់ការយោគយល់ទៅវិញទៅមកដោយអង្គការសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានអំពីឧបករណ៍ច្បាប់ និងពាក្យសុំរបស់ពួក | រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល |

| | |
|---|---|
| គេ បង្កើតមគ្គុទ្ទេសក៍បទប្បញ្ញត្តិដែលមិនច្បាស់លាស់ដើម្បីឲ្យអាជ្ញាធរមូលដ្ឋានយល់ដឹងបានកាន់តែប្រសើរ។<br>1.5. ចូលរួមក្នុងការពិគ្រោះយោបល់ជាមួយក្រសួង និងអ្នកធ្វើសេចក្តីសម្រេចចិត្តនានា ដើម្បីស្វែករកភាពល្អប្រសើរ និងបញ្ជាក់បំភ្លឺក្នុងប្រព័ន្ធច្បាប់។ | អង្គការសង្គមស៊ីវិល |
| 2. **សេរីភាពក្នុងការបញ្ចេញមតិ** | |
| 2.1. បង្កើតផ្លែតហ្វមអង្គការសង្គមស៊ីវិលមួយ ដើម្បីភ្ជាប់រដ្ឋាភិបាលឲ្យបានឲ្យកាន់តែប្រសើរទៅនឹងបញ្ហាសេរីភាពក្នុងការបញ្ចេញមតិ។<br>2.2. ផ្តួចផ្តើមគំនិតបង្កើតយុទ្ធនាការសម្រាប់ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌច្បាប់។<br>2.3. បង្កើនការយល់ដឹង និងយុទ្ធនាការតស៊ូមតិអំពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិផ្សេងៗទៀត។<br>2.4. ធ្វើឲ្យប្រសើរឡើងនូវការរក្សាទុកឯកសារ និងកំណត់ត្រាសំណុំរឿងរំលោភសិទ្ធិមនុស្ស និងការគាបសង្កត់សិទ្ធិ។<br>2.5. ពិនិត្យតាមដាន និងបន្ស៊ីសកម្មភាពជាមួយនឹងក្របខ័ណ្ឌ CSDG ដែលត្រូវបានអនុម័ត (ខែធ្នូ ឆ្នាំ២០១៨) ជាពិសេសទាក់ទងនឹង CSDGs។<br>2.6. គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុង និងក្នុងចំណោមបណ្តាប្រទេសនានា។<br>2.6.1. ទិសដៅដែលត្រូវបានអនុម័តចំនួនពីរសម្រាប់ CSDG ទី១៦ "លើកកម្ពស់សង្គម ដែលមានសន្តិភាពប្រកបដោយបរិយាប័ន្នដើម្បីអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត"។ | អង្គការសង្គមស៊ីវិល<br>អង្គការសង្គមស៊ីវិល និងដៃគូអភិឌ្ឍន៍<br>រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ |
| 3. **ការប្រមូលផ្តុំដោយសន្តិវិធី/សេរីភាពក្នុងការជួបប្រជុំ** | |
| 3.1. លើកកម្ពស់ការផ្សព្វផ្សាយ និងការប្រកាន់ភ្ជាប់ទៅនឹងក្របខ័ណ្ឌច្បាប់ដោយមន្ត្រីទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងមន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋាន។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |

| | |
|---|---|
| 3.2. ពង្រីកសកម្មភាពកសាងសមត្ថភាព ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងសិទ្ធិដោយមន្ត្រី អង្គការសង្គមស៊ីវិល និងសាធារណៈ។<br>3.3. ស្នើរដ្ឋាភិបាលឲ្យបង្កើតប្រព័ន្ធគណនេយ្យភាព និងកែតម្រូវ ដើម្បីតាមដានការយល់ដឹងខុសអំពី និងការរំលោភសិទ្ធិ និងក្របខ័ណ្ឌច្បាប់<br>3.4. លើកកម្ពស់ការពិនិត្យតាមដានការរំលោភសិទ្ធិមនុស្សដោយឯករាជ្យ | អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>រដ្ឋាភិបាល អង្គការសង្គមស៊ីវិល<br>អង្គការសង្គមស៊ីវិល |
| **4. ពន្ធដារ** | |
| 4.1. បន្តផ្សព្វផ្សាយសម្មភាពរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្រូវការក្នុងការអនុលោមតាមច្បាប់ពន្ធដែលកំពុងវិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល។<br>4.2. បង្កើត និងរក្សាមគ្គុទ្ទេសក៍ពន្ធមួយ និងធនធាន/បណ្ណាល័យដែលមានមូលដ្ឋានលើកុំព្យូទ័រខ្លោដ (Cloud) ស្តីពីអនុលោមភាពរបស់អង្គការសង្គមស៊ីវិលទៅនឹងច្បាប់និងបទប្បញ្ញត្តិពន្ធដែលកំពុងវិវឌ្ឍន៍។<br>4.3. តស៊ូមតិសម្រាប់ការអនុវត្តច្បាប់ពន្ធដោយមិនលម្អៀងទៅកាន់គ្រប់ផ្នែកទាំងអស់នៃសង្គម។<br>4.4. ពិនិត្យតាមដានការអនុវត្ត និងបទពិសោធរបស់អង្គការសង្គមស៊ីវិលជាមួយការិយាល័យពន្ធ ដើម្បីធានាថា អង្គការទាំងនេះទទួលរងការប្រព្រឹត្តដោយស្មើភាព។<br>4.5. តស៊ូមតិសម្រាប់ការលើកលែងពន្ធ និងការអនុវត្តប្រតិសកម្មអតិបរមានូវលក្ខខណ្ឌតម្រូវច្បាប់ពន្ធសម្រាប់គ្រប់វិស័យទាំងអស់។<br>4.6. លើកកម្ពស់ការយល់ដឹងសាធារណៈអំពីការអនុវត្តពន្ធលើប្រាក់ចំណូលតាមរយៈ "គំនិតផ្តួចផ្តើមថវិកាបើកចំហរ" និងតម្លាភាព។ | រដ្ឋាភិបាល<br>អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>អង្គការសង្គមស៊ីវិល<br>រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ |
| **5. លទ្ធភាពទទួលបានធនធាន (រួមទាំងវិស័យឯកជន)** | |
| 5.1. ក្រុមអ្នកតំណាងរបស់អង្គការសង្គមស៊ីវិលចាំបាច់ត្រូវតស៊ូមតិ ដើម្បីធ្វើឲ្យមានរបាយមូលនិធិកាន់តែប្រសើរ តាមរយៈអង្គការសង្គមស៊ីវិលនៅក្នុងវិស័យអាទិភាពដែលបានព្រមព្រៀង ដែលត្រូវបានបន្សុីជាមួយនឹងគោលបំណង និងអាទិភាពអភិវឌ្ឍន៍ជាតិ។<br>5.2. វាយតម្លៃការចំណាយ និងអត្ថប្រយោជន៍ដែលអាចកើតមាននៃការបង្កើត និងគាំទ្រកញ្ចប់មូលនិធិ (Trust fund) ដែលជាបណ្តុំអង្គការសង្គមស៊ីវិល/ពហុម្ចាស់ជំនួយ។ | អង្គការសង្គមស៊ីវិល/ ដៃគូអភិវឌ្ឍន៍<br>ដៃគូអភិវឌ្ឍន៍ |

| | |
|---|---|
| 5.2.1. រួមទាំងតំបន់សកម្មភាព ទំហំមូលនិធិ លក្ខខណៈប្រតិបត្តិការ វិស័យអាទិភាព។ល។ ដើម្បីមើលថាតើ វានឹងផ្តល់តម្លៃសម្រាប់ការវិនិយោគធៀបនឹងជម្រើសមូលនិធិដែលអាចមានផ្សេងទៀតដែរឬយ៉ាងណា។ | |
| 5.3. បង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ដើម្បីវាយតម្លៃធនធានដោយធានាបាននូវការបន្សុីឲ្យបានទាន់ពេលវេលា និងសកម្មស្របជាមួយនឹងការអភិវឌ្ឍដែលផ្លាស់ប្តូរ/អាទិភាពរបស់ម្ចាស់ជំនួយ និងវិធីសាស្ត្រនានា។ | អង្គការសង្គមស៊ីវិល |
| 5.4. លើកកម្ពស់ការចូលរួមរបស់ម្ចាស់ជំនួយ រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីទាញយកប្រយោជន៍ពីគោលដៅអភិវឌ្ឍន៍ជាតិ ការប្តេជ្ញាចិត្តរបស់ CSDG/SDG ក្នុងការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច។<br>5.4.1. រុករកសក្តានុពលសម្រាប់មូលនិធិអង្គការសង្គមស៊ីវិល ដើម្បីចូលរួមចំណែកដល់កិច្ចការទាំងនេះពីប្រភពទាំងនេះ។ | អង្គការសង្គមស៊ីវិល/ ដៃគូអភិវឌ្ឍន៍និងរដ្ឋាភិបាល |
| **6. សិទ្ធិទទួលបានព័ត៌មាន** | |
| 6.1. រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតក្របខ័ណ្ឌសិទ្ធិទទួលបានព័ត៌មានមួយដើម្បីចូលរួមចំណែកដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបើកចំហររដ្ឋាភិបាល។<br>6.1.1. ពិចារណាពីការកើនឡើងសង្គមឌីជីថល និង "ឆ្លាតវៃ" ដែលយើងរស់នៅ។ | រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ |
| 6.2. ផ្តល់ទិន្នន័យយោងភូមិសាស្ត្រ រួមទាំងក្នុងទម្រង់ជាអេឡិចត្រូនិចឲ្យបានទាន់ពេលវេលាដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍មូលដ្ឋាន។ | រដ្ឋាភិបាល |
| 6.2.1. បោះផ្សាយទិន្នន័យលទ្ធផលស្ថាប័ន ដើម្បីបង្កើតគណនេយ្យភាពសាធារណៈ។ | រដ្ឋាភិបាល |
| 6.3. កសាងសមត្ថភាពស្ថាប័ន និងអនុម័តខ្នាតគំរូ ដើម្បីផ្តល់ព័ត៌មានទៅក្នុងដៃរបស់សាធារណៈឲ្យបានទាន់ពេលវេលា។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 6.4. ជំរុញឲ្យមានការបញ្ចប់ និងការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត។ | រដ្ឋាភិបាល |

| | |
|---|---|
| **7. ទំនាក់ទំនងរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិល** | |
| 7.1. បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ផែនទី និងឯកសារដែលមានមូលដ្ឋានលើកុំព្យូទ័រ (cloud) ប្រភពចំហរមួយ។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ |
| 7.2. រៀបចំព្រឹត្តិការណ៍រៀនសូត្រ និងចែករំលែកតាមដំណាក់កាល (ពីរ ឬបួនដងក្នុងមួយឆ្នាំ) នៅថ្នាក់ក្រោមជាតិ ដោយនាំយករួមគ្នានូវអ្នកតំណាងរបស់រដ្ឋាភិបាល និងរបស់អង្គការសង្គមស៊ីវិល។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 7.3. លើកកម្ពស់យន្តការសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីកសាងទំនុកចិត្ត និងការយល់ដឹង។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 7.4. គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សមត្ថភាពរួមគ្នា ដើម្បីកសាងសមត្ថភាព។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| **8. ភាពជាដៃគូប្រកបដោយបរិយាប័ន្ន (ឯកជន រដ្ឋាភិបាល អង្គការសង្គមស៊ីវិល)** | |
| 8.1. បច្ចុប្បន្នមានតម្រូវក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃយន្តការចាប់ដៃគូ និងសម្របសម្រួលដែលមានស្រាប់ និងអនាគត ដើម្បីជូនដំណឹងកាន់តែប្រសើរទៅកាន់សាធារណៈ។<br>8.1.1. ប្រមូល និងបោះផ្សាយព័ត៌មាន អំពីអ្វីដែលត្រូវបានរៀបចំផែនការ និងពិភាក្សា និងអំពីលទ្ធផលកិច្ចប្រជុំដែលត្រូវបានរៀបចំធ្វើឡើង និងអំពីផលប៉ះពាល់នៃយន្តការដែលបានព្រមព្រៀង។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ |
| 8.2. រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវធានាថា ទស្សនៈ និងសំឡេងរបស់ប្រជាជនថ្នាក់ក្រោមជាតិត្រូវបានគេឮនិងយកមកពិចារណាកាន់តែប្រសើរ។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 8.3. យន្តការភាពជាដៃគូ និងសម្របម្រួល ចាំបាច់ត្រូវបង្កើនការតំណាងរបស់ភាគីពាក់ព័ន្ធអភិវឌ្ឍន៍ រួមទាំងអង្គការសង្គមស៊ីវិល/ក្រុមអ្នកតំណាង។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 8.3.1. អង្គការសង្គមស៊ីវិលចាំបាច់ត្រូវរួបរួមគ្នាស្ថិតក្រោមបណ្តាញឆ័ត្រដើម្បីតំណាងឲ្យពួកគេ។ | អង្គការសង្គមស៊ីវិល |
| 8.3.2. ពួកគេចាំបាច់ត្រូវពិភាក្សា និងព្រមព្រៀងលើគោលជំហរ/ផ្លែតហ្វមរួម។ | អង្គការសង្គមស៊ីវិល |

| | |
|---|---|
| 8.3.3. មានតម្រូវការដែលចាំបាច់ត្រូវ ជៀសវាង និងប្រឆាំងនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅលើការតំណាងរបស់អង្គការសង្គមស៊ីវិលអំពីយន្តការចាប់ដៃគូ និងសម្របសម្រួល។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |
| 8.4. រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងផ្សេងៗទៀត គួរពិចារណាបង្កើត/រៀបចំវេទិកាសម្របសម្រួលអភិវឌ្ឍន៍ពហុភាគីពាក់ព័ន្ធ ដែលរួមបញ្ចូលគ្នាមួយ ដែលមានការចូលរួមពិគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលកាន់តែប្រសើរ និងអាចឲ្យមានភាពជាដៃគូសម្រាប់ការអភិវឌ្ឍ។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ |
| 8.5. មានតម្រូវការកសាងសមត្ថភាព និងការយល់ដឹងអំពីវិធីសាស្ត្រភាពជាដៃគូប្រកបដោយបរិយាប័ន្នចំពោះភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចាប់ផ្តើមពន្លឿន និងលើកទឹកចិត្តឲ្យមានការរួមបញ្ចូលគ្នា ដើម្បីអាចឲ្យមានភាពជាដៃគូ។ | រដ្ឋាភិបាល អង្គការសង្គមស៊ីវិល |

# ឯកសារយោង

Australian Aid (2018). Investing In Infrastructure. Available at: http://3icambodia.org

CCC (2013). Assessment of the Enabling Environment for Civil Society, A country report by the Cooperation Committee for Cambodia

CCC (2015). Assessing the Enabling Environment (Kratie and Kampong Thom), by the Cooperation Committee for Cambodia

Collis, D. (2016) Lean Strategy. Harvard Business Review (March, 2016). Watertown, Massachussets: Harvard business Publishing.

CSOSI (2017). The CSO sustainability index for Cambodia. Available at: www.ccc-cambodia.org/

FIDH (2015). Worldwide movement for human rights. Cambodia: Adoption of Law on Associations and NGOs a severe attack on civil society. Published by www.FIDH.com 14th of July, 2015. Available at: https://www.fidh.org/en/region/asia/cambodia/cambodia-adoption-of-law-on-associations-and-ngos-a-severe-attack-on

ILO (2018). The informal economy in Asia Pacific. An online summary, available at: https://www.ilo.org/asia/media-centre/news/WCMS_627585/lang--en/index.htm

IVAR (2016). What is core funding? Available at: https://www.ivar.org.uk/get-support/voluntary-and-community-organisations/core-funding/

Johnson, G. (1988) 'Processes of managing strategic change', Management Research News, vol. 11, no. 4/5, pp. 43–6.

Khmer Times (2018). "Tourist arrivals up 12%" Published in the Khmer Times, November 14th 2018. At: Khttps://www.khmertimeskh.com/50550219/tourist-arrivals-up-12-pct/

Khmers Times, (2018). ADHOC 5 handed suspended sentences. Published September 27, 2018. Available at: https://www.khmertimeskh.com/536931/adhoc-5-handed-suspended-sentences/

Krafcik, John F. (1988). "Triumph of the lean production system". Sloan Management Review 30 (1): 41–52.

MoEYS (2014). 201Education Strategic Plan 2014-2018. Available at: http://www.moeys.gov.kh/en/policies-and-strategies/559.html#.XJg98i2B3eQ

Phnom Penh Post (2017). Ministry ups scrunity of NGOs. Published 10th of October, 2017. Available at: www.phnompenhpost.com/national/ministry-ups-scrutiny-ngos

UN (2019). United Nations on human rights, office of the commissioner, Cambodia. Available at: www.cambodia.ohchr.org

World Bank (2018). "An economic update for Cambodia, 2018". Published at: http://documents.worldbank.org/curated/en/888141543247252447/pdf/132482-WP-PUBLIC-nov-28-Economic-Update-Nov-final-01Low-res.pdf

World Bank (2013) Poverty Assessment Study: Where have all the poor gone? Available at: http://documents.worldbank.org/curated/en/2014/05/19677674/all-poor-gone-cambodia-poverty-assessment-2013

# ឧបសម្ព័ន្ធ

## ព័ត៌មានបន្ថែមសម្រាប់ក្របខ័ណ្ឌនៃការវិភាគតាមសមាសធាតុ

### ១. ការបង្កើត និង ប្រតិបត្តិការ

បញ្ជីឯកសារសម្រាប់ភ្ជាប់ក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

| តម្រូវការតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មាត្រា៦ | ប្រកាសក្រសួងមហាផ្ទៃលេខ ២១៩៣ ឆ្នាំ២០១៨ ស្តីពីការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
|---|---|
| 1. ពាក្យសុំ ចុះឈ្មោះ (២ ច្បាប់)<br>2. លិខិតបញ្ជាក់ពីអាសយដ្ឋានស្នាក់ការកណ្តាលនៃសមាគមក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាល ដែលចេញដោយមេឃុំឬចៅសង្កាត់ (១ ច្បាប់)<br>3. ប្រវត្តិរូបរបស់ស្ថាបនិក រួមជាមួយរូបថត (២ច្បាប់)<br>4. លក្ខន្តិកៈដែលចុះហត្ថលេខាដោយប្រធានសមាគមក្នុងស្រុកឬអង្គការមិនមែនរដ្ឋាភិបាល (២ច្បាប់។) | a) ពាក្យសុំ ចុះឈ្មោះ (២ ច្បាប់)<br>b) ឯកសារពាក់ព័ន្ធ (១ ច្បាប់)<br>c) អាស័យដ្ឋានរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានការបញ្ជាក់ទទួលស្គាល់ដោយមេឃុំ ឬសង្កាត់ (១ ច្បាប់)<br>d) ប្រវត្តិរូបរបស់ស្ថាបនិក រូមជាមួយរូបថត(២ច្បាប់)<br>e) លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល (២ ច្បាប់) |

| |
|---|
| **ខ្លឹមសារចាំបាច់នៃលក្ខន្តិកៈសមាគម / អង្គការមិនមែនរដ្ឋាភិបាល (មាត្រា ៧ នៃច្បាប់សមាគម ន អង្គការមិនមែនរដ្ឋាភិបាល)** |
| (i) គោលបំណង និងគោលដៅ |
| (ii) ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគមឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីមុនរួចហើយ |
| (iii) សញ្ញាសំគាល់ មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលកក្នុងស្រុក ដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិ |
| (iv) វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ |
| (v) វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសំគាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ |
| (vi) ប្រភពធនធាន និងទ្រព្យសម្បត្តិ |
| (vii) វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ |
| (viii) វិធាននៃការរំលាយ វិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ។ |

## ឯកសារចាំបាច់សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

ក) លិខិតរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានទីនស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំងតំណាងរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់បុគ្គល ដែលស្នើតែងតាំងចំនួន ១ (មួយ) ច្បាប់ និងស្នើបើកទីស្នាក់ការតំណាងចំនួន១(មួយ) ច្បាប់

ខ) លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ ឬចៅសង្កាត់ ០១ (មួយ) ច្បាប់

គ) លិខិតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើម អនុញ្ញាតឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ធ្វើប្រតិបត្តិការ ១ (មួយ) ច្បាប់

ឃ) លិខិតគាំទ្រគម្រោងនានា របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយអាជ្ញាធរសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០១ (មួយ) ច្បាប់

ង) លិខិតបញ្ជាក់ថវិកាសម្រាប់អនុវត្តគម្រោងនានា របស់សមាគម ឬអង្គការក្រៅរដ្ឋាភិបាលបរទេស រយៈពេលយ៉ាងតិច ០៦ (ប្រាំមួយ) ខែ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍ខ្លួននៅបរទេសចំនួន ១ (មួយ) ច្បាប់

ច) លិខិតសន្យាផ្តល់គណនីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់។

## ៣. សេរីភាពបញ្ចេញមតិ

### បទប្បញ្ញត្តិច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធ (ចាប់តាំងពីឆ្នាំ ២០១៣)

ការសិក្សានេះបាន ពិនិត្យឡើងវិញអំពីវិសាលភាព ដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជាស្របតាម និងអនុវត្តតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ ខណៈដែលក្តីកង្វល់មួយចំនួន ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ ឆ្នាំ២០១៣ នៅតែមានសុពលភាព។ ផ្នែកនេះនឹងផ្តោតសំខាន់ទៅលើច្បាប់ថ្មីៗបន្ថែមទៀត ទោះយ៉ាងណានឹងពិនិត្យមើលបន្ថែមលើក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ពីព្រោះវានៅតែសំខាន់ដែលអាចប្រើប្រាស់ និងប៉ះពាល់ដល់ការរំលោភបំពាន និងរឹតត្បិតសេរីភាពបញ្ចេញមតិ។

### ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩៖

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានចំនុចមួយចំនួនរិតត្បិតច្រើនដោយអាចដាក់ទោសទណ្ឌចំពោះសិទ្ធិសេរីភាពនៃការបញ្ចេញមតិដោយស្របច្បាប់។ មាត្រា ៣០៥ និង ៣០៧ មានពិរុទ្ធភាពពីបទបរិហារកេរ្តិ៍ និងប្រមាថជាដើម។ នៅក្រោមមាត្រាទាំងពីរ ការប្រព្រឹត្តបទល្មើស សម្រាប់ការបរិហារកេរ្តិ៍ ឬប្រមាថ គឺគ្រាន់តែ " ផ្សព្វផ្សាយជាសាធារណៈ ឬត្រូវបានមើលឃើញជាសាធារណៈ" ។ ដូច្នេះបុគ្គលម្នាក់ៗអាចត្រូវបានកាត់ទោសសម្រាប់ការសន្ទនាឯកជន ដែលអាចត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយគ្មាន ការយល់ព្រមពីបុគ្គល។

បទឧក្រិដ្ឋនៃការបរិហារកេរ្តិ៍ មិនស្របនឹងការអនុវត្តល្អរបស់អន្តរជាតិទេ។ ខណៈពេលដែលច្បាប់បរិហារកេរ្តិ៍អាចជាការរឹតត្បិតលើសេរីភាពបញ្ចេញមតិ ដើម្បីការពារកេរ្តិ៍ឈ្មោះអ្នកដទៃ។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានបញ្ជាក់យ៉ាងច្បាស់ថា ច្បាប់បែបនេះមិនគួរអនុវត្តជាក់ស្តែង ដែលរារាំងសេរីភាពក្នុងការបញ្ចេញមតិ។ នៅក្នុងសេចក្តីអត្ថាធិប្បាយទូទៅ ៣៤ គណៈកម្មាធិការសិទ្ធិមនុស្សបានអំពាវនាវបន្ថែមទៀតដល់រដ្ឋភាគី (ICCPR) ក្នុងការ "គិតគូទោសឧក្រិដ្ឋពីបទបរិហារកេរ្តិ៍"។

បទឧក្រិដ្ឋនៃការញុះញង់ គឺជាបទប្បញ្ញត្តិមួយទៀតនៃក្រមព្រហ្មទណ្ឌ ដែលមិនសមស្របតាមស្តង់ដារអន្តរជាតិ។ មាត្រា៤៩៥ "ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" និងមាត្រា ៤៩៦ "ការញុះញង់ឱ្យប្រព្រឹត្តការរើសអើង" មិនចាំបាច់មានបទឧក្រិដ្ឋកើតឡើង ជាលទ្ធផលនៃការញុះញង់នៅតែជាសំណួរ និងបង្កើតអោយមានការរឹតត្បិតសេរីភាពបញ្ចេញមតិ។ ភាពមិនច្បាស់ និងវិសាលភាពទូលំទូលាយនៃបទល្មើសទាំងនេះ ក៏មិនសមស្របតាមស្តង់ដារអន្តរជាតិដែរ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (LEMNA) ត្រូវបានអនុម័តកាលពីខែមីនាឆ្នាំ២០១៥ ដែលនេះជាការរឹតត្បិតយ៉ាងខ្លាំងដល់សេរីភាព នៃការបញ្ចេញមតិជាពិសេសក្នុងអំឡុង

ពេលឃោសនាផ្លូវការ។ មាត្រា ៨៤ និងមាត្រា ១៣៧ តម្រូវឲ្យ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមជាតិ និងអន្តរជាតិទាំងអស់អនុវត្ត "អព្យាក្រឹតភាព និងមិនលំអៀង" ទាក់ទងនឹងកិច្ចការប្រព្រឹត្តទៅនៃការបោះឆ្នោត។ ការផ្តល់ពាក្យមិនច្បាស់នេះ អាចកាត់បន្ថយតួនាទីរបស់សង្គមស៊ីវិលយ៉ាងខ្លាំងក្នុងនាមជាអ្នកឃ្លាំមើលសាធារណៈ។ មាត្រា ១៥២ នៃច្បាប់ បន្ថែមថា "ជនណាដែលជេរប្រមាថតាមមធ្យោបាយណាក៏ដោយដល់គណបក្សនយោបាយជាសាធារណៈ"នឹងត្រូវពិន័យជាប្រាក់។

មាត្រា ២៤ នៃច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវអោយអង្គការ ក្នុងស្រុកនិងបរទេស រក្សា" អព្យាក្រឹតភាពចំពោះគណបក្សនយោបាយនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា"។ ពាក្យអព្យាក្រិតភាពមិនត្រូវបានកំណត់ ហើយមិនមានភាពជាក់លាក់ ថាតើសកម្មភាពអ្វីខ្លះត្រូវបានចាត់ទុកថាផ្ទុយនឹងមាត្រានេះ ដោយទុកឱ្យមានការបើកចំហរ ឬអនុវត្តតាមអំពើចិត្ត។

មាត្រា ៣៤ នៃច្បាប់ស្តីពីការអប់រំក៏ តម្រូវឲ្យ មាន "អព្យាក្រឹតភាពនយោបាយ" ពីគ្រឹះស្ថានអប់រំផងដែរ ខណៈមាត្រា ៤២ តម្រូវឲ្យមានទទួលបានការអនុញ្ញាតពីក្រសួងអប់រំយុវជន និងកីឡាសម្រាប់ "ការផ្សព្វផ្សាយ និងឃោសនាព័ត៌មានអប់រំ" ។ ទាំងនេះគឺជាការរឹតត្បិតយ៉ាងសំខាន់ចំពោះសេរីភាពនៃការបញ្ចេញមតិ ព្រោះវាត្រូវបានគេប្រើតែម្ខាងនៅពេល ដែលតំណាងរដ្ឋាភិបាលមានព្រឹត្តិការណ៍អប់រំនយោបាយ។

ច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានប្រកាសឱ្យប្រើនៅដើមឆ្នាំ ២០១៦ នេះបានដាក់កម្រិតយ៉ាងខ្លាំងទៅលើសេរីភាពនៃការបញ្ចេញមតិ ដោយផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការត្រួតពិនិត្យទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក និងបង្កើតបទឧក្រិដ្ឋទាក់ទងនឹងការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍។ ការរំលោភបំពាន នឹងត្រូវជាប់ពន្ធនាគារ និងពិន័យជាប្រាក់។ មាត្រា ៨០ បានដាក់ទណ្ឌកម្ម រាល់ទម្រង់នៃការបញ្ចេញមតិ ដែលបង្ហាញតាមមធ្យោបាយអេឡិចត្រូនិក ដែលបង្ករ "អសន្តិសុខជាតិ" គឺមិនត្រូវបានកំណត់។ បទប្បញ្ញត្តិដែលបានព្រាងមិនច្បាស់លាស់បែបនេះ មិនអាចត្រូវបានគេចាត់ទុកថាជាសមាមាត្រ ការកំណត់ជាក់លាក់ ឬមានតម្លាភាព ដូច្នេះហើយរំលោភលើស្តង់ដារអន្តរជាតិសម្រាប់សេរីភាពនៃការបញ្ចេញមតិ។ មាត្រា ១០៧ ធ្វើឱ្យមេដឹកនាំនៃអង្គការទទួលខុសត្រូវចំពោះសកម្មភាពវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ។ បទប្បញ្ញត្តិនេះរំលោភទៅលើស្តង់ដារអន្តរជាតិនៃសេរីភាពសមាគម។

សម្រាប់ច្បាប់សហជីព ដែលត្រូវបានអនុម័តនៅខែឧសភា ឆ្នាំ២០១៦។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជឿជាក់ថា ច្បាប់មានការរឹតត្បិតទាក់ទងនឹងសិទ្ធិរបស់សហជីព ដើម្បីធ្វើសកម្មភាពដោយសេរី និងមិនស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងនៅកម្ពុជា[122]។ អង្គការពលកម្មអន្តរជាតិ បានកត់សម្គាល់ថា ច្បាប់នេះមាន "ការការពារសិទ្ធិមិនគ្រប់គ្រាន់ដល់សិទ្ធិរបស់កម្មករ និង

122 https://cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=71&id=5

និយោជក ក្នុងការបង្កើតអង្គការតាមជម្រើសរបស់ពួកគេ និងសិទ្ធិរបស់អង្គការទាំងនេះក្នុងការសម្រេចបញ្ហាផ្ទៃក្នុង ដោយគ្មានការជ្រៀតជ្រែក″[123]។ ច្បាប់នេះ ក៏រឹតត្បិតលើសិទ្ធិធ្វើបាតុកម្ម ដូចមាត្រា ១៣ ដែលតម្រូវអោយលក្ខន្តិកៈសហជីពត្រូវតែមានសេចក្ដីសំរេចចិត្ត ក្នុងការធ្វើកូដកម្មដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) បោះឆ្នោតចេញពីសមាជិកសហជីព[124]។ មាត្រា ៦៥ រឹតបន្តឹងសិទ្ធិធ្វើកូដកម្ម ដោយកំណត់ជាសកម្មភាពល្មើសច្បាប់ បើមាន ‟ការញុះញង់ក្នុងគោលបំណងនយោបាយសុទ្ធសាធ ឬសម្រាប់មហិច្ឆតាផ្ទាល់ខ្លួន″ និង‟ រារាំងច្រកចេញចូល របស់សហគ្រាស ឬគ្រឹះស្ថាន ឬការញុះញង់ ឬគំរាមកំហែង ឬការរំខានដោយអំពើហិង្សា និងការបង្ខិតបង្ខំឱ្យកម្មករដែលមិនធ្វើកូដកម្ម តាមមធ្យោបាយទាំងអស់ មិនឱ្យធ្វើការ និងបិទផ្លូវសាធារណៈ″។ វិសាលភាពទូលំទូលាយ និងការប្រើពាក្យមិនច្បាស់នៃមាត្រាទាំងនេះ បង្ករឱកាសក្នុងការរំលោភបំពានដោយអាជ្ញាធរ ដោយព្យាយាមបង្ហាញពីសកម្មភាពធ្វើកូដកម្មសមស្រប ទៅជាល្មើសច្បាប់។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏ជឿជាក់ផងដែរថា (i) ច្បាប់នេះ តម្រូវឱ្យមានការចុះបញ្ជី ដែលបន្ទុក ក្នុងការរឹតត្បិតសិទ្ធិសហជីពក្នុងការធ្វើសកម្មភាព។ (ii) ក៏ដូចជា‟ តម្រូវឱ្យរាយការណ៍ ដើម្បីអាចរក្សាភាពស្របច្បាប់ក្នុងការចុះបញ្ជី″។ មាត្រា ៧១ ហាមប្រាម ‟ការជ្រៀតជ្រែក ការញុះញង់ និងការរំខានដោយបុគ្គលណាមួយផ្សេងទៀត″ ដែលអាចដាក់កម្រិតលើសហជីពតូចតាច និងសមាជិក ក្នុងការបញ្ចេញមតិ៕

---

[123] ILO's statement on Trade Unions law in Cambodia (04/04/2016) https://www.ilo.org/asia/media-centre/news/WCMS_466553/lang--en/index.htm

[124] Ibid

## ទិដ្ឋភាពទូទៅ

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ហៅកាត់ (គ.ស.ក) គឺជាអង្គការ សមាជិកភាព ដែលមានទាំងអង្គការជាតិ និងអង្គការអន្តរជាតិប្រមាណជា១៧០ នៅកម្ពុជា។ អង្គការ គ.ស.ក បានដើរតួនាទីពិសេសចម្បងតាំងពីឆ្នាំ១៩៩០ សម្រាប់បង្ករលក្ខណៈងាយស្រួល ក្នុងការសម្របសម្រួល អង្គការសង្គមស៊ីវិលធ្វើការងាររួមគ្នាប្រកបដោយទំនួលខុសត្រូវ គណនេយ្យភាព ដើម្បីពង្រឹងអភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពអង្គការសង្គមស៊ីវិល នៅក្នុងប្រទេសកម្ពុជា។

## ទស្សនៈវិស័យ

ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា

## បេសកកម្ម

ជាអង្គការសមាជិកភាព អង្គការ គ.ស.ក ធ្វើការក្នុងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដើម្បីអភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពអង្គការសង្គមស៊ីវិលនៅកម្ពុជា

## គោលដៅ

សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតបទៅនឹង បញ្ហានៃការអភិវឌ្ឍនៅកម្ពុជា

## គុណតម្លៃ

- សុចរិតភាព
- ភាពឆ្លើយតប
- កិច្ចសហប្រតិបត្តិការ
- គុណភាព
- បរិយាប័ន្ន

**ផ្តល់ជំនួយដោយៈ**

**គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)**

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខណ្ឌចំការមន P.O Box ៨៨៥ រាជធានីភ្នំពេញ

ទូរស័ព្ទ: +855 (0)23 214 152   ទូរសារ: +855 (0)23 216 009

www.ccc-cambodia.org
info@ccc-cambodia.org
fb.com/CCCsince1990